00686456

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / 05 / 2011
ម៉ោង (Time/Heure): 13:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លេខ/No: D427/2/15

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៤៥ & ១៤៦)

ចំពោះមុខ៖ ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នីយ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ៖ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១

សាធារណៈ

សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ

សហព្រះរាជអាជ្ញា
ជា លាង
Andrew CAYLEY

ជនជាប់ចោទ
អៀង សារី
អៀង ធីរិទ្ធ
នួន ជា
ខៀវ សំផន

មេធាវីនៃភាគីដើមបណ្តឹងរដ្ឋប្បវេណី

នី ចាន់ឌី
Lyma Thuy NGUYEN
ហុង គីមសួន
Pascal AUBOIN
ជេត វណ្ណលី
វ៉ែន ពៅ
ឡោ ជុនធី
Olivier BAHOUGNE
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Christinne MARTINEAU
Elisabeth RABESANDRATANA
Philippe CANNONE
Martine JACQUIN
Annie DELAHIE
Fabienne TRUSSES-NAPROUS
គង់ ពិសី
យុង ផានិត
ស៊ិន សុវ៉ន
Silke STUNDZINSKY
Mahdev MOHAN
Patrick BAUDOIN
Marie GUIRAUD
ទី ស្រ៊ីនណា
Ferdinand DJAMMEN-NZEPA
Isabelle DURAND
Emmanuel ALTIT
Emmanuel JACOMY
Barnabe NEKUIE
Daniel LOSQ
Julien RIVET
Francoise GAUTRY
Laure DESFORGES

សហមេធាវីការពារក្តី

អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅស៊ាង
Diana ELLIS
សុន អរុណ
Michiel PESTMAN
Victor KOPPE
ស សូវ៉ាន
Jacques VERGÈS
Philippe GRECIANO

00686458

អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“**អ.វ.ត.ក**”) បានទទួល “បណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ” (“បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ”)[១] ដែលបានដាក់ដោយសហមេធាវីការពារក្តី អៀង ធីរិទ្ធ នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ និង “បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ” (“បណ្តឹងឧទ្ធរណ៍របស់ នួន ជា”)[២] ដែលបានដាក់ដោយសហមេធាវីការពារក្តី នួន ជា នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០។

I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានដាក់ និងបានជូនដំណឹងដល់ភាគីនានាថា សហចៅក្រមស៊ើបអង្កេតបានសម្រេចបញ្ចប់កិច្ចស៊ើបសួរ នៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (“សំណុំរឿង ០០២”)[៣]។ សំណុំរឿង ០០២ ត្រូវបានបញ្ជូនទៅសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង[៤]។

២. នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០ សហព្រះរាជអាជ្ញាបានចេញដីកាសន្និដ្ឋានស្ថាពរ អនុលោមតាមវិធាន ៦៦[៥] ដែលត្រូវបានជូនដំណឹងដល់ភាគីនានា នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០។

៣. នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានដាក់ដីកាដំណោះស្រាយ[៦] ដោយចោទប្រកាន់ជនជាប់ចោទ នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ បទឧក្រិដ្ឋប្រល័យពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញា

---

[១] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ ឯកសារ D427/2/1 (“បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ”)។

[២] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/3/1 (“បណ្តឹងឧទ្ធរណ៍របស់ នួន ជា”)។

[៣] សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០, ឯកសារ D317។

[៤] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៤) ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១០, វិធានផ្ទៃក្នុង ៦៦។

[៥] ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០, ឯកសារ D390។

[៦] ដីកាដំណោះស្រាយ, ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D427(“ដីកាដែលរងការជំទាស់”)។

00686459

ទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងការរំលោភបំពានក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[៧]។ ដីកាដំណោះស្រាយ ត្រូវបានជូនដំណឹងដល់ភាគីនានានៅថ្ងៃដដែល។

៤. នៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ សហមេធាវីការពារក្តី អៀង ធីរិទ្ធ បានដាក់សេចក្តីជូនដំណឹងស្តីពីការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[៨] និងនៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ សហមេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ("បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ")[៩]។ បណ្តឹងឧទ្ធរណ៍ត្រូវបានជូនដំណឹងជាភាសាអង់គ្លេស នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១០ និងជាភាសាខ្មែរ នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១០។

៥. នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ សហមេធាវីការពារក្តី នួន ជា បានដាក់សេចក្តីជូនដំណឹងស្តីពីការដាក់បណ្តឹងឧទ្ធរណ៍[១០] ហើយនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ សហមេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ("បណ្តឹងឧទ្ធរណ៍របស់ នួន ជា")[១១]។ បណ្តឹងឧទ្ធរណ៍ត្រូវបានជូនដំណឹងជាភាសាអង់គ្លេស នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ និងជាភាសាខ្មែរ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០។

៦. នៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១០ សហព្រះរាជអាជ្ញាបានដាក់ "សំណើសុំដាក់ចម្លើយតបរួមទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ នួន ជា , អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើសុំបន្ថែមចំនួនទំព័រកំណត់" ("សំណើរបស់សហព្រះរាជអាជ្ញា")[១២]។ សំណើរបស់សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងដល់ភាគីនានា នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ

---

[៧] ដីកាដែលរងការជំទាស់ កថាខណ្ឌ ១៦១៣។

[៨] សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ, ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D427/2។

[៩] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ។

[១០] សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D427/3។

[១១] បណ្តឹងឧទ្ធរណ៍របស់ នួន ជា។

[១២] សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំដាក់ចម្លើយតបរួមទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើសុំបន្ថែមចំនួនទំព័រកំណត់, ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១០, ឯកសារ D427/1/5 ("សំណើរបស់សហព្រះរាជអាជ្ញា")។

២០១០។

៧. នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសាកសួរថាតើខ្លួននឹងត្រូវបានអនុញ្ញាតឱ្យដាក់ចម្លើយតប ឬសេចក្តីអង្កេតលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដែរឬទេ[១៣]។

៨. នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១០ អង្គបុរេជំនុំជម្រះបានចេញដីកា អនុញ្ញាតឱ្យសហព្រះរាជអាជ្ញាដាក់ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ នៅក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ទាំងនោះចុងក្រោយបំផុតជាភាសាអង់គ្លេស និងជាភាសាខ្មែរ[១៤]។ អង្គបុរេជំនុំជម្រះបានពិចារណាឃើញថា បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន បានលើកឡើងនូវមូលដ្ឋានដាច់ដោយឡែកពីគ្នានៃបណ្តឹងឧទ្ធរណ៍ និងយល់ឃើញថា វាមានលក្ខណៈសមរម្យ សម្រាប់ព្រះរាជអាជ្ញាធ្វើការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ដាច់ដោយឡែកពីគ្នា[១៥]។ អង្គបុរេជំនុំជម្រះក៏បានបញ្ជាក់ផងដែរអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការដាក់សេចក្តីអង្កេត ដើម្បីគាំទ្រឬជំទាស់ចម្លើយតបរបស់ព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ នៅក្នុងរយៈពេល ៥ថ្ងៃ គិតពីថ្ងៃដាក់ចម្លើយតបរបស់ព្រះរាជអាជ្ញា[១៦]។

៩. នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍

---

[១៣] អ៊ីមែលចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១០ ពីមន្ត្រីគ្រប់គ្រងសំណុំរឿងនៃអង្គភាពដើមបណ្តឹងរដ្ឋប្បវេណីផ្ញើជូនក្រឡាបញ្ជីអង្គបុរេជំនុំជម្រះ។

[១៤] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំដាក់ចម្លើយតបរួមទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើសុំបន្ថែមចំនួនទំព័រកំណត់, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១០, ឯកសារ D427/1/8 ទំព័រ ៦។

[១៥] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំដាក់ចម្លើយតបរួមទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើសុំបន្ថែមចំនួនទំព័រកំណត់, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១០, ឯកសារ D427/1/8 កថាខណ្ឌ ១៣។

[១៦] សាលដីកាលើសំណើរបស់សហព្រះរាជអាជ្ញា, ទំព័រ ៦។

* អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER * CHAMBRE PRELIMINAIRE * E.C.C.C * C.E.T.C

("ចម្លើយតបរបស់សហព្រះរាជអាជ្ញា")[១៧] និងត្រូវបានជូនដំណឹងដល់ភាគីនានាជាភាសាខ្មែរ និងជាភាសាអង់គ្លេស នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១០។

១០. ដើម្បីត្រៀមលក្ខណៈឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា សហមេធាវីការពារក្តី អៀង ធីរិទ្ធ បានដាក់សំណើសុំពន្យារពេលក្នុងការឆ្លើយតប នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០[១៨] ដែលត្រូវបានជូនដំណឹងដល់ភាគីនានា នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ ជាភាសាខ្មែរ និងជាភាសាអង់គ្លេស។

១១. តាមរយៈសេចក្តីជូនដំណឹងអំពីចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១០ អង្គបុរេជំនុំជម្រះបានចេញការណែនាំ ដែលអនុញ្ញាតឱ្យក្រុមមេធាវីការពារក្តីដាក់សារណាតបជាលាយលក្ខណ៍អក្សរទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅក្នុងរយៈពេល ១០ថ្ងៃ គិតពីថ្ងៃជូនដំណឹង។

១២. នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សេចក្តីសង្កេតរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ ("សេចក្តីសង្កេត I របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី") ជាភាសាខ្មែរ និងជាភាសាបារាំងប៉ុណ្ណោះ[១៩]។ សេចក្តីសង្កេត I របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជូនដំណឹងដល់ភាគីនានា នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ជាភាសាខ្មែរ និងជាភាសាបារាំង និងត្រូវបានជូនដំណឹងជាភាសាអង់គ្លេស នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១០។

១៣. នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុមទីពីរ បានដាក់

---

[១៧] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០១០, ឯកសារ D427/2/7, D427/3/6("ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា")។

[១៨] សំណើរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សុំពន្យារពេលកំណត់ដើម្បីឆ្លើយតបចំពោះចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០, ឯកសារ D427/2/5។

[១៩] សារណារួមឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង នួន ជា ដែលជំទាស់នឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបសង្កេត, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០, ឯកសារ D427/1/18 ("សេចក្តីសង្កេត I របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី")។

សេចក្ដីសង្កេតរបស់ខ្លួន ("សេចក្ដីសង្កេត II របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី") ជាភាសាខ្មែរ និងជាភាសាបារាំងប៉ុណ្ណោះ[២០]។ សេចក្ដីសង្កេតទាំងនេះត្រូវបានជូនដំណឹងដល់ភាគីនានា នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០។ សេចក្ដីសង្កេត II របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានដាក់ និងត្រូវបានជូនដំណឹងជាភាសាអង់គ្លេស នៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១០។

១៤. នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្រុមទីបី បានដាក់សេចក្ដីសង្កេតរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ ("សេចក្ដីសង្កេត III របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី") ជាភាសាខ្មែរប៉ុណ្ណោះ[២១]។ សេចក្ដីសង្កេតទាំងនេះ ត្រូវបានជូនដំណឹងដល់ភាគីនានា នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ ជាភាសាខ្មែរ រីឯសំណៅជាភាសាអង់គ្លេសត្រូវបានជូនដំណឹង នៅថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១០។

១៥. នៅថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១០ សហមេធាវីការពារក្ដី អៀង ធីរិទ្ធ បានដាក់ចម្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ("ចម្លើយតបរបស់ អៀង ធីរិទ្ធ")[២២] ដែលត្រូវបានជូនដំណឹងដល់ភាគីនានានៅថ្ងៃដដែល។ សហព្រះរាជអាជ្ញាពុំបានដាក់ចម្លើយតបទៅនឹងសេចក្ដីសង្កេតនានាដែលបានដាក់ដោយសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។

១៦. នៅថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១០ សហមេធាវីការពារក្ដី នួន ជា បានដាក់ចម្លើយតបទៅនឹងចម្លើយតប

---

[២០] កំណត់សម្គាល់រួមចំពោះបណ្ដឹងឧទ្ធរណ៍ដាក់ដោយ លោក នួន ជា លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០, ឯកសារ D427/1/19 ("សេចក្ដីសង្កេត II របស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី")។

[២១] សេចក្ដីសង្កេតរបស់សហមេធាវីការពារក្ដីដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងនឹងបណ្ដឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ជំទាស់នឹងដីកាដំណោះស្រាយ, ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០, ឯកសារ D427/1/20 ("សេចក្ដីសង្កេត III របស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី")។

[២២] សារណាតបរបស់មេធាវីការពារក្ដី ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១០, ឯកសារ D427/2/11 ("សារណាតបរបស់ អៀង ធីរិទ្ធ")។

របស់សហព្រះរាជអាជ្ញា ("ចម្លើយតបរបស់ នួន ជា")[២៣] ដែលត្រូវបានជូនដំណឹងដល់ភាគីនានា នៅថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១០។ សហព្រះរាជអាជ្ញាពុំបានដាក់ចម្លើយតបទៅនឹងសេចក្តីសង្កេតនានា ដែលបានដាក់ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

១៧. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានប្រកាសជាលាយលក្ខណ៍អក្សរ អំពីការសម្រេចពីសេចក្តីសម្រេចចុងក្រោយលើបណ្តឹងឧទ្ធរណ៍ដោយបង្ហាញថា "សំអាងហេតុសម្រាប់សាលដីកានេះនឹងចេញតាមពេលវេលាកំណត់"[២៤]។

តាមរយៈនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទៈ

១. បណ្តឹងឧទ្ធរណ៍អាចទទួលយកបានតាមទម្រង់។

២. មូលដ្ឋានទីមួយ ទីពីរ ទីបី ទីបួន និងទីប្រាំ នៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង មូលដ្ឋានទីមួយ ទីពីរ ទីបី ទីបួន ទីប្រាំ (ផ្នែកខ្លះ) និងទីប្រាំពីរ (ផ្នែកខ្លះ) នៃ បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ អាចទទួលយកបាន។ មូលដ្ឋានបណ្តឹងឧទ្ធរណ៍ ដែលនៅសេសសល់ដទៃទៀតមិនអាចទទួលយកបានទេ។ មូលដ្ឋានដែលមិនអាច ទទួលយកបាននៃមូលដ្ឋានទីប្រាំ និងទីប្រាំពីរ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ មានដូចជា៖

- មូលដ្ឋានទីប្រាំ ពាក់ព័ន្ធនឹងផ្នែកដែលមូលដ្ឋាននេះលើកឡើងថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការបញ្ជាក់អះអាងអំពីយុត្តាធិការពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មជាតិ ដែលត្រូវបានចោទប្រកាន់តាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ជាការរំលោភលើសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់របស់ អៀង ធីរិទ្ធ។
- មូលដ្ឋានទីប្រាំពីរ ពាក់ព័ន្ធនឹងផ្នែកដែលមូលដ្ឋាននេះលើកឡើងថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានធ្វើការជជែកវែកញែកឲ្យបានត្រឹមត្រូវ ថាជា

[២៣] ចម្លើយតបទៅនឹងចម្លើយតបរួមរបស់ការិយាល័យសហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១០, ឯកសារ D427/3/11 ("ចម្លើយតបរបស់ នួន ជា")។

[២៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងដីកាដំណោះស្រាយ, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, ឯកសារ D427/2/12 និង D427/3/12។

បញ្ហាអង្គហេតុ អត្ថិភាពនៃកាតព្វកិច្ចផ្លូវច្បាប់ដែលត្រូវបំពេញ និងមូលដ្ឋាននៅក្នុងច្បាប់ ជាតិជាធាតុផ្សំមួយនៃការទទួលខុសត្រូវរបស់ថ្នាក់លើ។

៣. មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ត្រូវបានបដិសេធ។

៤. មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ត្រូវបានបដិសេធ។

៥. មូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ត្រូវបានបដិសេធ។

៦. មូលដ្ឋានទីបួននៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ត្រូវបានបដិសេធ។

៧. មូលដ្ឋានទីប្រាំនៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ត្រូវបានបដិសេធ។

៨. មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវបានបដិសេធ។

៩. មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវបានបដិសេធ។

១០. មូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវបានបដិសេធ។

១១. មូលដ្ឋានទីបួននៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវបានអនុញ្ញាតផ្នែកខ្លះដូចខាងក្រោម រីឯផ្នែកផ្សេងទៀតត្រូវបានបដិសេធ។

១- មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានទទួលយកត្រង់ផ្នែក ដែលសហមេធាវីការពារក្តីអះអាងថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំដោយខកខានមិនបានធ្វើការពិចារណាថា នៅក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានតម្រូវឱ្យមានចំណងពាក់ព័ន្ធគ្នារវាងអំពើជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធអន្តរជាតិ។ "អត្ថិភាពនៃចំណងពាក់ព័ន្ធគ្នារវាងអំពើជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធអន្តរជាតិ" ត្រូវបានបន្ថែមជាលក្ខខណ្ឌតម្រូវ "ធាតុផ្សំ" នៅក្នុងជំពូក IV(ក) នៃដីកាដំណោះស្រាយ។

២- មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានទទួលយក ត្រង់ផ្នែក ដែលសហមេធាវីការពារក្តីអះអាងថា ការរំលោភផ្លូវភេទមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេក្នុងរយៈពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចដកការរំលោភផ្លូវភេទចេញពីកថាខណ្ឌ ១៦១៣ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ កថាខណ្ឌ (ធ)) នៃដីកាដំណោះស្រាយ និងរក្សាទុកការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងកថាខណ្ឌ ១៤៣៣ នៃដីកាដំណោះស្រាយថា "អង្គហេតុដែលត្រូវបានកំណត់ថាជា ឧក្រិដ្ឋកម្ម

ប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ជាលក្ខណៈបន្ទាប់បន្សំថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបង្កឡើងពីអំពើអមនុស្សធម៌ដទៃទៀត"។

១២. ផ្នែកទាំងឡាយនៃមូលដ្ឋានទីប្រាំនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលត្រូវបានយល់ឃើញថាអាចទទួលយកបាន ត្រូវបានបដិសេធ។

១៣. ផ្នែកទាំងឡាយនៃមូលដ្ឋានទីប្រាំពីរនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលត្រូវបានយល់ឃើញថាអាចទទួលយកបាន ត្រូវបានបដិសេធ។

១៤. ផ្សេងពីនេះ បណ្តឹងឧទ្ធរណ៍ត្រូវបានបដិសេធ។

១៥. ជនជាប់ចោទត្រូវបានចោទប្រកាន់ និងត្រូវបានបង្គាប់ឱ្យបញ្ជូនខ្លួនឱ្យចូលរួមសវនាការ ដូចដែលបានចែងនៅក្នុងដីកាដំណោះស្រាយ ដែលត្រូវអានព្រមគ្នាជាមួយនឹងសាលដីកានេះ។

១៦. ការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន ត្រូវបានបង្គាប់ឱ្យបន្តចិរវេលា រហូតដល់ពេលដែលជនត្រូវចោទត្រូវបាននាំខ្លួនមកបង្ហាញ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

១៨. នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសំអាងហេតុនានាសម្រាប់ការសម្រេចសេចក្តីនៅក្នុងចំណុចទី ១៦ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍[២៥]។ សំអាងហេតុទាំងអស់នេះចែងថា:

> អនុលោមតាមវិធាន ៦៨(២) នៅពេលបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនថាលក្ខណៈនៃបណ្តឹងឧទ្ធរណ៍នោះយ៉ាងណាទេ "អានុភាពនៃដីកាឃុំខ្លួន ឬដីកាដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបន្តរហូតដល់មានសេចក្តីសម្រេចពីអង្គបុរេជំនុំជម្រះ"។

---

[២៥] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ៖ សំអាងហេតុសម្រាប់ការបន្តឃុំខ្លួនបណ្តោះអាសន្ន, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១, ឯកសារ D427/2/13 និង D427/3/13។

ជនជាប់ចោទមិនបានដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេតដែលបានចេញនៅក្នុងដីកាដំណោះស្រាយ។ គ្មានកាលៈទេសៈពិសេសណា ក្រៅពីការអះអាងលើការបញ្ជូនរឿងទៅជំនុំជម្រះពីអង្គបុរេជំនុំជម្រះ ដែលធ្វើឱ្យរឹងមាំពីមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយឬច្រើន ដូចមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ វាក៏ធ្វើឱ្យរឹងមាំផងដែរ ពីភាពចាំបាច់ដើម្បីរក្សា នួន ជា ក្នុងការឃុំខ្លួនបណ្តោះអាសន្ន ដើម្បីធានានូវវត្តមានរបស់គាត់នៅក្នុងដំណើរការនីតិវិធី ការពារសន្តិសុខគាត់ រក្សាសណ្តាប់ធ្នាប់សាធារណៈ និងរារាំងកុំឱ្យជនជាប់ចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬបំផ្លាញភស្តុតាង ប្រសិនបើត្រូវបានដោះលែង និងដើម្បីរក្សា អៀង ធីរិទ្ធ ក្នុងការឃុំខ្លួនបណ្តោះអាសន្ន ដើម្បីធានានូវវត្តមានរបស់គាត់នៅក្នុងកិច្ចដំណើរការនីតិវិធី ការពារសន្តិសុខគាត់ រក្សាសណ្តាប់ធ្នាប់សាធារណៈ និងរារាំងកុំឱ្យជនជាប់ចោទនោះ គាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬបំផ្លាញភស្តុតាង ប្រសិនបើត្រូវបានដោះលែង។ អង្គបុរេជំនុំជម្រះពិចារណាឃើញថាមូលហេតុដែលផ្តល់ឱ្យដោយសហចៅក្រមស៊ើបអង្កេតដើម្បីបង្គាប់ថា ជនជាប់ចោទរក្សាការឃុំខ្លួនបណ្តោះអាសន្ន ដែលអង្គជំនុំជម្រះយកតាមមានយុត្តិកម្មថា អង្គជំនុំជម្រះបង្គាប់ថាការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នត្រូវបានបង្គាប់ឱ្យបន្តចិរវេលា រហូតដល់ពេលដែលជនជាប់ចោទត្រូវបាននាំមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[២៦]។

១៩. ហេតុនេះ អង្គបុរេជំនុំជម្រះផ្តល់នូវសំអាងហេតុពេញលេញ សម្រាប់ធ្វើសេចក្តីសម្រេចនានាដែលមាននៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ទាំងអស់នេះ។

សំអាងហេតុសម្រាប់ធ្វើសេចក្តីសម្រេច:
II. សេចក្តីសង្ខេបអំពីបណ្តឹងឧទ្ធរណ៍

ដីកាដែលរងការជំទាស់

២០. នៅក្នុងដីកាដែលរងការជំទាស់ សហចៅក្រមស៊ើបអង្កេតបានលើកសំអាងហេតុពាក់ព័ន្ធទៅនឹង

---

[២៦] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ៖ សំអាងហេតុសម្រាប់ការបន្តឃុំខ្លួនបណ្តោះអាសន្ន, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១, ឯកសារ D427/2/13 និង D427/3/13, កថាខណ្ឌ ៤ និង ៥។

បណ្តឹងឧទ្ធរណ៍ទាំងអស់នេះ ដូចខាងក្រោម៖

ក) "បញ្ហាថាតើ អ.វ.ត.ក ជាស្ថាប័នយុត្តាធិការជាតិ ឬអន្តរជាតិ មិនមានបង្កើតជាផលវិបាកអ្វីចំពោះសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក ក្នុងការជំនុំជម្រះលើឧក្រិដ្ឋកម្មទាំងនេះនោះទេ" "ដរាបណាគោលការណ៍ *មិនមានបទល្មើសប្រសិនបើគ្មានច្បាប់ចែង (nullum crimen sine lege)* ត្រូវបានគោរព"[២៧]។

ខ) អនុលោមតាមគោលការណ៍នីត្យានុកូលភាព "ដែលមានចែងនៅក្នុងមាត្រា ៣៣(២) (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលយោងទៅដល់មាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ" "ដើម្បីអាចឱ្យអំពើមួយ ត្រូវចាត់ចូលជាបទល្មើសនៅក្នុងសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក ខណៈដែលអំពើនោះមិនត្រូវបានចាត់ជាបទល្មើសនៅក្នុងបញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាតិ ក្នុងពេលដែលអំពើនោះកើតឡើងនោះទេ នោះច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវចែងអំពីបទល្មើសនៃអំពើនោះដោយច្បាស់លាស់ ឬដោយតុល្យភាព ហើយអំពើនោះក៏ត្រូវតែជាបទល្មើសនៅក្រោមបញ្ញត្តិនៃច្បាប់អន្តរជាតិដែលអនុវត្តនៅក្នុងប្រទេសកម្ពុជា នៅខណៈពេលដែលអំពើនោះបានកើតឡើងផងដែរ"[២៨]។

គ) "ពាក់ព័ន្ធនឹងបញ្ហានៃភាពដែលអាចអនុវត្តដោយផ្ទាល់ នៃច្បាប់អន្តរជាតិនៅក្នុងប្រទេសកម្ពុជា ចាំបាច់ត្រូវរំឭកឡើងវិញថា មាត្រា ១ និងមាត្រា ២ និងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពី អ.វ.ត.ក បានដាក់បញ្ចូលក្នុងច្បាប់កម្ពុជានូវការរំលោភបំពានច្បាប់មួយចំនួនដែលត្រូវឋិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក [...] ក៏ដូចជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលត្រូវអនុវត្ត [...] ដោយយោងទៅលើបទប្បញ្ញត្តិទាំងនេះ បញ្ហាដែលចោទឡើងថាតើច្បាប់អន្តរជាតិអាច ឬមិនអាចអនុវត្តដោយផ្ទាល់ នៅក្នុងប្រទេសកម្ពុជានឹងមិនមានបង្កើតជាផលវិបាកអ្វីចំពោះសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក. នោះឡើយ[២៩]។

ឃ) "ម្យ៉ាងវិញទៀត បទប្បញ្ញត្តិនៃច្បាប់អន្តរជាតិដែលចែងអំពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

---

[២៧] ដីកាដែលរងការជំទាស់, កថាខណ្ឌ ១៣០១។

[២៨] ដីកាដែលរងការជំទាស់, កថាខណ្ឌ ១៣០២។

[២៩] ដីកាដែលរងការជំទាស់, កថាខណ្ឌ ១៣០៤។

អង្គជំនុំជម្រះសាលាដំបូង E.C.C.C * C.E.T.C PRE-TRIAL CHAMBER PRÉLIMINAIRE

និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និងដែលបានកំណត់យ៉ាងច្បាស់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ គឺមានអានុភាពគតិយុត្តចាប់បង្ខំ តម្រូវឱ្យកម្ពុជាត្រូវតែគោរពតាម ដូចមានបកស្រាយខាងក្រោមនេះ ក្នុងន័យនេះ បទប្បញ្ញត្តិទាំងនេះត្រូវបានចាត់ទុកថា បានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ ដែលអាចឱ្យជនត្រូវចោទទទួលបានព័ត៌មាន ក្នុងឋានៈដែលខ្លួនជាសមាជិកនៃថ្នាក់ដឹកនាំកម្ពុជា[៣០]។

ង) ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិវិញ ការកំណត់ថាអំពើនេះជាបទល្មើសដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានចាត់ទុកថា បានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដល់ជនត្រូវចោទ តាមរយៈការជំនុំជម្រះនានាដែលបានធ្វើឡើងបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ នៅទីក្រុង Nuremburg និងតូក្យូ ជាដើម"[៣១]។

ច) ចំពោះទម្រង់នៃការទទួលខុសត្រូវដែលនៅសេសសល់វិញ ដូចជា សហឧក្រិដ្ឋកម្មរួម [...] និងការទទួលខុសត្រូវរបស់ថ្នាក់លើ វាក៏ត្រូវបានទទួលស្គាល់ផងដែរដោយច្បាប់អន្តរជាតិឆ្លងតាមរយៈការជំនុំជម្រះនានា ដែលត្រូវបានរៀបចំឡើងបន្ទាប់ពីសង្គ្រាមលោកលើកទីពីរបានបញ្ចប់។ ដូច្នេះ ទម្រង់នៃការទទួលខុសត្រូវទាំងនេះត្រូវបានចាត់ទុកថា បានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដល់ជនត្រូវចោទ"[៣២]។

ឆ) ជាមួយនឹងគោលការណ៍ទាំងនេះ ចាំបាច់ត្រូវកត់សម្គាល់ថា គោលការណ៍ *មិនមានបទល្មើសប្រសិនបើគ្មានច្បាប់ចែង* *(nullum crimen sine lege)* មិនរារាំងដល់សហចៅក្រមស៊ើបអង្កេតក្នុងការបកស្រាយបទប្បញ្ញត្តិ ដែលទាក់ទងនឹងសមត្ថកិច្ចយុត្តាធិការរបស់ខ្លួនឡើយ ហើយប្រសិនបើចាំបាច់អាចយោងទៅដល់យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិផ្សេងៗទៀត"[៣៣]។

[៣០] ដីកាដែលរងការជំទាស់, កថាខណ្ឌ ១៣០៥។

[៣១] ដីកាដែលរងការជំទាស់, កថាខណ្ឌ ១៣០៦។

[៣២] ដីកាដែលរងការជំទាស់, កថាខណ្ឌ ១៣០៧។

[៣៣] ដីកាដែលរងការជំទាស់, កថាខណ្ឌ ១៣០៨។

PRE-TRIAL CHAMBER CHAMBRE · E.C.C.C · C.E.T.C

00686469

ជ) "អនុលោមតាមគោលការណ៍ *មិនមានបទល្មើសប្រសិនបើគ្មានច្បាប់ចែង* ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្តែងឡើងតាមរយៈការប្រព្រឹត្ត អំពើណាមួយក្នុងចំណោមអំពើខាងក្រោម នៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ ធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិល ដូចជា៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ ពូជសាសន៍ ឬសាសនា និងរួមទាំងអំពើអមនុស្សធម៌ផ្សេងទៀត ដូចជា អាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ ការបាត់ខ្លួនដោយបង្ខំ និងការជម្លៀសប្រជាជនដោយបង្ខំ"[៣៤]។

ឈ) "អង្គហេតុដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់នៃការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ជាលក្ខណៈបន្ទាប់បន្សំថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបង្កឡើងពីអំពើអមនុស្សធម៌ដទៃទៀត ក្រោមទម្រង់ជាការបំពារបំពានផ្លូវភេទ"[៣៥]។

ញ) "សហចៅក្រមស៊ើបអង្កេតសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះនៅមុខអង្គជំនុំជម្រះសាលាដំបូង ក្រោមបទចោទប្រកាន់នៃអំពើមនុស្សឃាត អំពើទារុណកម្ម និងការវាយប្រហារលើសាសនា ដែលជាឧក្រិដ្ឋកម្មដែលមានចែង និងផ្តន្ទាទោសដោយក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦"[៣៦]។

<u>**បណ្តឹងឧទ្ធរណ៍របស់ នួន ជា**</u>

២១. បណ្តឹងឧទ្ធរណ៍របស់ នួន ជា ផ្អែកលើមូលដ្ឋានទាំងប្រាំខាងក្រោមនៃបណ្តឹងឧទ្ធរណ៍ ដោយស្នើសុំឱ្យមានការយល់ឃើញថា "ក.ស.ច.ស មានការភ័ន្តច្រឡំលើអង្គច្បាប់ នៅពេលបញ្ជាក់ថា អ.វ.ត.ក មានយុត្តាធិការលើបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋកម្មសង្គ្រាម និងទម្រង់នៃការទទួលខុសត្រូវដទៃៗទៀត ដែលមិនមានចែងទទួលស្គាល់នៅក្នុងប្រព័ន្ធ

---

[៣៤] ដីកាដែលរងការជំទាស់, កថាខណ្ឌ ១៣១៤។

[៣៥] ដីកាដែលរងការជំទាស់, កថាខណ្ឌ ១៤៣៣។

[៣៦] ដីកាដែលរងការជំទាស់, កថាខណ្ឌ ១៥៧៦។

ច្បាប់ជាតិកម្ពុជា នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩"[៣៧] និងសន្និដ្ឋានថា បញ្ហានេះស្របតាមគោលការណ៍នីត្យានុកូលភាព[៣៨]។ បណ្តឹងឧទ្ធរណ៍របស់ នួន ជា ស្នើសុំឱ្យអង្គបុរេជំនុំជម្រះ "ចាត់ទុកជាឥតបានការ និង/ឬកែតម្រូវដីកាដំណោះស្រាយឱ្យបានត្រឹមកម្រិតមួយថា ការទទួលខុសត្រូវរបស់ នួន ជា ដូចដែលបានចោទប្រកាន់ ត្រូវបញ្ជាក់យោងដាច់ដោយឡែកលើបទល្មើស និងទម្រង់នៃការទទួលខុសត្រូវនៅក្នុងច្បាប់សារធាតុ ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦"[៣៩]។

២២. មូលដ្ឋានទីមួយលើកឡើងថា ក.ស.ច.ស មានការភ័ន្តច្រឡំនៅក្នុងការសន្និដ្ឋាននៅក្នុងដីកាដែលរងការជំទាស់ថា "បញ្ហាថាតើ អ.វ.ត.ក គឺជាស្ថាប័នយុត្តាធិការជាតិ ឬអន្តរជាតិ មិនបង្កើតជាផលវិបាកអ្វីចំពោះសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក នៅក្នុងការជំនុំជម្រះលើឧក្រិដ្ឋកម្មទាំងនោះទេ"[៤០]។ ផ្ទុយទៅវិញ បណ្តឹងឧទ្ធរណ៍របស់ នួន ជា លើកឡើងថា "អ.វ.ត.ក ដែលមានឋានៈជាតុលាការជាតិកម្ពុជាសុទ្ធសាធនោះ ត្រូវតែអនុវត្តច្បាប់ជាតិដែលនៅជាធរមាននៅក្នុងចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ច្បាប់នេះរួមទាំងវិធីសាស្ត្ររបស់កម្ពុជាចំពោះគោលការណ៍ *មិនមានបទល្មើស ប្រសិនបើគ្មានច្បាប់ចែងផងដែរ*"[៤១]។

២៣. មូលដ្ឋានទីពីរលើកឡើងថា "របបច្បាប់ជាតិជាធរមាននៅពេលហេតុការណ៍ដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយបានកើតឡើង មិនបានកំណត់បទល្មើសទាំងឡាយដូចមានចែងចាប់ពីមាត្រា ៤ ដល់មាត្រា ៦ នៃច្បាប់ អ.វ.ត.ក នោះទេ"[៤២]។

២៤. មូលដ្ឋានទីបីលើកឡើងថា ដីកាដែលរងការជំទាស់ថាបានលើកឡើងដោយភ័ន្តច្រឡំថា ច្បាប់ អ.វ.ត.ក ផ្តល់នូវច្បាប់សារធាតុសម្រាប់បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

---

[៣៧] បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កថាខណ្ឌ ៣៨។

[៣៨] បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កថាខណ្ឌ ១១។

[៣៩] បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កថាខណ្ឌ ៣៨។

[៤០] បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កថាខណ្ឌ ២៦, ជើងទំព័រ ៨៧។

[៤១] បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កថាខណ្ឌ ២៦។

[៤២] បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កថាខណ្ឌ ២៧។

និងបទឧក្រិដ្ឋសង្គ្រាមនៅក្នុងប្រទេសកម្ពុជា[៤៣]។

២៥. មូលដ្ឋានទីបួនលើកឡើងថា គោលការណ៍នីត្យានុកូលភាពអន្តរជាតិដែលត្រូវបានរកឃើញនៅក្នុង "មាត្រា ៣៣(២) នៃច្បាប់ អ.វ.ត.ក ដែលចែងយោងលើមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិ មិនបានធ្វើឱ្យបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬបទឧក្រិដ្ឋកម្មសង្គ្រាមក្លាយជាបទល្មើសព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជាឡើយ ពីព្រោះតែបទល្មើសអន្តរជាតិទាំងនេះមិនអាចអនុវត្តបានឡើយនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩"[៤៤]។

២៦. មូលដ្ឋានទីប្រាំអះអាងថា ទោះបីជា "ច្បាប់ អ.វ.ត.ក បានកំណត់បទល្មើសទាំងឡាយដូចមានចែងចាប់ពីមាត្រា ៤ ដល់មាត្រា៦ ថាជាបទល្មើសព្រហ្មទណ្ឌ ច្បាប់ធ្វើឡើងតាមអានុភាពប្រតិសកម្មបែបនេះ រំលោភលើគោលការណ៍នីត្យានុកូលភាពរបស់ប្រទេសកម្ពុជា"[៤៥]។

<u>**បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ**</u>

២៧. បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ លើកឡើងថា ក.ស.ច.ស មានការភាន់ច្រឡំដោយយល់ឃើញចំនួនប្រាំពីរចំណុច នៅពេលដែល ក.ស.ច.ស បានសម្រេចថា អ.វ.ត.ក មានយុត្តាធិការក្នុងការកាត់ទោស អៀង ធីរិទ្ធ ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និងបទឧក្រិដ្ឋផ្អែកតាមច្បាប់ជាតិ និងដើម្បីកាត់ទោស អៀង ធីរិទ្ធ ដោយផ្អែកលើមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលជាទម្រង់នៃការទទួលខុសត្រូវ[៤៦]។ ហេតុនេះ បណ្តឹងឧទ្ធរណ៍ "ស្នើសុំអង្គបុរេជំនុំជម្រះបដិសេធចោលដីកាដំណោះស្រាយនេះ លើចំណុចទាំងឡាយដែលបានលើកឡើងទាំងនោះ"[៤៧]។

---

[៤៣] បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កថាខណ្ឌ ៣០-៣២។

[៤៤] បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កថាខណ្ឌ ៣៣។

[៤៥] បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កថាខណ្ឌ ៣៥។

[៤៦] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៦។

[៤៧] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ១០៣។

២៨. មូលដ្ឋានទីមួយ ដល់ទីបួន លើកឡើងនូវទឡ្ហីករណ៍នានាដើម្បីគាំទ្រដល់ការលើកឡើងថា អ.វ.ត.ក មិនមានយុត្តាធិការដើម្បីកាត់ទោសម្ចាស់បណ្តឹងឧទ្ធរណ៍ ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ នោះទេ ពីព្រោះ "ការកាត់សេចក្តីនេះ នឹងរំលោភលើគោលការណ៍ជាសារវ័ន្ត *គ្មានបទល្មើសប្រសិន បើគ្មានច្បាប់ចែង*"[៤៨]។

២៩. ជាពិសេស មូលដ្ឋានទីមួយលើកឡើងថា បទល្មើសទាំងអស់នេះមិនអាចត្រូវបានកាត់សេចក្តីនោះទេ ពីព្រោះឧក្រិដ្ឋកម្មទាំងអស់នេះ មិនមែនជាបទឧក្រិដ្ឋនោះទេ តាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ នៅពេលដែលឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាំងនោះត្រូវបានប្រព្រឹត្ត[៤៩]។

៣០. មូលដ្ឋានទីពីរលើកឡើងថា ពាក់ព័ន្ធទៅនឹងបទល្មើសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩[៥០] ក.ស.ច.ស "បានធ្វើការបកស្រាយមិនត្រឹមត្រូវតាមរបៀបដែលថា ច្បាប់ អ.វ.ត.ក មានបំណងបង្កើតច្បាប់ព្រហ្មទណ្ឌថ្មី និងអនុវត្តច្បាប់នោះឱ្យមានប្រតិសកម្មទៅលើអំពើដែលរងការចោទប្រកាន់ថា ត្រូវបានប្រព្រឹត្ត កាលពី៣០ឆ្នាំមុន"[៥១]។

៣១. មូលដ្ឋានទីបីលើកទឡ្ហីករណ៍ជាច្រើនដែលអះអាងថា បទល្មើសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ក្រោមច្បាប់អន្តរជាតិ មិនអាចអនុវត្តផ្ទាល់នៅ អ.វ.ត.ក បានទេ ហេតុដូច្នេះហើយ អៀង ធីរិទ្ធ មិនអាចទទួលការកាត់សេចក្តី ផ្អែកតាមមូលដ្ឋានទាំងអស់នេះបានទេ[៥២]។

---

[៤៨] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ១៩។

[៤៩] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ១៦, ១៧, ៤២, ៤៣, ៦៧, ៦៨។

[៥០] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ១៨-២១, ៤៤-៤៥, ៧០។

[៥១] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ១៩។

[៥២] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ២២-៣៧, ៤៦-៥៧, ៧១-៧២។

អង្គជំនុំជម្រះសាលាដំបូង PRE-TRIAL CHAMBER E.C.C.C. C.E.T.C.

៣២. មូលដ្ឋានទីបួនលើកឡើងថា ក.ស.ច.ស មានការភ័ន្តច្រឡំដោយយល់ឃើញថា អៀង ធីរិទ្ធ បានដឹងជាមុនថាមានច្បាប់ចែង និងដឹងថាទង្វើរបស់គាត់គឺជាបទឧក្រិដ្ឋ ដែលអាចត្រូវបានផ្តន្ទាទោសក្រោមបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[៥៣]។

៣៣. មូលដ្ឋានទីប្រាំលើកឡើងថា ក.ស.ច.ស មានការភ័ន្តច្រឡំដោយយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្មជាតិ ស្របតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[៥៤] ពីព្រោះការពន្យារពេលនៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាទាក់ទងនឹងឧក្រិដ្ឋកម្មទាំងអស់នេះ រយៈពេល៣០ឆ្នាំថែមទៀត ស្របតាមមាត្រា ៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ "ចាត់ទុកថាជាការបំពានលើគោលការណ៍ទូទៅស្តីពី *គ្មានបទល្មើសបើគ្មានច្បាប់ចែង*"[៥៥] និង "គោលការណ៍ទូទៅស្តីពីសិទ្ធិស្មើភាពគ្នាក្នុងរឿងក្តីដូចគ្នា"[៥៦]។

៣៤. មូលដ្ឋានទីប្រាំមួយអះអាងថា ដីកាដែលរងការជំទាស់មានការភ័ន្តច្រឡំ នៅក្នុងការអនុវត្តសហឧក្រិដ្ឋកម្មរួមធ្វើជាគំរូនៃការទទួលខុសត្រូវរបស់បុគ្គល។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែអង្គបុរេជំនុំជម្រះបានសម្រេចលើបញ្ហានេះរួចហើយ អៀង ធីរិទ្ធ មានចេតនា "ជំទាស់ការអនុវត្តទ្រឹស្តីនេះនៅក្នុងសវនាការបឋមរបស់អង្គជំនុំជម្រះសាលាដំបូង ហើយមិនទាន់ជំទាស់ក្នុងបណ្តឹងឧទ្ធរណ៍នៅពេលនេះទេ"[៥៧]។

---

[៥៣] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៣៥-៣៧, ៥៨-៦៣។ តាមការយោង អៀង ធីរិទ្ធ ក៏បានលើកឡើងនូវទឡ្ហីករណ៍ដូចគ្នាផងដែរ ពាក់ព័ន្ធនឹងការបំពារបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ (បណ្តឹងឧទ្ធរណ៍ របស់ អៀង ធីរិទ្ធ, កថាខណណ្ឌ ៦៦)។ ទោះបីជាទឡ្ហីករណ៍ទាំងនេះពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលមានរៀបរាប់នៅក្នុងមូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធក៏ដោយ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ទឡ្ហីករណ៍ទាំងនោះពិតជាមានការពាក់ព័ន្ធទៅនឹងមូលដ្ឋានទីបួននៃបណ្តឹងឧទ្ធរណ៍ ដែលបានលើកឡើងពីទឡ្ហីករណ៍ដូចគ្នាដែលទាក់ទិននឹងអំពើប្រល័យពូជសាសន៍។ ដូចនេះ អង្គបុរេជំនុំជម្រះនឹងធ្វើការពិចារណាលើទឡ្ហីករណ៍ទាំងនោះជាមួយនឹងមូលដ្ឋានទីបួន។

[៥៤] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៧៣-៧៩។

[៥៥] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៧៧។

[៥៦] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៧៨។

[៥៧] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៨០។

00686474

៣៥. មូលដ្ឋានទីប្រាំពីរអះអាងថា ដីកាដែលរងការជំទាស់មានការភ័ន្តច្រឡំនៅក្នុងការអនុវត្ត "ការទទួលខុសត្រូវរបស់ថ្នាក់លើ ជាទម្រង់នៃការទទួលខុសត្រូវដែលទាក់ទងទៅនឹងបទឧក្រិដ្ឋកម្មបីដែលកំណត់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[៥៨] ពីព្រោះ "គ្មានមូលដ្ឋានទំនៀមទម្លាប់ដែលគាំទ្រការអនុវត្តទ្រឹស្តីនេះទេ ក្នុងអំឡុងពេលចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩" ការកាត់សេចក្តីចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើជាការរំលោភបំពានលើគោលការណ៍ដែលថា *គ្មានបទល្មើសបើគ្មានច្បាប់ចែង*[៥៩]។ ឬក៏ជាជម្រើសមួយផ្សេងវិញ ការទទួលខុសត្រូវរបស់ថ្នាក់លើ "អាចត្រូវបានគេយកមកចោទប្រកាន់លើឧក្រិដ្ឋកម្មសង្គ្រាមតែប៉ុណ្ណោះ"[៦០]។ ជាងនេះទៅទៀត "ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ គឺផ្អែកលើមូលដ្ឋាននៃការខកខានមិនបានចាត់វិធានការ" និង "ដីកាដំណោះស្រាយខកខានមិនបានបង្ហាញអំពីកាតព្វកិច្ចបែបនេះ"[៦១]។

៣៦. បន្ថែមពីលើនេះទៀត បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ លើកឡើងនូវមូលដ្ឋានចំនួនបី ដើម្បីគាំទ្រដល់ទឡ្ហីករណ៍ដែលថា "ដីកាដំណោះស្រាយរំលោភបំពានលើសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌" ហេតុនេះហើយ "ស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលទុកជាអសារឥតការនូវដីកាដំណោះស្រាយនេះដោយផ្អែកលើមូលដ្ឋាននេះ"[៦២]។

៣៧. ជាពិសេស មូលដ្ឋានទីប្រាំបី លើកឡើងថា ដីកាដែលរងការជំទាស់ "មិនរវីរវល់ទៅនឹងការរកឃើញអង្គច្បាប់ដទៃៗទៀតឡើយ" ពីព្រោះសហចៅក្រមស៊ើបអង្កេតខកខានមិនបានផ្តល់មូលដ្ឋានភស្តុតាងដោយមានសំអាងហេតុ ដើម្បីគាំទ្រលើសេចក្តីសម្រេចរបស់ខ្លួនឡើយ"[៦៣]។

៣៨. មូលដ្ឋានទីប្រាំបួន លើកឡើងថា សហចៅក្រមស៊ើបអង្កេត "មានការភ័ន្តច្រឡំនៅពេលដែលខ្លួនខកខាន មិនបានយកអង្គហេតុជាក់លាក់នៅក្នុងរឿងក្តី [...] មកអនុវត្តចំពោះបញ្ហាទាំងឡាយដែលត្រូវ

---

[៥៨] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៨១។

[៥៩] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៨៤។

[៦០] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៩០។

[៦១] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៩៣។

[៦២] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ១០៤។

[៦៣] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៩៧។

00686475

សម្រេចឡើយ" និង "គ្រាន់តែបានយោងលើការរកឃើញអង្គហេតុដែលទទួលស្គាល់រួចហើយ ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្ដី ឌុច តែប៉ុណ្ណោះ" ដោយគ្មានការលើកហេតុផលសមរម្យឡើយ[៦៤]។

៣៩. មូលដ្ឋានទីដប់ លើកឡើងថា កថាខណ្ឌ ១៥៧៤ នៃដីកាដំណោះស្រាយ "ត្រង់ផ្នែកដែលទាក់ទិននឹងការចោទប្រកាន់បញ្ជូនដើមបណ្ដឹងឧទ្ធរណ៍ទៅជំនុំជម្រះ ពីបទល្មើសទាំងឡាយដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ត្រូវចាត់ទុកជាមោឃៈ"[៦៥] ពីព្រោះវា "ខកខានមិនបានចែងអំពីការកំណត់បទល្មើសដោយផ្អែកលើអង្គហេតុឡើយ"[៦៦] ដែលចាំបាច់ដើម្បីឱ្យដើមបណ្ដឹងឧទ្ធរណ៍អាចរៀបចំការការពារខ្លួន "និងដើម្បីជៀសវាងហេតុការណ៍ដែលប៉ះពាល់ដល់ខ្លួនដោយថាហេតុ"[៦៧]។

<u>**ចម្លើយតបនានា**</u>

៤០. នៅក្នុងចម្លើយតបរួម សហព្រះរាជអាជ្ញាស្នើសុំឱ្យបដិសេធចោលបណ្ដឹងឧទ្ធរណ៍ ពីព្រោះ "បណ្ដឹងឧទ្ធរណ៍ទាំងនេះ មិនអាចទទួលយកបានឡើយ ពីព្រោះរយៈពេលកំណត់បានផុតរលត់ទៅហើយ តាមនីតិវិធីសម្រាប់បណ្ដឹងឧទ្ធរណ៍ទាំងនេះ ហើយលើសពីនេះទៀត បណ្ដឹងឧទ្ធរណ៍ទាំងនេះមិនមានអង្គសេចក្ដីគ្រប់គ្រាន់"[៦៨] សម្រាប់សំអាងហេតុនានាដូចខាងក្រោម: ១) អ.វ.ត.ក មានយុត្តាធិការលើបទឧក្រិដ្ឋអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវក្រោមច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដែល "ផ្ដល់អំណាចឱ្យតុលាការអនុវត្តច្បាប់អន្តរជាតិ ហើយប្រការនេះស៊ីសង្វាក់គ្នាជាមួយនឹងគោលការណ៍នីត្យានុកូលភាព"[៦៩] ២) "ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានផ្ដន្ទាទោសបទឧក្រិដ្ឋកម្មទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នៅក្នុងវិសាលភាព

---

[៦៤] បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៩៨។

[៦៥] បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៩៩។

[៦៦] បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ១០០។

[៦៧] បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ១០១។

[៦៨] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២។

[៦៩] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២(៤)។

ដែលមានក្នុងដីកាដំណោះស្រាយ”[៧០] ៣) បញ្ហានៃសុពលភាពនៃការពន្យារចិរវេលានៃអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋជាតិ [...] ស្របទៅនឹងគោលការណ៍នីត្យានុកូលភាព សិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់ ព្រមទាំងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌”[៧១] ៤) “ការទទួលខុសត្រូវរបស់ថ្នាក់លើ គឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នៅក្នុងវិសាលភាពដែលមាននៅក្នុងដីកាដំណោះស្រាយ”[៧២] ៥) “ពុំមានការបង្ហាញពីការរំលោភបំពានសិទ្ធិឡើយ” នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលចោទថា មានការបំពានលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌[៧៣]។

៤១. បន្ថែមពីលើចម្លើយតបរបស់សហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីក្រុម បានដាក់សេចក្តីសង្កេតទៅនឹងបណ្តឹងឧទ្ធរណ៍នានា។

៤២. ទីមួយ សេចក្តីសង្កេត I របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី “ឆ្លើយតបរាល់ចំណុចដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តី”[៧៤] ដែលជំទាស់អំពីយុត្តាធិការរបស់ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ និងដោយលើកឡើងអំពីការរំលោភបំពានលើគោលការណ៍នីត្យានុកូលភាពនៅក្នុងការចោទប្រកាន់ពីបទឧក្រិដ្ឋទាំងនោះនៅក្នុងដីកាដំណោះស្រាយ[៧៥]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏បានឆ្លើយតបទៅនឹងបញ្ហានានាដូចតទៅ: អាជ្ញាយុកាលសម្រាប់បទឧក្រិដ្ឋផ្អែកតាមច្បាប់ជាតិ ត្រូវបានលើកឡើងថារារាំងយុត្តាធិការរបស់ អ.វ.ត.ក លើបទឧក្រិដ្ឋទាំងនោះ, យុត្តាធិការរបស់ អ.វ.ត.ក លើសហឧក្រិដ្ឋកម្មរួមដែលជាទម្រង់នៃការទទួលខុសត្រូវ, យុត្តាធិការរបស់ អ.វ.ត.ក លើការទទួលខុសត្រូវរបស់ថ្នាក់លើដែលជាទម្រង់នៃការទទួលខុសត្រូវ, និងការរំលោភលើសិទ្ធិក្នុងការទទួលការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលបានចោទប្រកាន់នៅក្នុង

[៧០] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២(៦)។

[៧១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២(៣)។

[៧២] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២(៨)។

[៧៣] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២(១១)។

[៧៤] សេចក្តីអង្កេត I របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ៧។

[៧៥] សេចក្តីអង្កេត I របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ៨-៣៦។

ដីកាដំណោះស្រាយដូចដែលបានលើកឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍[៧៦]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ម្នាក់ៗ ពាក់ព័ន្ធទៅនឹងបញ្ហាទាំងអស់នេះគ្មានន័យខ្លឹមសារនោះទេ និង "ភ្ជាប់ទៅនឹងការចោទប្រកាន់ និងស្នើសុំថា" ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបញ្ជូនខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីឆ្លើយតបនឹងការចោទប្រកាន់នានាដែលមាននៅក្នុងដីកាដំណោះស្រាយ[៧៧]។

៤៣. ទីពីរ នៅក្នុងសេចក្តីសង្កេត II របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា "រាល់ទឡ្ហីករណ៍ទាំងអស់ដែលបានបង្ហាញនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ [...] មិនអាចទទួលយកបានទេ ហើយយើងខ្ញុំសូមប្រកាសថា យើងគាំទ្ររាល់ទឡ្ហីករណ៍ទាំងអស់ដែលបានបង្ហាញដោយសហព្រះរាជអាជ្ញានៅក្នុងចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា [...] និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០"[៧៨]។ ដូចនេះ "សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យអង្គបុរេជំនុំជម្រះ៖ ១. ប្រកាសថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន និង ២. បញ្ជូនដីកាដំណោះស្រាយទៅអង្គជំនុំជម្រះសាលាដំបូងឱ្យបានឆាប់រហ័ស"[៧៩]។

៤៤. ទីបី នៅក្នុងសេចក្តីសង្កេត III របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញអំពីទឡ្ហីករណ៍នានា ដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួនដែលថា ម្ចាស់បណ្តឹងឧទ្ធរណ៍: ១) បកស្រាយដោយភ័ន្តច្រឡំ ដោយកត់សម្គាល់ថាច្បាប់អន្តរជាតិ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មអន្តរជាតិ ដែលពួកគាត់ត្រូវបានចោទប្រកាន់ មិនអាចយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក ទេ"[៨០] ២) មានការភ័ន្តច្រឡំនៅពេលម្ចាស់បណ្តឹងឧទ្ធរណ៍ទាមទារថា "អនុលោមតាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដោយយោងលើអង្គហេតុ មិនប៉ះពាល់ដល់គោលការណ៍នីត្យា

[៧៦] សេចក្តីអង្កេត I របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ៣៧-៦២។

[៧៧] សេចក្តីអង្កេត I របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ៦៧។

[៧៨] សេចក្តីអង្កេត II របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ៨ (ជើងទំព័រដែលត្រូវបានលុបចេញ)។

[៧៩] សេចក្តីអង្កេត II របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ១១។

[៨០] សេចក្តីអង្កេត III របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, ទំព័រ ៤។

00686478

នុកូលភាព”[៨១] និង ៣) “ប្រព្រឹត្តកំហុសខុសឆ្គងក្នុងការវាយតម្លៃអង្គហេតុ ដោយចាត់ទុកថា ខ្លួនមិនបានដឹងពីឧក្រិដ្ឋកម្មអន្តរជាតិ ដែលបានចោទប្រកាន់ចំពោះខ្លួននោះទេ” ពីព្រោះជនជាប់ចោទបានដឹងអំពីឧក្រិដ្ឋកម្មអន្តរជាតិទាំងនោះ “ដោយសារលក្ខណៈព្រៃផ្សៃជាពិសេសនៃឧក្រិដ្ឋកម្មទាំងនេះ”[៨២] និង “ដោយមូលហេតុពួកគាត់មានមុខងារជាអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យ”[៨៣]។ ដូចនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យអង្គបុរេជំនុំជម្រះ៖ ១) “កត់សម្គាល់ថា ជនជាប់ចោទសុទ្ធតែបានដឹងអំពីភាពព្រៃផ្សៃនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត”[៨៤] ២) “កត់សម្គាល់ថា ជនជាប់ចោទទាំងអស់សុទ្ធតែមានសមត្ថភាពអាចដឹងថា ខ្លួនអាចនឹងត្រូវគេចាប់ឱ្យទទួលខុសត្រូវ”[៨៥] ៣) “កត់សម្គាល់ថា នៅសម័យនោះ ជនជាប់ចោទដឹងអំពីបទប្បញ្ញត្តិច្បាប់ជាតិ និងអន្តរជាតិ”[៨៦] ៤) “កត់សម្គាល់ថា បទឧក្រិដ្ឋនីមួយៗសុទ្ធតែត្រូវបានចែងក្នុងច្បាប់អនុសញ្ញាអន្តរជាតិ និង/ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលវេលាពាក់ព័ន្ធ”[៨៧] និង “អាស្រ័យហេតុដូច្នេះ ច្រានចោលនូវរាល់សំណើរបស់ជនជាប់ចោទ” ពាក់ព័ន្ធនឹងការចោទប្រកាន់ លើជនជាប់ចោទអំពីបទឧក្រិដ្ឋអន្តរជាតិ[៨៨]។

<u>សារណាតបឆ្លើយ</u>

៤៥. នៅក្នុងការឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ដើម្បីបន្ថែមទៅលើទឡ្ហីករណ៍នានាដែលបានធ្វើឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, នួន ជា អះអាងថា: “(i) បណ្តឹងឧទ្ធរណ៍បានដាក់ទាន់ពេលវេលា និងអាចទទួលយកបាន (ii) ការបន្ថែមអាជ្ញាយុកាលសម្រាប់បទឧក្រិដ្ឋនានាដែលមាននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ រំលោភលើគោលការណ៍នីត្យានុកូលភាព និង (iii) ការិយាល័យសហព្រះរាជអាជ្ញា [...] ខកខានមិនបានបដិសេធជំហររបស់មេធាវីការពារក្តីដែលថា

[៨១] សេចក្តីអង្កេត III របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ២៥។

[៨២] សេចក្តីអង្កេត III របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, ទំព័រ ១២។

[៨៣] សេចក្តីអង្កេត III របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, ទំព័រ ១៣។

[៨៤] សេចក្តីអង្កេត III របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ៤២។

[៨៥] សេចក្តីអង្កេត III របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ៤៣។

[៨៦] សេចក្តីអង្កេត III របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ៤៤។

[៨៧] សេចក្តីអង្កេត III របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ៤៥។

[៨៨] សេចក្តីអង្កេត III របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ៤៦។

"នៅក្នុងការបញ្ជាក់អំពីយុត្តាធិការរបស់តុលាការ សហចៅក្រមស៊ើបអង្កេត [...] មានការភ័ន្តច្រឡំអង្គច្បាប់ដោយសន្និដ្ឋានថា ការអនុវត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ [...] និងទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត ដែលត្រូវបានទទួលស្គាល់នៅក្នុងដីកាដំណោះស្រាយស្របជាមួយនឹងគោលការណ៍នីត្យានុកូលភាព"[៤៩]។ "ហេតុដូច្នេះ ក៏ដូចជាសំអាងហេតុដែលមាននៅក្នុងបណ្ដឹងឧទ្ធរណ៍ទាំងអស់នោះ មេធាវីការពារក្ដីស្នើសុំឱ្យអង្គបុរេជំនុំជម្រះទុកជាមោឃៈនូវដីកាដំណោះស្រាយ ប្រកាសថា ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក រំលោភលើគោលការណ៍នីត្យានុកូលភាពរបស់ប្រទេសកម្ពុជា និងដោះលែង នួន ជា ចេញពីមន្ទីរឃុំឃាំងរបស់តុលាការជាបន្ទាន់"[៥០]។

៤៦. ស្រដៀងគ្នានេះដែរ អៀង ធីរិទ្ធ ឆ្លើយតបថា "ទឡ្ហីករណ៍ទាំងប៉ុន្មានដែលមាននៅក្នុងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាគួរតែបោះបង់ចោល និងទទួលយកបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី"[៥១]។ ផ្ទុយទៅនឹងទឡ្ហីករណ៍នានាដែលបានលើកឡើង នៅក្នុងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ចម្លើយតបរបស់ អៀង ធីរិទ្ធ លើកឡើងថា "បណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដីគឺអាចទទួលយកបាន នៅគ្រប់ទិដ្ឋភាពទាំងអស់"[៥២]។ លើសពីនេះទៀត ចម្លើយតបរបស់ អៀង ធីរិទ្ធ ជំទាស់អំពីទម្រង់នៃចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ដោយលើកឡើងថា វាមានភាពមិនច្បាស់លាស់ បកស្រាយទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ខុស យោងលើច្បាប់យុត្តិសាស្ត្រកាលពីមុនមិនគ្រប់គ្រាន់ អះអាងមិនត្រឹមត្រូវអំពីអង្គហេតុ និងរំលោភលើបទដ្ឋាននៃការសន្មតទុកជាមុនថាគ្មានទោស[៥៣]។ ជាចុងក្រោយ សារណាតបរបស់ អៀង ធីរិទ្ធ បដិសេធចោលនូវទឡ្ហីករណ៍មួយចំនួនរបស់សហព្រះរាជអាជ្ញាលើអង្គសេចក្ដី ដែលពាក់ព័ន្ធជាមួយនឹងការចោទប្រកាន់អំពីបទឧក្រិដ្ឋផ្អែកតាមច្បាប់ជាតិ[៥៤] អ.វ.ត.ក មានយុត្តាធិការលើបទឧក្រិដ្ឋអន្តរជាតិ[៥៥] លក្ខណៈរបស់ អ.វ.

---

[៤៩] ចម្លើយតបរបស់ នួន ជា, កថាខណ្ឌ ១ (ជើងទំព័ររងការលុប)។

[៥០] ចម្លើយតបរបស់ នួន ជា, កថាខណ្ឌ ១៦។

[៥១] សារណាតបរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៨៦។

[៥២] សារណាតបរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៧។

[៥៣] សារណាតបរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៨-២២។

[៥៤] សារណាតបរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ ២៣-៣១។

[៥៥] សារណាតបរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៣២-៣៧។

ត.ក[៩៦] គោលការណ៍នីត្យានុកូលភាព[៩៧] និងការទទួលខុសត្រូវរបស់ថ្នាក់លើ[៩៨]។ នៅក្នុងសេចក្តីសន្និដ្ឋានចម្លើយតបរបស់ អៀង ធីរិទ្ធ ស្នើសុំឱ្យអង្គបុរេជំនុំជម្រះ៖ "សម្រេចថា អ.វ.ត.ក ពុំមានយុត្តាធិការកាត់សេចក្តីម្ចាស់បណ្តឹងឧទ្ធរណ៍ពីបទឧក្រិដ្ឋមួយចំនួន និងទម្រង់នៃការទទួលខុសត្រូវដែលមានរៀបរាប់នៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ហើយបដិសេធចោលនូវដីកាដំណោះស្រាយដោយសារកង្វះយុត្តាធិការ និងជាលទ្ធផលបានរំលោភលើសិទ្ធិក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដូចមានរៀបរាប់ក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី"[៩៩]។

III. **ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍**

៤៧. មុនពេលលើកឡើងអំពីអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ទាំងអស់នេះ អង្គបុរេជំនុំជម្រះត្រូវធ្វើការសម្រេចជាបញ្ហាបឋមថាតើបណ្តឹងឧទ្ធរណ៍ទាំងនេះអាចទទួលយកបានដែរឬទេ។ ពាក់ព័ន្ធទៅនឹងមូលដ្ឋានទីប្រាំមួយនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលលើកឡើងពីកង្វះយុត្តាធិការលើសហឧក្រិដ្ឋកម្មរួមដែលជាទម្រង់នៃការទទួលខុសត្រូវ ជាដំបូង អង្គជំនុំជម្រះកត់សម្គាល់ឃើញថាដូចដែលបានទទួលស្គាល់ដោយម្ចាស់បណ្តឹងឧទ្ធរណ៍ អង្គជំនុំជម្រះ "បានសម្រេចលើបញ្ហានេះរួចហើយ"[១០០]។ ដោយគិតអំពីអង្គហេតុនេះ និងដោយម្ចាស់បណ្តឹងឧទ្ធរណ៍បង្ហាញថា ខ្លួនមានគម្រោង "ធ្វើការជំទាស់នឹងការអនុវត្តទ្រឹស្តីនេះ នៅពេលសវនាការបឋមនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងមិនមែននៅពេលនេះទេ" អង្គបុរេជំនុំជម្រះនឹងមិនធ្វើការពិចារណាលើមូលដ្ឋានទីប្រាំមួយនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ថែមទៀតទេ[១០១]។

៤៨. សម្រាប់មូលដ្ឋានទីមួយ ដល់ទីប្រាំ នៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា និងមូលដ្ឋានទីមួយ ដល់ទីបួន,

---

[៩៦] សារណាតបរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៣៨-៣៩។

[៩៧] សារណាតបរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៤០-៦៩។

[៩៨] សារណាតបរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៧០-៨៥។

[៩៩] សារណាតបរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៨៦។

[១០០] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៨០។

[១០១] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៨០។

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C.

ទីប្រាំ និងទីប្រាំពីរ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថា ដោយសារតែមូលដ្ឋានទាំងនោះលើកឡើងអំពីមូលដ្ឋានយុត្តាធិការក្រោមវិធាន ៦៧(៥), ៧៤ និង ៧៥ នៃវិធានផ្ទៃក្នុង មូលដ្ឋានទាំងនោះអាចទទួលយកបានទេ[១០២]។ លើសពីនេះទៀត បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ អះអាងថា មូលដ្ឋានទីប្រាំបី ដល់ទីដប់នៃបណ្តឹងឧទ្ធរណ៍ដែលលើកឡើងពីការបំពារបំពានលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ អាចទទួលយកបានផ្អែកលើវិធាន ២១ នៃវិធានផ្ទៃក្នុង[១០៣]។

៤៩. សហព្រះរាជអាជ្ញាលើកឡើងនូវការជំទាស់ជាច្រើន ទៅនឹងភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ទាំងអស់នេះ ដែលអង្គបុរេជំនុំជម្រះនឹងធ្វើការពិនិត្យជាបន្តបន្ទាប់នាពេលនេះ។

ក. <u>បញ្ហាថាតើបណ្តឹងឧទ្ធរណ៍ទាំងនេះ គឺជាបណ្តឹងដែលជំទាស់នឹងផ្នែកយុត្តាធិការដែរឬទេ អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង</u>

១. <u>សារណានានា</u>

៥០. សហព្រះរាជអាជ្ញាលើកឡើងថា ផ្នែកមួយចំនួននៃមូលដ្ឋានដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវតែបដិសេធចោល ដោយអង្គបុរេជំនុំជម្រះថាមិនអាចទទួលយកបានទេ ពីព្រោះផ្នែកទាំងនោះមិនពាក់ព័ន្ធទៅនឹងការប្តឹងឧទ្ធរណ៍ អំពីបញ្ហាយុត្តាធិការដែលមានបញ្ជាក់នៅក្នុងដីកាដែលរងការជំទាស់នោះទេ[១០៤]។

៥១. ទីមួយ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា នៅក្នុងបរិបទនៃមូលដ្ឋានទីមួយ ដល់ទីបី នៃ

---

[១០២] បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កថាខណ្ឌ ៥។ បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ២-៣, ៥។

[១០៣] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៤-៥ (ទាញសំអាងហេតុ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំឲ្យកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1), ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០, ឯកសារ D264/2/6) ("សាលដីកាស្តីពីការរំលោភលើនីតិវិធី")។ សារណាតបរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៥។

[១០៤] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៩, ១២-៣១។

ECCC * CETC PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលបានលើកឡើងពីកង្វះយុត្តាធិការលើការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ "អៀង ធីរិទ្ធ បានថ្លែងអំពីការមិនយល់ស្របរបស់ខ្លួនចំពោះសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ និងការកំណត់លក្ខណៈថា ទាហាននិងជនស៊ីវិលវៀតណាមជាជនដែលត្រូវបានការការពារដែរ"[១០៥]។ សហព្រះរាជអាជ្ញាតវ៉ាថា "បញ្ហាថាតើបទល្មើសមួយដែលត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយត្រូវនឹងលក្ខខណ្ឌតម្រូវនៃធាតុផ្សំនៃឧក្រិដ្ឋកម្មដែរឬទេ គឺជាបញ្ហាអង្គហេតុដែលគេពុំអាចប្តឹងឧទ្ធរណ៍នៅអង្គបុរេជំនុំជម្រះបានឡើយ"[១០៦] ហេតុដូច្នេះហើយកថាខណ្ឌ ៦៤ និង ៦៥ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវតែបដិសេធចោលថាមិនអាចទទួលយកបានទេ។

៥២. ទីពីរ សហព្រះរាជអាជ្ញាអះអាងថា ចំពោះវិសាលភាពដែលថាមូលដ្ឋានទីបួននៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ នៅក្នុងកថាខណ្ឌ ៦០ ដល់ ៦៣ លើកឡើងពីកង្វះយុត្តាធិការលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការជំទាស់នឹងការកំណត់និយមន័យរបស់សហចៅក្រមស៊ើបអង្កេត និងការអនុវត្តធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះត្រូវតែបដិសេធចោលថាមិនអាចទទួលយកបានទេ[១០៧]។ នេះដោយសារតែ "នៅពេលដែលឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវណាមួយត្រូវបានទទួលការយល់ព្រម ដូចដែលមានមូលដ្ឋាននៅក្នុងច្បាប់ហើយនោះ ទង្វើទាំងឡាយណាដែលនៅជុំវិញឧក្រិដ្ឋកម្ម ឬការទទួលខុសត្រូវនោះ គឺមិនអាចឱ្យប្តឹងតវ៉ាជំទាស់ ដោយផ្អែកលើទឡ្ហីករណ៍ដែលទាក់ទងនឹងយុត្តាធិការបានឡើយ"[១០៨]។

៥៣. ទីបី សហព្រះរាជអាជ្ញាអះអាងថា មូលដ្ឋានទីប្រាំនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលលើកឡើងពីកង្វះយុត្តាធិការពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋផ្អែកតាមច្បាប់ជាតិ ស្របតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[១០៩] ពីព្រោះការពន្យារថិរវេលាដែលមានភាពប្រតិសកម្មនៃអាជ្ញាយុកាលលើបទឧក្រិដ្ឋ

---

[១០៥] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២៦ និង ជើងទំព័រ ៧៤, ៧៧ (ទាញសំអាងហេតុ បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៦៤, ៦៥)។

[១០៦] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២២។

[១០៧] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២៨។

[១០៨] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២៧។

[១០៩] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៧៣-៧៩។

ទាំងអស់នេះ ផ្ទុយទៅនឹងគោលការណ៍នីត្យានុកូលភាព និងសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ មិនអាចទទួលយកបានទេ។ នេះដោយសារតែ "សុពលភាពនៃការពន្យារថិរវេលានៃអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋជាតិដែលជាបញ្ហាលាយឡំគ្នានៃច្បាប់ និងអង្គហេតុ មិនបានលើកឡើងនូវបញ្ហាយុត្តាធិការឡើយ"[១១០]។

៥៤. ជាចុងក្រោយ សហព្រះរាជអាជ្ញាលើកឡើងថា កថាខណ្ឌ ៩៣ នៃមូលដ្ឋានទីប្រាំពីរនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលលើកឡើងពីកង្វះយុត្តាធិការលើការទទួលខុសត្រូវរបស់ថ្នាក់លើដែលជាទម្រង់នៃការទទួលខុសត្រូវ ត្រូវតែបដិសេធចោលថាមិនអាចទទួលយកបានឡើយ ដោយហេតុថា កថាខណ្ឌនេះលើកឡើងពី "វិការៈផ្នែកទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺមិនទាក់ទងនឹងយុត្តាធិការទេ ហេតុដូច្នេះ មិនអាចប្តឹងឧទ្ធរណ៍បានទេ"[១១១]។ កថាខណ្ឌ ៩៣ លើកឡើងថា "ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ គឺផ្អែកលើមូលដ្ឋាននៃការខកខានមិនបានចាត់វិធានការ។ ដូច្នេះ កាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការរារាំងការប្រព្រឹត្តបទល្មើសចាំបាច់ត្រូវមានអត្ថិភាព [...]។ នៅពេលខកខានមិនបានបង្ហាញអំពីអត្ថិភាពនៃកាតព្វកិច្ចបែបនេះ និងមូលដ្ឋានរបស់វានៅក្នុងច្បាប់ជាតិ សហចៅក្រមស៊ើបអង្កេតមិនបានផ្តល់មូលដ្ឋានលើការចោទប្រកាន់លើការទទួលខុសត្រូវរបស់ថ្នាក់លើរបស់ដើមបណ្តឹងឧទ្ធរណ៍[...]"[១១២]។

៥៥. ស្រដៀងគ្នានេះដែរ សហព្រះរាជអាជ្ញាអះអាងថា មូលដ្ឋានទីប្រាំបី ដល់ទីដប់ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលបានលើកឡើងអំពីការបំពារបំពានលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[១១៣] ដែលកើតឡើងដោយសារសហចៅក្រមស៊ើបអង្កេតសំអាងលើប្រភពនៃភស្តុតាងដែលមិនគ្រប់គ្រាន់, ការខកខានក្នុងការ "អនុវត្តអង្គហេតុជាក់លាក់ទៅនឹងបញ្ហានានាដែលត្រូវដោះស្រាយ", និងការខកខាន "ក្នុងការកំណត់លក្ខណៈផ្លូវច្បាប់នៃអង្គហេតុនានា" សម្រាប់ការចោទប្រកាន់នានា ស្របតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ គឺជាការជំទាស់ទៅនឹងទម្រង់នៃដីកាបញ្ជូន

---

[១១០] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២(៣)។

[១១១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២៩, ៣០។

[១១២] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៩៣។

[១១៣] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៩៥-១០១។

00686484

រឿងទៅជំនុំជម្រះ ជាជាងការជំទាស់ទៅនឹងយុត្តាធិការ[១១៤]។

៥៦. ចំពោះផ្នែកដែលនៅសេសសល់ដទៃទៀតនៃមូលដ្ឋានទីមួយ ដល់ទីបួន និងទីប្រាំពីរនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និងមូលដ្ឋានទីមួយ ដល់ទីប្រាំ នៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ដែលជំទាស់ទៅនឹងដីកាដែលរងការជំទាស់អំពីកង្វះយុត្តាធិការ សហព្រះរាជអាជ្ញាមិនជំទាស់ថា មូលដ្ឋានទាំងនោះលើកឡើងពីការជំទាស់នឹងយុត្តាធិការនោះទេ។

២. ការពិភាក្សា

៥៧. ជាបឋម ពាក់ព័ន្ធនឹងកថាខណ្ឌ ៦៤ និង ៦៥ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដូចដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា[១១៥] កថាខណ្ឌទាំងនោះពុំមានការប្តឹងឧទ្ធរណ៍ជាផ្លូវការទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក លើការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ នោះទេ។ ផ្ទុយទៅវិញ កថាខណ្ឌទាំងនោះបញ្ជាក់អំពីការមិនយល់ស្របពាក់ព័ន្ធនឹងការសន្និដ្ឋានមួយចំនួន ដែលធ្វើឡើងនៅក្នុងដីកាដែលរងការជំទាស់។ ជាការពិត បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ទទួលស្គាល់ថា "បញ្ហានេះមិនស្ថិតក្នុងនីតិវិធីប្រឆាំងនឹងសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតថាមានជម្លោះប្រដាប់អាវុធ [...] ដោយសារបញ្ហានេះទាក់ទងនឹងសារធាតុនៃភស្តុតាង មេធាវីការពារក្តីរក្សាសិទ្ធិក្នុងការជំទាស់នឹងការសន្និដ្ឋាននោះ ក្នុងពេលជំនុំជម្រះលើអង្គសេចក្តី"[១១៦]។ ដូចនេះ អង្គបុរេជំនុំជម្រះនឹងមិនពិចារណាអំពីទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ៦៤ និង ៦៥ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ នោះទេ ពីព្រោះទឡ្ហីករណ៍ទាំងនោះមិនបានលើកឡើងជាផ្លូវការអំពីមូលដ្ឋាននានានៃបណ្តឹងឧទ្ធរណ៍ដើម្បីឱ្យអង្គបុរេជំនុំជម្រះធ្វើការពិចារណាឡើយ។

៥៨. ពាក់ព័ន្ធនឹងការជំទាស់ដោយ ក.ស.ព ដែលនៅសេសសល់ សម្រាប់សំអាងហេតុដែលលើកឡើងបន្តទៀត អង្គបុរេជំនុំជម្រះយល់ឃើញថា កថាខណ្ឌ ៧៨ នៅក្នុងមូលដ្ឋានទីប្រាំ កថាខណ្ឌ ៩៣

[១១៤] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២៩, ៣០។

[១១៥] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, ជើងទំព័រ ៧៤។

[១១៦] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៦៤។

នៅក្នុងមូលដ្ឋានទីប្រាំពីរ និងមូលដ្ឋានទីប្រាំបី ដល់ទីដប់ នៃបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ មិនអាចទទួលយកបានទេ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះយល់ឃើញថា កថាខណ្ឌ ៦០ ដល់ ៦៣ នៅក្នុងមូលដ្ឋានទីបួន និងកថាខណ្ឌ ៧៣ ដល់ ៧៧ នៅក្នុងមូលដ្ឋានទីប្រាំ អាចទទួលយកបាន។

៥៩. អង្គបុរេជំនុំជម្រះរំឭកថា អនុលោមតាមវិធាន ៦៧(៥) នៃវិធានផ្ទៃក្នុង តាមការចេញដីកាដំណោះស្រាយដោយសហចៅក្រមស៊ើបអង្កេត "ដីកាដំណោះស្រាយនេះបើកផ្លូវប្ដឹងឧទ្ធរណ៍ដូចមានចែងក្នុងវិធាន ៧៤"[១១៧]។ វិធាន ៧៤ នៃវិធានផ្ទៃក្នុង ចែងអំពីមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ថា អាចត្រូវបានលើកឡើងដោយភាគីនានានៅចំពោះមុខអង្គបុរេជំនុំជម្រះ ហើយពាក់ព័ន្ធទៅនឹងបណ្ដឹងឧទ្ធរណ៍នានាពេលនេះ វិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងចែងថា "ជនត្រូវចោទ ឬជនជាប់ចោទ អាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត [...] ដែលបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"[១១៨]។

៦០. នៅក្នុងការបកស្រាយវិធាន ៧៤(៣)(ក) អង្គបុរេជំនុំជម្រះបានលើកឡើងកាលពីលើកមុននៅក្នុង "សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE)" ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ (សាលដីកា JCE") ថាមានតែការជំទាស់ផ្នែកយុត្តាធិការប៉ុណ្ណោះ ដែលអាចលើកឡើងស្របតាមវិធាននោះបាន[១១៩]។ នៅក្នុងការសម្រេចអំពីអ្វីដែលបង្កើតជាការជំទាស់ផ្នែកយុត្តាធិការត្រឹមត្រូវ អង្គបុរេជំនុំជម្រះបានពិចារណាឃើញថា អ.វ.ត.ក "ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នានឹងតុលាការ *មិនអចិន្ត្រៃយ៍*នានា" ដែលផ្ទុយទៅនឹងប្រព័ន្ធច្បាប់ស៊ីវិលជាតិ នៅពេលដែលលក្ខខណ្ឌនៃច្បាប់លក្ខន្តិកៈពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ និងការទទួលខុសត្រូវដែលអាចត្រូវបានចោទប្រកាន់ មានលក្ខណៈទូលំទូលាយ នៅពេលដែលច្បាប់ជាធរមានគ្មានការកំណត់ច្បាស់លាស់ និងនៅពេលដែល "គោលការណ៍នីត្យានុកូលភាព

---

[១១៧] វិធាន ៦៧ (៥) នៃវិធានផ្ទៃក្នុង របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មលើកទី៦, ដូចដែលត្រូវបានពិនិត្យឡើងវិញនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០ ("វិធាន៦៧(៥) នៃវិធានផ្ទៃក្នុង")។

[១១៨] វិធាន ៧៤(៣)(ក)។

[១១៩] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE), ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០, ឯកសារ D97/15/9 ("សាលដីកាលើ JCE"), កថាខណ្ឌ ២១។

តម្រូវឱ្យតុលាការអនុវត្តច្បាប់ជាធរមានចំពោះអំពើដែលចោទប្រកាន់ជនជាប់ចោទ នៅពេលនោះ [...] [និង] សុំឱ្យវិធានច្បាប់ត្រូវតែអនុវត្តតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[១២០]។ ជាលទ្ធផល អង្គបុរេជំនុំជម្រះបានអនុម័តវិធីសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍*នានា ដែលមានបណ្តឹងឧទ្ធរណ៍ថា ១) បណ្តឹងជំទាស់អត្ថិភាពនៃទម្រង់នៃការទទួលខុសត្រូវ ឬការទទួលស្គាល់ទម្រង់នោះតាមច្បាប់ទំនៀមទម្លាប់នៅពេលដែលចោទប្រកាន់" ឬក៏ ២) តវ៉ាថា ទម្រង់នៃការទទួលខុសត្រូវមិន "អាចអនុវត្តបានចំពោះបទឧក្រិដ្ឋជាក់លាក់" នៅពេលដែលចោទប្រកាន់នោះទេ និង ៣) បង្ហាញថា "ការអនុវត្តទម្រង់នៃការទទួលខុសត្រូវ នឹងរំលោភលើគោលការណ៍នីត្យានុកូលភាព" លើកឡើងនូវការជំទាស់យុត្តាធិការដែលអាចទទួលយកបាន ដែលអាចធ្វើឡើងនៅដំណាក់កាលបុរេជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី[១២១]។ ទោះបីជាយ៉ាងណាក៏ដោយ "ការជំទាស់ដែលទាក់ទិននឹងដំណើរការជាក់លាក់នៃ [...] ទម្រង់នៃការទទួលខុសត្រូវ គឺជាបញ្ហាដែលត្រូវដោះស្រាយនៅតុលាការ[១២២]។

៦១. អង្គបុរេជំនុំជម្រះយល់ឃើញថា វិធីសាស្ត្រដដែលអនុវត្តពាក់ព័ន្ធនឹងមូលដ្ឋាននានានៃបណ្តឹងឧទ្ធរណ៍នៅដំណាក់កាលបុរេជំនុំជម្រះ ដោយជំទាស់នឹងបទឧក្រិដ្ឋជាសារធាតុដែលត្រូវបានចោទប្រកាន់តាមមាត្រា ៣(ថ្មី) - មាត្រា ៨ នៃច្បាប់ អ.វ.ត.ក។ បណ្តឹងឧទ្ធរណ៍ទាំងនេះលើកឡើងតែពីការជំទាស់យុត្តាធិការដែលអាចទទួលយកបានប៉ុណ្ណោះ នៅពេលដែលមានបណ្តឹងតវ៉ាទៅនឹងអត្ថិភាពអង្គច្បាប់នៃបទឧក្រិដ្ឋ និងធាតុផ្សំនៃបទឧក្រិដ្ឋនោះនៅពេលដែលចោទប្រកាន់ និងដែលការ

---

[១២០] សាលដីកាលើ JCE, កថាខណ្ឌ ២៣, ២៤ (សម្រង់ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milutinović និងអ្នកផ្សេងទៀត.,* IT-05-98, សាលដីកាលើញត្តិរបស់ Dragoljub Ojdanić ជំទាស់នឹងយុត្តាធិការ - សហឧក្រិដ្ឋកម្មរួម", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៣, កថាខណ្ឌ ១០)។

[១២១] សាលដីកាលើ JCE, កថាខណ្ឌ ២៣-២៤។

[១២២] សាលដីកាលើ JCE, កថាខណ្ឌ ២៣ (ទាញសំអាងហេតុ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Blaškić*, IT-95-14-A, សាលដីកា, អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤, កថាខណ្ឌ ៣២-៤២ (បញ្ជាក់ការពិតពីវិសាលភាព នៃធាតុផ្សំអត្តនោម័តនៃ "ការបញ្ជា" ស្របតាមមាត្រា ៧(១) នៃច្បាប់លក្ខន្តិកៈ)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milutinović និងអ្នកផ្សេងទៀត,* IT-05-87-PT, "សេចក្តីសម្រេចលើសំណើរបស់ Ojdanić's ជំទាស់នឹងយុត្តាធិការ - សហចារីមិនផ្ទាល់" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦, កថាខណ្ឌ ២៣។

អនុវត្តនេះ និងធ្វើឲ្យមានការរំលោភលើគោលការណ៍នីត្យានុកូលភាព[១២៣]។

៦២. ទោះបីជាយ៉ាងណាក៏ដោយ "ការជំទាស់ទាក់ទងនឹងបញ្ហាជាក់លាក់មួយចំនួននៃបទល្មើសសំខាន់មួយ ឬទម្រង់នៃការទទួលខុសត្រូវ [...] គឺជាបញ្ហាដែលត្រូវដោះស្រាយនៅតុលាការ"[១២៤]។ ឧទាហរណ៍ ការជំទាស់ទៅនឹងនិយមន័យជាក់លាក់ និងការអនុវត្តធាតុផ្សំនៃបទល្មើសដែលត្រូវបានចោទប្រកាន់ មិនអាចទទួលយកបានទេនៅដំណាក់កាលបុរេជំនុំជម្រះ[១២៥]។ លើសពីនេះទៀត ការជំទាស់ទាក់ទងនឹងបញ្ហាថាតើធាតុផ្សំនានានៃបទល្មើស ដែលត្រូវបានចោទប្រកាន់ពិតជាមានជាក់ស្តែង ដែលផ្ទុយទៅនឹងច្បាប់នៅពេលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលបានចោទប្រកាន់ដែរឬទេនោះ មិនអាចទទួលយកបានទេ[១២៦]។ បញ្ហានេះដោយសារតែការជំទាស់នេះ ជាញឹកញាប់មាន

---

[១២៣] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Gotovina និងអ្នកផ្សេងទៀត,* IT-06-90-AR72.1, "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្តិ របស់ Ante Gotovina ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំជាច្រើនដែលជំទាស់នឹងយុត្តាធិការអង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៧ ("សាលដីកាលើយុត្តាធិការក្នុងរឿងក្តី *Gotovina និងអ្នកផ្សេងទៀត.*"), កថាខណ្ឌ ១៥, ១៨។

[១២៤] សាលដីកាលើ JCE, កថាខណ្ឌ ២៣ (ទាញហេតុសំអាង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Delalic *និងអ្នកផ្សេងទៀត,* IT-96-21-AR72.5, "សាលដីកាលើពាក្យសុំអនុញ្ញាតប្តឹងឧទ្ធរណ៍ធ្វើឡើងដោយ Hazim Delić (វិការៈនៅក្នុងទម្រង់នៃដីកា បញ្ជូនរឿងទៅជំនុំជម្រះ) អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ១៩៩៦, កថាខណ្ឌ ២៧ (លើកឡើងថា ទំនាស់ណាមួយដែលពាក់ព័ន្ធនឹងខ្លឹមសារនៃបទឧក្រិដ្ឋនានាដែលមានចែងនៅក្នុងមាត្រា ២,៣,៤ និង ៥ នៃច្បាប់លក្ខន្តិកៈ "គឺជាបញ្ហាសម្រាប់ជំនុំជម្រះក្តី មិនមែនសម្រាប់ជំទាស់នៅបុរេជំនុំជម្រះនោះទេ") *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Furundžija, IT-05-17/1-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨, កថាខណ្ឌ ១៧២-១៨៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត,* IT-96-23-T & IT-96-23/1-T, "សាលក្រម", អង្គជំនុំជម្រះសាលា ដំបូងនៃតុលាការ ICTY, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១, កថាខណ្ឌ ៤៣៦-៤៦០ (សាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលបញ្ជាក់ការពិតពីវិសាលភាពនៃការរំលោភផ្លូវភេទដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ស្របតាមមាត្រា ៥(ឆ) នៃច្បាប់លក្ខន្តិកៈ) ។

[១២៥] សាលដីកាលើយុត្តាធិការក្នុងរឿងក្តី *Gotovina និងអ្នកផ្សេងទៀត.*, កថាខណ្ឌ 15, 18 (ដោយយល់ឃើញថា មិនអាចទទួលយកបាននូវមូលដ្ឋាននានានៃបណ្តឹងឧទ្ធរណ៍ ដែលជំទាស់នឹងនិយមន័យនៃធាតុផ្សំមួយចំនួននៃការនិរទេស និងការជម្លៀសដោយបង្ខំដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងរំលោភលើមាត្រា ៣ រួម នៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ និងដោយតវ៉ាថាមូលដ្ឋានទាំងនោះត្រូវតែធ្វើការបកស្រាយឲ្យបានតឹងរ៉ឹង)។

[១២៦] សាលដីកាលើយុត្តាធិការក្នុងរឿងក្តី *Gotovina និងអ្នកផ្សេងទៀត,* កថាខណ្ឌ២១ (ដោយបដិសេធថាមិនអាចទទួលយក បាននូវមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ដែលអះអាងបញ្ហាថាតើស្ថានភាពនៃជម្លោះប្រដាប់អាវុធ កើតមានជាក់ស្តែងពាក់ព័ន្ធនឹង ការរំលោភលើច្បាប់មនុស្សធម៌អន្តរជាតិដែលបានលើកឡើងដូចដែលបានចោទប្រកាន់ដែរឬទេ)។ សូមមើលផងដែរ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Boškoski *និង* Tarčulovsk, IT-04-82-AR72.1, "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្តិស្តីពីយុត្តាធិការ", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៥, កថាខណ្ឌ១១-១៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Delić, IT-04-83-

00686488

ការពាក់ព័ន្ធនឹងការសម្រេចលើបញ្ហាពិតប្រាកដ ឬបញ្ហាលាយឡំគ្នានៃអង្គច្បាប់ និងអង្គហេតុដែលត្រូវធ្វើឡើងនៅពេលសវនាការតាមការសួរដេញដោល និងការថ្លឹងថ្លែងលើភស្តុតាងទាំងអស់[១២៧]។

៦៣. ជាចុងក្រោយ ទាក់ទិននឹងការជំទាស់ដែលលើកឡើងពីវិការៈនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការជំទាស់ទាំងនោះមិនមានលក្ខណៈយុត្តាធិការនោះទេ ហេតុដូច្នេះហើយ មិនអាចទទួលយកបានទេ នៅដំណាក់កាលបុរេជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី ស្របជាមួយនឹងអត្ថន័យទាំងមូលនៃវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង និងជំពូក II នៃច្បាប់ អ.វ.ត.ក ដែលគូសបញ្ជាក់ពីយុត្តាធិការលើរូបបុគ្គល យុត្តាធិការពេលវេលា និងយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក[១២៨]។ ពុំមានបញ្ញត្តិណាមួយនៅក្នុងច្បាប់ អ.វ.ត.ក ឬវិធានផ្ទៃក្នុងចែងថា

AR72, "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំ ជំទាស់នឹងយុត្តាធិការរបស់តុលាការ", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ២០០៥, កថាខណ្ឌ១១ (លើកឡើងថា "ក្នុងវិសាលភាពដែលទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងឧទ្ធរណ៍មិនជាប់ទាក់ទិននឹងភាពគ្រប់គ្រាន់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប៉ុន្តែជាប់ទាក់ទិននឹងភាពគ្រប់គ្រាន់ នៃភស្តុតាងគាំទ្រ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ឯកភាពជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងថា នេះជាបញ្ហាដែលត្រូវដោះស្រាយ នៅពេលសវនាការ")។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Šešelj,* IT-03-67-AR72.1, "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំ ទាក់ទងនឹងយុត្តាធិការ", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤, កថាខណ្ឌ១៤ (ដោយលើកឡើង ថាតើការចោទប្រកាន់អាចបង្ហាញនូវការទាក់ទងរវាងឧក្រិដ្ឋកម្មតាមមាត្រា ៥ ដែលបានលើកឡើង នៅ Vojvodina និងជម្លោះប្រដាប់អាវុធនៅ Croatia និង/ឬ Bosnia និង Herzegovina ជាបញ្ហាអង្គហេតុដែលត្រូវធ្វើការ សម្រេចនៅពេលសវនាការដែរឬទេ)។

១២៧ អង្គបុរេជំនុំជម្រះមិនឯកភាពជាមួយនឹងសារណាតបរបស់ អៀង ធីរិទ្ធ (ត្រង់កថាខណ្ឌ 6) ដែលថា ច្បាប់យុត្តិសាស្ត្ររបស់តុលាការ ICTY ស្តីពីការជំទាស់ផ្នែកយុត្តាធិការដែលត្រឹមត្រូវ ត្រូវធ្វើការអនុវត្តដោយប្រុងប្រយ័ត្ន ពីព្រោះ វាជាតុលាការ "ដែលផ្អែកលើច្បាប់ខំមិនឡូ" និងទស្សនៈច្បាប់ស៊ីវិលរបស់ អ.វ.ត.ក ចែងថា "បញ្ហាជាច្រើនតាមដែលអាចធ្វើបាន ត្រូវបានដោះស្រាយនៅដំណាក់កាលបុរេជំនុំជម្រះ" ពាក់ព័ន្ធនឹងការបំភ្លឺអំពីយុត្តាធិការរបស់ អ.វ.ត.ក។ នៅក្នុងតុលាការ ទាំងអំពីបញ្ហាអង្គហេតុត្រូវធ្វើការសម្រេចនៅពេលសវនាការ ហេតុដូច្នេះហើយ ការជំទាស់ផ្នែកយុត្តាធិការដែលបានលើកឡើង ដូចជាការជំទាស់ទាំងឡាយណាដែលបានរៀបរាប់នៅក្នុងកថាខណ្ឌនេះដែលលើកឡើងនូវបញ្ហាអង្គហេតុនានា ឬបញ្ហាលាយឡំគ្នានៃអង្គហេតុ និងអង្គច្បាប់ ត្រូវធ្វើការសម្រេចឱ្យបានល្អបំផុតផ្អែកតាមការថ្លឹងថ្លែង និងការពិចារណាលើភស្តុតាងដែលបានដាក់នៅពេលសវនាការ។

១២៨ សាលដីកាលើយុត្តាធិការក្នុងរឿងក្តី *Gotovina និងអ្នកផ្សេងទៀត,* កថាខណ្ឌ២១, ២៤ (ដោយយល់ឃើញថា ទឡ្ហីករណ៍នានាដែលបានលើកឡើងថា រដ្ឋអាជ្ញាបានខកខានមិនបានអះអាងអំពីធាតុផ្សំនៃទម្រង់នៃការទទួលខុសត្រូវឱ្យបានត្រឹមត្រូវ និងថាបទប្បញ្ញត្តិនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរួមមានភាពមិនស៊ីសង្វាក់គ្នា និងថា រដ្ឋអាជ្ញាខកខានមិនបានអះអាងអំពីអង្គហេតុនានាដើម្បីគាំទ្រដល់អត្ថិភាពនៃធាតុផ្សំនៃបទល្មើស ដែលមានការលើកឡើងអំពីវិការៈនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមិនអាចទទួលយកបាន)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Prlić និងអ្នកផ្សេងទៀត, IT-04-74-AR72.1,*

វិការៈដែលបានលើកឡើងនៅក្នុងទម្រង់ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះលើកឡើងបញ្ហាយុត្តាធិការនោះទេ។ ដូចនេះ ទឡ្ហីករណ៍ទាំងអស់នេះអាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីធ្វើការពិចារណាលើអង្គសេចក្តីនានានៅពេលសវនាការ។ ទោះបីជាយ៉ាងណាក៏ដោយ ទឡ្ហីករណ៍ទាំងនេះមិនបង្ហាញពីកង្វះយុត្តាធិការរបស់ អ.វ.ត.ក ឡើយ។

៦៤. ផ្អែកតាមការលើកឡើងខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា ដោយសារតែកថាខណ្ឌ ៩៣ នៅក្នុងមូលដ្ឋានទីប្រាំពីរនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ លើកឡើងថាជាបញ្ហាអង្គហេតុសហចៅក្រមស៊ើបអង្កេតខកខានមិនបានតវ៉ាឱ្យបានត្រឹមត្រូវ អំពីអត្ថិភាពនៃកាតព្វកិច្ចផ្លូវច្បាប់ដែលត្រូវបំពេញ និងមិនបានឈរលើមូលដ្ឋានច្បាប់ជាតិដែលជាធាតុផ្សំនៃការទទួលខុសត្រូវរបស់ថ្នាក់លើនោះទេ។ បញ្ហានេះបង្កឱ្យមានវិការៈដែលបានចោទប្រកាន់នៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាជាងការជំទាស់យុត្តាធិការ។ ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍ត្រង់ផ្នែកនេះ មិនអាចទទួលយកបានទេ។ ស្រដៀងគ្នានេះដែរ ទឡ្ហីករណ៍នានាដែលបានលើកឡើងក្រោមមូលដ្ឋានទីប្រាំបីដល់ទីដប់ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ពាក់ព័ន្ធនឹងប្រភពភស្តុតាងមិនគ្រប់គ្រាន់។ ការខកខានក្នុងការអនុវត្តអង្គហេតុឱ្យបានត្រឹមត្រូវ និងការខកខានក្នុងការផ្តល់លក្ខណៈផ្លូវច្បាប់នៃអង្គហេតុសម្រាប់ការចោទប្រកាន់ក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ បង្កើតបានជាការជំទាស់ដែលចោទប្រកាន់ពីវិការៈនានានៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមិនអាចទទួលយកបាន។

៦៥. ពាក់ព័ន្ធនឹងកថាខណ្ឌ ៧៨ នៅក្នុងមូលដ្ឋានទីប្រាំ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើងនូវមូលដ្ឋានរងចំនួនពីរដែលស្ថិតនៅក្នុងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍។ ជាដំបូង ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថាៈ (i) ការពន្យារអាជ្ញាយុកាលនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចំពោះបទឧក្រិដ្ឋនានានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ គឺជាការរំលោភលើគោលការណ៍ទូទៅនៃច្បាប់ដែលត្រូវបានពណ៌នាថាជាសិទ្ធិក្នុងការទទួលបានការប្រព្រឹត្តស្មើភាពគ្នាសម្រាប់រឿងក្តីដូចគ្នា និង (ii) ការពន្យារអាជ្ញាយុកាលនេះ និងការ

"សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំរបស់ Petković ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីយុត្តាធិការ" អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២00៥, កថាខណ្ឌ ១៣។

អនុវត្តនៅក្នុងរឿងក្តីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ បានធ្វើឱ្យមានការរើសអើងលើម្ចាស់បណ្តឹងឧទ្ធរណ៍[១២៩]។ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសន្និដ្ឋានទាំងពីរនៃសេចក្តីសន្និដ្ឋានទាំងនេះមិនអាចទទួលយកបានទេ ពីព្រោះសេចក្តីសន្និដ្ឋានទាំងនេះលើកឡើងពីការរំលោភលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ អង្គបុរេជំនុំជម្រះបានបំភ្លឺខាងក្រោមថា អង្គបុរេជំនុំជម្រះមានយុត្តាធិការមានកំណត់ ក្នុងការស្តាប់ការដេញដោលអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅដំណាក់កាលនេះ ស្របតាមវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ទាក់ទិននឹងបញ្ហាការជំនុំជម្រះដោយយុត្តិធម៌[១៣០]។ ជាលទ្ធផល ម្ចាស់បណ្តឹងឧទ្ធរណ៍អាចលើកឡើងនូវបញ្ហាទាំងអស់នេះចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងអំឡុងដំណាក់កាលសវនាការនៃការកិច្ចដំណើរការនីតិវិធី។

៦៦. ទោះបីជាយ៉ាងណាក៏ដោយ ពាក់ព័ន្ធនឹងកថាខណ្ឌ ៦០ ដល់៦៣ នៅក្នុងមូលដ្ឋានទីបួន នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ អង្គបុរេជំនុំជម្រះយល់ឃើញថា កថាខណ្ឌទាំងនេះលើកឡើងនូវការជំទាស់យុត្តាធិការលើរឿងក្តីដែលអាចទទួលយកបាន ពីព្រោះកថាខណ្ឌទាំងនេះអះអាងអំពីអត្ថិភាពនៅក្នុងច្បាប់នៅពេលដែលចោទប្រកាន់នៃធាតុផ្សំមួយចំនួន នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានអនុវត្តដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដែលរងការជំទាស់ នៅពេលក្រឡេកមើលទៅលើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ស្របតាមមាត្រា ៧ នៃច្បាប់លក្ខន្តិកៈឆ្នាំ ១៩៩៨ របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ ជាពិសេស កថាខណ្ឌទាំងនេះជំទាស់: ការលុបចោលអត្ថិភាពនៃលក្ខខណ្ឌកំណត់ស្តីពីជម្លោះប្រដាប់អាវុធរបស់ ក.ស.ច.ស, ការរួមបញ្ចូលនូវការរំលោភផ្លូវភេទថាជាអំពើសំខាន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, និងការរួមបញ្ចូលនូវការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ និងការបាត់ខ្លួនដោយបង្ខំ ថាស្ថិតនៅក្នុងប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" ដែលជាអំពើសំខាន់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[១៣១]។ ម្ចាស់បណ្តឹងឧទ្ធរណ៍អះអាងថា "ដូចនេះ សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំក្នុងការពង្រីកវិសាលភាពនៃអំពើដែលអាចបង្កើតបានជាបទល្មើសប្រឆាំងនឹងមនុស្សជាតិ ក្នុងក្របខ័ណ្ឌពេលវេលា

[១២៩] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៧៨។

[១៣០] សូមមើល "ផ្នែកពិភាក្សា" ក្នុងផ្នែក III(ខ) ខាងក្រោម។

[១៣១] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៦០-៦១។

ដែលពាក់ព័ន្ធ" ដោយរំលោភលើគោលការណ៍នីត្យានុកូលភាព[១៣២]។

៦៧. ស្រដៀងគ្នានេះដែរ កថាខណ្ឌ ៧៣ ដល់៧៧ នៅក្នុងមូលដ្ឋានទីប្រាំនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ លើកឡើងនូវការជំទាស់យុត្តាធិការលើរឿងក្តីដែលអាចទទួលយកបាន។ ម្ចាស់បណ្តឹងឧទ្ធរណ៍ លើកឡើងថា អ.វ.ត.ក គ្មានយុត្តាធិការក្នុងការកាត់សេចក្តីម្ចាស់បណ្តឹងឧទ្ធរណ៍ចំពោះបទឧក្រិដ្ឋជាតិ ស្របតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ទេ។ ផ្អែកតាមសេចក្តីសន្និដ្ឋានដែលធ្វើឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ដែលថា ផ្នែកនៃមូលដ្ឋានទីប្រាំនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ នេះស្ថិតនៅក្នុងលក្ខខណ្ឌកំណត់នៃវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ហេតុនេះម្ចាស់បណ្តឹងឧទ្ធរណ៍មានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្តីសម្រេចដែលបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ[១៣៣]។ បញ្ហាលទ្ធភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ ក្នុងការកាត់សេចក្តីបទឧក្រិដ្ឋជាតិនានា ដែលមានអាជ្ញាយុកាលគឺជាបញ្ហាយុត្តាធិការ។ ដីកាដែលរងការជំទាស់បញ្ជាក់ពីយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក លើម្ចាស់បណ្តឹងឧទ្ធរណ៍សម្រាប់បទល្មើសជាតិនានា។ ដូចនេះ បញ្ហាណាមួយដែលពាក់ព័ន្ធនឹងលទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងម្ចាស់បណ្តឹងឧទ្ធរណ៍សម្រាប់បទល្មើសជាតិនានា ត្រូវយកមកដោះស្រាយនៅដំណាក់កាលនេះ។

៦៨. ជាចុងក្រោយ ទោះបីជាមិនត្រូវបានជំទាស់ដោយសហព្រះរាជអាជ្ញា អង្គបុរេជំនុំជម្រះយល់ឃើញថា ផ្អែកតាមការពិនិត្យផ្នែកនៅសល់នៃមូលដ្ឋានទីមួយ ដល់ទីបួន នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ក៏ដូចជាមូលដ្ឋានទីមួយ ដល់ទីប្រាំ នៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ផ្នែកនៅសល់ទាំងនេះក៏អាចទទួលយកបានផងដែរ។ មូលដ្ឋានទាំងអស់នេះលើកឡើងអំពីការជំទាស់យុត្តាធិការលើរឿងក្តីត្រឹមត្រូវរបស់ដីកាដែលរងការជំទាស់ ដោយលើកឡើងថាតើឧក្រិដ្ឋកម្មអន្តរជាតិនានាដែលត្រូវបានចោទប្រកាន់ មាននៅក្នុងច្បាប់ថាជាបញ្ហាទូទៅនៅពេលប្រព្រឹត្តបទល្មើសដែលបានលើកឡើងដែរឬទេ និងបញ្ហាថាតើការចោទប្រកាន់បទឧក្រិដ្ឋទាំងនេះនឹងស្របតាមគោលការណ៍នីត្យានុកូលភាពដែរឬទេ។ ស្រដៀងគ្នានេះដែរ ផ្នែកដែលនៅសល់នៃមូលដ្ឋានទីប្រាំពីរនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ អាចទទួលយកបាន ពីព្រោះផ្នែកនេះជំទាស់នឹងអត្ថិភាពនៃការទទួលខុសត្រូវរបស់ថ្នាក់

[១៣២] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៦២។

[១៣៣] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៥, ៦ និង៧៣។

លើដែលជាទម្រង់នៃការទទួលខុសត្រូវ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅពេលដែលចោទប្រកាន់, ផ្នែកនេះតវ៉ាថា ការទទួលខុសត្រូវរបស់ថ្នាក់លើអនុវត្តពាក់ព័ន្ធតែនឹងឧក្រិដ្ឋកម្មសង្គ្រាមនៅពេលនោះ និងផ្នែកនេះបានលើកឡើងថា ការអនុវត្តទម្រង់នៃការទទួលខុសត្រូវនេះពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នឹងរំលោភលើគោលការណ៍នីត្យានុកូលភាព។ ដូចនេះផ្នែកនេះលើកឡើងនូវការជំទាស់យុត្តាធិការលើរឿងក្តីដែលអាចទទួលយកបាន ដែលអាចត្រូវបានលើកឡើងនៅ ក្នុងដំណាក់កាលបុរេជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី។

ខ. <u>បញ្ហាថាតើមូលដ្ឋាននានានៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ផ្អែកតាមការបំពានលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលបានលើកឡើង អាចទទួលយកបានដែរឬទេ អនុលោមតាម (១) ការបកស្រាយវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ឬ (២) វិធាន ២១ នៃវិធានផ្ទៃក្នុង</u>

១. <u>សារណានានា</u>

៦៩. អៀង ធីរិទ្ធ លើកឡើងថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបានផ្អែកតាមវិធាន ៧៤(៣) , វិធាន ២១ នៃវិធានផ្ទៃក្នុង និងតាមរយៈការបកស្រាយវិធាន ៧៤(៣) ឲ្យទូលំទូលាយ ដោយគិតដល់វិធាន ២១[១៣៤]។ ផ្ទុយទៅវិញ ក.ស.ព អះអាងថា មូលដ្ឋានទីប្រាំបី ដល់ទីដប់ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលលើកឡើងពីការបំពារបំពានលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[១៣៥] មិនអាចទទួលយកបានទេ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។ ក.ស.ព តវ៉ាថា “វិធាន ៧៤(៣) បានកំណត់អំពីសិទ្ធិផ្តាច់មុខរបស់ដើមបណ្តឹងឧទ្ធរណ៍នៅក្នុងការប្តឹងឧទ្ធរណ៍: វិធាន ២១ មិនបានបង្កើតទឡ្ហីករណ៍ថ្មីដាច់ដោយឡែកនៃបណ្តឹងឧទ្ធរណ៍សម្រាប់ជនត្រូវចោទទេ”[១៣៦]។ សហព្រះរាជអាជ្ញាលើកឡើងថា ការបកស្រាយវិធាន ២១ នេះ “មានន័យស្មើនឹងការស្នើសុំឲ្យអង្គបុរេជំនុំជម្រះកែប្រែវិធាននេះ” ដែលសកម្មភាពនឹងតំណាងឲ្យការទទួលខុសត្រូវជាឯកត្តោភាគីរបស់អង្គបុរេជំនុំជម្រះ នៅក្រៅនីតិវិធីសមស្របសម្រាប់ការធ្វើវិសោធនកម្មដែលធ្វើឡើង

[១៣៤] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៥ និង សារណាតបរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៥។

[១៣៥] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៩៥-១០១។

[១៣៦] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៨។

00686493

ដោយសម័យប្រជុំពេញអង្គរបស់ចៅក្រម យោងតាមឯកសារជាមូលដ្ឋានរបស់ អ.វ.ត.ក[១៣៧]។ លើសពីនេះទៀត សហព្រះរាជអាជ្ញា "លើកឡើងថា ការពង្រីកវិសាលភាពនៃសិទ្ធិប្ដឹងឧទ្ធរណ៍របស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ តាមវិធាន ២១ មិនសមស្របឡើយ នៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី"[១៣៨]។ ហេតុដូច្នេះ "ដោយសារហេតុផលនេះ ទើបបញ្ជីរៀបរាប់គ្មានសល់មួយអំពីទម្លីករណ៍សម្រាប់ប្ដឹងឧទ្ធរណ៍នៅមុនពេលសវនាការក្នុងវិធាន ៧៤ គួរតែត្រូវបានអនុវត្តគ្មានការកែប្រែដោយអង្គបុរេជំនុំជម្រះ"[១៣៩]។

២. ការពិភាក្សា

៧០. អង្គបុរេជំនុំជម្រះរំឭកថា វិធាន ៦៧ នៃវិធានផ្ទៃក្នុង ចែងពីការចេញដីកាដំណោះស្រាយដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនៅពេលបញ្ចប់កិច្ចស៊ើបសួរ។ ដូចដែលបានកត់សម្គាល់កាលពីមុន វិធាន ៦៧(៥) នៃវិធានផ្ទៃក្នុង បានចែងយ៉ាងច្បាស់លាស់ថា តាមការចេញដីកាដំណោះស្រាយ "ដីកានេះបើកផ្លូវប្ដឹងឧទ្ធរណ៍ដូចមានចែងនៅក្នុងវិធាន ៧៤"[១៤០]។ ពុំមានវិធានផ្ទៃក្នុងផ្សេងទៀតត្រូវបានរៀបរាប់នៅក្នុងវិធាន ៦៧ ដោយចែងអំពីមូលដ្ឋានសម្រាប់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។ លើសពីនេះទៀត ខុសពីវិធាន ៧៤ នៃវិធានផ្ទៃក្នុង វិធាន ២១ មិនបានបង្ហាញពីមូលដ្ឋាននានា សម្រាប់បណ្ដឹងឧទ្ធរណ៍នៅអង្គបុរេជំនុំជម្រះនោះទេ។ ផ្ទុយទៅវិញ វិធាន ២១ លាតត្រដាងអំពីគោលការណ៍គ្រឹះដែលគ្រប់គ្រងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ ហេតុដូច្នេះ ក្រោមលក្ខខណ្ឌច្បាស់លាស់នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះមិនយល់ស្របជាមួយនឹងការអះអាងនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលថា មូលដ្ឋានទីប្រាំបី ដល់ទីដប់ ដែលលើកឡើងពីការបំពារបំពានលើសិទ្ធិក្នុងការជំនុំជម្រះក្ដីដោយយុត្តិធម៌ អាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងនោះទេ។

៧១. បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ អះអាងថែមទៀតថា មូលដ្ឋានទាំងអស់នេះអាចទទួលយកបាន

---

[១៣៧] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៩ (ទាញហេតុសំអាង វិធាន៣ នៃវិធានផ្ទៃក្នុង)។

[១៣៨] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២១។

[១៣៩] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២១។

[១៤០] វិធាន ៦៧(៥) នៃវិធានផ្ទៃក្នុង។

ពីព្រោះវិធាន ២១ "ចែងអំពីមូលដ្ឋានបន្ថែមក្នុងការប្តឹងឧទ្ធរណ៍ នៅពេលដែលអាចមានការបង្ហាញថា សិទ្ធិក្នុងការទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានគេរំលោភ ហើយដូច្នេះបានធ្វើឱ្យប៉ះពាល់ដល់ភាពត្រឹមត្រូវនៃដំណើរការនីតិវិធី"[១៤១]។ អង្គបុរេជំនុំជម្រះបាន លើកឡើងកាលពីលើកមុនថា ដោយគិតអំពីមាត្រា ៣៣(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលចែងថា "ការជំនុំជម្រះក្តីដោយភាពយុត្តិធម៌" និងធ្វើឡើង "ដោយគោរពសិទ្ធិនានារបស់ ជនជាប់ចោទ" និងដោយគិតដល់មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិ នយោបាយ ("ICCPR") ដែល "អាចអនុវត្តបាននៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី នៅ ចំពោះមុខ អ.វ.ត.ក [...] ការពិចារណាលើសលុបនៅក្នុងរាល់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក គឺភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីទាំងនេះ ដូចមានចែងនៅក្នុងវិធាន ២១(១)(ក) នៃ វិធានផ្ទៃក្នុង"[១៤២]។ ហេតុដូច្នេះ នៅពេលដែលអង្គហេតុ និងកាលៈទេសៈនានានៃបណ្តឹងឧទ្ធរណ៍ តម្រូវឱ្យអង្គបុរេជំនុំជម្រះបានយល់ឃើញថា អង្គបុរេជំនុំជម្រះមានសមត្ថកិច្ចធ្វើការពិចារណាលើ មូលដ្ឋាននានាដែលបានលើកឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលមិនត្រូវបានរៀបរាប់ច្បាស់លាស់ ក្រោមវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង តាមរយៈការបកស្រាយដោយសេរីអំពីសិទ្ធិរបស់ជនត្រូវចោទ ក្នុងការប្តឹងឧទ្ធរណ៍ ស្របតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។

៧២. ជាឧទាហរណ៍ អង្គបុរេជំនុំជម្រះរំឭកថា នៅក្នុងសាលដីកាលើការរំលោភនីតិវិធី អង្គបុរេជំនុំជម្រះ បានរកឃើញថា អង្គបុរេជំនុំជម្រះមានសមត្ថកិច្ចធ្វើការពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតលើសំណើរបស់ អៀង ធីរិទ្ធ សុំផ្អាកកិច្ចដំណើរការ នីតិវិធី ដោយផ្អែកលើការរំលោភនីតិវិធី ពីព្រោះសំណើសុំ "លើកឡើងនូវបញ្ហាធ្ងន់ធ្ងរនៃភាព យុត្តិធម៌"[១៤៣]។ ស្រដៀងគ្នានេះដែរ នៅក្នុងសាលដីកា JCE អង្គបុរេជំនុំជម្រះបានយល់ឃើញថា អង្គបុរេជំនុំជម្រះមានសមត្ថកិច្ចធ្វើការពិចារណាលើបណ្តឹងឧទ្ធរណ៍ ដែលបានលើកឡើងអំពីបញ្ហា ថាតើជនត្រូវចោទបានទទួលសេចក្តីជូនដំណឹងគ្រប់គ្រាន់ អំពីការចោទប្រកាន់អំពីសហឧក្រិដ្ឋកម្មរួម ដែលជាទម្រង់នៃការទទួលខុសត្រូវស្របនឹងបញ្ញត្តិនៅក្នុងវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុងដែល ចែងថា "ជនណា [ដែលត្រូវសង្ស័យ ឬត្រូវបានចោទប្រកាន់] មានសិទ្ធិទទួលដំណឹងអំពីបទល្មើស

---

[១៤១] សារណាតបរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៥។

[១៤២] សាលដីកាស្តីពីការរំលោភលើនីតិវិធី, កថាខណ្ឌ ១៣-១៤។

[១៤៣] សាលដីកាស្តីពីការរំលោភលើនីតិវិធី, កថាខណ្ឌ ១៥។

E.C.C.C • C.E.T.C ... CHAMBRE ...

ដែលចោទប្រកាន់ចំពោះខ្លួន [...]" និងអង្គហេតុដែលថា "ទាំងបទដ្ឋានអន្តរជាតិ និងមាត្រា ៣៥(ថ្មី) នៃច្បាប់ អ.វ.ត.ក តម្រូវឱ្យមានភាពច្បាស់លាស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ"[១៤៤]។

៧៣. ការណ៍ដែលលើកឡើងយ៉ាងដូច្នេះ អង្គបុរេជំនុំជម្រះបញ្ជាក់ថា នៅក្នុងសាលដីកាទាំងពីរនោះ អង្គបុរេជំនុំជម្រះមិនបានលើកឡើងថា ជាបទដ្ឋានទូទៅ ស្របតាមវិធាន ៧៤(៣) ឬ វិធាន ២១ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះនឹងមានសមត្ថកិច្ចជាស្វ័យប្រវត្តិ ដើម្បីធ្វើការពិចារណាលើមូលដ្ឋាននានានៃបណ្តឹងឧទ្ធរណ៍ ដែលក្នុងនោះម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងពីបញ្ហានានាដែលទាក់ទងនឹងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីនោះ។ ផ្ទុយទៅវិញ បញ្ហាតុល្យភាព នៅក្នុងរឿងក្តីនីមួយៗ អង្គបុរេជំនុំជម្រះបានធ្វើការពិចារណាយ៉ាងយកចិត្តទុកដាក់លើបញ្ហាថាតើ "អង្គហេតុនានា និងកាលៈទេសៈនានា" នៃបណ្តឹងឧទ្ធរណ៍បានតម្រូវឱ្យមានការបកស្រាយទូលំទូលាយជាងនេះអំពីសិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ដែរឬទេ[១៤៥]។ ឧទាហរណ៍ នៅក្នុងសាលដីកាលើការរំលោភនីតិវិធី អង្គបុរេជំនុំជម្រះបានធ្វើការពិចារណាលើបញ្ហាថាតើភាពធ្ងន់ធ្ងរ និងភាពខុសប្រក្រតីនៃបញ្ហាស្តីពីភាពយុត្តិធម៌ដែលត្រូវបានលើកឡើងក្រោមទ្រឹស្តីនៃការរំលោភនីតិវិធី និងផលប៉ះពាល់នៃភាពធ្ងន់ធ្ងរ និងភាពខុសប្រក្រតីនេះលើកិច្ចដំណើរការនីតិវិធី ដែលបានធានាឱ្យមានការទទួលយកបណ្តឹងឧទ្ធរណ៍[១៤៦]។ ស្រដៀងគ្នានេះដែរ នៅក្នុងសាលដីកា JCE បញ្ហាតុល្យភាព អង្គបុរេជំនុំជម្រះបានពិចារណាលើបញ្ហាថាតើ "ផលប្រយោជន៍នៅក្នុងការសន្សំនូវធនធានតុលាការ ហើយការបង្កើនល្បឿននៃដំណើរការនីតិវិធី និងច្បាប់" មិនមានសារៈសំខាន់ជាងផលប្រយោជន៍នៃភាពយុត្តិធម៌ដែលនឹងត្រូវបានបំពេញ តាមរយៈការប្រកាសទទួលយកមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ទាំងអស់នោះដែលពាក់ព័ន្ធទៅនឹងសិទ្ធិទទួលបានភាពច្បាស់លាស់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ[១៤៧]។

៧៤. នៅពេលនេះ អង្គបុរេជំនុំជម្រះមិនយល់ឃើញថា អង្គហេតុនានា និងកាលៈទេសៈនានាតម្រូវឱ្យអង្គបុរេជំនុំជម្រះត្រូវតែយល់ឃើញថា ខ្លួនត្រូវតែទទួលយកមូលដ្ឋានទីប្រាំបី ដល់ទីដប់ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលលើកឡើងពីការបំពារបំពានលើសិទ្ធិក្នុងការទទួលបាននូវការជំនុំ-

---

[១៤៤] សាលដីកាលើ JCE, កថាខណ្ឌ ៣០-៣៤។

[១៤៥] សាលដីកាស្តីពីការរំលោភលើនីតិវិធី, កថាខណ្ឌ ១៤។ សាលដីកាលើ JCE, កថាខណ្ឌ ៣០។

[១៤៦] សាលដីកាស្តីពីការរំលោភលើនីតិវិធី, កថាខណ្ឌ ១៤។

[១៤៧] សាលដីកាលើ JCE, កថាខណ្ឌ ៣៤, ៣៥។

00686496

ជម្រះក្តីដោយយុត្តិធម៌ ស្របតាមការបកស្រាយទូលំទូលាយអំពីវិធាន ៧៤(៣)(ក) ឬវិធាន ២១ នៃវិធានផ្ទៃក្នុងនោះទេ។ អង្គបុរេជំនុំជម្រះរំឭកថា មាត្រា ៣៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក ចែងថា "អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ *និងឆាប់រហ័ស*"[១៤៨]។ លើសពីនេះទៀត វិធាន ២១(៤) នៃវិធានផ្ទៃក្នុងចែងថា គោលការណ៍គ្រឹះដែលបានអនុវត្តដោយ អ.វ.ត.ក គឺថា "ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប"[១៤៩]។ ស្រដៀងគ្នានេះដែរ មាត្រា ១៤(៣) នៃ ICCPR ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងវិធាន២១ នៃវិធានផ្ទៃក្នុង[១៥០] ចែងថា "ក្នុងការសម្រេចសេចក្តីចោទ-ប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា [...] ៖ គ) ត្រូវបានជំនុំជម្រះដោយឥតពន្យារពេលយូរហួស"[១៥១]។

៧៥. បទប្បញ្ញត្តិទាំងអស់នេះគូសបញ្ជាក់ថា សិទ្ធិមួយក្នុងចំណោមសិទ្ធិនានាដែលមានរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ គឺសិទ្ធិក្នុងការទទួលបានការជំនុំជម្រះឱ្យបានឆាប់រហ័ស។ ដូចនេះ "ភារកិច្ចក្នុងការធានាអំពីភាពយុត្តិធម៌ និងភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះតម្រូវឱ្យមានតុល្យភាពដ៏ល្អិតល្អន់នៃភាពយុត្តិធម៌"[១៥២]។ ទោះបីជាមូលដ្ឋានទីប្រាំបី ដល់ទីដប់ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ លើកឡើងនូវបញ្ហានានាដែលប៉ះពាល់ដល់វិការៈនានា នៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានចោទប្រកាន់[១៥៣] ដែលស្រដៀងគ្នាទៅនឹងមូលដ្ឋាននានាដែលត្រូវបានពិចារណានៅក្នុងសាលដីកា JCE ក៏ដោយ ក៏សាលដីកានោះត្រូវបានចេញដើម្បីឆ្លើយតបទៅនឹងភាពខ្វះចន្លោះដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលបានដាក់ដោយសហព្រះរាជ-

[១៤៨] ច្បាប់ អ.វ.ត.ក, មាត្រា ៣៣ (ថ្មី) (គូសបញ្ជាក់បន្ថែម)។

[១៤៩] វិធាន ២១(៤) នៃវិធានផ្ទៃក្នុង។

[១៥០] សាលដីកាស្តីពីការរំលោភលើនីតិវិធី, កថាខណ្ឌ ១៣។

[១៥១] ICCPR, មាត្រា ១៤(៣)។

[១៥២] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Nyiramasuhuko និងអ្នកផ្សេងទៀត,* ICTR-98-42-AR73, "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Joseph Kanyabashi ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ II នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៧ ទាក់ទងនឹងការច្រានចោលសំណើសុំប្តូរបញ្ជីឈ្មោះសាក្សីរបស់គាត់", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៧, កថាខណ្ឌ ២៤ (គូសបញ្ជាក់បន្ថែម)។

[១៥៣] សាលដីកាលើ JCE, កថាខណ្ឌ ៣១-៣៣។

អាជ្ញាតែប៉ុណ្ណោះ[១៥៤]។ នៅពេលនោះ ការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតកំពុងតែបន្តនៅឡើយ ចំណែកឯដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនទាន់បានចេញដែរ។ ដោយគិតអំពីសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជូនដំណឹងយ៉ាងឆាប់រហ័ស អំពីការចោទប្រកាន់លើខ្លួន ប្រសិនបើម្ចាស់បណ្ដឹងឧទ្ធរណ៍បានលើកឡើងដោយជោគជ័យថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមានវិការៈនោះ ម៉្លេះសមអង្គជំនុំជម្រះបានតម្រូវឱ្យមានការដាក់ឯកសារដែលមានខ្លឹមសារយ៉ាងពិស្ដារថែមទៀតអំពីការចោទប្រកាន់ដែលបានបញ្ជូនដោយសហព្រះរាជអាជ្ញា ដែលគួសបញ្ជាក់អំពីដំណើរការស៊ើបអង្កេត។ បន្ថែមពីលើនេះទៀត វាមានសារៈសំខាន់ណាស់នៅដំណាក់កាលនោះនៃកិច្ចដំណើរការនីតិវិធីនោះសម្រាប់អង្គបុរេជំនុំជម្រះធ្វើការបំភ្លឺថា លក្ខខណ្ឌកំណត់ដែលភ្ជាប់ទៅនឹងភាពច្បាស់លាស់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាបញ្ហាធំជាងលក្ខខណ្ឌកំណត់ដែលភ្ជាប់ទៅនឹងភាពច្បាស់លាស់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដូចនេះ ការពិតដែលថា មូលដ្ឋាននានានៃបណ្ដឹងឧទ្ធរណ៍នៅក្នុងសាលដីកា JCE ត្រូវបានលើកឡើង មុនពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត គឺជាមូលដ្ឋានក្នុងការយល់ឃើញថា មូលដ្ឋាននានាគឺអាចទទួលយកបាន។

៧៦. នៅដំណាក់កាលនេះ សហចៅក្រមស៊ើបអង្កេតបានបញ្ចប់កិច្ចស៊ើបសួរអូសបន្លាយអស់រយៈពេលបីឆ្នាំ បានចេញដីកាដែលរងការជំទាស់ដោយសម្រេចចោទប្រកាន់លើម្ចាស់បណ្ដឹងឧទ្ធរណ៍ និងបានបញ្ជូនរឿងក្ដីប្រឆាំងនឹងជនជាប់ចោទ ដូចដែលបានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទៅអង្គជំនុំជម្រះសាលាដំបូង។ ដូចនេះ "ផលប្រយោជន៍នៅក្នុងការពន្លឿននៃដំណើរការនីតិវិធី និងច្បាប់"[១៥៥] ជាបញ្ហាធំជាង និងមានសារៈសំខាន់ជាងផលប្រយោជន៍ដែលត្រូវទទួលបានតាមរយៈការពិចារណាលើមូលដ្ឋាននានានៃបណ្ដឹងឧទ្ធរណ៍នៅដំណាក់កាលនេះ។ ជាងនេះទៅទៀត ការចោទប្រកាន់អំពីវិការៈនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អាចត្រូវបានលើកឡើងដោយ អៀង ធីរិទ្ធ នៅពេលសវនាការ។

[១៥៤] សាលដីកាលើ JCE, កថាខណ្ឌ ៦, ៣១។

[១៥៥] សាលដីកាលើ JCE, កថាខណ្ឌ ៣៥។

គ. បញ្ហាថាតើការជំទាស់ផ្នែកនីតិវិធី នៅក្នុងបណ្តឹងឧទ្ធរណ៍ត្រូវបានរារាំងដោយពេលវេលាដែរឬទេ ពីព្រោះដីកាដែលរងការជំទាស់មិនមែនជាដីកា "ដែលបញ្ជាក់ពីយុត្តាធិការ" ដែលស្ថិតនៅក្នុងអត្ថន័យនៃវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងនោះទេ

១. សារណានានា

៧៧. ការជំទាស់ចុងក្រោយដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាគឺថា មូលដ្ឋាននានាដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ត្រូវបានរារាំងដោយពេលវេលា ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទាំងនោះមានការជំទាស់ផ្នែកយុត្តាធិការស្របតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ពីព្រោះដីកាដែលរងការជំទាស់មិនមែនជាដីកា "ដែលបញ្ជាក់ពីយុត្តាធិការ"[១៥៦]។ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា ជាដំបូងសហចៅក្រមស៊ើប-អង្កេតបានបញ្ជាក់ពីយុត្តាធិការតាមរយៈដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន នៅឆ្នាំ ២០០៧[១៥៧] ហើយដីកាទាំងនោះមិនត្រូវបានប្តឹងឧទ្ធរណ៍នៅក្នុងរយៈពេល ១០ថ្ងៃ ដែលបានចែងដោយវិធានផ្ទៃក្នុងនោះទេ[១៥៨]។ ដូចនេះ "ការសន្សំសំចៃថវិការបស់តុលាការ និងប្រសិទ្ធភាពនីតិវិធីតម្រូវថា ការដែលគ្មានការតវ៉ាចំពោះយុត្តាធិការរបស់តុលាការ [...] នាំឱ្យគេយល់បានថាជាការបាត់បង់សិទ្ធិរបស់ដើមបណ្តឹងឧទ្ធរណ៍ នឹងមានឱកាសតវ៉ាអំពីយុត្តាធិការរបស់តុលាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[...]"[១៥៩]។ លើសពីនេះទៀត "វាពុំមែនជាផលប្រយោជន៍យុត្តិធម៌ឡើយក្នុងការបោះបង់នូវពេលវេលាកំណត់ដែលមានក្នុងវិធាននានា។ ពេលវេលាកំណត់ទាំងនេះ គឺមានបំណងដោះស្រាយបញ្ហាយុត្តាធិការ នៅមុនពេលបំពេញកិច្ចស៊ើបសួរទូលំទូលាយដោយសហចៅក្រមស៊ើបអង្កេត"[១៦០]។ ជាចុងក្រោយ "ដោយហេតុថា វិធានផ្ទៃក្នុងពុំបានចែងដែលអនុញ្ញាតឱ្យមានបណ្តឹងឧទ្ធរណ៍ជំទាស់ នឹងដីកា*សម្រេចដែលបញ្ជាក់ឡើងវិញ*នូវយុត្តាធិការរបស់តុលាការ ករណីនេះគឺ

---

[១៥៦] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៣៥, ៤៣-៤៤។

[១៥៧] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៤០, ៤២។

[១៥៨] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៣៥-៤២។

[១៥៩] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៣៦។

[១៦០] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៤២។

បណ្តឹងឧទ្ធរណ៍ ជំទាស់នឹងដីកាដំណោះស្រាយ គឺពុំអាចទទួលយកបានឡើយ"[១៦១]។

២. ការពិភាក្សា

៧៨. អង្គបុរេជំនុំជម្រះមិនឯកភាពជាមួយនឹងសារណាការបស់សហព្រះរាជអាជ្ញា អំពីការបញ្ជាក់ឡើងវិញឡើយ។ ទីមួយ វាមិនច្បាស់លាស់ទេថា ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នសម្រាប់ម្ចាស់បណ្តឹងឧទ្ធរណ៍ បញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក ពាក់ព័ន្ធនឹងបទឧក្រិដ្ឋនានាដែលបានចោទប្រកាន់លើម្ចាស់បណ្តឹងឧទ្ធរណ៍។ គោលបំណងដំបូងនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន គឺដើម្បី "បញ្ជាក់អំពីអង្គហេតុ និងអង្គច្បាប់ដែលនាំឱ្យមានការឃុំខ្លួន"[១៦២]។ ដូចនេះ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដែលបានលើកឡើង បានកត់សម្គាល់អំពីបទឧក្រិដ្ឋនានា និងការចោទប្រកាន់អង្គហេតុដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, បានសម្រេចថា មានមូលហេតុសមស្របដែលនាំឱ្យជឿបានថា ម្ចាស់បណ្តឹងឧទ្ធរណ៍បានប្រព្រឹត្តបទឧក្រិដ្ឋនានាដែលបានលើកឡើង, និងបានរកឃើញថា សម្រាប់សំអាងហេតុផ្សេងៗ ការឃុំខ្លួនមានលក្ខណៈចាំបាច់នៅក្នុងដំណើរការស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត[១៦៣]។ នៅពេលមានការតវ៉ាថា ក្នុងការធ្វើបែបនេះ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ដោយមិនច្បាស់លាស់អំពីយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក ពាក់ព័ន្ធនឹងបទឧក្រិដ្ឋនានាដែលបានលើកឡើងថាត្រូវបានប្រព្រឹត្ត និងបទឧក្រិដ្ឋនានាដែលត្រូវបានជំទាស់លើមូលដ្ឋានយុត្តាធិការនៅក្នុងបណ្តឹងឧទ្ធរណ៍ទាំងនេះ ទឡ្ហីករណ៍នេះមិនអាចឱ្យជឿជាក់បាន និងមិនអាចឱ្យធ្វើការសម្រេចបានទេ។

៧៩. លើសពីនេះទៀត ស្របតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង នៅពេលបិទកិច្ចស៊ើបសួរ និងចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានធ្វើការសម្រេចចុងក្រោយពាក់ព័ន្ធនឹងការកំណត់លក្ខណៈផ្លូវច្បាប់នៃអំពើនានាដែលបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា និងសម្រេចលើបញ្ហាថាតើ អំពើទាំងនោះចាត់ទុកថាជាបទឧក្រិដ្ឋនានាដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរ

---

[១៦១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៣៥។

[១៦២] វិធាន ៦៣(២)(ក) នៃវិធានផ្ទៃក្នុង។

[១៦៣] ដីកាឃុំខ្លួន នួន ជា បណ្តោះអាសន្ន, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤, កថាខណ្ឌ ៥-៦។ ដីកាឃុំខ្លួន អៀង ធីរិទ្ធ បណ្តោះអាសន្ន, កថាខណ្ឌ ៥-១១។

ឬទេ[១៦៤]។ ក្នុងការធ្វើបែបនេះ "ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាមិនចងសហចៅក្រមស៊ើបអង្កេតឡើយ" នៅក្នុងដំណើរការស៊ើបអង្កេត[១៦៥]។ ដូចនេះ ពុំមានការកំណត់នៅពេលចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នទេថា បទឧក្រិដ្ឋនានាដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា និងជាបទឧក្រិដ្ឋដែលម្ចាស់បណ្ដឹងឧទ្ធរណ៍ នឹងត្រូវបានសម្រេចចោទប្រកាន់នៅពេលក្រោយៗមកទៀត នៅពេលបិទកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត។ ជាការពិត ម្ចាស់បណ្ដឹងឧទ្ធរណ៍មិនត្រូវបានចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍នោះទេ រហូតដល់ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩ ក្រោយពេលចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន[១៦៦]។ អនុលោមតាមលក្ខខណ្ឌនៃវិធាន ៦៧ នៃវិធានផ្ទៃក្នុង វានឹងជាការសមស្របសម្រាប់ម្ចាស់បណ្ដឹងឧទ្ធរណ៍ធ្វើការសន្មតថា ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នមិនបានបញ្ជាក់ពីយុត្តាធិការនោះទេ និងថានឹងមានប្រសិទ្ធភាពក្នុងការលើកឡើងអំពីការជំទាស់ផ្នែកយុត្តាធិការលើរឿងក្ដី បន្ទាប់ពីមានសេចក្ដីសន្និដ្ឋានស្ថាពរអំពីយុត្តាធិការដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយ។

៨០. ទីពីរ ទោះបីជាអង្គបុរេជំនុំជម្រះមានការជឿជាក់ថា សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់អំពីយុត្តាធិការលើរឿងក្ដីរបស់ អ.វ.ត.ក នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នដែលស្ថិតនៅក្នុងអត្ថន័យនៃវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងក៏ដោយ អង្គបុរេជំនុំជម្រះរំឭកថា តាមសំណើផ្ទាល់ខ្លួន អង្គបុរេជំនុំជម្រះអាច "ទទួលស្គាល់ថាមានសុពលភាពចំពោះកិច្ចទាំងឡាយណាដែលបានធ្វើក្រោយពីពេលកំណត់ ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះត្រូវបានផុតរលត់ ប្រសិនបើខ្លួនយល់ឃើញថាត្រឹមត្រូវសមហេតុផល"[១៦៧]។ នៅពេលនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ចំពោះសំអាងហេតុនានាដូចខាងក្រោម វាជាផលប្រយោជន៍យុត្តិធម៌ក្នុងការអនុញ្ញាតឱ្យមានការជំទាស់ផ្នែកយុត្តាធិការរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ទៅនឹងដីកាដែលរងការជំទាស់ ទោះបីជាម្ចាស់បណ្ដឹងឧទ្ធរណ៍អាចតវ៉ាថា ខ្លួនត្រូវធ្វើបណ្ដឹងឧទ្ធរណ៍លើដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នដោយផ្អែកលើមូលដ្ឋាន "នៅក្នុងរយៈពេល ១០(ដប់) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្ដីជូនដំណឹងអំពីសេចក្ដីសម្រេច ឬដីកា" ទាំង

[១៦៤] វិធាន ៦៧(១)-(៣) នៃវិធានផ្ទៃក្នុង។

[១៦៥] វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង។

[១៦៦] កំណត់ហេតុនៃការសួរចម្លើយ, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩, ឯកសារ D286។

[១៦៧] វិធាន ៣៩(៤)(ខ) នៃវិធានផ្ទៃក្នុង។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C C.E.T.C

អស់នេះ[១៦៨]។

៨១. ជាដំបូង ដូចដែលបានកត់សម្គាល់កាលពីមុន វាអាចនឹងគ្មានភាពច្បាស់លាស់ចំពោះម្ចាស់បណ្តឹងឧទ្ធរណ៍ដែលថា ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នបានបញ្ជាក់អំពីយុត្តាធិការស្របតាមលក្ខខណ្ឌនៃវិធាន ៦៣ និង ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។ បន្ថែមពីលើនេះ វាក៏គ្មានភាពច្បាស់លាស់ផងដែរតាមរយៈវិធានផ្ទៃក្នុងផ្ទាល់ ឬនៅក្នុងច្បាប់ជាធរមានផ្សេងទៀត នៅអង្គជំនុំជម្រះវិសាមញ្ញ ដែលសរសេរឃ្លា "បញ្ជាក់អំពីយុត្តាធិការ" នៅក្នុងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ច្រានចោលការប្តឹងឧទ្ធរណ៍លើដីកា ឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត "ដោយបញ្ជាក់ឡើងវិញ" អំពីយុត្តាធិការរបស់ អ.វ.ត.ក ដូចដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា។

៨២. លើសពីនេះទៀត ដូចដែលបានកត់សម្គាល់ដោយសហព្រះរាជអាជ្ញា ការជំទាស់ទៅនឹងយុត្តាធិការគឺជាសិទ្ធិជាមូលដ្ឋាន[១៦៩]។ ដោយខុសពីបណ្តឹងឧទ្ធរណ៍នានា ដែលលើកឡើងពីការបំពារបំពានលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ បញ្ហានេះត្រូវបានបង្ហាញនៅក្នុងអង្គហេតុដែលថា បណ្តឹងឧទ្ធរណ៍ផ្នែកយុត្តាធិការត្រូវបានជ្រើសរើសយ៉ាងច្បាស់លាស់ថាជាបណ្តឹងឧទ្ធរណ៍មួយនៃមូលដ្ឋានមានកំណត់នៃបណ្តឹងឧទ្ធរណ៍ ដែលម្ចាស់បណ្តឹងឧទ្ធរណ៍អាចធ្វើបាននៅក្នុងកិច្ចដំណើរ-ការនីតិវិធី នៅដំណាក់កាលបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។ អង្គ-បុរេជំនុំជម្រះឯកភាពថា ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុងចែងថា កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ត្រូវធ្វើឡើងឱ្យបានឆាប់រហ័ស និងថា បញ្ហាសំខាន់ដូចជាបញ្ហាយុត្តាធិការនេះត្រូវតែដោះស្រាយឱ្យបានកាន់តែឆាប់ តាមដែលអាចធ្វើបាននៅក្នុងកិច្ចដំណើរការនីតិវិធី។ ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះមិនយល់ឃើញថា ការពិចារណាលើការជំទាស់ផ្នែកយុត្តាធិការរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍នៅពេលបិទកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត និងមុនពេលចាប់ផ្តើមការជំនុំជម្រះ ប៉ះពាល់ដល់ភាពឆាប់រហ័សនោះទេ។ ផ្ទុយទៅវិញ ការពិចារណានៅពេលនេះគាំទ្រដល់ការប្រព្រឹត្តទៅយ៉ាងឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី តាមរយៈការការពារប្រឆាំងនឹងលទ្ធផលដែលក្នុងនោះ "បញ្ហាសំខាន់នេះ ដែលជា [...] យុត្តាធិការ [...] [ត្រូវបាន] រក្សាទុកដើម្បីធ្វើការសម្រេច នៅពេលចប់ការជំនុំជម្រះក្តីដែលអាចមានរយៈពេលវែង ដែលគួរឱ្យរំភើប និងដែល

---

[១៦៨] វិធាន ៧៥(១) នៃវិធានផ្ទៃក្នុង។

[១៦៩] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៣៧។

00686502

ចំណាយថវិកាច្រើន" [១៧០]។

៨៣. សរុបមក ដោយគិតដល់កង្វះនៃបទប្បញ្ញត្តិនៅក្នុងវិធានផ្ទៃក្នុងស្តីពីផលប៉ះពាល់នៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឬពាក់ព័ន្ធនឹងការបញ្ជាក់ឡើងវិញ លក្ខណៈនៃការជំទាស់ផ្នែកយុត្តាធិការ និងដំណាក់កាលដំបូងនៃកិច្ចដំណើរការនីតិវិធី អង្គបុរេជំនុំជម្រះពិចារណាឃើញថា វាជាផលប្រយោជន៍នៃភាពយុត្តិធម៌ក្នុងការពិចារណាអំពីមូលដ្ឋាននានា នៃបណ្តឹងឧទ្ធរណ៍របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលបានលើកឡើងអំពីការជំទាស់ផ្នែកយុត្តាធិការ ប្រឆាំងនឹងដីកាដែលរងការជំទាស់នៅពេលនេះ។ ការខកខានធ្វើដូច្នេះដោយផ្អែកលើទស្សនៈដែលថា ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានរារាំងដោយពេលវេលាមិនឱ្យលើកឡើងនូវបណ្តឹងឧទ្ធរណ៍ដែលត្រូវបានអនុញ្ញាត យោងតាមការអានពាក្យពេចន៍នៃវិធានផ្ទៃក្នុងទាំងស្រុង តាមរយៈការពឹងផ្អែកជំនួសលើការបកស្រាយវិធានផ្ទៃក្នុងមិនទាន់ច្បាស់លាស់ដែលមានការប្រានចោលបណ្តឹងឧទ្ធរណ៍ប្រភេទនេះ ដោយគ្រាន់តែហេតុផលផ្នែកនីតិវិធី អាចធ្វើឱ្យមានភាពអយុត្តិធម៌យ៉ាងសំខាន់ចំពោះម្ចាស់បណ្តឹងឧទ្ធរណ៍។

ឃ. <u>ការសន្និដ្ឋាន</u>

៨៤. ផ្អែកតាមមូលដ្ឋានដែលបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទីមួយដល់ទីប្រាំ នៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា និងមូលដ្ឋានទីមួយ ដល់ទីប្រាំ និងទីប្រាំពីរ (លើកលែងកថាខណ្ឌ ៩៣) នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ អាចទទួលយកបាន។

IV. អង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍

៨៥. ពេលនេះ អង្គបុរេជំនុំជម្រះងាកទៅពិចារណាលើអង្គសេចក្តីនៃមូលដ្ឋាននានាដែលនៅសេសសល់នៅក្នុងបណ្តឹងឧទ្ធរណ៍នានា ដែលលើកឡើងពីបញ្ហាយុត្តាធិការចំនួនបួនដូចខាងក្រោម។ បញ្ហាទូទៅទីមួយ ថាតើការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតថា បទឧក្រិដ្ឋអន្តរជាតិនានា និងទម្រង់

---

[១៧០] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tadić*, IT-94-AR72, "សាលដីកាលើសំណើបន្ទាន់របស់មេធាវីការពារក្តីស្តីអំពីបញ្ហាយុត្តាធិការ", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៥, កថាខណ្ឌ ៦។

E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

នៃការទទួលខុសត្រូវដែលមិនត្រូវបានរកឃើញនៅក្នុងច្បាប់ជាតិកម្ពុជា ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ហើយបែរជាស្ថិតនៅក្នុងវិសាលភាពនៃយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក នោះ ជាការភ័ន្តច្រឡំ និងរំលោភលើគោលការណ៍នីត្យានុកូលភាពដែរឬទេ[១៧១]។ ទីពីរ បញ្ហាថាតើការយល់ឃើញជាក់-លាក់របស់សហចៅក្រមស៊ើបអង្កេត នៅពេលបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក លើអំពើប្រល័យពូជសាសន៍ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ជាការភ័ន្តច្រឡំ និងរំលោភលើគោលការណ៍នីត្យានុកូលភាពដែរឬទេ[១៧២]។ ទីបី បញ្ហាថា តើ ក.ស.ច.ស មានការភ័ន្ត-ច្រឡំនៅពេលបញ្ជាក់ពីយុត្តាធិការលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរឬទេ[១៧៣]។ ទីបួន បញ្ហាថាតើការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតថា អ.វ.ត.ក មានយុត្តាធិការលើរឿងក្តីនៃបទ-ឧក្រិដ្ឋជាតិដែលស្ថិតក្រោមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៥៦) ("ក្រមព្រហ្ម-ទណ្ឌ ឆ្នាំ១៩៥៦")[១៧៤] ជាការភ័ន្តច្រឡំ និងរំលោភលើគោលការណ៍នីត្យានុកូលភាពដែរឬទេ[១៧៥]។ ជាចុងក្រោយ បញ្ហាថាតើសហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ នៅក្នុងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ ថ្នាក់លើដែលជាទម្រង់នៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលនាំឱ្យរំលោភលើគោលការណ៍នីត្យានុកូលភាព ដែរឬទេ[១៧៦]។

ក. បទដ្ឋាននៃការពិនិត្យមើលឡើងវិញ

៨៦. អង្គបុរេជំនុំជម្រះរំឭកថា អង្គបុរេជំនុំជម្រះបានលើកឡើងកាលពីលើកមុនថា នៅពេលដែលដីកាដែលចេញដោយសហចៅក្រមស៊ើបអង្កេត ដូចជាដីកាដែលរងការជំទាស់ "ដោះស្រាយបញ្ហាយុត្តា-ធិការ ដីកានោះមិនពាក់ព័ន្ធនឹងឆន្ទានុសិទ្ធិរបស់ ក.ស.ច.ស នោះទេ"[១៧៧]។ ដូចនេះ អង្គបុរេជំនុំជម្រះមិនអនុវត្តបទដ្ឋាននៃការពិនិត្យមើលឡើងវិញផ្សេងពីគ្នា ដែលអាចអនុវត្តចំពោះសេចក្តីសម្រេចតាម

---

[១៧១] បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កថាខណ្ឌ ២៣-២៨។ បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៦-៧២។

[១៧២] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៣៥-៣៧, ៦៦។

[១៧៣] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៣៨-៦៣។

[១៧៤] ប្រកាសឱ្យប្រើនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៥៥ ដោយព្រះមហាក្សត្រ (ក្រមលេខ. ៩៣៣នស), ព្រះរាជាណាចក្រកម្ពុជា, *Recueil Judiciaire,* ប្រែសម្រួលពិសេស, ឆ្នាំ១៩៥៦, ទំព័រ ១១-៤០៣ (អង់គ្លេស)។

[១៧៥] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៧៣-៧៧។

[១៧៦] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៨១-៩៤។

[១៧៧] សាលដីកាលើ JCE, កថាខណ្ឌ ៣៦។

ឆន្ទានុសិទ្ធិដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតនោះទេ[១៧៨]។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះនឹងបដិសេធសេចក្តីសម្រេច ឬដីកាដែលបញ្ជាក់យុត្តាធិការនៅពេលដែល "ក.ស.ច.ស បានប្រព្រឹត្តនូវការភ័ន្តច្រឡំអង្គច្បាប់ ឬអង្គហេតុជាក់លាក់ ដែលធ្វើមោឃភាពសេចក្តីសម្រេច ឬបានថ្លឹងថ្លែងការពិចារណានានាដែលពាក់ព័ន្ធ ឬការពិចារណានានាដែលមិនពាក់ព័ន្ធនៅក្នុងលក្ខណៈមិនសមស្រប"[១៧៩]។ មានការបង្ហាញយ៉ាងច្បាស់លាស់នៅក្នុងច្បាប់យុត្តិសាស្ត្រអន្តរជាតិថា នៅពេលមានបណ្តឹងឧទ្ធរណ៍ ការភ័ន្តច្រឡំអង្គច្បាប់ដែលបានលើកឡើង ត្រូវតែពិនិត្យមើល *ជាថ្មី* ដើម្បីសម្រេចថា តើការលើកឡើងតាមផ្លូវច្បាប់មានលក្ខណៈត្រឹមត្រូវដែរឬទេ ចំណែកឯការភ័ន្តច្រឡំអង្គហេតុដែលបានលើកឡើង ត្រូវបានពិនិត្យមើលក្រោមបទដ្ឋាននៃភាពសមស្រប ដើម្បីសម្រេចថា តើពិតជាមាន ឬគ្មានអ្នកកាត់សេចក្តីដែលសមហេតុផល បានឈានដល់ការយល់ឃើញទៅលើអង្គហេតុដែលកំពុងមានបញ្ហានេះដែរឬទេ។[១៨០]

---

[១៧៨] សេចក្តីសម្រេចតាមឆន្ទានុសិទ្ធិគឺជាសេចក្តីសម្រេចទាំងឡាយណាដែលធ្វើឡើងផ្អែកតាមបទពិសោធន៍បំពេញការងាររបស់ ក.ស.ច.ស ក្នុងរឿងក្តី និងការប្រព្រឹត្តជាប្រចាំថ្ងៃ ព្រមទាំងតម្រូវការនៃការអនុវត្តកិច្ចស៊ើបសួរ។ ឧទាហរណ៍នានាអាចបូកបញ្ចូលនូវសេចក្តីសម្រេចនានាស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ឬដោះលែង ការវាយតម្លៃលើភស្តុតាង ឬការសម្រេចលើចំណុចផ្សេងៗនៃការអនុវត្ត និងនីតិវិធីនៅក្នុងដំណើរការស៊ើបសួរ។ *ប្រៀបធៀប រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tolimir និងអ្នកផ្សេងទៀត,* IT-04-80-AR73.1, "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំរបស់ Radivoje Miletić ប្រឆាំងនឹងសេចក្តីសម្រេចលើការរួមគ្នារបស់ជនជាប់ចោទ", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០០៦, កថាខណ្ឌ៤ (ទាញហេតុសំអាង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milošević,* IT-99-37-AR73, IT-01-50-AR73 និង IT-01-51-AR73, "សំអាងហេតុសម្រាប់សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំរបស់រដ្ឋអាជ្ញា ដែលកើតចេញពីការបដិសេធទៅនឹងការបញ្ចូលជាដីកាតែមួយ [Order Joinder]", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២, កថាខណ្ឌ៣; *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milošević,* IT-02-54-AR73.7, "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំនៃសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៤, កថាខណ្ឌ ៩)។

[១៧៩] *រឿងក្តី Karadžić សេចក្តីសម្រេចលើយុត្តាធិការ,* កថាខណ្ឌ ១០ (ទាញហេតុសំអាង រឿងក្តី *Gotovina និងអ្នកផ្សេង ទៀត,* សេចក្តីសម្រេចលើយុត្តាធិការ, កថាខណ្ឌ៧, ទាញហេតុសំអាង រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Prlić និងអ្នកផ្សេងទៀត,* IT-04-74-AR72.1, "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំរបស់ Petković ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ សាលាដំបូងលើយុត្តាធិការ", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥, កថាខណ្ឌ១១ (និង រឿងក្តីទាញ ហេតុសំអាងក្នុងនោះ)។

[១៨០] *រឿងដក្តីរដ្ឋអាជ្ញា តទល់នឹង. Hardinaj និងអ្នកផ្សេងទៀត,* IT-04-84-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ១១, ១២។

ខ. បញ្ហាតើវាជាការភ័ន្តច្រឡំ និងការរំលោភបំពានលើគោលការណ៍នីត្យានុកូលភាពដែរឬទេ នៅពេលយកបទល្មើសអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវ ដែលពុំមានចែងនៅក្នុងច្បាប់កម្ពុជា ពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ មកដាក់បញ្ចូលនៅក្នុងវិសាលភាពនៃយុត្តាធិការរបស់ អ.វ.ត.ក (មូលដ្ឋានទី ១ ដល់ មូលដ្ឋានទី ៥ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង មូលដ្ឋានទី ១ ដល់ មូលដ្ឋានទី ៣ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ)

១. សារណាទាំងឡាយ

៨៧. ដើមបណ្តឹងឧទ្ធរណ៍លើកឡើងនូវកាកាំង ចំណុចមួយចំនួននៅក្នុងបណ្តឹងឧទ្ធរណ៍ទាំងនេះ មកធ្វើជាចំណុចរួមមួយ ដើម្បីតវ៉ាចំពោះការបញ្ជាក់យុត្តាធិការលើរឿងក្តីរបស់សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធនឹងបទល្មើសអន្តរជាតិ ដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ អនុលោមតាមមាត្រា ៤ ដល់ មាត្រា ៦ នៃច្បាប់ អ.វ.ត.ក និងទម្រង់នៃការទទួលខុសត្រូវ អនុលោមតាមមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក ដែលមិនឃើញមានចែងនៅក្នុងច្បាប់ជាតិកម្ពុជាចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា អ.វ.ត.ក មិនមានយុត្តាធិការក្នុងការចោទប្រកាន់បទល្មើសអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវទាំងនេះឡើយ ដោយហេតុថា ប្រសិនបើចោទប្រកាន់ដូច្នេះ អ.វ.ត.ក ខកខានមិនបានគោរពលើគោលការណ៍នៃនីត្យានុកូលភាពជាមូលដ្ឋាន។

៨៨. ចំណុចទីមួយ ដើមបណ្តឹងឧទ្ធរណ៍អះអាងផ្ទុយពីជំហររបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដែលរងការជំទាស់ថា[១៨១] លក្ខណៈនៃ អ.វ.ត.ក ជាសាលាក្តីកម្ពុជា ឬ អន្តរជាតិ គឺកត្តាកំណត់យ៉ាងច្បាស់លាស់លើយុត្តាធិការលើរឿងក្តីរបស់តុលាការ[១៨២]។ មូលដ្ឋានទី ១ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ចោទប្រកាន់ថា កត្តាមួយចំនួនបញ្ជាក់ច្បាស់ថា អ.វ.ត.ក មិនមែនជាសាលាក្តី

[១៨១] ដីកាដែលរងការជំទាស់ កថាខណ្ឌ ១៣០១ ("បញ្ហាដែលថាតើ អ.វ.ត.ក ជាស្ថាប័នយុត្តាធិការជាតិ ឬ អន្តរជាតិមិនបង្កើតផលវិបាកអ្វីចំពោះសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក ក្នុងការជំនុំជម្រះលើឧក្រិដ្ឋកម្មទាំងនេះនោះទេ ដរាបណាគោលការណ៍ *មិនមានបទល្មើសប្រសិនបើគ្មានច្បាប់ចែង* ត្រូវបានគោរព")។

[១៨២] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ២៦។ បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ២៣ ៤៧-៤៨, ៧១។

អន្តរជាតិឡើយ ប៉ុន្តែវាជា "តុលាការកម្ពុជាសុទ្ធសាធ"[១៨៣]។ ហេតុដូច្នេះ អ.វ.ត.ក "ត្រូវអនុវត្តច្បាប់ជាតិ ដែលនៅជាធរមាននៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ នេះរួមបញ្ចូលទាំងវិធីសាស្ត្រជាតិកម្ពុជាចំពោះគោលការណ៍ *មិនមានបទល្មើសប្រសិនបើគ្មានច្បាប់ចែង*"[១៨៤]។ ដូចគ្នានេះដែរ មូលដ្ឋានទី ៣ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ អះអាងថា អ.វ.ត.ក "មិនមែនជាតុលាការ "អន្តរជាតិ" ឡើយ ប៉ុន្តែជាតុលាការចម្រុះមួយ ដែលជាផ្នែកមួយនៃប្រព័ន្ធតុលាការក្នុងស្រុក"[១៨៥]។ ដូច្នេះ "ច្បាប់អន្តរជាតិ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ផ្តល់មូលដ្ឋានមិនគ្រប់គ្រាន់ដើម្បីកាត់សេចក្តីដើមបណ្តឹងឧទ្ធរណ៍នៅចំពោះមុខតុលាការនេះឡើយ។ អ.វ.ត.ក អាចកាត់សេចក្តីតែបទល្មើសអន្តរជាតិ ប្រសិនបើបទល្មើសនោះ ត្រូវបានកំណត់ត្រឹមត្រូវថាជាបទល្មើសព្រហ្មទណ្ឌ ផ្អែកតាមច្បាប់ជាតិនៃប្រទេសកម្ពុជា មុនពេល ឬ នៅពេលប្រព្រឹត្តិបទល្មើសនោះ"[១៨៦]។

៨៩. ចំណុចទី២ ដើមបណ្តឹងឧទ្ធរណ៍ចោទប្រកាន់ថា ដោយពិចារណាលើឋានៈរបស់ អ.វ.ត.ក ជាសាលាក្តីមួយនៅក្នុងប្រព័ន្ធតុលាការកម្ពុជា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ នៅពេលខ្លួនរកឃើញថា "បញ្ហាដែលចោទឡើងថាតើច្បាប់អន្តរជាតិអាច ឬ មិនអាចអនុវត្តដោយផ្ទាល់នៅក្នុងប្រទេសកម្ពុជា នឹងមិនបង្កើតជាផលវិបាកអ្វីចំពោះសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក នោះឡើយ"[១៨៧] ចំពោះបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងមាត្រា ៤ ដល់ មាត្រា ៦ នៃច្បាប់ អ.វ.ត.ក។ មូលដ្ឋានទី២ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ នួន ជា និងមូលដ្ឋានទី១ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កត់សម្គាល់ឃើញថា ច្បាប់ក្នុងប្រទេសកម្ពុជាចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដោយក្នុងនោះរួមទាំងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ មិនបានបញ្ញត្តិ ឬ ដាក់ទោស

---

[១៨៣] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ២៤, ២៦ (ដែលបានចង្អុលបញ្ជាក់ *ក្នុងចំណោមរឿងនោះគឺ* ការបង្កើត អ.វ.ត.ក តាមច្បាប់ជាតិ។ ការដាក់ អ.វ.ត.ក នៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជា ដែលមានស្រាប់។ ការតែងតាំងមន្ត្រីតុលាការ ដោយរាជរដ្ឋាភិបាលកម្ពុជា និងការផ្តល់អាទិភាពលើបញ្ហានីតិវិធីតាមច្បាប់កម្ពុជា)។

[១៨៤] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ២៦។

[១៨៥] បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ២៦ (កត់សម្គាល់ថា ទោះបីជា អ.វ.ត.ក ត្រូវបានបង្កើតឡើងតាមកិច្ចព្រមព្រៀងទ្វេភាគី ហើយ "មានសមត្ថកិច្ចអនុវត្តយុត្តាធិការលើបទល្មើសជាតិ និងបទល្មើសអន្តរជាតិ" ក៏ដោយ ក៏ អ.វ.ត.ក "គឺជាតុលាការនៅក្នុងប្រព័ន្ធតុលាការកម្ពុជា" និងត្រូវបានគ្រប់គ្រងដោយច្បាប់កម្ពុជា។

[១៨៦] បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ២៧។

[១៨៧] ដីកាដែលរងការជំទាស់ កថាខណ្ឌ ១៣០៥។

បទល្មើសទាំងនេះជាបទល្មើសព្រហ្មទណ្ឌឡើយ[១៨៨]។ អាស្រ័យហេតុនេះ "មូលដ្ឋានមួយទៀតតែមួយគត់នោះគឺការអនុវត្តច្បាប់អន្តរជាតិ" ដែលមូលដ្ឋានបែបនេះមិនមានឡើយ ដោយសារតែប្រព័ន្ធទ្វិកនិយមរបស់ប្រទេសកម្ពុជា និងដោយហេតុថា នៅក្នុងប្រទេសកម្ពុជាមិនមានច្បាប់ទំនៀមទម្លាប់ ឬ បទដ្ឋានច្បាប់សន្ធិសញ្ញាណាមួយ នៅជាធរមាន ចំពោះបទល្មើសអន្តរជាតិទាំងនេះ នៅពេលទង្វើដែលត្រូវបានគេចោទប្រកាន់ថាខុសច្បាប់នេះ បានប្រព្រឹត្តឡើង[១៨៩]។

៩០. អ្វីដែលជាក់លាក់ជាងនេះគឺ មូលដ្ឋានទី ៣ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ផ្តល់ទឡ្ហីករណ៍ថា "ទោះបីជាកម្ពុជាបានក្លាយជាសមាជិកនៃអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងឆ្នាំ ១៩៥០ ក៏ដោយ ក៏ប្រទេសកម្ពុជាមិនទាន់បានអនុម័តច្បាប់លើបទល្មើសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះនៅឡើយទេ" អនុលោមតាមមាត្រា៥ នៃអនុសញ្ញា "ហើយក៏គ្មានការកំណត់បែបនោះទេ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនអាចយកមកប្រើដើម្បីកាត់សេចក្តីនៅក្នុងប្រព័ន្ធច្បាប់ជាតិទេ"[១៩០]។ លើសពីនេះ បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ អះអាងថា អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍មិនអាចយកមកអនុវត្តដោយផ្ទាល់ជាច្បាប់ជាតិបានឡើយ ដោយហេតុថា អនុលោមតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញា រួមទាំងមាត្រា ៥ នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មិនអាចត្រូវបានគេចោទទុកថាមានអានុភាពយកមកអនុវត្តដោយផ្ទាល់បានទេ[១៩១]។ ដូចគ្នានេះដែរ បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ចោទប្រកាន់ថា ទោះបីជាសហចៅក្រមស៊ើបអង្កេតបានរកឃើញថា មានការហាមឃាត់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ ដែលចងកាតព្វកិច្ចលើរដ្ឋក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតខកខានមិនបានបង្ហាញថា បទដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិនេះ បញ្ញត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជា*បទល្មើសព្រហ្មទណ្ឌ* ដែលចាំបាច់ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល[១៩២]។ លើសពីនេះ បទដ្ឋាននេះមិនត្រូវបានអនុម័តនៅក្នុងច្បាប់កម្ពុជាជាធរមាន នៅពេលដែលអំពើល្មើសព្រហ្មទណ្ឌដូចបានចោទប្រកាន់បានកើតឡើង ដែលបទដ្ឋាននេះតម្រូវឲ្យរដ្ឋ "ចោទប្រកាន់ជនណាម្នាក់ដែលត្រូវបាន

[១៨៨] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ២៨។ បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ១៥-១៧, ៤១-៤៣, ៦៧-៦៨។

[១៨៩] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ២៧, ២៨។

[១៩០] បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ២៨, ៣០។

[១៩១] បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ៣២។

[១៩២] បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ៤៩-៥៣។

ចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើស អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ”[១៥៣]។ ចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កត់សម្គាល់ថា នៅពេលបទល្មើសដែលបានចោទប្រកាន់កើតឡើង ប្រទេសកម្ពុជាមិនមានច្បាប់ជាធរមានណាមួយ បញ្ញត្តិការបំពារបំពានយ៉ាងធ្ងន់ធ្ងរនេះជាបទល្មើសព្រហ្មទណ្ឌ ដូចបានកំណត់នៅក្នុងអនុសញ្ញានោះឡើយ[១៥៤]។ ដូច្នេះ អ.វ.ត.ក មិនមានយុត្តាធិការលើប្រភេទនៃបទល្មើសមួយនេះទេ។

៩១. ចំណុចទី៣ ដើមបណ្តឹងឧទ្ធរណ៍សន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន ដោយលើកឡើងថា “ច្បាប់ អ.វ.ត.ក បានកំណត់ថា បទល្មើសទាំងឡាយដែលបានទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិ” មានចែងក្នុងច្បាប់ជាតិជាធរមាន”[១៥៥]។ មូលដ្ឋានទី៣ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អះអាងថា ច្បាប់ អ.វ.ត.ក ត្រូវបានព្រាងឡើងដោយកំណត់យុត្តាធិការអនុវត្ត និងត្រឹមតែកំណត់យុត្តាធិការបុគ្គលចំពោះបទល្មើសទាំងឡាយ ដូចបានរៀបរាប់នៅក្នុងមាត្រា ៣(ថ្មី) ដល់មាត្រា ៦ តែប៉ុណ្ណោះ[១៥៦]។ មូលដ្ឋានទី២ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ផ្តល់ទឡ្ហីករណ៍ថា ច្បាប់ អ.វ.ត.ក “គ្រាន់តែចែងអំពីនិយមន័យរបស់បទឧក្រិដ្ឋទាំងឡាយដែល អ.វ.ត.ក មានយុត្តាធិការ”[១៥៧] តែប៉ុណ្ណោះ។

៩២. លើសពីនេះ មូលដ្ឋានទី៤ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ នួន ជា លើកឡើងថា គោលការណ៍នីត្យានុកូលភាពអន្តរជាតិ អនុលោមតាម “មាត្រា ៣៣(២) នៃច្បាប់ អ.វ.ត.ក ដែលចែងយោងលើមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិ មិនបានធ្វើឱ្យបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬ បទឧក្រិដ្ឋកម្មសង្គ្រាម ក្លាយជាបទល្មើសព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជាឡើយ”[១៥៨] ប៉ុន្តែ វាគ្រាន់តែអនុញ្ញាតឱ្យមានការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ អនុលោមតាម*ច្បាប់អន្តរជាតិតែប៉ុណ្ណោះ*។

---

[១៥៣] បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ៥៤, ៥៦។

[១៥៤] បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ៦៩, ៧១-៧២។

[១៥៥] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ៣០។

[១៥៦] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ៣១។

[១៥៧] បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ២០។

[១៥៨] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ៣៣។

"ដូចតាមរយៈភស្តុតាងនៃការអនុវត្តរបស់រដ្ឋដែរ [...] គោលការណ៍ *មិនមានបទល្មើស* អន្តរជាតិស្ថិតនៅក្រោមចំណុះអធិបតេយ្យជាតិ (រួមទាំងគោលការណ៍នីត្យានុកូលភាពរបស់ប្រទេសកម្ពុជាខ្លួនឯងផងដែរ)។ ការលើកគោលការណ៍នេះឡើង [...] តាមនិយាម មិនមានអានុភាពលើច្បាប់ជាតិឡើយ ប្រសិនបើច្បាប់ជាតិមិនបានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌ"[១៩៩] នោះទេ។

៩៣. ហេតុដូច្នេះ យោងតាមច្បាប់ អ.វ.ត.ក "មាត្រាទាំងនេះមិនបានផ្តល់អានុភាពជាបទល្មើសព្រហ្មទណ្ឌអនុលោមតាមច្បាប់សារធាតុ ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ឡើយ"[២០០]។ ម្យ៉ាងវិញទៀត ការសន្និដ្ឋានបទល្មើសព្រហ្មទណ្ឌចេញពីបទប្បញ្ញត្តិទាំងនេះនឹងមិនមានភាពសមហេតុផល ដោយសារតែការអនុវត្តបទល្មើសទាំងនេះ តាមអានុភាពប្រតិសកម្មចំពោះអំពើដែលបានប្រព្រឹត្តឡើងនៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នឹងរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព[២០១]។

៩៤. ចំណុចចុងក្រោយ មូលដ្ឋានទី៥ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អះអាងថា "ក្នុងគោលបំណងបង្ហាញទឡ្ហីករណ៍ យើងសន្មតថា អង្គជំនុំជម្រះនេះជឿថា ច្បាប់ អ.វ.ត.ក *បាន*កំណត់បទល្មើសទាំងឡាយដូចមានចែងចាប់ពីមាត្រា ៤ ដល់ មាត្រា ៦ ថាជាបទល្មើសព្រហ្មទណ្ឌ ច្បាប់ធ្វើឡើងតាមអានុភាពប្រតិសកម្មបែបនេះ រំលោភលើគោលការណ៍នីត្យានុកូលភាព*របស់ប្រទេសកម្ពុជា*"[២០២]។ ករណីនេះដោយសារតែ "វាពិបាកយល់ថាតើបុគ្គលមួយរូបដែលដំណើរការងារនៅក្នុងប្រព័ន្ធទ្វិកនិយមនៅក្នុងប្រទេសដែលទទួលការការពារតាមគោលការណ៍ *មិនមានបទល្មើស* យ៉ាងរឹងមាំ អាច (ឬ គួរ) យល់ឃើញថាជាបទល្មើសព្រហ្មទណ្ឌនៅក្នុងតុលាការកម្ពុជា អនុលោមតាមច្បាប់អន្តរជាតិ" នៅក្នុងពេលនោះ ដូចដែលបានអនុញ្ញាតតាមគោលការណ៍នីត្យានុកូលភាពអន្តរជាតិ នៅក្នុងមាត្រា ៣៣ នៃច្បាប់ អ.វ.ត.ក[២០៣]។ ដោយសារហេតុនេះ បណ្តឹងឧទ្ធរណ៍របស់ នួន ជា ផ្តល់ទឡ្ហីករណ៍ថា ភាពតានតឹងដែលបានបង្កើតឡើងដោយភាពខុសគ្នារវាងវិធីសាស្ត្រជាតិ និងអន្តរជាតិ

---

[១៩៩] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ៣៣ (គូសបញ្ជាក់បន្ថែម)។

[២០០] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ៣១។

[២០១] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ៣២។ បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ២១។

[២០២] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ៣៥ (គូសបញ្ជាក់បន្ថែម)។

[២០៣] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ៣៦ (គូសបញ្ជាក់បន្ថែម)។

ចំពោះគោលការណ៍ *មិនមានបទល្មើស* នោះ ត្រូវតែលុបចោល អនុលោមតាមគោលការណ៍*វិមតិសង្ស័យ* ត្រូវបានប្រយោជន៍ដល់ជនជាប់ចោទ"[២០៤]។

២. ការពិភាក្សា

៩៥. អង្គបុរេជំនុំជម្រះរំឭកឡើងថា ច្បាប់ អ.វ.ត.ក ផ្តល់យុត្តាធិការយ៉ាងជាក់លាក់ដល់ អ.វ.ត.ក ក្នុងការចោទប្រកាន់ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើ "ច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់"[២០៥]។ ដោយហេតុថា បណ្តឹងឧទ្ធរណ៍នីមួយៗអះអាងថា ការធ្វើដូច្នេះនឹងនាំឱ្យមានការរំលោភលើគោលការណ៍នីត្យានុកូលភាព អង្គបុរេជំនុំជម្រះរំឭកថា គោលការណ៍នេះមានចែងនៅក្នុងមាត្រា ៣៣(២)(ថ្មី) នៃច្បាប់ អ.វ.ត.ក ដោយបញ្ញត្តិថា អ.វ.ត.ក ត្រូវអនុវត្ត "យុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនៃដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងនៅក្នុងមាត្រា [...] ១៥" នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[២០៦]។ មាត្រា១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងនៅក្នុងផ្នែកដែលពាក់ព័ន្ធថា "គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ"[២០៧]។ លើសពីនេះ អនុលោមតាមមាត្រា ១៥(២) "គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះ ប្រឆាំងនឹងការជំនុំជម្រះក្តី ឬ ការផ្តន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើ ឬការខកខានណាមួយ ដែលជននោះបានប្រព្រឹត្ត ក្នុងខណៈពេលដែលអំពើ ឬការខកខាននោះ ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ"[២០៨]។

---

[២០៤] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ៣៧។

[២០៥] ច្បាប់ អ.វ.ត.ក មាត្រា ១ សូមមើលផងដែរនូវ មាត្រា ៤ ដែលយោងជាក់លាក់លើអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ និងមាត្រា ៦ ដែលយោងលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩។

[២០៦] មាត្រា ៣៣(២)(ថ្មី) នៃច្បាប់ អ.វ.ត.ក។

[២០៧] មាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[២០៨] មាត្រា ១៥(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

៩៦. អ.វ.ត.ក បានបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងរួមមួយរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ហើយប្រទេសកម្ពុជាបានទទួលស្គាល់កិច្ចព្រមព្រៀង អ.វ.ត.ក នេះ ជាច្បាប់នៅក្នុងប្រទេស[២០៩]។ ច្បាប់ អ.វ.ត.ក ផ្តល់យុត្តាធិការយ៉ាងជាក់លាក់ឲ្យអង្គជំនុំជម្រះ យកសន្ធិសញ្ញានានាដែលប្រទេសកម្ពុជាបានទទួលស្គាល់ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ មកអនុវត្ត ដរាបណាខ្លួនបានគោរពគោលការណ៍នីត្យានុកូលភាព[២១០]។ ដោយហេតុថា ច្បាប់ អ.វ.ត.ក ចែងយោងយ៉ាងច្បាស់លាស់លើមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ វាគ្មានការសង្ស័យណាមួយឡើយថា គោលការណ៍នីត្យានុកូលភាព ដែលច្បាប់ អ.វ.ត.ក បានបញ្ញត្តិទុកចំពោះបទល្មើសអន្តរជាតិនោះ គឺជាគោលការណ៍នីត្យានុកូលភាពអន្តរជាតិ។ អង្គជំនុំជម្រះសាលាដំបូងក៏បានរកឃើញផងដែរថា គោលការណ៍នីត្យានុកូលភាពអន្តរជាតិ នឹងយកមកអនុវត្ត[២១១]។ ជាសំខាន់នោះ ដើមបណ្តឹងឧទ្ធរណ៍បានសូមឲ្យអង្គបុរេជំនុំជម្រះច្រានចោលបទប្បញ្ញត្តិនៃច្បាប់ អ.វ.ត.ក ដែលបានចែងយ៉ាងច្បាស់ត្រង់ចំណុចនេះ ហើយសូមឲ្យអង្គបុរេជំនុំជម្រះពិចារណាថា អង្គបុរេជំនុំ-ជម្រះមានកាតព្វកិច្ចត្រូវអនុវត្តគោលការណ៍នីត្យានុកូលភាព“ជាតិ” ចំពោះការចោទប្រកាន់លើបទល្មើសអន្តរជាតិ ក៏ដូចជាបទល្មើសជាតិ ដោយសារគោលការណ៍នីត្យានុកូលភាពជាតិមានលក្ខណៈតឹងរ៉ឹងជាងគោលការណ៍នីត្យានុកូលភាពអន្តរជាតិ[២១២]។ ដើមបណ្តឹងឧទ្ធរណ៍សន្និដ្ឋានថា អ.វ.ត.ក គឺជាតុលាការជាតិកម្ពុជា ហើយត្រូវអនុវត្តគោលការណ៍នីត្យានុកូលភាព ដូចមានចែងនៅក្នុងមាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលចែងនៅក្នុងផ្នែកដែលពាក់ព័ន្ធថា “ច្បាប់ព្រហ្មទណ្ឌគ្មានអានុភាពជាប្រតិសកម្មទេ។ គ្មានបទល្មើសណាមួយ ដែលនឹងត្រូវផ្តន្ទាទោសដោយការអនុវត្តបទប្បញ្ញត្តិ ដែលបទប្បញ្ញត្តិនោះមិនទាន់បានចូលជាធរមានតាមផ្លូវច្បាប់ នៅពេលបទល្មើសនោះត្រូវបានប្រព្រឹត្ត”។ ដោយសារតែប្រទេសកម្ពុជាអនុវត្តប្រព័ន្ធទ្វិកនិយម ដើមបណ្តឹងឧទ្ធរណ៍យល់ឃើញថា អ.វ.ត.ក មិនអាចអនុវត្តច្បាប់អន្តរជាតិដោយផ្ទាល់នោះទេ ពីព្រោះច្បាប់អន្តរជាតិមិនបានចែងបញ្ចូលនៅក្នុងច្បាប់ជាតិកម្ពុជា នៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។

---

[២០៩] មាត្រា ៤៧*ស្ទួន*(ថ្មី) នៃច្បាប់ អ.វ.ត.ក។

[២១០] មាត្រា ៣៣(២)(ថ្មី) នៃច្បាប់ អ.វ.ត.ក។

[២១១] សាលក្រម *ឌុច* កថាខណ្ឌ ២៦-៣៤។

[២១២] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ១៧-១៩។ បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ ផ្នែក ៣.៣.៣ ពាក់ព័ន្ធនឹងបទប្រល័យពូជសាសន៍ និងដាក់បញ្ចូលនូវការយោងលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (កថាខណ្ឌ ៤៨) និងការរំលោភបំពានធ្ងន់ធ្ងរ (កថាខណ្ឌ ៧១)។

៩៧. នៅក្នុងការទាមទារឱ្យ អ.វ.ត.ក អនុវត្តច្បាប់សន្ធិសញ្ញា និងច្បាប់ទំនៀមទម្លាប់ ដែលកំណត់បទល្មើសអន្តរជាតិចម្បងៗ ជាបទល្មើសព្រហ្មទណ្ឌ ដោយផ្ទាល់តែម្តង និងការទាមទារឱ្យ អ.វ.ត.ក អនុវត្តយុត្តាធិការរបស់ខ្លួនលើបទល្មើសទាំងនេះ ឱ្យស្របទៅតាមគោលការណ៍នីត្យានុកូលភាពអន្តរជាតិ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ប្រទេសកម្ពុជាបានអនុវត្តតាមវិធីសាស្ត្រ ដែលរដ្ឋមួយចំនួនបានយកមកអនុវត្តរួចមកហើយ ដែលវិធីសាស្ត្រនេះ យោងតាមបទប្បញ្ញត្តិនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប[២១៣] បានចែងបញ្ចូលអញ្ញត្រកម្មលើបទល្មើសអន្តរជាតិ ដោយអនុញ្ញាតឱ្យកំណត់ទៅតាមគោលការណ៍នីត្យានុ-កូលភាពនៅក្នុងច្បាប់ជាតិរបស់ខ្លួន[២១៤]។ ទោះបីជាករណីនេះ មិនផ្ទុះបញ្ចាំងអំពីការអនុវត្តរួមមួយ

---

[២១៣] មាត្រា ៧ នៃ*អនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន* អនុម័តនៅទីក្រុងរ៉ូម នាថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៥០ ដោយក្រុមប្រឹក្សាអឺរ៉ុប (“ECHR”) រួមមានបទប្បញ្ញត្តិមួយស្រដៀងនឹងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សនិងសិទ្ធិពលរដ្ឋ (“១. គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬ ការខកខានណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬ ច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោសឱ្យធ្ងន់ជាងទោស ដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ។ ២. គ្មានបទប្បញ្ញត្តិណាមួយក្នុងមាត្រានេះ ប្រឆាំងនឹងការជំនុំជម្រះក្តី ឬ ការផ្តន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើ ឬ ការខកខានណាមួយ ដែលជននោះបានប្រព្រឹត្ត ក្នុងខណៈពេលដែលអំពើ ឬ ការខកខាននោះ ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ”)។

[២១៤] សូមមើលឧទាហរណ៍ មាត្រា ៤២(១) នៃរដ្ឋធម្មនុញ្ញប្រទេសប៉ូឡូញឆ្នាំ ១៩៩៧។ យោងតាមមាត្រានេះ គោលការណ៍នីត្យានុកូលភាព “មិនរារាំងការដាក់ទោសចំពោះអំពើណាមួយ ដែលនៅពេលប្រព្រឹត្តនោះ វាជាបទល្មើស អនុលោមតាមអត្ថន័យនៃច្បាប់អន្តរជាតិ”។ បទប្បញ្ញត្តិស្រដៀងគ្នាឃើញមាននៅក្នុងមាត្រា ១១(ឆ) នៃធម្មនុញ្ញប្រទេសកាណាដាឆ្នាំ ១៩៨២ ស្តីពីសិទ្ធិ និងសេរីភាព ដែលមានឋានៈជារដ្ឋធម្មនុញ្ញ និងកំណត់ថា “ជនណាដែលត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយនោះ ត្រូវមានសិទ្ធិសន្មតជាមុនថាគ្មានទោសចំពោះអំពើ ឬ ការខកខានរបស់ខ្លួន លើកលែងតែនៅពេលប្រព្រឹត្ត ឬ ខកខាននោះ វាជាបទល្មើសអនុលោមតាមច្បាប់ប្រទេសកាណាដា ឬ ច្បាប់អន្តរជាតិ ឬ ជាបទល្មើសព្រហ្មទណ្ឌ យោងតាមគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ”។ យោងតាមរបាយការណ៍នៃគណៈកម្មការស៊ើបអង្កេតលើឧក្រិដ្ឋជនសង្គ្រាម (ការប្រព្រឹត្ត Deschenes) ការបកស្រាយលើគោលការណ៍នីត្យានុកូលភាព មានអានុភាពលើច្បាប់ទាំងឡាយដែលផ្ទុយពីគោលការណ៍នេះ។ សូមមើលផងដែរនូវក្រមព្រហ្មទណ្ឌប្រទេសបូស្នី និងហេហ្សេហ្គោវីណា (មាត្រា ៣ (២))។ ដូចគ្នានេះដែរ គណៈកម្មាធិការពិសេសសម្រាប់បទល្មើសធ្ងន់ធ្ងរនៅទីម័រខាងកើត បានបកស្រាយផ្នែកទី ៩.១ និង ៣១ នៃរដ្ឋធម្មនុញ្ញរបស់ប្រទេសទីម័រខាងកើតថា ការអនុញ្ញាតឱ្យកាត់ទោស ឬ ដាក់ទោសជនណាម្នាក់ ចំពោះការប្រព្រឹត្ត ឬ ការខកខានមិនបានប្រព្រឹត្ត ដែលនៅពេលប្រព្រឹត្តឡើងនោះ ការប្រព្រឹត្ត ឬ ការខកខានប្រព្រឹត្តនោះ “គឺជាបទល្មើសព្រហ្មទណ្ឌ អនុលោមតាមគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ” ដូចមានចែងនៅក្នុងមាត្រា ១៥(២)នៃកតិកាសញ្ញាអន្តរជាតិស្តីពី

និងជាហូរហែមកក៏ដោយ តុលាការក្នុងស្រុកមួយចំនួនបានចេញសេចក្តីសម្រេចរបស់ខ្លួន ដោយអនុវត្តបទដ្ឋានគោលការណ៍នីត្យានុកូលភាពខុសគ្នារវាងបទល្មើសជាតិ និងបទល្មើសអន្តរជាតិ[២១៥]។

សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ (*រដ្ឋអាជ្ញា ទល់នឹង Mondonca និងជនដទៃទៀត* រឿងក្តីលេខ ១៨ក/២០០១ "សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ (Domingos Mendonca) សុំឱ្យតុលាការបង្គាប់រដ្ឋអាជ្ញាកែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌទី ១៨)។ សេចក្តីសម្រេចនេះបានច្រានចោលការរកឃើញមុនៗរបស់សាលាឧទ្ធរណ៍នៃប្រទេសទីម័រខាងកើត (*Armando dos Santos* "សេចក្តីសម្រេចលើច្បាប់បន្ទាប់បន្សំ ដែលអនុវត្តជាធរមាន") ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០២ ទំព័រទី ១៤)។

២១៥ សូមមើលឧទាហរណ៍នៅក្នុងប្រទេសហុងគ្រី ស្តីពីការរកឃើញរបស់តុលាការធម្មនុញ្ញឆ្នាំ ១៩៩៣ ដែលយោងលើមាត្រា ១៥(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ៧(២) នៃ ECHR ដែលចែងថា ការចោទប្រកាន់លើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមមិនគ្រប់គ្រងដោយគោលការណ៍នីត្យានុកូលភាពជាតិឡើយ (ប្រទេសហុងគ្រី តុលាការធម្មនុញ្ញ "សេចក្តីសម្រេចលេខ ៥៣/១៩៩៣ ស្តីពីឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩៣ ការបកប្រែជាភាសាអង់គ្លេសនៅ Sólyom និង Brunner ឆ្នាំ ២០០០ ទំព័រ ២៧៣ ដល់ទំព័រ ២៨៣ និង ២៧៩។ សូមមើលផងដែរនូវការបកស្រាយរបស់តុលាការប្រទេសអាហ្សង់ទីន ស្តីពីគោលការណ៍នីត្យានុកូលភាពនៅក្នុងលក្ខណៈអន្តរជាតិ ប្រទេសអាហ្សង់ទីន តុលាការសហព័ន្ធទីក្រុងប៊ូនណុស អ៊ែរ *Videla* សេចក្តីសម្រេចលើការឃុំខ្លួនមុនពេលជំនុំជម្រះ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៩ ដែលចង្អុលបញ្ជាក់ថា គោលការណ៍នីត្យានុកូលភាព ដូចមានចែងនៅក្នុងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចងកាតព្វកិច្ចដល់ប្រទេសអាហ្សង់ទីន ឱ្យគោរពតាម ហើយប្រទេសអាហ្សង់ទីនមិនអាចមិនគោរពច្បាប់ទាំងឡាយ ដែលបង្កើតឡើងដោយប្រព័ន្ធច្បាប់អន្តរជាតិ ដែលមានអានុភាពលើច្បាប់ជាតិឡើយ "ទោះបីជាករណីនេះមានន័យថាបានផ្តល់អានុភាពលើគោលការណ៍នីត្យានុកូលភាព ដែលមានលក្ខណៈខុសពីគោលការណ៍នីត្យានុកូលភាព ដែលត្រូវបានផ្តល់អានុភាពដោយតុលាការក្នុងស្រុក និងដោយរដ្ឋាភិបាលអាហ្សង់ទីន ដែលខរក្សាសិទ្ធិរបស់តុលាការជាតិ និងរដ្ឋាភិបាលអាហ្សង់ទីនលើបញ្ហានេះ មិនអាចកែប្រែបទប្បញ្ញត្តិជាតិ និងថ្លឹងថ្លែងកាតព្វកិច្ចដែលកើតចេញពីប្រភពនៃនិយាមច្បាប់អន្តរជាតិដទៃៗទៀតឡើយ" ទំព័រ ៣៩-៤០ (អង់គ្លេស)។ ប្រទេសអាហ្សង់ទីន *Arancibia Clavel Enrique Lautaro s/ homicidio alificado y associación illicita y otros* តុលាការកំពូល ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៤ សេចក្តីសម្រេចភាគច្រើនច្រានចោលការរកឃើញថាមានការរំលោភលើគោលការណ៍នីត្យានុកូលភាព ចាប់តាំងពីពេលកើតមានអំពើដែលចោទជាបញ្ហាទាំងនេះ ចាត់តាំងពីមានច្បាប់ទំនៀមទម្លាប់អន្តរជាតិ កំណត់បទប្បញ្ញត្តិព្រហ្មទណ្ឌចំពោះអំពើទាំងនេះ និងការហាមឃាត់លើអាជ្ញាយុកាល កថាខណ្ឌ ២២, ២៣, ២៨ និង ៣៣។ សេចក្តីសម្រេចទាំងពីរបានដកស្រង់នៅក្នុង Ward N. Ferdinadusse *ការអនុវត្តដោយផ្ទាល់នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិនៅក្នុងតុលាការជាតិ* TMC Asser Presse ឆ្នាំ ២០០៦ ទំព័រ ៧៤-៧៥។ សូមអានការរកឃើញរបស់តុលាការធម្មនុញ្ញប្រទេសកូឡុំប៊ី នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនក្នុងឆ្នាំ ២០០២ ស្តីពីធម្មនុញ្ញភាពនៃលក្ខន្តិកៈ ICC ថា បទដ្ឋាននៃគោលការណ៍នីត្យានុកូលភាពមិនដូចគ្នាបេះបិទនឹងច្បាប់ព្រហ្មទណ្ឌជាតិ និងច្បាប់អន្តរជាតិ (ប្រទេសកូឡុំប៊ី Corte Constitutional, Sala Plena *Sentencia C-៥៧៨ (ក្រមព្រហ្មទណ្ឌអន្តរជាតិ)* ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២, ៣១ Jurisprudencia y Doctrina ២២៣១ ទៅ ២២៩២)។ នៅក្នុង *Barbie* (១៩៨៥) តុលាការកំពូលបារាំងបានច្រានចោលសំណងវិសាមញ្ញមួយ ដែលធ្វើឡើងដោយ Barbie (pourvoi) ដោយយោងលើមាត្រា ១៥(២)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ៧(២) នៃ ECHR ដោយរកឃើញថា ឧក្រិដ្ឋកម្ម

ប្រឆាំងមនុស្សជាតិ រងការរួចផុតពីគោលការណ៍នីត្យានុកូលភាព ដូចបានបង្កើតឡើងនៅក្នុងច្បាប់បារាំង (ប្រទេសបារាំង Cour de Cassation *Barbie* (លេខ ២) ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៨៤ Bull. Crim. លេខ ៣៤ ទំព័រ ៩២ ដោយដកស្រង់ និងតម្កល់ការរកឃើញរបស់សាលាឧទ្ធរណ៍៖ "ជាស្ថាពរ ការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានលក្ខណៈស្រប គ្នាទៅនឹងគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយអារ្យប្រទេស ក្នុងករណីនេះ ឧក្រិដ្ឋកម្មទាំងនេះ មិនស្ថិតនៅក្រោម គោលការណ៍អាជ្ញាភាពមិនប្រតិសកម្មនៃច្បាប់អាជ្ញាឡើយ")។ ប៉ុន្តែ សូមមើលផងដែរ តុលាការប្រទេសបារាំង សាលាដំបូងក្រុង ប៉ារីស ចៅក្រមស៊ើបអង្កេត ក្នុងរឿងក្តី *Javor* "Ordonnance" ចុះថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ១៩៩៤ (ក្នុងករណីដែលចៅក្រម ស៊ើបអង្កេតបានរកឃើញថា គោលការណ៍សាកលបានកំណត់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថាជាបទល្មើសអន្តរជាតិ គឺមិន គ្រប់គ្រាន់នៅក្នុងការបង្កើតយុត្តាធិការរបស់តុលាការបារាំងឡើយ) ហើយសំខាន់ជាងនេះនោះគឺ នៅក្នុង Aussaresses (ឆ្នាំ ២០០៣) មានការច្រានចោលពីតុលាការកំពូលរបស់ប្រទេសបារាំង ចំពោះការយកទំនៀមទម្លាប់មកអនុវត្តដោយផ្ទាល់ និង ការចោទប្រកាន់ឧត្តមសេនីយ៍របស់ប្រទេសបារាំង ១ រូប លើអំពើទារុណកម្ម ដែលមានការឆ្លើយសារភាពដោយខ្លួនឯង និងការ សម្លាប់ជនស៊ីវិលក្រៅប្រព័ន្ធតុលាការ នៅក្នុងសង្គ្រាមអាល់ហ្សេរី ដោយឈរលើមូលដ្ឋានថា "វិធានទំនៀមទម្លាប់អន្តរជាតិ មិនអាចបង្កើតឡើងនៅពេលមិនមានច្បាប់ចែងឡើយ ប្រសិនបើបទប្បញ្ញត្តិ ដែលកំណត់អំពើទាំងឡាយ ជាបទល្មើសព្រហ្មទណ្ឌ រងការប្តឹងបរិហារថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយដើមបណ្តឹងជាជនស៊ីវិល" (ប្រទេសបារាំង តុលាការកំពូល *Aussaresses* ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៣ ១០៨ RGDIP ៧៥៤)។ ចំពោះឧទាហរណ៍បន្ថែមទៀតលើការអនុវត្តផ្ទុយពី នេះ សូមមើល តុលាការទីក្រុងអូស្លូ *រដ្ឋអាជ្ញា ទល់នឹង Misrad Repak* លេខរឿងក្តី ០៨-០១៨៩៨៥ MED-OTIR/០៨ ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៦ - ៩ (ក្នុងករណីដែលតុលាការបានច្រានចោលបទចោទដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្ស ជាតិ ពីព្រោះតែ នៅពេលដែលបទល្មើសបានប្រព្រឹត្តនោះ មិនមានបទប្បញ្ញត្តិនៅក្នុងច្បាប់ប្រទេសន័រវែស កំណត់ទង្វើនេះថាជា បទល្មើសព្រហ្មទណ្ឌ នៅក្នុងពាក្យពេចន៍ដូចគ្នា ដូចបានប្រើប្រាស់នៅក្នុងច្បាប់ដែលពាក់ព័ន្ធជាធរមាន ហើយរដ្ឋធម្មនុញ្ញប្រទេស ន័រវេស ហាមឃាត់អនុវត្តច្បាប់តាមអានុភាពប្រតិសកម្ម)។ *Re Habre* សាលដីកាតុលាការកំពូល បណ្តឹងសាទុក្ខលេខ ១៤ ILDC ១៦៤ (SN ២០០១) កថាខណ្ឌ ៣៣ (ក្នុងករណីដែលតុលាការបានរកឃើញថា ខ្លួនមិនអាចចោទប្រកាន់ជនបរទេស ចំពោះអំពើទារុណកម្ម ដែលបានប្រព្រឹត្តនៅបរទេស នៅពេលដែលបទប្បញ្ញត្តិនៅក្នុងអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និង ការប្រព្រឹត្ត ឬ ដាក់ទណ្ឌកម្មសាហាវ អមនុស្សធម៌ ឬ បន្ថុះបង្អាប់ដទៃទៀត មិនត្រូវបានចែងបញ្ចូលនៅក្នុងច្បាប់របស់ប្រទេស សេណេហ្គាល់។ ប្រទេសហូឡង់ តុលាការកំពូល *In re Bouterse* ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០១ ការបកប្រែជាភាសា អង់គ្លេស នៅក្នុងសៀវភៅប្រចាំឆ្នាំរបស់ប្រទេសហូឡង់ស្តីពីច្បាប់អន្តរជាតិ កថាខណ្ឌ ៤.៥ (ក្នុងករណីដែលតុលាការកំពូល ហូឡង់បានរកឃើញថា គោលការណ៍នីត្យានុកូលភាព ដូចបានបង្កើតឡើងនៅក្នុងច្បាប់ហូឡង់ មិនចែងអំពីអញ្ញត្រកម្មចំពោះ បទល្មើសអន្តរជាតិឡើយ។ ប្រទេសអូស្ត្រាលី តុលាការសហព័ន្ធ *Nulyarimma ទល់នឹង Thompson* [១៩៩៩] FCA ១៩៩២ កថាខណ្ឌ ២០ - ២៦, ៣២ (ចៅក្រម ២ រូប ជាសំឡេងភាគច្រើន បានរកឃើញថា ប្រសិនបើមិនមានច្បាប់ជាធរមានណាមួយ នោះទេ បទប្រល័យពូជសាសន៍មិនត្រូវបានទទួលនៅក្នុងតុលាការអូស្ត្រាលីឡើយ បើមិនដូច្នោះទេ វាជាការរំលោភលើគោល-ការណ៍នីត្យានុកូលភាព (កថាខណ្ឌ ២៦)។ ចៅក្រម Merkel ដែលផ្តល់មតិជំទាស់ បានពិចារណាឃើញថា ការអនុវត្តបទល្មើស នៅក្នុងយុត្តាធិការសាកល អនុលោមតាមច្បាប់អន្តរជាតិ មិនមែនជាការរំលោភបំពានគោលការណ៍នេះឡើយ ហើយចៅក្រមរូប នេះបានគូសបញ្ជាក់នូវភាពចាំបាច់ចំពោះតុលាការជាតិពិចារណាលើការវិវឌ្ឍន៍នៃច្បាប់អន្តរជាតិ (កថាខណ្ឌ ១៦១ និង ១៧៨)

ហេតុដូច្នេះ រដ្ឋមួយចំនួនបានអនុវត្តច្បាប់អន្តរជាតិដោយផ្ទាល់តែម្តង ដោយគ្រាន់តែផ្អែកលើសន្ធិសញ្ញា និង/ឬ ច្បាប់ទំនៀមទម្លាប់ ដោយមិនចាំបាច់មានបទប្បញ្ញត្តិជាក់លាក់ណាមួយនៅក្នុងច្បាប់ជាតិ ចែងកំណត់ថា ទង្វើមួយជាបទល្មើសព្រហ្មទណ្ឌ ឬ នៅក្នុងករណីមួយចំនួន ដោយគ្រាន់តែបញ្ចូលច្បាប់អន្តរជាតិ[២១៦] តែប៉ុណ្ណោះ។ វិធីសាស្ត្រនេះ គឺស្របនឹងយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលមិនខុសពីបណ្តាតុលាការជាតិទាំងឡាយ បានធ្វើការបែងចែកយ៉ាងច្បាស់រវាងបទល្មើសអន្តរជាតិ និងបទល្មើសជាតិ[២១៧]។ ដូចគ្នានេះដែរ សាលាក្តី *មិនអចិន្ត្រៃយ៍* បានធ្វើការចោទប្រកាន់បទល្មើសអន្តរជាតិ ដោយផ្អែកលើមូលដ្ឋាននៃច្បាប់ទំនៀមទម្លាប់តែប៉ុណ្ណោះ ក្រោមលក្ខខណ្ឌនៃការគោរពគោលការណ៍នីត្យានុកូលភាពអន្តរជាតិ[២១៨]។ វិធីសាស្ត្រនេះ ទទួលស្គាល់តួនាទីរបស់យុត្តាធិការសាលាក្តីអន្តរជាតិ និងជាតិ ក្នុងការចោទប្រកាន់បទល្មើសអន្តរជាតិចម្បងៗដែលតាំងពីដើមមក តម្រូវឱ្យផ្អែកលើច្បាប់អន្តរជាតិ ដោយសារដំណើរការឃើតយ៉ាវ

ពោលគឺ "វានឹងជាការចម្លែកសម្រាប់តុលាការជាតិ ដែលមិនបន្តតួនាទីយូរមកហើយរបស់ខ្លួន ទទួលស្គាល់ តាមរយៈការអនុម័តការផ្លាស់ប្តូរ និងការវិវឌ្ឍន៍នៅក្នុងច្បាប់អន្តរជាតិ" (កថាខណ្ឌ ១៨១))។

[២១៦] បន្ថែមលើចំណុចយោងដកស្រង់នៅក្នុងលេខយោងជើងទំព័រខាងលើ សូមមើល៖ Ward N. Ferdinadusse *ការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិដោយផ្ទាល់នៅក្នុងតុលាការជាតិ* TMC Asser Presse ឆ្នាំ ២០០៦ ទំព័រ ៨៥ (អង់គ្លេស)។

[២១៧] ECtHR, *Naletilic ទល់នឹង ប្រទេសក្រូអាត* បណ្តឹងលេខ ៥១៨៩១/៩៩ សេចក្តីសម្រេចលើភាពអាចទទួលយកបាន ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០០០។ សូមមើលផងដែរ *Kononov ទល់នឹងប្រទេសឡេតូនី* បណ្តឹងលេខ ៣៦៣៧៦/០៤ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះជាន់ខ្ពស់ (Grand Chamber) ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១០ ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះជាន់ខ្ពស់លើករណី Kononvo") កថាខណ្ឌ ១៨៥, ១៨៦ (EctHR រំឭកឡើងថា កថាខណ្ឌចំនួន ២ នៅក្នុងមាត្រា ៧ មានការជាប់ពាក់ព័ន្ធគ្នា និងត្រូវយកមកបកស្រាយនៅក្នុងលក្ខណៈស្របគ្នា" ហើយ *"ឯកសាររៀបចំ" សម្រាប់*អនុសញ្ញាបង្ហាញថា គោលបំណងនៃកថាខណ្ឌទី២ នៃមាត្រា ៧ គឺត្រូវបញ្ជាក់ថា មាត្រា ៧ មិនប៉ះពាល់នឹងច្បាប់ទាំងឡាយ ដែលនៅក្នុងកាលៈទេសៈលើកលែងទាំងស្រុងក្នុងចុងសម័យសង្គ្រាមលោកលើកទី ២ ត្រូវបានអនុវត្ត ក្នុងគោលបំណងដាក់ទោសលើ *ក្នុងចំណោមបទល្មើសទាំងឡាយ* ឧក្រិដ្ឋកម្មសង្គ្រាម ដើម្បីធានាថា មាត្រា ៧ មិនមានគោលបំណងណាមួយ យកសេចក្តីសម្រេចតាមផ្លូវច្បាប់ និងផ្លូវសីលធម៌ មកដាក់បញ្ចូលក្នុងច្បាប់ទាំងនោះ"។ មាត្រានេះគូសបញ្ជាក់ថា ការកាត់ទោសដើមបណ្តឹងឧទ្ធរណ៍លើឧក្រិដ្ឋកម្មសង្គ្រាម ត្រូវបានផ្អែកលើច្បាប់អន្តរជាតិ ជាជាងច្បាប់ជាតិ ហើយតុលាការយល់ឃើញថា មាត្រានេះត្រូវយកមកពិនិត្យតាមទស្សនវិស័យនេះ ជាចម្បង)។

[២១៨] សូមមើល *រដ្ឋអាជ្ញា ទល់នឹង Hadzihasanovic និងជនដទៃទៀត* IT-០១-៤៧-AR៧២ "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បន្ទំ តវ៉ាលើយុត្តាធិការលើការទទួលខុសត្រូវរបស់មេបញ្ជាការ" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ៣៥, ៤៤-៤៦ និង ៥៥។ អៀង ធីរិទ្ធ ទទួលស្គាល់នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនថា សាលាក្តី *មិនអចិន្ត្រៃយ៍*នានា ធ្វើការចោទប្រកាន់បុគ្គលទាំងឡាយ ដោយផ្អែកលើច្បាប់ទំនៀមទម្លាប់ (បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ២៤)។

នៅក្នុងការចងក្រងច្បាប់របស់ខ្លួន[២១៩]។ គ្មានទឡ្ហីករណ៍ណាមួយ បង្កើតឡើងនៅក្នុងមូលដ្ឋានទី១ ដល់ ទី៥ នៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា និងមូលដ្ឋានទី១ ដល់ ទី៣ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ រួមបញ្ចូលការយោងលើបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជា និងបទប្បញ្ញត្តិ*គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង* នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ជំរុញឱ្យអង្គបុរេជំនុំជម្រះជឿថា ខ្លួនមានកាតព្វកិច្ចអនុវត្តយុត្តាធិការលើបទល្មើសអន្តរជាតិ ឱ្យស្របតាមគោលការណ៍នីត្យានុកូលភាពជាតិ ហើយមានកាតព្វកិច្ចមិនត្រូវគោរពតាមបទដ្ឋានណែនាំយ៉ាងច្បាស់លាស់របស់ អ.វ.ត.ក នៅក្នុងករណីនេះឡើយ។

៩៨. ចុងចោទក៏បានផ្តល់ការអះអាងផងដែរថា អ.វ.ត.ក ត្រូវបានរារាំងមិនឱ្យធ្វើការចោទប្រកាន់លើបទល្មើសអន្តរជាតិ ដោយហេតុថា តាមការចោទប្រកាន់ ប្រទេសកម្ពុជាគឺជាប្រទេសអនុវត្តប្រព័ន្ធទ្វិកនិយម[២២០]។ ទឡ្ហីករណ៍របស់ នួន ជា ដែលថា ជាគោលការណ៍ គ្មានហេតុផលណាមួយត្រូវបកស្រាយការយោងលើ "ច្បាប់" និង "បទប្បញ្ញត្តិទាំងឡាយ" នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្នឡើយ[២២១] ដោយសារតែការបកស្រាយលើច្បាប់ដទៃ ក្រៅពីច្បាប់ក្នុងស្រុកដែលបានធ្វើឡើងនោះគឺមិនត្រឹមត្រូវ និងដោយសារច្បាប់ អ.វ.ត.ក តម្រូវឱ្យ អ.វ.ត.ក អនុវត្តយុត្តាធិការរបស់ខ្លួនឱ្យស្រប

---

[២១៩] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះជាន់ខ្ពស់លើករណី *Kononvo* កថាខណ្ឌ ២០៨ (ECtHR រំឭកថា "ក្នុងពេលនៃការចងក្រងជាឧក្រិដ្ឋកម្មសង្គ្រាម សាលាក្តីយោធា និងព្រហ្មទណ្ឌក្នុងស្រុកទាំងឡាយ គឺជាយន្តការចម្បងសម្រាប់ពង្រឹងការអនុវត្តច្បាប់ និងទំនៀមទម្លាប់នៃការធ្វើសង្គ្រាម [...] ហើយការចោទប្រកាន់ជាលក្ខណៈអន្តរជាតិតាមរយៈសាលាក្តីយោធាអន្តរជាតិ គឺជាករណីលើកលែង"។ ហេតុដូច្នេះ "ក្នុងករណីច្បាប់ជាតិមិនបានចែងអំពីការកំណត់លក្ខណៈបទល្មើសឧក្រិដ្ឋកម្មសង្គ្រាមជាក់លាក់នោះទេ តុលាការជាតិអាចផ្អែកលើច្បាប់អន្តរជាតិជាមូលដ្ឋាននៃសំអាងហេតុ ដោយមិនឱ្យរំលោភលើគោលការណ៍*គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង* និង*គោលការណ៍គ្មានទោសប្រសិនបើគ្មានច្បាប់ចែង*។) សូមមើលផងដែរ ៖ ផ្នែក១៣ នៃ Lieber Code ឆ្នាំ១៨៦៣ ដែលបានចែងថា "ឧក្រិដ្ឋកម្មយោធាដែលមិនមានចែងក្នុងលក្ខន្តិកៈត្រូវតែកាត់ទោស និងផ្តន្ទាទោសអនុលោមតាមច្បាប់សង្គ្រាមទូទៅ។" (សេចក្តីណែនាំដល់កងប្រដាប់អាវុធរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកក្នុងសមរភូមិ រៀបរៀងដោយ Francis Lieber បានប្រកាសឱ្យប្រើដោយប្រធានាធិបតី Lincoln នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៨៦៣ ជាការបង្គាប់បញ្ជាជាទូទៅ (General Orders) លេខ ១០០, ("Lieber Code"))។

[២២០] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ២០-២២។ បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ៣២។

[២២១] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ២០ យោងលើរដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្ន ដែលចែងថា "ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនជនណាមួយ និងអាចធ្វើទៅកើត លុះត្រាតែ*អនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់*" ហើយការជំនុំជម្រះនាពេលក្រោយមក "ត្រូវធ្វើឡើង [...] *ឱ្យស្របទៅនឹងនីតិវិធីច្បាប់ និងច្បាប់ជាធរមាន*" (រដ្ឋធម្មនុញ្ញ មាត្រា ៣៨ និងមាត្រា ១១០ (ការគូសបញ្ជាក់បន្ថែម))។

តាមគោលការណ៍នីត្យានុកូលភាពអន្តរជាតិ។ គោលការណ៍នីត្យានុកូលភាពអន្តរជាតិតម្រូវឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌលើបទល្មើសទាំងឡាយ ដែលមានលក្ខណៈជាតិ ឬអន្តរជាតិ នៅពេលបទល្មើសទាំងនេះបានប្រព្រឹត្ត[២២២]។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដើមបណ្ដឹងឧទ្ធរណ៍មិនបានតវ៉ាលើធម្មនុញ្ញភាពនៃច្បាប់ អ.វ.ត.ក ហើយ ទោះក្នុងករណីណាក៏ដោយ មិនបានរំឭកឡើងវិញថា អង្គបុរេជំនុំជម្រះមិនមានអំណាចពិនិត្យមើលធម្មនុញ្ញភាពនៃច្បាប់ អ.វ.ត.ក ទេ[២២៣]។ អង្គបុរេជំនុំជម្រះមិនជឿថា ទឡ្ហីករណ៍នេះ ចាប់បង្ខំមិនឱ្យខ្លួនគោរពតាមបទដ្ឋានណែនាំជាក់លាក់នៅក្នុងច្បាប់ អ.វ.ត.ក នៅក្នុងករណីនេះនោះទេ។ ដោយហេតុថា គោលការណ៍នីត្យានុកូលភាពអន្តរជាតិមិនតម្រូវឱ្យបទល្មើសអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវ ត្រូវអនុវត្តតាមច្បាប់ជាតិ ដើម្បីកំណត់ពិរុទ្ធភាពរបស់ជនល្មើស ដូច្នេះ ការកំណត់ប្រព័ន្ធតុលាការកម្ពុជាជាប្រព័ន្ធឯកនិយម ឬ ទ្វិកនិយម មិនមានការជាប់ពាក់ព័ន្ធនឹងសុពលភាពនៃច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក នោះទេ។

៩៥. អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះយល់ស្របជាមួយនឹងសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា[២២៤]ថា លក្ខណៈនៃ អ.វ.ត.ក ជាតុលាការជាតិ មិនមានការរារាំងលើយុត្តាធិការរបស់ខ្លួននៅក្នុងករណីនេះឡើយ[២២៥]។ ឋានៈរបស់ អ.វ.ត.ក ជាតុលាការជាតិ ដូចដើមបណ្ដឹងឧទ្ធរណ៍បានអះអាង ឬជាតុលាការអន្តរជាតូបនីយកម្ម ដូចអង្គបុរេជំនុំជម្រះ[២២៦] និងអង្គជំនុំជម្រះសាលាដំបូង[២២៧]

---

[២២២] មាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[២២៣] សូមមើលតាមសទិសភាព៖ សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស(អបជ០១) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៧ C5/45 (ក្នុងករណីអង្គបុរេជំនុំជម្រះសម្រេចថា "អ.វ.ត.ក ក៏មិនមានសិទ្ធិសើរើសេចក្ដីសម្រេចរបស់តុលាការណាមួយដែលមិនស្ថិតក្នុងរចនាសម្ព័ន្ធរបស់ខ្លួនដែរ")។ សូមមើលផងដែរនូវការយល់ឃើញរបស់ចៅក្រមកម្ពុជានៅក្នុង (រឿងក្ដីលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជសដ "សេចក្ដីសម្រេចស្ដីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្ដី" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ("សេចក្ដីសម្រេចស្ដីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ") កថាខណ្ឌ ៣៨)។

[២២៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣៧។

[២២៥] បណ្ដឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ២៦។ បណ្ដឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ២៣, ៤៧-៤៨, ៧១។

[២២៦] សេចក្ដីសម្រេចជាសាធារណៈស្ដីពីបណ្ដឹងជំទាស់ចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ ៣០ ដែលអង្គបុរេជំនុំជម្រះបានរកឃើញទាក់ទងនឹងការតែងតាំងចៅក្រម អ.វ.ត.ក ថា "ក្នុងបរិបទនេះ អ.វ.ត.ក គឺជាតុលាការអន្តរជាតិថ្មីមួយ ដែលអនុវត្តបទដ្ឋាន និងនិយាមអន្តរជាតិ"។ សូមមើលផង

បានរកឃើញ មិនជាប់ពាក់ព័ន្ធនឹងយុត្តាធិការរបស់ខ្លួននោះទេ នៅពេលពិចារណាលើបទប្បញ្ញត្តិចែងជាក់លាក់នៅក្នុងច្បាប់ អ.វ.ត.ក[២២៨]។ ដោយហេតុថា ទាំងអង្គការសហប្រជាជាតិ ទាំងរាជរដ្ឋាភិបាលកម្ពុជា បានព្រមព្រៀងគ្នាយ៉ាងច្បាស់លាស់ ផ្តល់យុត្តាធិការឱ្យ អ.វ.ត.ក លើបទល្មើសទាំងឡាយ ដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ដូច្នេះ យុត្តាធិការបែបនេះ មិនផ្អែកលើលក្ខណៈរបស់ អ.វ.ត.ក ជាសាលាក្តីជាតិ ឬ អន្តរជាតូបនីយកម្មនោះទេ ដូចមានសំអាងហេតុលើកឡើងខាងលើ[២២៩]។ ទោះក្នុងវិធីសាស្ត្រណាក៏ដោយ អ.វ.ត.ក មានយុត្តាធិការជំនុំជម្រះលើបទល្មើស ដូចមានចែងរៀបរាប់នៅក្នុងច្បាប់ អ.វ.ត.ក ហើយនៅពេលអនុវត្តច្បាប់អន្តរជាតិ អង្គជំនុំជម្រះមានកាតព្វកិច្ចគោរពតាមគោលការណ៍នីត្យានុកូលភាពអន្តរជាតិ។ ទោះក្នុងករណីណាក៏ដោយ ដើមបណ្តឹងឧទ្ធរណ៍មិនផ្តល់សំអាងហេតុគួរឱ្យជឿជាក់នៅក្នុងបណ្តឹងឧទ្ធរណ៍នេះទេ ដែលសំអាងហេតុនេះ នឹងចាប់បង្ខំអង្គបុរេជំនុំជម្រះឱ្យពិចារណាឡើងវិញលើការយល់ឃើញរបស់ខ្លួននាពេលមុនថា អ.វ.ត.ក គឺជាតុលាការអន្តរជាតូបនីយកម្ម។

១០០. ចំណុចចុងក្រោយ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សំអាងហេតុដូចគ្នានេះបានយកទៅអនុវត្តចំពោះទម្រង់នៃការទទួលខុសត្រូវ ដូចមានចែងនៅក្នុងមាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក។ នៅក្នុងករណីនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដើមបណ្តឹងឧទ្ធរណ៍ចោទប្រកាន់ថា អ.វ.ត.ក អាចអនុវត្តបានតែចំពោះទម្រង់នៃការទទួលខុសត្រូវ ដូចបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដោយពុំបានបញ្ជាក់ថា ទម្រង់នៃការទទួលខុសត្រូវណាមួយដែលមានចែងនៅក្នុងច្បាប់ អ.វ.ត.ក ទំនងជាមិនត្រូវបានបញ្ញត្តិទុកនៅក្នុងច្បាប់នោះទេ។ ទោះបីជា នួន ជា បានយោងលើលេខយោងជើងទំព័រ ភ្ជាប់ទៅនឹងកថាខណ្ឌនៃដីកាដំណោះស្រាយ ដែល ក.ស.ច.ស បានលើកឡើងថា ទម្រង់

ដែរនូវបណ្តឹងឧទ្ធរណ៍របស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ប្រឆាំងនឹងការសម្រេចឃុំខ្លួនបណ្តោះអាសន្ន សំណុំរឿងលេខ ០០១/១/០៧-២០០៧/អវតក/កសចស (អបជ០១) ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ កថាខណ្ឌ ១៨-២០។

[២២៧] ២០០៧/អ.វ.ត.ក/កសចស (អបជ០១) សេចក្តីសម្រេចលើសំណើសុំដោះលែងឱ្យមានសេរីភាព សំណុំរឿងលេខ ០០១/១/-០៧-២០០៧/អ.វ.ត.ក/អជសដ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ ("សេចក្តីសម្រេចលើសំណើដោះលែង *ឌុច* ឱ្យមានសេរីភាព") កថាខណ្ឌ ១០។

[២២៨] មាត្រា ១ នៃច្បាប់ អ.វ.ត.ក។

[២២៩] មាត្រា ១ នៃកិច្ចព្រមព្រៀង អ.វ.ត.ក (ផ្តល់សមត្ថកិច្ចដល់ អ.វ.ត.ក ក្នុងការអនុវត្តយុត្តាធិការលើបទល្មើសជាតិ និងអន្តរជាតិ) មាត្រា ២(ថ្មី)-៨ នៃកិច្ចព្រមព្រៀង អ.វ.ត.ក (រៀបរាប់នូវបទល្មើសទាំងឡាយ ដែល អ.វ.ត.ក មានយុត្តាធិការជំនុំជម្រះ)។

នៃការទទួលខុសត្រូវមួយចំនួន ដូចមានរៀបរាប់នៅក្នុងមាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក មិនមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[២៣០] ដូចជា ការញុះញង់ សហឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវរបស់ថ្នាក់លើ[២៣១] យ៉ាងក៏ដោយ ក៏ដើមបណ្តឹងឧទ្ធរណ៍មិនបានផ្តល់ទឡ្ហីករណ៍នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនថាតើទម្រង់នៃការទទួលខុសត្រូវទាំងនេះ មានលក្ខណៈខុសគ្នានឹងទម្រង់នៃការទទួលខុសត្រូវនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ យ៉ាងដូចម្តេចនោះដែរ។ ទោះក្នុងករណីណាក៏ដោយ អង្គបុរេជំនុំជម្រះសូមរំឭកសេចក្តីសម្រេចមុនៗរបស់ខ្លួនថា នៅក្នុងការពិនិត្យលើបណ្តឹងឧទ្ធរណ៍ទាំងនេះ អង្គបុរេជំនុំជម្រះនឹងមិនពិចារណាថា ខ្លួនមិនមានយុត្តាធិការលើសហឧក្រិដ្ឋកម្មរួម ដូចដែលបានចោទប្រកាន់ឡើយ ហើយអង្គបុរេជំនុំជម្រះប្រកាសថា ការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ ឱ្យស្របជាមួយនឹងគោលការណ៍នីត្យានុកូលភាពអន្តរជាតិ ទៅតាមលក្ខខណ្ឌនៃការដឹងថាមានច្បាប់ចែង និងការអាចប្រមើលមើលឃើញថាជាបទល្មើស នឹងត្រូវលើកឡើងនៅក្នុងផ្នែកទី IV (ច) នៅក្នុងសាលដីកានេះ។

១០១. ដោយមានការផ្តល់ទឡ្ហីករណ៍ពីដើមបណ្តឹងឧទ្ធរណ៍ទាំងពីរ អង្គបុរេជំនុំជម្រះសូមបែរទៅពិចារណាបញ្ហាចោទថា តើសហចៅក្រមស៊ើបអង្កេតបានផ្អែកលើការលើកឡើងដោយភ័ន្តច្រឡំដែរឬទេ នៅពេលខ្លួនលើកឡើងថា អ.វ.ត.ក បានកំណត់តាមប្រតិសកម្មថា ការរំលោភបំពានលើច្បាប់អន្តរជាតិគឺជាបទល្មើសព្រហ្មទណ្ឌ[២៣២]។ ការអះអាងរបស់ នួន ជា ថា ដីកាដំណោះស្រាយ "ពិតជាបានលើកឡើងដោយភ័ន្តច្រឡំថា ច្បាប់ អ.វ.ត.ក បានកំណត់ថា បទល្មើសទាំងឡាយដែលបានទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិ ជាបទល្មើសអន្តរជាតិ" គឺផ្អែកទៅតាមកថាខណ្ឌ ១៣០៥ ដល់កថាខណ្ឌ ១៣០៧ នៅក្នុងដីកាដំណោះស្រាយ។ ការអះអាងដូច្នេះ គឺមិនត្រឹមត្រូវឡើយ។ ការអានដោយមិនលម្អៀងលើកថាខណ្ឌទាំងនេះនៅក្នុងដីកាដំណោះស្រាយ អាចត្រឹមតែឱ្យមានការសន្និដ្ឋានតែមួយប៉ុណ្ណោះថា ច្បាប់ អ.វ.ត.ក ផ្តល់យុត្តាធិការឱ្យតុលាការនេះជំនុំជម្រះបទល្មើសទាំងនេះ និងអនុវត្តទម្រង់នៃការទទួលខុសត្រូវ ដែលបានកំណត់នៅក្នុងច្បាប់ជាតិ និង/ឬ អន្តរជាតិ ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ កថាខណ្ឌ ១៣០៤ នៅក្នុងដីកាដំណោះស្រាយ ដែល អៀង ធីរិទ្ធ បានយកទឡ្ហីករណ៍របស់ខ្លួនមកសំអាងនោះ គឺមានលក្ខណៈស្រពេចស្រពិលជាងនេះ៖

---

[២៣០] បណ្តឹងឧទ្ធរណ៍ នួន ជា លេខយោងជើងទំព័រ ៧។

[២៣១] ដីកាដែលរងការជំទាស់ កថាខណ្ឌ ១៣០៧។

[២៣២] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ៣០-៣១។ បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ២០។

ពាក់ព័ន្ធនឹងបញ្ហានៃភាពដែលអាចអនុវត្តដោយផ្ទាល់នៃច្បាប់អន្តរជាតិនៅក្នុងប្រទេសកម្ពុជា ចាំបាច់ត្រូវរំឭកឡើងវិញថា មាត្រា ១ និងមាត្រា ២ និងមាត្រា ២៩(ថ្មី) នៃច្បាប់ស្តីពី អ.វ.ត.ក បានដាក់បញ្ចូលក្នុងច្បាប់កម្ពុជានូវការរំលោភបំពានច្បាប់អន្តរជាតិមួយចំនួន ដែលត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក (ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ការបំផ្លិចបំផ្លាញ សម្បត្តិវប្បធម៌ក្នុងពេលមានជម្លោះប្រដាប់អាវុធ ព្រមទាំងឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកដែលទទួលបានការការពារជាអន្តរជាតិ) ក៏ដូចជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលត្រូវអនុវត្ត (ដោយបញ្ចូលផងដែរនូវរបបទោសបញ្ញត្តិ ដែលអនុលោមតាមគោលការណ៍ *មិនមានទោសប្រសិនគ្មានច្បាប់ចែង /nulla poena sine lege*)។ ដោយយោងទៅលើបទប្បញ្ញត្តិទាំងនេះ បញ្ហាដែលចោទឡើងថា តើច្បាប់អន្តរជាតិ អាច ឬ មិនអាចអនុវត្តដោយផ្ទាល់នៅក្នុងប្រទេសកម្ពុជានឹងមិនបង្កើតផលវិបាកអ្វីចំពោះសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក នោះឡើយ (លុបចោលលេខយោងជើងទំព័រ)។

១០២. ទោះបីជាយ៉ាងនេះក្តី វាមិនអាចនាំឱ្យមានការសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតបានបកស្រាយច្បាប់ អ.វ.ត.ក ថាបានកំណត់បទល្មើសទាំងឡាយដែលបានចោទប្រកាន់ គឺជាបទល្មើសព្រហ្មទណ្ឌឡើយ។ មាត្រាទាំងឡាយនៅក្នុងច្បាប់ អ.វ.ត.ក ដែលត្រូវបានដកស្រង់នៅក្នុងកថាខណ្ឌនោះ ត្រឹមតែកំណត់គោលបំណង និងយុត្តាធិការរបស់តុលាការនេះ លើបទល្មើស និងទម្រង់នៃការទទួលខុសត្រូវ ដូចបានរៀបរាប់ ជាជាងកំណត់ថា ទង្វើទាំងឡាយនេះ គឺជាបទល្មើសព្រហ្មទណ្ឌ។ កថាខណ្ឌនេះ ត្រូវតែអានរួមគ្នាជាមួយនឹងការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងកថាខណ្ឌ ១៣០២ នៅក្នុងដីកាដែលរងការជំទាស់ ដែលបានលើកឡើងថា ដើម្បីអនុវត្តទៅតាមគោលការណ៍នីត្យានុកូលភាព និងដើម្បីអនុវត្តគោលការណ៍នេះនៅមុខ អ.វ.ត.ក "ខណៈដែលអំពើនោះមិនត្រូវបានចាត់ជាបទល្មើស នៅក្នុងបញ្ញត្តិច្បាប់ព្រហ្មទណ្ឌក្នុងពេលដែលអំពើនោះកើតឡើងនោះទេ នោះច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវចែងអំពីបទល្មើសនៃអំពើនោះដោយច្បាស់លាស់ ឬដោយតុណ្ហីភាព ហើយអំពើនោះក៏ត្រូវតែជាបទល្មើសនៅក្រោមបញ្ញត្តិនៃច្បាប់អន្តរជាតិ ដែលអនុវត្តនៅក្នុងប្រទេសកម្ពុជា នៅខណៈពេលដែលអំពើនោះបានកើតឡើងផងដែរ" ព្រមទាំងការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតរបស់ខ្លួននៅក្នុងកថាខណ្ឌ ១៣០៣ ដែលថា គោលការណ៍នេះក៏អនុវត្តចំពោះទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ នៅពេលអានក្នុងបរិបទនេះ អង្គបុរេជំនុំជម្រះជឿថា សហចៅក្រមស៊ើបអង្កេតមិនបានពិចារណាថា ច្បាប់ អ.វ.ត.ក បានកំណត់ទង្វើទាំងនេះជាបទល្មើសព្រហ្មទណ្ឌឡើយ ប៉ុន្តែ ច្បាប់នេះគ្រាន់តែផ្តល់យុត្តាធិការដល់ អ.វ.ត.ក ក្នុងការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលមានអត្ថិភាពនៅចន្លោះថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ និង ថ្ងៃទី ៦ ខែមករា ឆ្នាំ១៩៧៩ និង ច្បាប់សន្ធិសញ្ញា ដែលចងកាតព្វកិច្ចលើប្រទេសកម្ពុជានៅក្នុង

ចន្លោះឆ្នាំនោះ។

១០៣. ចំពោះការផ្តល់ទឡ្ហីករណ៍បន្ថែមរបស់ នួន ជា ដែលលើកឡើងថា នៅពេលផ្តល់យុត្តាធិការដល់ អ.វ.ត.ក លើបទល្មើសអន្តរជាតិ ច្បាប់ អ.វ.ត.ក នឹងប្រាកដជាមាន "អានុភាពជាប្រតិសកម្ម" ដែលរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ការផ្តល់ទឡ្ហីករណ៍នេះ ជាការយល់ច្រឡំលើអត្ថន័យនៃច្បាប់ អ.វ.ត.ក[២៣៣]។ ច្បាប់ អ.វ.ត.ក មិនបានផ្តល់អំណាចដល់រាជរដ្ឋាភិបាលកម្ពុជា ធ្វើការចោទប្រកាន់មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬ បុគ្គលដែលត្រូវបានចោទប្រកាន់ថាជាជនទទួលខុសត្រូវខ្ពស់បំផុតលើបទល្មើសអន្តរជាតិបែបនេះឡើយ។ ការមិនផ្តល់អំណាចបែបនេះ មិនសំខាន់នោះទេ[២៣៤]។ នៅក្នុងការអនុវត្តយុត្តាធិការមូលដ្ឋានរបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជាមិនត្រឹមតែមានសេរីភាពនៅក្នុងការចោទប្រកាន់បទល្មើសបែបនេះ ដែលបានកើតឡើងនៅលើដែនដី ដែលខ្លួនមានយុត្តាធិការប៉ុណ្ណោះទេ, ខ្លួនក៏មានកាតព្វកិច្ចចោទប្រកាន់បទល្មើសបែបនេះផងដែរ តាមច្បាប់អន្តរជាតិ[២៣៥]។ ទោះបីជាយ៉ាងនេះក្តី

[២៣៣] ការឆ្លើយតបរបស់ នួន ជា កថាខណ្ឌ ១៤។

[២៣៤] សូមមើលឧទាហរណ៍ សាលក្រមរបស់អង្គជំនុំជម្រះជាន់ខ្ពស់លើករណី *Kononov* កថាខណ្ឌ ២០៧ (ដែល ECtHR បានរំឭកថា ធម្មនុញ្ញនៃសាលាក្តីយោធាអន្តរជាតិនៅ Nuremburg មិនមែនជាច្បាប់ព្រហ្មទណ្ឌបង្កើតឡើង*ក្រោយហេតុការណ៍*ឡើយ ដោយសារមានកិច្ចព្រមព្រៀងនៅក្នុងលទ្ធិទាសម័យទំនើបលើកឡើងថា ច្បាប់អន្តរជាតិបានកំណត់ឧក្រិដ្ឋកម្មសង្គ្រាមរួចទៅហើយ ហើយទាមទារឲ្យបានការចោទប្រកាន់លើបុគ្គលទាំងឡាយ)។

[២៣៥] *អនុសញ្ញាស្តីពីការបង្ការ និងការដាក់ទណ្ឌកម្មលើបទប្រល័យពូជសាសន៍* (១៩៥១) ៧៨ U.N.T.S ២៧៧ បានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៥០ ("អនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍") មាត្រា I និង មាត្រា V។ អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬ ដាក់ទណ្ឌកម្មសាហាវ អមនុស្សធម៌ និងបន្ទុះបង្អាប់ដទៃទៀត ផ្តល់សច្ចាប័នដោយប្រទេសកម្ពុជានៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ មាត្រា ៤ និងមាត្រា ៥។ *អនុសញ្ញាទីក្រុងហ្សឺណែវពាក់ព័ន្ធនឹងការការពារឈ្លើយសឹកនៅក្នុងពេលសង្គ្រាម* ៧៥ U.N.T.S ២៨៧ (បើកឲ្យចុះហត្ថលេខានៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ បានចូលជាធរមាននៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០) ផ្តល់សច្ចាប័នដោយប្រទេសកម្ពុជានៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ១៩៥៨ ("អនុសញ្ញាទីក្រុងហ្សឺណែវទី IV") មាត្រា ១៤៦។ ប្រទេសកម្ពុជា ដែលបានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាន និងនៅតែបន្តមានកាតព្វកិច្ចធ្វើយ៉ាងណាធានាថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលតាមនិយមន័យ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះបានបង្កនូវការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្ស បានទទួល និងទទួលបាននូវការដោះស្រាយដ៏ស័ក្តិសម។ នៅក្នុងន័យនេះ មាត្រា ២(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា "រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យា៖ (ក) ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួន ដែលទទួលស្គាល់ដោយ កតិកាសញ្ញានេះ ជននោះ *មានសិទ្ធិឲ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិ* ទោះបីជាការរំលោភនោះបានប្រព្រឹត្តដោយ

00686522

ជាជាងការប្រើប្រាស់រចនាសម្ព័ន្ធតុលាការរបស់ខ្លួនដែលមានស្រាប់រួចទៅហើយ រាជរដ្ឋាភិបាលកម្ពុជា បានព្រមព្រៀងជាមួយនឹងអង្គការសហប្រជាជាតិ បង្កើត អ.វ.ត.ក ដែលមានជំនាញអន្តរជាតិ ហើយបានផ្ទេរយុត្តាធិការទៅឱ្យ អ.វ.ត.ក ធ្វើការជំនុំជម្រះលើរឿងក្តីទាំងនេះ។ ទឡ្ហីករណ៍ដែលថា ច្បាប់ អ.វ.ត.ក បានកំណត់បទល្មើសព្រហ្មទណ្ឌ ដោយមិនត្រឹមត្រូវ ដែលបទល្មើសទាំងនេះត្រូវ បានទទួលស្គាល់រួចហើយតាមច្បាប់អន្តរជាតិ យោងតាមសហចៅក្រមស៊ើបអង្កេតនោះ គឺជា ទឡ្ហីករណ៍គ្មានមូលដ្ឋាន។

១០៤. នៅពេលសម្រេចថា អ.វ.ត.ក មានយុត្តាធិការជំនុំជម្រះរឿងក្តីទាំងឡាយ ដែលបានចោទប្រកាន់ លើការរំលោភបំពានច្បាប់អន្តរជាតិ ជាទូទៅ អង្គបុរេជំនុំជម្រះត្រូវសម្រេចនាពេលក្រោយ ថាតើ អ.វ.ត.ក អាចចេញសាលក្រមលើបទល្មើសជាក់លាក់ទាំងនេះ ដូចបានចោទប្រកាន់នៅក្នុងដីកា ដំណោះស្រាយ បានត្រឹមត្រូវដែរឬទេ។

១០៥. មុនពេលធ្វើការវិភាគដូចនេះ អង្គបុរេជំនុំជម្រះរំឭកថា គោលការណ៍នីត្យានុកូលភាព អនុវត្ត "ចំពោះឧក្រិដ្ឋកម្មផង និងទម្រង់នៃការទទួលខុសត្រូវផង" ដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះ ស្រាយ ដែលចេញដោយសហចៅក្រមស៊ើបអង្កេត[២៣៦]។ អាស្រ័យហេតុនេះ ដើម្បីស្ថិតចូលនៅក្នុង

ជនដែលបំពេញមុខនាទីរាជការក៏ដោយ" (ការគូសបញ្ជាក់បន្ថែម)។ ជាទូទៅ កាតព្វកិច្ចនេះ ទាមទារឱ្យរដ្ឋធ្វើការចោទប្រកាន់ និងដាក់ទណ្ឌកម្មចារីដែលបានធ្វើការរំលោភបំពាន។ សូមមើល IACtHR *រឿងក្តី Velázquez Rodríguez* "សេចក្តីសម្រេច និងសាលក្រម" ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៨៨ កថាខណ្ឌ ១៧៦ ("រដ្ឋមានកាតព្វកិច្ចស៊ើបអង្កេតគ្រប់ស្ថានភាពដែលពាក់ព័ន្ធ នឹងការរំលោភសិទ្ធិ ដែលត្រូវបានការពារតាមរយៈអនុសញ្ញានេះ។ ប្រសិនបើអង្គការរដ្ឋ បានប្រព្រឹត្តក្នុងលក្ខណៈ ដែលមិនមាន ការដាក់ទណ្ឌកម្ម ហើយការទទួលបាននូវសិទ្ធិបែបនេះមិនបានផ្តល់ជូនដល់ជនរងគ្រោះឱ្យបានពេញលេញឱ្យបានលឿនទេនោះ គឺរដ្ឋខកខានមិនបានគោរពកាតព្វកិច្ចរបស់ខ្លួនដែលត្រូវធានានូវសិទ្ធិទាំងនេះឱ្យបានពេញលេញ និងសេរី ដល់ជនទាំងឡាយដែល ស្ថិតនៅក្នុងយុត្តាធិការរបស់ខ្លួន។ ករណីនេះដូចគ្នាផងដែរ នៅពេលរដ្ឋណាមួយអនុញ្ញាតឱ្យបុគ្គលឯកជន ឬក្រុមទាំងឡាយ ធ្វើអំពើតាមអំពើចិត្ត និងធ្វើឱ្យមាននិទណ្ឌភាពចំពោះការធ្វើឱ្យខូចខាតសិទ្ធិទាំងឡាយ ដែលទទួលស្គាល់ដោយអនុសញ្ញា" (គូសបញ្ជាក់បន្ថែម)។ ឧទាហរណ៍ សាលក្រមរបស់អង្គជំនុំជម្រះជាន់ខ្ពស់លើករណី *Kononov* កថាខណ្ឌ ២១៣ (ដែល ECtHR បានរកឃើញថា មកត្រឹមខែ ឧសភា ឆ្នាំ ១៩៤៤ មុនពេលអនុម័តលិខិតុបករណ៍សិទ្ធិមនុស្ស មានការលើកឡើងថា "រដ្ឋទាំងឡាយ យ៉ាងហោចណាស់ ត្រូវបានអនុញ្ញាត (ទោះបីមិនមែនជាលក្ខខណ្ឌទាមទារក៏ដោយ) ឱ្យចាត់វិធានការដាក់ ទណ្ឌកម្មលើជនទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម [សង្គ្រាម] ដោយរួមទាំងផ្អែកលើការទទួលខុសត្រូវរបស់មេបញ្ជាការ"។

[២៣៦] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច* ០០១/១៨-០៧-២០០៧/អវតក/អជសដ "សាលក្រម" ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ("សាលក្រម *ឌុច*") កថាខណ្ឌ ២៨។

យុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក បទល្មើស និងទម្រង់នៃការចូលរួម ដូចបានចោទប្រកាន់ ត្រូវតែ៖ ១) "ត្រូវតែមានចែងនៅក្នុង [ច្បាប់ អ.វ.ត.ក] ឲ្យបានច្បាស់លាស់ ឬ ដោយលក្ខណៈប្រយោល"[២៣៧] និង ២) ត្រូវបាន "ទទួលស្គាល់ដោយច្បាប់កម្ពុជា និងច្បាប់អន្តរជាតិក្នុងចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ដែរឬយ៉ាងណា"[២៣៨]។ ដូចបានរកឃើញដោយអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក "ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ គឺជាច្បាប់ជាតិជាធរមាន ដែលគ្របដណ្តប់នៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩"[២៣៩]។ លើសពីនេះ "ទាក់ទងនឹងប្រភពពាក់ព័ន្ធនឹងច្បាប់អន្តរជាតិដែលអនុវត្តក្នុងអំឡុងពេលនោះ អង្គជំនុំជម្រះអាចផ្អែកលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងអនុសញ្ញាអន្តរជាតិ ព្រមទាំងគោលការណ៍ទូទៅនៃច្បាប់ ដែលបានទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ"[២៤០]។ អង្គបុរេជំនុំជម្រះអាចផ្អែកលើ "ច្បាប់អនុសញ្ញាអន្តរជាតិ នៅពេលដែលសន្ធិសញ្ញាមួយ (i) ចងភ្ជាប់កាតព្វកិច្ចភាគីនានាយ៉ាងពិតប្រាកដ នៅពេលដែលបទឧក្រិដ្ឋត្រូវបានចោទប្រកាន់ និង (ii) មិនផ្ទុយ ឬ មិនប៉ះពាល់ដល់បទដ្ឋានអាជ្ញាបញ្ញានៃច្បាប់អន្តរជាតិ។ [...] នៅក្នុងការអនុវត្តជាក់ស្តែង តុលាការអន្តរជាតិនានាបានបញ្ជាក់ថាតើបទប្បញ្ញត្តិរបស់សន្ធិសញ្ញាមួយគឺជាបទប្បញ្ញត្តិ ដែលត្រូវតែប្រកាសជាទំនៀមទម្លាប់ផងដែរ ឬយ៉ាងណា"[២៤១]។

១០៦. ម្យ៉ាងវិញទៀត គោលការណ៍នីត្យានុកូលភាពទាមទារថា បទល្មើស ឬ ទម្រង់នៃការទទួលខុសត្រូវ ត្រូវតែ "គេប្រមើលមើលឃើញច្បាស់ថាជាបទឧក្រិដ្ឋ ហើយច្បាប់ដែលចែងអំពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនោះត្រូវតែដឹងដោយជនជាប់ចោទ នៅពេលគាត់ប្រព្រឹត្តបទឧក្រិដ្ឋនោះ"[២៤២]។ "ចំពោះលក្ខខណ្ឌតម្រូវនៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ ជនត្រូវចោទត្រូវតែអាចដឹងថាមានច្បាប់ចែងបង្ហាញថា អំពើនោះគឺជាអំពើឧក្រិដ្ឋ នៅក្នុងអារម្មណ៍ដែលអាចដឹងជាទូទៅដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយទេ។ ចំពោះលក្ខខណ្ឌតម្រូវនៃការដឹងថាមាន

---

[២៣៧] សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៤៣។

[២៣៨] សាលក្រម *ឌុច* កថាខណ្ឌ ២៨។

[២៣៩] សាលក្រម *ឌុច* កថាខណ្ឌ ២៩។

[២៤០] សាលក្រម *ឌុច* កថាខណ្ឌ ៣០ (លុបចោលលេខយោងជើងទំព័រ)។

[២៤១] សាលក្រម *ឌុច* កថាខណ្ឌ ៣៣។

[២៤២] សាលក្រម *ឌុច* កថាខណ្ឌ ២៨។

អង្គជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00686524

ច្បាប់ចែង វាក៏រួមបញ្ចូលសំអាងច្បាប់ទាំងឡាយណាដែលផ្អែកលើទំនៀមទម្លាប់ផងដែរ” ឬគោលការណ៍ទូទៅ ក្រៅពីលក្ខន្តិកៈ ឬ ច្បាប់សន្ធិសញ្ញា ដែលមានគ្រប់គ្រាន់សម្រាប់ជនត្រូវចោទ[២៤៣]។ “ទោះបីជាអំពើដែលគ្មានសីលធម៌ ឬឃោរឃៅ មិនមាននូវកត្តាគ្រប់គ្រាន់ដើម្បីចាត់ទុកថាជាឧក្រិដ្ឋភាព [...] ជាការពិត អំពើគ្មានសីលធម៌ ឬ អំពើឃោរឃៅនោះដើរតួនាទី [...] ដែលអាចបដិសេធការអះអាងរបស់មេធាវីការពារក្តី ដែលបានលើកឡើងថា ជនជាប់ចោទមិនបានដឹងពីអំពើឧក្រិដ្ឋរបស់ខ្លួននោះទេ”[២៤៤]។

១០៧. អង្គបុរេជំនុំជម្រះនឹងធ្វើការវិភាគជាបឋមលើទឡ្ហីករណ៍ ដែលលើកឡើងដោយ អៀង ធីរិទ្ធ ពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលមានបញ្ហាស្រដៀងៗគ្នា ដោយសារបទល្មើសទាំងពីរនេះត្រូវបានចែងបញ្ចូលនៅក្នុងច្បាប់សន្ធិសញ្ញា។ អង្គបុរេជំនុំជម្រះនឹងពិចារណាដោយឡែកៗពីគ្នាលើទឡ្ហីករណ៍របស់ អៀង ធីរិទ្ធ ដែលបានបង្កើតឡើងយ៉ាងលម្អិតជាងនេះ នៅក្នុងមូលដ្ឋានទី ៤ នៃបណ្តឹងឧទ្ធរណ៍ ដែលពាក់ព័ន្ធជាក់លាក់លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

គ. **<u>បញ្ហាថាតើ ក.ស.ច.ស មានការភ័ន្តច្រឡំដែរឬទេ នៅពេលបញ្ជាក់យុត្តាធិការរបស់ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដោយហេតុថា ដើមបណ្តឹងឧទ្ធរណ៍មិនអាចប្រមើលមើលដឹងថាមានច្បាប់ចែង ឬមិនអាចដឹងថាទង្វើរបស់ខ្លួនគឺជាបទឧក្រិដ្ឋ នៅពេលដែលគេចោទថា អំពើល្មើសព្រហ្មទណ្ឌទាំងនេះបានកើតឡើង (មូលដ្ឋានទី ៣ និង មូលដ្ឋានទី ៤ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ)</u>**

[២៤៣] សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៤៥។

[២៤៤] សាលក្រម *ឌុច* កថាខណ្ឌ ៣២ (ដកស្រង់ *រដ្ឋអាជ្ញា ទល់នឹង Milutinovic និងជនដទៃទៀត* IT-៩៩-៣៧-AR៧២ “សាលដីកាលើបណ្តឹងរបស់ Dragoljub Ojdanic ដែលប្តឹងតវ៉ាយុត្តាធិការ - សហឧក្រិដ្ឋកម្មរួម”) អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២00៣ កថាខណ្ឌ ៤២)។

១. សារណាខាងបាន

១០៨. មូលដ្ឋានទី ៣ និងមូលដ្ឋានទី ៤ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ចោទប្រកាន់បន្ថែមថា ក.ស.ច.ស មានការភ័ន្តច្រឡំនៅពេលបញ្ជាក់យុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក លើអំពើប្រល័យពូជសាសន៍ ដោយហេតុថា "ម្ចាស់បណ្តឹងឧទ្ធរណ៍មិនទាន់បានដឹងមុនអំពីច្បាប់ដែលចែងជាបទល្មើសព្រហ្មទណ្ឌចំពោះអំពើនោះឡើយ ហើយម្ចាស់បណ្តឹងឧទ្ធរណ៍ក៏មិនអាចដឹងជាមុនថា អំពើដែលប្រព្រឹត្តចន្លោះឆ្នាំ ១៩៧៥-៧៩ ជាបទឧក្រិដ្ឋដែរ" ដូចបានតម្រូវទៅតាមគោលការណ៍នីត្យានុកូលភាព[២៤៥]។ ចំពោះអំពើប្រល័យពូជសាសន៍ អៀង ធីរិទ្ធ អះអាងថា បទប្បញ្ញត្តិនៃច្បាប់អន្តរជាតិដែលហាមឃាត់អំពើនេះ គឺចងកាតព្វកិច្ចលើរដ្ឋភាគី ហើយសហចៅក្រមស៊ើបអង្កេត "បានធ្វើការសន្និដ្ឋានដោយខុសឆ្គងថា ការហាមឃាត់នោះបានធ្វើឲ្យបុគ្គលម្នាក់ត្រូវទទួលខុសត្រូវបទឧក្រិដ្ឋចំពោះអំពើប្រល័យពូជសាសន៍ ដែលបានប្រព្រឹត្តនៅប្រទេសកម្ពុជាចន្លោះឆ្នាំ ១៩៧៥-៧៩"[២៤៦]។ បទប្បញ្ញត្តិទាំងនេះ តាមផ្លូវច្បាប់ មិនមានអានុភាពចងកាតព្វកិច្ចលើប្រទេសកម្ពុជាឡើយ ដោយហេតុថា "មិនមានច្បាប់ព្រហ្មទណ្ឌសារធាតុនៅថ្នាក់ជាតិ ដែលបានចែងជាបទល្មើសព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋនៅពេលដែលអំពើនោះត្រូវបានប្រព្រឹត្តឡើយ"[២៤៧]។ អៀង ធីរិទ្ធ តាមរយៈការចង្អុលយោង បានលើកទឡ្ហីករណ៍ដូចគ្នាចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[២៤៨]។

២. ការពិភាក្សា

១០៨. ប្រទេសកម្ពុជាបានចូលជាភាគីនៃអនុសញ្ញាប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨ នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៥០[២៤៩] និងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ នៅថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ១៩៥៨[២៥០]។ វាបញ្ជាក់ដោយគ្មានការជំទាស់ឡើយថា អំពើប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញា

---

[២៤៥] បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ៣៧។ សូមមើលផងដែរ បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ១៣។

[២៤៦] បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ៣៦។

[២៤៧] បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ៣៧។

[២៤៨] បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ៦៦។

[២៤៩] កម្រងសន្ធិសញ្ញាអង្គការសហប្រជាជាតិ មូលដ្ឋានទិន្នន័យ MTDSG "ឋានៈនៃសន្ធិសញ្ញា"។

[២៥០] ដីកាដែលរងការជំទាស់ កថាខណ្ឌ ១៣១៦។

អង្គជំនុំជម្រះបុរេជំនុំ * PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C.

00686526

ទីក្រុងហ្សឺណែវ បានក្លាយទៅជាផ្នែកមួយនៃច្បាប់អន្តរជាតិ ដែលអាចយកមកអនុវត្តបាននៅក្នុងប្រទេសកម្ពុជា នៅពេលបទល្មើសដែលបានចោទប្រកាន់ទាំងនេះ បានកើតឡើង។ ប៉ុន្តែ ដើមបណ្តឹងឧទ្ធរណ៍ផ្តល់ទឡ្ហីករណ៍ថា ការមិនបានយកមកអនុវត្តនៅក្នុងច្បាប់ក្នុងស្រុក មានន័យថា ជនជាប់ចោទនីមួយៗ មិនអាចប្រមើលមើលឃើញនូវលក្ខណៈព្រហ្មទណ្ឌនៃបទល្មើសដូចបានចោទប្រកាន់ទាំងនេះ ឬ មិនអាចដឹងថាមានច្បាប់ចែងអំពីបទល្មើសទាំងនេះឡើយ[២៥១]។

១០៩. ចំពោះលក្ខខណ្ឌនៃការដឹងថាមានច្បាប់ចែង អង្គបុរេជំនុំជម្រះរំឭកឡើងវិញថា ការគ្រាន់តែមិនបានដឹងថា អំពើមួយជាអំពើព្រហ្មទណ្ឌ មិនគ្រប់គ្រាន់សម្រាប់យកមកការពារចុងចោទបានឡើយ អនុលោមតាមគោលការណ៍*គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង*។ ដូចសំអាងហេតុទាំងឡាយបានលើកឡើងខាងក្រោមនេះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា សូម្បីនៅក្នុងឆ្នាំ ១៩៧៥ ដើមបណ្តឹងឧទ្ធរណ៍អាចដឹងថា អំពើដូចបានចោទប្រកាន់ អនុលោមតាមអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ III និង IV[២៥២] ជាអំពើព្រហ្មទណ្ឌ ដោយហេតុថាមានសន្ធិសញ្ញាទាំងឡាយ ដែលប្រទេសកម្ពុជាចូលជាភាគី លក្ខណៈនៃច្បាប់ទំនៀមទម្លាប់ដែលមានតាំងពីមុនរួចមកហើយ ដែលបានយកមកដាក់បញ្ចូលនៅក្នុងសន្ធិសញ្ញាទាំងនោះ និងលក្ខណៈនៃសិទ្ធិនីមួយៗ ដែលត្រូវបានគេចោទប្រកាន់ថាបានរំលោភបំពាន។

១១០. អង្គបុរេជំនុំជម្រះពិចារណាឃើញថា ទឡ្ហីករណ៍របស់ដើមបណ្តឹងឧទ្ធរណ៍ច្រានចោលការពិតដែលថា ទោះបីជាដើមបណ្តឹងឧទ្ធរណ៍មិនអាចដឹងថា លក្ខណៈព្រហ្មទណ្ឌនៃអំពើដែលបានចោទប្រកាន់ មានចែងនៅក្នុងច្បាប់ក្នុងស្រុករបស់ខ្លួនក៏ដោយ សូម្បីនៅក្នុងឆ្នាំ ១៩៧៥ ក៏ដើមបណ្តឹងឧទ្ធរណ៍អាចដឹងអំពីករណីនេះ តាមរយៈស្មារតីនៃសន្ធិសញ្ញាទាំងឡាយ ដែលប្រទេសកម្ពុជាបានចុះហត្ថលេខា[២៥៣]។ ដើមបណ្តឹងឧទ្ធរណ៍មិនបានផ្តល់ហេតុផលគួរឱ្យជឿជាក់ដល់អង្គបុរេជំនុំជម្រះ ឬ មិនបានផ្តល់ហេតុ

---

[២៥១] បណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌ ១៣។ បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ៣៥-៣៧, ៦៦។

[២៥២] ដោយហេតុថា ដើមបណ្តឹងឧទ្ធរណ៍ត្រូវបានចោទប្រកាន់ចំពោះការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវទី III និងទីIV ប៉ុណ្ណោះ អង្គបុរេជំនុំជម្រះនឹងកម្រិតការវិភាគរបស់ខ្លួនលើសន្ធិសញ្ញាទាំងនេះ ចំពោះអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩។

[២៥៣] សូមមើល EctHR, *C.R ទល់នឹង ចក្រភពអង់គ្លេស* បណ្តឹងលេខ ២០១៩០/៩២ "សាលក្រម" ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៥ កថាខណ្ឌ ៣៣។

ផលទាល់តែសោះថា ហេតុអ្វីបានជាត្រូវធ្វើការបែងចែករវាងច្បាប់ជាតិ និងច្បាប់ដែលផ្អែកមូលដ្ឋានលើសន្ធិសញ្ញា ចំពោះការលើកឡើងអំពីលក្ខខណ្ឌនៃការដឹងថាមានច្បាប់ចែង។

១១១.ទោះបីជាបទប្បញ្ញត្តិជាក់លាក់នៃសន្ធិសញ្ញាទាំងនេះអាចលើកឡើងថា យោងតាមអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាទីក្រុងហ្សឺណែវ ការហាមឃាត់ទាំងនេះអនុវត្តចំពោះរដ្ឋ ជាជាងចំពោះបុគ្គលនីមួយៗក៏ដោយ ក៏អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ចែងយ៉ាងច្បាស់ថា "ជនទាំងឡាយណាដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬ អំពើណាមួយដទៃទៀត ដូចបានរៀបរាប់នៅក្នុងមាត្រា III ត្រូវទទួលទោស មិនថាជនទាំងនោះ តាមរដ្ឋធម្មនុញ្ញ ជាមេដឹកនាំដែលមានការទទួលខុសត្រូវ មន្ត្រីសាធារណៈ ឬ បុគ្គលឯកជនឡើយ"[២៥៤]។ ទាំងអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍[២៥៥] ទាំងអនុសញ្ញាទីក្រុងហ្សឺណែវ[២៥៦] រួមមានកាតព្វកិច្ចជាក់លាក់ចំពោះរដ្ឋ ក្នុងការចោទប្រកាន់ចារីនៃអំពើទាំងឡាយ ដែលត្រូវបានហាមឃាត់នៅក្នុងនោះ។ ទោះបីជាសន្ធិសញ្ញាមិនត្រូវបានអនុវត្តនៅក្នុងច្បាប់កម្ពុជាក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ក៏ដោយ ក៏សន្ធិសញ្ញានេះត្រូវគោរពតាមគោលការណ៍*គោរពកិច្ចព្រមព្រៀង*[២៥៧]។ ដូច *មេធាវីគ្មានព្រំដែន* បានកត់សម្គាល់នៅក្នុងសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី មាត្រា ២៧ នៃអនុសញ្ញាទីក្រុងវីយ៉ែនស្តីពីច្បាប់សន្ធិសញ្ញា ហាមឃាត់ភាគីនៃសន្ធិសញ្ញា មិនឱ្យយកច្បាប់ជាតិមកធ្វើជាយុត្តិកម្ម នៅពេលខ្លួនខកខានមិនបំពេញកាតព្វកិច្ច

---

[២៥៤] អនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ មាត្រា IV។

[២៥៥] មាត្រា I នៃអនុសញ្ញាទីក្រុងហ្សឺណែវ "រដ្ឋចុះកិច្ចសន្យាបញ្ជាក់ថា បទប្រល័យពូជសាសន៍ មិនថាប្រព្រឹត្តនាពេលសន្តិភាព ឬ នៅពេលសង្គ្រាមក៏ដោយ គឺជាបទល្មើស អនុលោមតាមច្បាប់អន្តរជាតិ ដែលរដ្ឋទាំងនេះត្រូវធ្វើការបង្ការ និងដាក់ទណ្ឌកម្ម")។ មាត្រា XV នៃអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ ("រដ្ឋចុះកិច្ចសន្យាត្រូវអនុម័តឱ្យស្របតាមរដ្ឋធម្មនុញ្ញរបស់ខ្លួន នូវច្បាប់ចាំបាច់ ដែលផ្តល់អានុភាពលើបទប្បញ្ញត្តិនៃអនុសញ្ញាបច្ចុប្បន្ន ហើយជាពិសេស ត្រូវដាក់ទណ្ឌកម្មឱ្យបានស័ក្តិសមលើពិរុទ្ធជននៃបទប្រល័យពូជសាសន៍ ឬ លើរាល់អំពើទាំងឡាយ ដែលបានរៀបរាប់នៅ) ក្នុងមាត្រា ៣"។)

[២៥៦] *អនុសញ្ញាស្តីពីការប្រព្រឹត្តលើឈ្លើយសឹកសង្គ្រាម* ៧៥ U.N.T.S ១៣៥ (បើកឱ្យចុះហត្ថលេខានៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ បានចូលជាធរមាននៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០) ("អនុសញ្ញាទីក្រុងហ្សឺណែវទី III") មាត្រា ១២៩។ អនុសញ្ញាទីក្រុងហ្សឺណែវទី IV មាត្រា ១៤៦ (អនុសញ្ញាទាំងពីរបានលើកឡើងនៅក្នុងផ្នែកដែលពាក់ព័ន្ធថា "រដ្ឋចុះហត្ថលេខានីមួយៗត្រូវមានកាតព្វកិច្ចស្រាវជ្រាវរកជនទាំងឡាយដែលរងការចោទប្រកាន់ថាបានប្រព្រឹត្ត ឬ បានបញ្ជាឱ្យប្រព្រឹត្ត ការរំលោភបំពានធ្ងន់ធ្ងរ ហើយត្រូវនាំជនទាំងនោះមកចំពោះមុខតុលាការរបស់ខ្លួន ដោយមិនគិតពីសញ្ជាតិរបស់ជនទាំងនោះឡើយ។ ប្រសិនបើខ្លួនចង់នោះ រដ្ឋទាំងនេះអាច ដោយស្របតាមបទប្បញ្ញត្តិនៃច្បាប់របស់ខ្លួន បញ្ជូនជនទាំងនេះមកធ្វើការជំនុំជម្រះ នៅរដ្ឋចុះកិច្ចសន្យាមួយទៀត ប្រសិនបើរដ្ឋចុះកិច្ចសន្យានោះបានធ្វើការចោទប្រកាន់*តាមភស្តុតាងជឿជាក់បឋមនោះ*"។

[២៥៧] មាត្រា ២៦ នៃអនុសញ្ញាទីក្រុងវីយ៉ែនស្តីពីច្បាប់សន្ធិសញ្ញា។

របស់ខ្លួន[២៥៨]។ ដូច្នេះ ករណីទាំងនេះបញ្ជាក់យ៉ាងច្បាស់ថា បុគ្គលម្នាក់ៗអាចទទួលខុសត្រូវព្រហ្មទណ្ឌ នៅពេលប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ។

១១២.ក្រៅពីសន្ធិសញ្ញា ប្រភពដទៃៗទៀត បង្ហាញនៅក្នុងឆ្នាំ ១៩៧៥ ថា បុគ្គលនីមួយៗអាចរកឃើញនូវការទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ឬ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ។

១១៣. នៅដើមឆ្នាំ ១៩៤៦ មហាសន្និបាតនៃអង្គការសហប្រជាជាតិបានទទួលស្គាល់អំពើប្រល័យពូជសាសន៍ថាជាបទល្មើសអន្តរជាតិដោយឡែកមួយ[២៥៩]។ នៅក្នុងឆ្នាំ ១៩៥១ តុលាការយុត្តិធម៌អន្តរជាតិ ("ត.យ.អ") បានចេញមតិប្រឹក្សាមួយនៅក្នុង "រឿងក្តីលើខដាក់លក្ខខណ្ឌចំពោះអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍" ដោយក្នុងនោះបានសរសេរថា៖

> ប្រភពនៃអនុសញ្ញាបង្ហាញថា *អង្គការសហប្រជាជាតិមានបំណងថ្កោលទោស និងដាក់ទណ្ឌកម្មលើអំពើប្រល័យពូជសាសន៍ ថាជា "បទល្មើសមួយ អនុលោមតាមច្បាប់អន្តរជាតិ"* ដោយសារអំពើនេះបានបដិសេធសិទ្ធិរស់រានមានជីវិតរបស់ក្រុមមនុស្សទាំងអស់ ពោលគឺការបដិសេធ ដែលធ្វើឱ្យមនសិការរបស់មនុស្សតក់ស្លុត និងបង្កឱ្យមានការខាតបង់ធំធេងលើមនុស្សជាតិ ហើយអំពើនេះផ្ទុយនឹងច្បាប់សីលធម៌ និងស្មារតី និងគោលបំណងរបស់អង្គការសហប្រជាជាតិ។ ផលវិបាកដំបូងដែលកើតចេញពីទស្សនាទាននេះគឺថា គោលការណ៍ទាំងឡាយនៅក្នុងអនុសញ្ញានេះ គឺជាគោលការណ៍ដែលបានទទួលស្គាល់ដោយរដ្ឋស៊ីវិល័យ ថាជាគោលការណ៍ចងកាតព្វកិច្ចលើរដ្ឋទាំងឡាយ ទោះបីជារដ្ឋទាំងនោះមិនមានកាតព្វកិច្ចអនុលោមតាមអនុសញ្ញានេះក៏ដោយ[២៦០]។

១១៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ថាជាង ២០ឆ្នាំ មកហើយ ក្រៅពីអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ សេចក្តីសម្រេចរបស់មហាសន្និបាត និងសេចក្តីសម្រេចរបស់ ត.យ.អ បានដាក់ឱ្យបុគ្គលម្នាក់ៗ

---

[២៥៨] សេចក្តីសង្កេត I របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៥។

[២៥៩] បទប្រល័យពូជសាសន៍ សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ៩៦(I) អនុម័តនៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦។

[២៦០] *មតិប្រឹក្សាពាក់ព័ន្ធនឹងខព្យួរលក្ខខណ្ឌអនុសញ្ញាស្តីពីការបង្ការ និងការដាក់ទណ្ឌកម្មបទប្រល័យពូជសាសន៍* ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៥១ របាយការណ៍របស់ ត.យ.អ ឆ្នាំ ១៩៥១ ទំព័រ ២៣ (អង់គ្លេស) (ការគូសបញ្ជាក់បន្ថែម)។

ដឹងថា អំពើប្រល័យពូជសាសន៍ ដោយមិនគិតពីចន្លោះប្រហោងនៅក្នុងច្បាប់ជាតិរបស់រដ្ឋាភិបាលខ្លួន គឺជាបទល្មើសអន្តរជាតិ ដែលនឹងនាំឱ្យអ្នករំលោភបំពាន ទទួលរងនូវការចោទប្រកាន់ មុនពេលនៃការប្រព្រឹត្តបទល្មើសទាំងឡាយ ដូចបានចោទប្រកាន់នៅក្នុងរឿងក្តីនេះ។

១១៥. ម្យ៉ាងវិញទៀត និយមន័យនៃបទប្រល័យពូជសាសន៍គឺជានិយមន័យសាកល អាចទាយទុកបាន និងគ្មានការប្រែប្រួល ដោយកំណត់ដូចគ្នាបេះបិទនៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍[២៦១] និងច្បាប់ អ.វ.ត.ក[២៦២]។ ការដឹងថាមាននិយមន័យដូច្នេះ គឺបានគូសបញ្ជាក់តាមរយៈបទប្បញ្ញត្តិនៅក្នុងអនុសញ្ញាស្តីពីប្រល័យពូជសាសន៍ នៅក្នុងផ្នែកពីរខុសៗគ្នា ដោយមានការអំពាវនាវឱ្យរដ្ឋដាក់ទណ្ឌកម្មព្រហ្មទណ្ឌលើបុគ្គលទាំងឡាយណា ដែលបានរំលោភបំពានអំពើប្រល័យពូជសាសន៍[២៦៣]។

---

[២៦១] មាត្រា II អនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ចែងថា៖

“នៅក្នុងអនុសញ្ញានេះ អំពើប្រល័យពូជសាសន៍ គឺជាអំពើទាំងឡាយដូចខាងក្រោម ដែលបានប្រព្រឹត្តឡើង ក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយដូចជា៖

ក. ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម

ខ. ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬ សតិបញ្ញាសមាជិកនៃក្រុម

គ. ការធ្វើដោយចេតនាឱ្យក្រុមនេះ ទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើង សម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬ មួយផ្នែក

ឃ. ការដាក់វិធានការនានា ដែលមានបំណងរារាំងមិនឱ្យមានការផ្តល់កំណើតទារក

ង. ការបញ្ជូនកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយផ្សេងទៀត

មាត្រា III ចែងថា “អំពើដូចខាងក្រោមនេះត្រូវទទួលទោស៖

(ក) អំពើប្រល័យពូជសាសន៍

(ខ) ការឃុបឃិតប្រព្រឹត្តបទប្រល័យពូជសាសន៍

(គ) ការញុះញង់ដោយផ្ទាល់ និងជាសាធារណៈឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍

(ឃ) ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍

(ង) ការសមគំនិតនៅក្នុងអំពើប្រល័យពូជសាសន៍”

[២៦២] មាត្រា ៤ នៃច្បាប់ អ.វ.ត.ក។ ករណីនេះដូចគ្នានឹងលក្ខន្តិកៈរបស់តុលាការ ICTY (មាត្រា ៤) និងលក្ខន្តិកៈរបស់តុលាការ ICTR (មាត្រា ២)។

[២៦៣] មាត្រា ១ និងមាត្រា ១៥ នៃអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ ដកស្រង់នៅចំណុចខាងលើ។

១១៦. ដូចគ្នានេះដែរ នៅត្រឹមឆ្នាំ ១៩៧៥ ដើមបណ្ដឹងឧទ្ធរណ៍បានដឹងថាមាននិយមន័យនេះតាមរយៈបទប្បញ្ញត្តិនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ហើយបទប្បញ្ញត្តិនេះបញ្ជាក់ច្បាស់ថា ការរំលោភបំពានលើបទប្បញ្ញតិនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរ នឹងនាំឱ្យមានការចោទប្រកាន់ព្រហ្មទណ្ឌ។ អនុសញ្ញាទីក្រុងហ្សឺណែវរួមមានបទប្បញ្ញត្តិមួយ ដែលរៀបរាប់ថាអំពើណាខ្លះជា "ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ" នៃអនុសញ្ញាទីក្រុងហ្សឺណែវ[២៦៤] និងបទប្បញ្ញត្តិមួយទៀត ដែលចែងយ៉ាងច្បាស់ថាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញា ផ្ដល់យុត្តាធិការព្រហ្មទណ្ឌចាំបាច់ និងជាសាកល ក្នុងចំណោមរដ្ឋចុះសន្ធិសញ្ញា[២៦៥]។ ហេតុដូច្នេះ ទោះបីជារដ្ឋាភិបាលកម្ពុជាមិនធ្វើការដាក់ទណ្ឌកម្មលើដើមបណ្ដឹងឧទ្ធរណ៍ក៏ដោយ គេតែងតែងអាចប្រមើលមើលឃើញ ឬ រដ្ឋហត្ថលេខីណាមួយផ្សេងទៀតតែងតែអាចធ្វើបណ្ដឹងអាជ្ញាចំពោះចុងចោទ ដែលបានរំលោភបំពានលើបទប្បញ្ញត្តិនៃការបំពារ

---

[២៦៤] អនុសញ្ញាទីក្រុងហ្សឺណែវទី III មាត្រា ១៣០ ("អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលពាក់-ព័ន្ធនឹងមាត្រាមុននេះ គឺជាអំពើទាំងឡាយដែលពាក់ព័ន្ធនឹងអំពើដូចតទៅ ដូចជា អំពើប្រឆាំងមនុស្ស ឬ ទ្រព្យសម្បត្តិ ដែលត្រូវការការពារដោយបទប្បញ្ញត្តិនៃអនុសញ្ញានេះ៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬ ការធ្វើបាបដោយអមនុស្សធម៌ រួមទាំងការពិសោធន៍ជីវសាស្ត្រ, ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬ ឱ្យមានការឈឺចាប់ដល់រាងកាយ ឬ សុខភាព ការបង្ខំឱ្យឈ្លើយសឹកបម្រើការនៅក្នុងកងកម្លាំងរបស់គូបដិបក្ខ ឬ ការដកហូតដោយចេតនាពីឈ្លើយសឹកនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ដូចមានចែងនៅក្នុងអនុសញ្ញានេះ។ អនុសញ្ញាទីក្រុងហ្សឺណែវទី IV មាត្រា ១៤៧ ("អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលពាក់ព័ន្ធនឹងមាត្រាមុននេះ គឺជាអំពើទាំងឡាយដែលពាក់ព័ន្ធនឹងអំពើដូចតទៅ ដូចជា អំពើប្រឆាំងមនុស្ស ឬ ទ្រព្យសម្បត្តិ ដែលត្រូវការការពារដោយបទប្បញ្ញត្តិនៃអនុសញ្ញានេះ៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬ ការធ្វើបាបដោយអមនុស្សធម៌ រួមទាំងការពិសោធន៍ជីវសាស្ត្រ, ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬ ឱ្យមានការឈឺចាប់ដល់រាងកាយ ឬ សុខភាព ការជម្លៀស ឬ ការបញ្ជូនដោយខុសច្បាប់ ឬ ការឃុំឃាំងដោយខុសច្បាប់លើជនដែលទទួលបានការការពារ កាចាប់បង្ខំជនដែលទទួលបានការការពារឱ្យបម្រើក្នុងកងកម្លាំងរបស់គូបដិបក្ខ ឬ ការដកហូតដោយចេតនាពីជនដែលទទួលបានការការពារនូវសិទ្ធិទទួលបានការកាត់ទោសដោយ យុត្តិធម៌ និងទៀងទាត់ ដូចមានចែងនៅក្នុងអនុសញ្ញានេះ ការចាប់ជាចំណាប់ខ្មាំង និងការបំផ្លិចបំផ្លាញធំធេង និងការរឹបអូសទ្រព្យសម្បត្តិដែលមិនមានភាពត្រឹមត្រូវចាំបាច់ផ្នែកយោធា ហើយបានប្រព្រឹត្តឡើងដោយខុសច្បាប់ និងគ្មានត្រាប្រណី")។

[២៦៥] អនុសញ្ញាទីក្រុងហ្សឺណែវទី III មាត្រា ១២៩។ អនុសញ្ញាទីក្រុងហ្សឺណែវទី IV មាត្រា ១៤៦ (អនុសញ្ញាទាំងពីរបានលើកឡើងនៅក្នុងផ្នែកដែលពាក់ព័ន្ធថា "រដ្ឋចុះកិច្ចសន្យា ត្រូវអនុម័តច្បាប់ចាំបាច់ដើម្បីដាក់ទោសព្រហ្មទណ្ឌឱ្យស័ក្តិសមចំពោះជនដែលបានប្រព្រឹត្ត ឬបញ្ជាឱ្យប្រព្រឹត្ត អំពើបំពារបំពារណាមួយក្នុងចំណោមអំពើបំពារបំពានដូចមានចែងនៅមាត្រាក្រោយនេះ ក្នុងអនុសញ្ញានេះ។ រដ្ឋចុះកិច្ចសន្យា ត្រូវមានកាតព្វកិច្ចស្រាវជ្រាវរកជនទាំងឡាយដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ឬបានបញ្ជាឱ្យប្រព្រឹត្ត ការរំលោភបំពានធ្ងន់ធ្ងរ ហើយត្រូវនាំជនទាំងនោះមកចំពោះមុខតុលាការរបស់ខ្លួន ដោយមិនគិតពីសញ្ជាតិរបស់ជនទាំងនោះឡើយ។ ប្រសិនបើខ្លួនចង់នោះ រដ្ឋទាំងនេះអាច ដោយស្របតាមបទប្បញ្ញត្តិនៃច្បាប់របស់ខ្លួន បញ្ជូនជនទាំងនេះមកធ្វើការជំនុំជម្រះ នៅរដ្ឋចុះកិច្ចសន្យាមួយទៀត ប្រសិនបើរដ្ឋចុះកិច្ចសន្យានោះបានធ្វើការចោទប្រកាន់*តាមភស្តុតាងជឿជាក់បឋមនោះ*"។

00686531

បំពានយ៉ាងធ្ងន់ធ្ងរ ដូចដែលបានចោទប្រកាន់។ អង្គបុរេជំនុំជម្រះសូមរំឭកផងដែរថា បទប្បញ្ញត្តិនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរហាមឃាត់យ៉ាងជាក់លាក់ និងកំណត់បទល្មើសទាំងឡាយ ដូចបានរៀបរាប់នៅក្នុងមាត្រា ៦ នៃច្បាប់ អ.វ.ត.ក និងដីកាដែលរងការជំទាស់ថា ជាបទល្មើសព្រហ្មទណ្ឌ[២៦៦]។ ជាការពិត យើងគួរកត់សម្គាល់នៅក្នុងករណីនេះថា នួន ជា និង អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ចំពោះការរំលោភបំពានលើបទប្បញ្ញត្តិនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរ មិនមែនលើបទប្បញ្ញត្តិដទៃៗទៀត នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវឡើយ[២៦៧]។

១១៧. បន្ថែមពីនេះ អនុសញ្ញាទីក្រុងហ្សឺណែវ មិនគ្រាន់តែបង្ហាញនូវការវិវឌ្ឍន៍មួយនៅក្នុងនីតិអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានចងក្រងបញ្ញត្តិនូវច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលកើតមានតាំងពីមុនមកម្ល៉េះ[២៦៨]។ ដូចអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់នាពេលមុនរួចហើយថា បទល្មើសទាំងឡាយដូចបានរៀបរាប់នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវបានចោទប្រកាន់នៅតុលាការ Nuremburg តាំងពីមុនពេលអនុសញ្ញាទាំងនេះមានអត្ថិភាពម្ល៉េះ[២៦៩]។ ចំពោះអំពើទាំងឡាយដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ វាមិនមានការរារាំងមិនឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលឡើយ ទោះបីជាមិនមានបទប្បញ្ញត្តិនៅក្នុងសន្ធិសញ្ញាចែងអំពីទណ្ឌកម្មលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរក៏ដោយ[២៧០]។ ពាក់ព័ន្ធនឹងបទប្រល័យពូជសាសន៍វិញ លក្ខណៈដ៏ភ័យរន្ធត់នៃបទល្មើសទាំងនេះ ដែលបង្កើតជាការបំពារបពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវនោះ ជួយដល់ការបង្ហាញថា ទង្វើដូចបានចោទប្រកាន់ទាំងនេះ *មានលក្ខណៈព្រហ្មទណ្ឌដោយឯកឯង* ពោលគឺមាន

---

[២៦៦] អនុសញ្ញាទីក្រុងហ្សឺណែវទី III មាត្រា ១៣០។ អនុសញ្ញាទីក្រុងហ្សឺណែវទី IV មាត្រា ១៤៧ ដកស្រង់នៅក្នុងចំណុចខាងលើ។

[២៦៧] ដីកាដែលរងការជំទាស់ កថាខណ្ឌ ១៣១៦-១៧។

[២៦៨] ឧទាហរណ៍ *សកម្មភាពយោធា និងយោធាប្រតិព័ទ្ធនៅក្នុង និងប្រឆាំងប្រទេសនីហ្គារ៉ាក័រ (នីហ្គារ៉ាក័រ ទល់នឹង សហរដ្ឋអាមេរិក* "សាលក្រមលើអង្គសេចក្តី" ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៨៦ របាយការណ៍ ត.យ.អ ឆ្នាំ ១៩៨៦ ទំព័រ ១១៤ (អង់គ្លេស) ត្រង់កថាខណ្ឌ ២១៨ ("អនុសញ្ញាទីក្រុងហ្សឺណែវ នៅក្នុងទិដ្ឋភាពមួយ គឺជាការវិវឌ្ឍន៍មួយ ហើយនៅក្នុងទិដ្ឋភាពផ្សេងមួយទៀត គឺជា គ្មានអ្វីក្រៅពីការបញ្ជាក់នូវ" គោលការណ៍មូលដ្ឋាននៃច្បាប់មនុស្សធម៌អន្តរជាតិតែប៉ុណ្ណោះ។ *រដ្ឋអាជ្ញាទល់នឹង Delacic* និង ជនដទៃទៀត IT ៩៦-២១-A "សាលដីកា" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌទី ១១២ - ១៣ (បានទទួលស្គាល់នូវលក្ខណៈទំនៀមទម្លាប់នៃអនុសញ្ញាទីក្រុងហ្សឺណែវ)។

[២៦៩] សាលក្រម *ឌុច* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤០៥។

[២៧០] *សូមមើល ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗនៅចំពោះមុខសាលាក្តីយោធាអន្តរជាតិ៖ Nuremburg* ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៤៦- ថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៤៦ (១៩៤៨) Vol. ២២ ទំព័រ ៤៦៣-៦៤ (អង់គ្លេស)។

លក្ខណៈដ៏អាក្រក់ជាប់មកជាមួយ ដែលពុំអាចឱ្យយកមកបដិសេធចំពោះការអះអាងណាមួយថា ចារីនៃបទល្មើសទាំងនេះ មិនបានដឹងអំពីលក្ខណៈព្រហ្មទណ្ឌនៃទង្វើទាំងនេះឡើយ[២៧១]។

១១៨. ម្យ៉ាងវិញទៀត លក្ខណៈ*អាជ្ញាបញ្ញា*នៃបទល្មើសប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ គឺគ្រប់គ្រាន់នៅក្នុងការផ្តល់យុត្តិកម្មលើការចោទប្រកាន់ ដោយពុំចាំបាច់ពិចារណាថាមានបទប្បញ្ញត្តិជាក់លាក់ ចែងនៅក្នុងច្បាប់ជាតិកម្ពុជាឡើយ[២៧២]។ ចំពោះបទល្មើសទាំងឡាយ ដែលត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ អនុលោមតាមអំពើប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរនៅក្នុងដីកាដំណោះស្រាយ បទល្មើសទាំងនេះ តាមលក្ខណៈរបស់វា បណ្តាលឱ្យមានការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្សជាមូលដ្ឋានរបស់ជនរងគ្រោះនៃបទល្មើសទាំងនេះ ដូចជា សិទ្ធិរស់រានមានជីវិត សេរីភាពរួច

[២៧១] សូមមើល *រដ្ឋអាជ្ញា ទល់នឹង Milutinovic និងជនដទៃទៀត* IT-៩៩-៣៧-AR៧២ "សាលដីកាលើបណ្តឹងរបស់ Dragoljub Ojdanic ដែលប្តឹងតវ៉ាយុត្តាធិការ - សហឧក្រិដ្ឋកម្មរួម") អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៤២)។

[២៧២] សូមមើលឧទាហរណ៍ *នីត្យានុកូលភាពនៃការគំរាមកំហែង ឬ ការប្រើប្រាស់អាវុធនុយក្លេអ៊ែរ* មតិប្រឹក្សា ចុះថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៩៩៦ (១៩៩៦) របាយការណ៍ ត.យ.អ ឆ្នាំ ១៩៩៦ ទំព័រ ២២៦ (អង់គ្លេស) ត្រង់កថាខណ្ឌ ៧៩ (បានសម្រេចថា អនុសញ្ញាទីក្រុងហ្សឺណែវ "ត្រូវគោរពដោយរដ្ឋគ្រប់ទាំងអស់ មិនថារដ្ឋទាំងនោះបានផ្តល់ ឬ មិនផ្តល់សច្ចាប័នឡើយ [...] ពីព្រោះអនុសញ្ញាទាំងនេះគឺជាគោលការណ៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលគ្មាននរណាអាចរំលោភបំពានបាន")។ *មតិប្រឹក្សាលើខព្វរលក្ខខណ្ឌនៃអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍* របាយការណ៍ ត.យ.អ ឆ្នាំ ១៩៥១ ទំព័រទី ១៥ ត្រង់ទំព័រ ២៣ (អង់គ្លេស) (ផ្តល់មតិប្រឹក្សាថា បទប្បញ្ញត្តិនៃអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍គួរត្រូវគេយល់ឃើញថាជាការចងកាតព្វកិច្ចដល់ [រដ្ឋដទៃៗទៀត] ទោះបីរដ្ឋទាំងនោះមិនបានបង្ហាញនូវការទទួលស្គាល់ដោយជាក់លាក់លើអនុសញ្ញាទាំងនេះក៏ដោយ ពោលគឺអនុសញ្ញាទាំងនេះ បង្កើតជាប្រភេទនៃទំនៀមទម្លាប់ដែលចងកាតព្វកិច្ច ឬ គឺជាគោលការណ៍ ដែលរដ្ឋទាំងអស់ត្រូវគោរពតាមដោយហេតុថាខ្លួនមានការពឹងផ្អែកគ្នាទៅវិញទៅមក និងដោយហេតុមានអត្ថិភាពនៃអង្គការអន្តរជាតិ)។ សូមមើលផងដែរនូវ *រដ្ឋអាជ្ញា ទល់នឹង Furundzija* IT-៩៥-១៧/១-T "សាលក្រម" ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៩៨ កថាខណ្ឌ ១៥៦ (អង្គជំនុំជម្រះតុលាការកំពូលរបស់ ICTY បានអះអាងពាក់ព័ន្ធនឹងការធ្វើទារុណកម្មថា លក្ខណៈអាជ្ញាបញ្ញានៃបទល្មើសនេះ បង្ហាញនូវផលវិបាកថា "រដ្ឋនីមួយៗមានសិទ្ធិធ្វើការស៊ើបអង្កេតចោទប្រកាន់ និងដាក់ទណ្ឌកម្ម ឬ ធ្វើបត្យាប័នជនទាំងឡាយដែលត្រូវបានចោទប្រកាន់" អំពីបទល្មើសទាំងនេះ។ អង្គជំនុំជម្រះតុលាការកំពូលបានយោងលើសេចក្តីថ្លែងការណ៍ជាទូទៅរបស់តុលាការកំពូលរបស់ប្រទេសអ៊ីស្រាអែលនៅក្នុងរឿងក្តី Eichmann ថា "វាគឺជាលក្ខណៈសាកលនៃបទល្មើសដែលបានតវ៉ាទាំងនេះ [ពោលគឺបទល្មើសអន្តរជាតិ] ដែលបានផ្តល់ឱ្យរដ្ឋទាំងឡាយ នូវអំណាចជំនុំជម្រះ និងដាក់ទណ្ឌកម្មជនទាំងឡាយ ដែលបានចូលរួមនៅក្នុងការប្រព្រឹត្ត (*អគ្គរដ្ឋអាជ្ញានៃរដ្ឋាភិបាលអ៊ីស្រាអែល ទល់នឹង Eichmann* តុលាការកំពូលរបស់ប្រទេសអ៊ីស្រាអែល ៣៦ I.L.R ២៨ (ឆ្នាំ ១៩៦២) ("រឿងក្តី *Eichmann*") ត្រង់ទំព័រ ២៩៨) (អង់គ្លេស)។

ផុតពីទារុណកម្ម ការប្រព្រឹត្ត ឬ ការដាក់ទណ្ឌកម្មសាហាវ អមនុស្សធម៌ និងមិនមានសេចក្តីថ្លៃថ្នូរ សិទ្ធិទទួលបានសេរីភាព និងសន្តិសុខ និងសិទ្ធិទទួលបានការប្រព្រឹត្តដោយមនុស្សធម៌។ ចំពោះសេចក្តីថ្លៃថ្នូរជាប់មកជាមួយសម្រាប់មនុស្សជាតិ នៅពេលមានការដកហូតសេរីភាព និងការទទួលការជំនុំជម្រះដោយយុត្តិធម៌ វាជំរុញឲ្យរដ្ឋមានកាតព្វកិច្ចធ្វើការចោទប្រកាន់ឲ្យមានប្រសិទ្ធភាពសម្រាប់ជនរងគ្រោះឲ្យស្របទៅតាមមាត្រា ២(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាបានចុះហត្ថលេខានៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៨០ និងផ្តល់សច្ចាប័ននៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩២។

១១៩. ចាប់តាំងពីពេលដែលអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨ និងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ អំពាវនាវឲ្យមានការចោទប្រកាន់ចំពោះបុគ្គលទាំងឡាយ ដែលបានរំលោភលើអំណាចរបស់ខ្លួន បទល្មើសទាំងឡាយដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយត្រូវបានកំណត់យ៉ាងច្បាស់លាស់ នៅក្នុងលក្ខណៈមួយគ្រប់គ្រាន់ឲ្យដើមបណ្តឹងឧទ្ធរណ៍បានដឹង នៅក្នុងពេលដែលបទល្មើសទាំងឡាយដូចបានចោទប្រកាន់នេះ បានកើតឡើង[២៧៣]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌដឹងថាមានច្បាប់ចែង អនុលោមតាមគោលការណ៍នីត្យានុកូលភាពអន្តរជាតិ ត្រូវបានបំពេញចំពោះការរំលោភលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និង អនុសញ្ញាទីក្រុងហ្សឺណែវ ដូចបានចោទប្រកាន់។

១២០. គោលការណ៍នីត្យានុកូលភាពអន្តរជាតិ មិនត្រឹមតែទាមទារនូវលក្ខខណ្ឌឲ្យចុងចោទដឹងអំពីប្រភពនៃច្បាប់ ដែលបានកំណត់ទង្វើដូចដែលបានចោទប្រកាន់ថាជាបទល្មើសព្រហ្មទណ្ឌឡើយ វាក៏ទាមទារឲ្យចុងចោទអាចប្រមើលមើលឃើញនូវផលវិបាកផ្នែកព្រហ្មទណ្ឌនានា ដែលអាចកើតចេញពីទង្វើទាំង

---

[២៧៣] សូមមើល ECtHR *Kokkinakis ទល់នឹង ប្រទេសក្រិច* បណ្តឹងលេខ ១៤៣០៧/៨៨ "សាលក្រម" ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៥២ ("បទល្មើសណាក៏ដោយត្រូវតែកំណត់ឲ្យបានច្បាស់នៅក្នុងច្បាប់។ លក្ខខណ្ឌនេះបានបំពេញ ក្នុងករណីបុគ្គលអាចដឹងតាមរយៈពាក្យពេចន៍នៃបទប្បញ្ញត្តិដែលពាក់ព័ន្ធ" ដែលចែងថា ទង្វើដូចបានចោទប្រកាន់ គឺខុសច្បាប់ អនុលោមតាមច្បាប់ព្រហ្មទណ្ឌ)។

E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER PRÉLIMINAIRE

ឡាយដូចបានចោទប្រកាន់នេះផងដែរ[២៧៤]។ ដោយមានសំអាងហេតុដូចនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ផ្នែកទី ២ នៃគោលការណ៍នីត្យានុកូលភាពអន្តរជាតិ ត្រូវបានបំពេញនៅក្នុងរឿងក្ដីនេះ។

១២១. ដូចបានពន្យល់ខាងលើរួចហើយ សន្ធិសញ្ញា និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ អាចឲ្យគេប្រមើលមើលឃើញថា ចារីនៃអំពើប្រល័យពូជសាសន៍ ឬ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ អាចត្រូវបានចោទប្រកាន់ និងទទួលទណ្ឌកម្ម។ ជាការពិតណាស់ ក្រោយពីការជំនុំជម្រះនៅតូក្យូ និង Nuremburg មក បុគ្គលម្នាក់ៗអាចប្រមើលមើលឃើញថា ការរំលោភបំពានផ្នែកព្រហ្មទណ្ឌលើច្បាប់អន្តរជាតិ អាចឲ្យខ្លួនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ ចំពោះ "កម្រិតនៃទោស" វិញ អង្គបុរេជំនុំជម្រះសង្កេតឃើញថា គោលការណ៍នីត្យានុកូលភាព ដូចបានចែងនៅក្នុងមាត្រា ១៥(១)នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតម្រូវថា ជនណាក៏ដោយមិនត្រូវទទួល "ទោសធ្ងន់ជាង [...] ទោសដែលមានជាធរមាននៅពេលបទល្មើសព្រហ្មទណ្ឌនេះបានប្រព្រឹត្តឡើងឡើយ"។ បទប្បញ្ញត្តិស្រដៀងគ្នាមួយ មានចែងនៅក្នុងពិធីសារបន្ថែមទី I និងទី II នៃអនុសញ្ញាទីក្រុងហ្សឺណែវ[២៧៥]។ ដូច្នេះ ដរាបណាទោសដែលបានកំណត់ស្ថិតនៅក្នុងកម្រិតអតិបរមា ដែលមាននៅក្នុងច្បាប់ជាធរមាននៅពេលបទល្មើសកើតឡើង វាមិនមែនជាការរំលោភលើគោលការណ៍*មិនមានទោស ប្រសិនបើមិនមានច្បាប់ចែង* ដូចមានចែងនៅក្នុងមាត្រា ១៥(១)នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឡើយ។

១២២. អង្គបុរេជំនុំជម្រះសង្កេតឃើញថា អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាទីក្រុងហ្សឺណែវ មិនបានចែងអំពីទោស ទោះបីជាអនុសញ្ញាទាំងពីរទាមទារឲ្យភាគីចុះកិច្ចសន្យាអនុម័ត

---

[២៧៤] សូមមើល EctHR, *G ទល់នឹង ប្រទេសបារាំង* បណ្ដឹងលេខ ១៥៣១២/៨៩ "សាលក្រម" ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ កថាខណ្ឌ ២៤-២៥។

[២៧៥] ពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងដែលពាក់ព័ន្ធនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ *(ពិធីសារទី I) ១១២៥* U.N.T.S ៣ (អនុម័តនៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៧ ចូលជាធរមាននៅថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ១៩៧៨ ("ពិធីសារបន្ថែមទី I") មាត្រា ៧៥(៤)(គ) ផ្ដល់សច្ចាប័នដោយប្រទេសកម្ពុជានៅក្នុងឆ្នាំ ១៩៩៣។ ពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងដែលពាក់ព័ន្ធនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធមិនមែនជាលក្ខណៈអន្តរជាតិ *(ពិធីសារទី II) ១១២៥* U.N.T.S ៦០៩ (អនុម័តនៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៧ ចូលជាធរមាននៅថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ១៩៧៨ ("ពិធីសារបន្ថែមទី II") មាត្រា ៦(២)(គ)។

ច្បាប់ចាំបាច់ "ដើម្បីចែងអំពីទោសឲ្យមានប្រសិទ្ធភាពក៏ដោយ"[២៧៦]។ ទោះបីជាយ៉ាងនេះក្ដី ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានបញ្ជាក់យ៉ាងច្បាស់ នៅក្រោយផលវិបាកនៃសង្គ្រាមលោកលើកទី II ហើយសូម្បីមុនរយៈពេលនេះ អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាទីក្រុងហ្សឺណែវស្ដីពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរ អាចនាំឲ្យមានការដាក់ទោសធ្ងន់ធ្ងរជាងនេះ គឺរហូតដល់មានការបញ្ចូលនូវទោសប្រហារជីវិតទៅទៀត។ ចំណុចគួរកត់សម្គាល់នោះគឺ សាលាក្ដីយោធាអន្តរជាតិ ដែលគេស្គាល់ទូទៅនោះ មានអំណាចដាក់ទោសព្រហ្មទណ្ឌបានដែលសាលាក្ដីនេះ "បានកំណត់ថាជាយុត្តិធម៌" ចំពោះជនជាតិអាល្លឺម៉ង់ ដែលបានប្រព្រឹត្តបទល្មើស អនុលោមតាមច្បាប់អន្តរជាតិ[២៧៧]។ ជាការពិតណាស់ ចុងចោទចំនួន ១២ នាក់ ត្រូវបានកាត់ទោសប្រហារជីវិតដោយសាលាក្ដីយោធាអន្តរជាតិនេះ ហើយ ៧ នាក់ ទៀត ត្រូវបានជាប់ទោសពី ១០ ឆ្នាំ រហូតអស់មួយជីវិត[២៧៨]។ ទោសធ្ងន់ជាងនេះត្រូវបានសាលាក្ដី IMTFE នៅទីក្រុងតូក្យូ ធ្វើការប្រកាសឡើង[២៧៩]។ មកត្រឹមឆ្នាំ ១៩៥០ គោលការណ៍ Nuremburg ជាពិសេស គោលការណ៍ទី II ត្រូវបានបង្កើតឡើងថា "ច្បាប់ជាតិដែលមិនបានដាក់ទោសអំពើណាមួយ ដែលជាបទល្មើស អនុលោមតាមច្បាប់អន្តរជាតិនោះ មិនបាន

---

[២៧៦] អនុសញ្ញាស្ដីពីបទប្រល័យពូជសាសន៍ មាត្រា V។ អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា ១២៩។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា ១៤៦ បានដកស្រង់នៅក្នុងចំណុចខាងលើ។

[២៧៧] ធម្មនុញ្ញនៃសាលាក្ដីយោធាអន្តរជាតិសម្រាប់ការជំនុំជម្រះលើឧក្រិដ្ឋជនសង្គ្រាមធំៗ ដាក់អមភ្ជាប់ជាមួយនឹងកិច្ចព្រមព្រៀងទីក្រុងឡុងដ៍ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥ ៨២ U.N.T.S ២៨០ ("ធម្មនុញ្ញរបស់សាលាក្ដីយោធាអន្តរជាតិ") មាត្រា ៧។

[២៧៨] សាលក្រមរបស់សាលាក្ដីយោធាអន្តរជាតិ។ សូមមើលផងដែរនូវឧទាហរណ៍ *សហរដ្ឋអាមេរិក ទល់នឹង Ohlendorf* ៣ LRTWC ៤៧០ (១៩៤៨)។ *សហរដ្ឋអាមេរិក ទល់នឹង Alsotter ៦* LRTWC ១, ៣ (១៩៤៨)។ *សហរដ្ឋអាមេរិក ទល់នឹង Greifelt ១៣* LRTWC ១, ១ (១៩៤៨)។ រឿងក្ដី Eichmann។ សូមមើលផងដែរនូវ យោធាសហរដ្ឋអាមេរិក *វិធានស្ដីពីសង្គ្រាមលើដីគោក* ឯកសាររបស់សេនាធិការ ២៧-១០៣៥៧ ចុះថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៤០ (បង្ហាញថា "ទោសអាចត្រូវបានដាក់" លើខ្មាំងទាំងឡាយ ដែលបានប្រព្រឹត្តការរំលោភលើឧក្រិដ្ឋកម្មសង្គ្រាម)។

[២៧៩] នៅទីក្រុងតូក្យូ ចុងចោទភាគច្រើន ដែលត្រូវបានកាត់ទោសពីឧក្រិដ្ឋកម្មសង្គ្រាម ត្រូវបានដាក់ទោសប្រហារជីវិត ឬ ទោសជាប់ពន្ធនាគារអស់មួយជីវិត (សាលាក្ដីយោធាអន្តរជាតិសម្រាប់ចុងបូព៌ា *សហរដ្ឋអាមេរិក និងជនដទៃទៀត ទល់នឹង Araki និងជនដទៃទៀត* "សាលក្រមចៅក្រមភាគច្រើន") ថ្ងៃទី ៤ - ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៤៨ បានដកស្រង់នៅក្នុង Neil Boister និង Robert Cryer (eds) *ឯកសារស្ដីពីសាលាក្ដីយោធាអន្តរជាតិនៅទីក្រុងតូក្យូ៖ ធម្មនុញ្ញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង សាលក្រម* Oxford University Press ឆ្នាំ ២០០៨ ("សាលក្រមរបស់សាលាក្ដីយោធាអន្តរជាតិសម្រាប់ចុងបូព៌ា") ទំព័រ ៤៩, ៨៥៤-៤៩, ៨៥៨) (អង់គ្លេស)។

ជួយឱ្យជនដែលបានប្រព្រឹត្តអំពើនោះ រួចផុតពីការទទួលខុសត្រូវតាមច្បាប់អន្តរជាតិឡើយ”[២៨០]។ ដោយពិចារណាលើករណីដែលថា ច្បាប់អន្តរជាតិអនុញ្ញាតឱ្យដាក់ទណ្ឌកម្ម ដែលអាចជាទោសជាប់ពន្ធនាគារអស់មួយជីវិត និងទោសប្រហារជីវិតចំពោះអំពើប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ច្បាប់ អ.វ.ត.ក ដែលចែងអំពីទោសអតិបរិមានៃទោសជាប់ពន្ធនាគារអស់មួយជីវិត និង “ការរឹបអូសទ្រព្យសម្បត្តិ ជាចលនវត្ថុ និងអចលនវត្ថុ និងលុយកាក់ដែលទទួលបានដោយខុសច្បាប់ ឬក៏បានដោយការប្រព្រឹត្តឧក្រិដ្ឋកម្ម”[២៨១] មិននាំឱ្យដើមបណ្តឹងឧទ្ធរណ៍ទទួលទោសធ្ងន់ធ្ងរជាងទោសអតិបរិមា ដែលមានជាធរមាន អនុលោមតាមច្បាប់អន្តរជាតិឡើយ។

១២៣. ហេតុដូច្នេះ អំពើដូចបានចោទប្រកាន់លើដើមបណ្តឹងឧទ្ធរណ៍ ដែលបានប្រព្រឹត្តអំពើប្រល័យពូជ-សាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវនោះ គឺខុសច្បាប់ នៅពេលដែលអំពើទាំងនោះបានកើតឡើង ដែលទាមទារឱ្យមានការជំនុំជម្រះក្នុងក្របខ័ណ្ឌអន្តរជាតិ[២៨២]។ ដូចគ្នានេះដែរ ដើមបណ្តឹងឧទ្ធរណ៍អាចប្រមើលមើលឃើញនៅទីនេះថា សូម្បីនៅក្នុងឆ្នាំ ១៩៧៥ “អំពើជាក់លាក់របស់ខ្លួន អាចទទួលទោស នៅពេលដែលបានប្រព្រឹត្តឡើង”[២៨៣]។ វាអាចទំនងដែលថា ចារីដូចបានចោទប្រកាន់ចំពោះអំពើទាំងនេះ ដែលបានប្រព្រឹត្តឡើងនៅពេលខ្មែរក្រហមកាន់កាប់អំណាចខ្លាំងបំផុតនោះ មិនអាចប្រមើលមើលឃើញថា ខ្លួននឹងមិនអាចទទួលទោសឡើយ ដោយសារវាជាបញ្ហានយោបាយ។ ក៏ប៉ុន្តែ កង្វះនៃភាពមិនអាចប្រមើលមើលឃើញក្នុងរូបភាពនេះ មិនផ្តល់ជាការការពារឡើយ អនុលោមតាមច្បាប់អន្តរជាតិ នៅពេលដែលអំពើទាំងនេះ តាមលក្ខណៈរបស់វាអាចទទួលទោសបាននោះ។

[២៨០] គោលការណ៍ច្បាប់អន្តរជាតិ ដែលទទួលស្គាល់នៅក្នុងធម្មនុញ្ញនៃសាលាក្តី Nuremburg និងនៅក្នុងសាលក្រមរបស់សាលាក្តី របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិ លើកឡើងសម័យប្រជុំលើកទីពីររបស់ខ្លួន ថ្ងៃទី ៥ ខែ មិថុនា - ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៥០ ឯកសារ A/១៣១៦ (“គោលការណ៍ Nuremburg”) គោលការណ៍ទី II។

[២៨១] ច្បាប់ អ.វ.ត.ក មាត្រា ៣៨ និង មាត្រា ៣៩។

[២៨២] សូមមើលឧទាហរណ៍ *រដ្ឋអាជ្ញា ទល់នឹង Hadzihasanovic និងជនដទៃទៀត* IT-០១-៤៧-PT “សាលក្រមលើការតវ៉ារួមលើយុត្តាធិការ” អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២ កថាខណ្ឌ ៦២។

[២៨៣] ដូចខាងលើ។

១២៤. ជាសរុបមក អង្គជំនុំជម្រះយល់ឃើញថា នៅគ្រប់ពេលទាំងអស់ដែលពាក់ព័ន្ធនឹងដីកាដំណោះស្រាយ... ជំទាស់ អំពើប្រល័យពូជសាសន៍ ដូចបានកំណត់នៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវទី III និងទី IV ឆ្នាំ១៩៤៩ ដែលត្រូវបានរក្សាទុកនៅក្នុងដីកាដែលរងការជំទាស់នេះ គឺជាបទល្មើស អនុលោមតាមច្បាប់អន្តរជាតិ។ ហេតុដូច្នេះ អ.វ.ត.ក មានយុត្តាធិការជំនុំជម្រះលើដើមបណ្តឹងឧទ្ធរណ៍ចំពោះការរំលោភលើសន្ធិសញ្ញាទាំងនេះ ដូចបានរៀបរាប់លម្អិតនៅក្នុងដីកាដំណោះស្រាយ។

ឃ. <u>បញ្ហាថាតើ ក.ស.ច.ស មានការភ័ន្តច្រឡំដែរឬទេ នៅពេលបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារដើមបណ្តឹងឧទ្ធរណ៍មិនអាចប្រមើលមើលដឹងថាមានច្បាប់ចែង ឬដឹងដឹងថាទង្វើរបស់ខ្លួនគឺជាបទឧក្រិដ្ឋ នៅពេលដែលខ្លួនប្រព្រឹត្តបទឧក្រិដ្ឋទង្វើដែលត្រូវបានចោទប្រកាន់នោះ (មូលដ្ឋានទីបួន នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ)</u>

<u>១. សារណាភាគី</u>

១២៥. មូលដ្ឋានទីបួន នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ បានចោទប្រកាន់ថា ក.ស.ច.ស មានការភ័ន្តច្រឡំនៅពេលបញ្ជាក់ពីយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក ជាពិសេសទាក់ទិនទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារដើមបណ្តឹងឧទ្ធរណ៍ "គ្មានលទ្ធភាពគ្រប់គ្រាន់ក្នុងការព្យាករណ៍ដឹងថាមានច្បាប់ចែង និងដឹងថាទង្វើរបស់ខ្លួនគឺជាឧក្រិដ្ឋ និងទទួលព័ត៌មានពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានទេ ក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់តុលាការ"[២៨៤]។ ទីមួយ បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កត់សម្គាល់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនដែលបានក្លាយជាកម្មវត្ថុ នៃអនុសញ្ញាពិសេសណាមួយឡើយ ហើយមុនពេលមានយុត្តិសាស្ត្រត្រូវបានសម្រេចដោយតុលាការព្រហ្មទណ្ឌពិសេស "គ្មាននិយមន័យជាក់លាក់រឹងមាំនៃ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ត្រូវបានអនុម័តក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ"[២៨៥]។ ហេតុនេះ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិខ្វះភាព

[២៨៤] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ៥៩។

[២៨៥] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ៥៩។

អង្គជំនុំជម្រះសាលាដំបូង * PRE-TRIAL CHAMBER CHAMBRE PRÉ... E.C.C.C. C.E.T.C.

00686538

ជាក់លាក់ ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយនាពេលនោះ ដើមបណ្តឹងឧទ្ធរណ៍គ្មានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រមើលមើលដឹងជាមុនថាមានច្បាប់ចែង និងដឹងថាទង្វើរបស់ខ្លួនគឺជាបទឧក្រិដ្ឋនោះទេ[២៨៦]។

១២៦. ទីពីរ ក.ស.ច.ស មានការភ័ន្តច្រឡំ នៅពេលយោងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅដល់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិឆ្នាំ១៩៩៨ ដោយសារនិយមន័យនោះដាច់ចេញពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយ "បានពង្រីកធាតុផ្សំមួយចំនួន និងទម្រង់នៃអំពើប្រព្រឹត្តយ៉ាងទូលាយ"[២៨៧]។ ជាលក្ខណៈពិសេស បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ជំទាស់ទៅនឹង ក.ស.ច.ស ដែលបានលុបចោលអត្ថិភាពនៃលក្ខខណ្ឌតម្រូវនៃជម្លោះប្រដាប់អាវុធ បានបញ្ចូលការរំលោភលើផ្លូវភេទជាអំពើមួយដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបានបញ្ចូលការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ និងការបាត់ខ្លួនដោយបង្ខំដែលស្ថិតក្នុងប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលចាត់ទុកជាអំពើនានានៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[២៨៨]។ ដើមបណ្តឹងឧទ្ធរណ៍ជំទាស់ថា "សហចៅក្រមស៊ើបអង្កេតមានកំហុស ក្នុងការពង្រីកវិសាលភាពនៃអំពើដែលអាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងក្របខ័ណ្ឌពេលវេលាដែលពាក់ព័ន្ធ"[២៨៩]។ សរុបមក "ការធ្វើបែបនេះមិនត្រឹមតែបំពានលើ *មិនមានបទល្មើសប្រសិនបើគ្មានច្បាប់ចែង* ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានន័យថា មិនបានបំពេញតាមលក្ខខណ្ឌជាក់លាក់នៃភាពអាចព្យាករណ៍បាន និងទទួលបានព័ត៌មានទៀតផងការដឹងថាមានច្បាប់ចែង និងការដឹងថាទង្វើរបស់ខ្លួនគឺជាបទឧក្រិដ្ឋ"[២៩០]។

២. ការពិភាក្សា

១២៧. អង្គបុរេជំនុំជម្រះសូមរំឭកថា តាមមាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក៖

[២៨៦] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ៥៨-៥៩។

[២៨៧] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ៦០។

[២៨៨] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ៦០-៦១។

[២៨៩] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ៦២។

[២៩០] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ៦២។

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ [...] គឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារ ជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា ណាមួយដូចជា៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុ នយោបាយ ពូជសាសន៍ ឬ សាសនា អំពើអមនុស្សធម៌ផ្សេងៗទៀត។

១២៨. នៅក្នុងដីកាដំណោះស្រាយ ក.ស.ច.ស បានសម្រេចថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះមានចែងជាបទឧក្រិដ្ឋអន្តរជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយនៅក្នុងទិដ្ឋភាពនៃច្បាប់យុត្តិសាស្ត្រនៃសង្គ្រាមលោកលើកទី២ ដើមបណ្តឹងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រមើលមើលដឹងថាមានច្បាប់ចែង និងដឹងថាទង្វើរបស់ខ្លួន គឺជាបទឧក្រិដ្ឋដែលនឹងត្រូវជំនុំជម្រះផ្តន្ទាទោសជាក់ជាពីបទល្មើសទាំងនេះមិនខាន[២៩១]។ ម្យ៉ាងវិញទៀត ក្នុងការសន្និដ្ឋានថា អ.វ.ត.ក មានយុត្តាធិការទៅលើការចោទប្រកាន់ពីបទរំលោភលើផ្លូវភេទ និង អំពើអមនុស្សធម៌ផ្សេងៗទៀត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលទាក់ទិនជាពិសេសទៅនឹងការចោទប្រកាន់ប្រឆាំងនឹង អៀង ធីរិទ្ធ នោះ ក.ស.ច.ស បានសម្រេចថា បទល្មើសជាមូលដ្ឋាននៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" រួមមានអំពើនានាដែលត្រូវបានចោទប្រកាន់រួមមាន៖ ការរៀបអាពាហ៍ពិពាហ៍អាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ និងការបាត់ខ្លួនដោយបង្ខំ[២៩២]។

(i) <u>**បញ្ហាថាតើការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពិតជាអាចប្រមើលមើលដឹងថាមានច្បាប់ចែង និងដឹងថាជាបទឧក្រិដ្ឋដែរឬទេ នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩**</u>

១២៩. បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ បានអះអាងថា ដោយសារឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនដែលបានក្លាយជាកម្មវត្ថុនៃអនុសញ្ញាពិសេសណាមួយ ដោយសារមានការខ្វែងយោបល់គ្នាទៅលើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅពេលដែលគណៈកម្មការច្បាប់អន្តរជាតិ ("ILC") កំពុងរៀបរៀងសេចក្តីព្រាងក្រមស្តីពីបទល្មើសនានា សម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិនាពេលអនាគត

[២៩១] ដីកាដែលរងការជំទាស់ កថាខណ្ឌ១៣០៨ (លុបជើងទំព័រ)។

[២៩២] ដីកាដែលរងការជំទាស់ កថាខណ្ឌ១៣១៤ (លុបជើងទំព័រ)។

ចាប់ពីទសវត្សរ៍ឆ្នាំ ១៩៥០ រហូតដល់ពេលមានយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិពិសេសសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងរវ៉ាន់ដាក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ និងដោយសារធាតុផ្សំ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនត្រូវបានកំណត់ឱ្យបានច្បាស់លាស់មុនពេលមានយុត្តិសាស្ត្រនោះ "គ្មាននិយមន័យជាក់លាក់រឹងមាំនៃ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ត្រូវបានអនុម័តក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ រហូតមកទល់ពេលនោះ"[២៩៣]។

១៣០. អង្គបុរេជំនុំជម្រះមិនយល់ស្របនឹងការលើកឡើងនេះទេ។ ក្រោយសង្គ្រាមលោកលើកទី២ និយមន័យ និងធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាបទឧក្រិដ្ឋអន្តរជាតិ ត្រូវបានបង្កើតឡើងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយមានចែង និងអនុវត្តនៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ ("IMT")[២៩៤] ធម្មនុញ្ញតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ("IMTFE")[២៩៥] ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ("ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រង")[២៩៦] យុត្តិសាស្ត្រតុលាការ IMT Nuremberg[២៩៧] និងពីការអនុវត្តនានានៃយោធានៅក្នុងតំបន់ដែលគ្រប់គ្រងដោយសម្ព័ន្ធមិត្រ នៅប្រទេសអាល្លឺម៉ង់[២៩៨] និងគោលការណ៍ Nuremberg ឆ្នាំ ១៩៥០[២៩៩]។ និយមន័យដែលត្រូវបានចងក្រង និងអនុម័តដោយ ILC នៅក្នុងគោលការណ៍ Nuremberg អនុលោមតាម សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 177 (II) កថាខណ្ឌ(ក) និងត្រូវបានអះអាងបញ្ជាក់

---

[២៩៣] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ៥៩។

[២៩៤] ធម្មនុញ្ញតុលាការ IMT មាត្រា៦(គ)។

[២៩៥] ធម្មនុញ្ញតុលាការយោធាសម្រាប់ចុងបូព៌ា ("ធម្មនុញ្ញ IMTFE") មាត្រា៥(គ)។

[២៩៦] *ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង: ការផ្តន្ទាទោសបុគ្គលដែលមានពិរុទ្ធពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* អនុម័តដោយក្រុមប្រឹក្សាសម្ព័ន្ធមិត្តគ្រប់គ្រងប្រទេសអាល្លឺម៉ង់ រួមមានចក្រភពអង់គ្លេស បារាំង សហរដ្ឋអាមេរិក និងសហភាពសូវៀត ក្រុងប៊ែរឡាំង ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៤៥ ក្រុមប្រឹក្សាគ្រប់គ្រងអាល្លឺម៉ង់ ៥០-៥៥ ("ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង") មាត្រាII(១)(គ)។

[២៩៧] ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៅតុលាការយោធាអន្តរជាតិ "សាលក្រម" ចុះថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៤៦ បោះពុម្ពសាជាថ្មីនៅក្នុងការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ លេខាធិការដ្ឋាននៃតុលាការយោធាអន្តរជាតិ ឆ្នាំ ១៩៤៧ Vol. I ទំព័រ១៧១ ("សាលក្រមតុលាការ Nuremberg (IMT)") ត្រង់ Vol. I, ទំព័រ ១៧៤, ២៥៣, ២៥៤-២៥៥ (អង់គ្លេស)។

[២៩៨] សូមមើល ជាឧទាហរណ៍ រឿងក្តីនានាដែលត្រូវបានជំនុំជម្រះ និងសម្រេចសេចក្តីតាមច្បាប់របស់ក្រុមប្រឹក្សាគ្រប់គ្រង ពីខែតុលា ឆ្នាំ ១៩៤៦ ដល់ខែ មេសា ឆ្នាំ ១៩៤៩ នៅចំពោះមុខតុលាការយោធា Nuremberg ("NMT") ដែលបានដកស្រង់នៅក្នុងផ្នែក IV(ច) ខាងក្រោម។

[២៩៩] គោលការណ៍ Nuremberg។

ដោយសេចក្តីសម្រេចរបស់មហាសន្និបាត[៣០០] បានឆ្លុះបញ្ចាំងពីគោលការណ៍នៃច្បាប់អន្តរជាតិ ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅតាមពេលវេលាដូចខាងក្រោម៖

> ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖
> ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលមានធ្វើឡើងប្រឆាំងប្រជាជនស៊ីវិល ឬការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា នៅពេលដែលប្រព្រឹត្តអំពើទាំងនេះ ឬនៅពេលអនុវត្តការធ្វើទុក្ខបុកម្នេញទាំងនេះ ដើម្បីប្រតិបត្តិ ឬមានទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាម[៣០១]។

១៣១. អង្គបុរេជំនុំជម្រះកត់សម្គាល់ ដូចដែលបានលើកឡើងដោយដើមបណ្តឹងឧទ្ធរណ៍ដែរថា នោះជាការពិតដែលថា ចាប់តាំងពីមានសេចក្តីព្រាងនៃក្រមស្តីពីបទល្មើសឆ្នាំ ១៩៥៤[៣០២] រហូតពេលមានសេចក្តីព្រាងនៃក្រមស្តីពីឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិឆ្នាំ ១៩៩៦[៣០៣] ILC មិនអាចអនុម័តយកនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលព្រមព្រៀងគ្នាបាន នៅពេលដែលគណៈកម្មការនេះចងក្រងក្រមព្រហ្មទណ្ឌមួយសម្រាប់តុលាការនាពេលអនាគត។ ទោះជាយ៉ាងណាក្តី អង្គបុរេជំនុំជម្រះយល់ឃើញថា ចំណុចនេះមិនបង្ហាញថានិយមន័យពេញលេញសម្រាប់ឧក្រិដ្ឋកម្ម

---

[៣០០] *ការបញ្ជាក់ពីគោលការណ៍នានានៃច្បាប់អន្តរជាតិដែលទទួលស្គាល់ដោយធម្មនុញ្ញនៃតុលាការ Nuremberg* សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 95 (I), U.N. GAOR, 1st Sess., pt. 2 ត្រង់ទំព័រ១១៨៨ (អង់គ្លេស) ឯកសារលេខ A/236 ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦។

[៣០១] គោលការណ៍ Nuremberg, គោលការណ៍ VI(គ)។

[៣០២] *សេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ* របាយការណ៍ទីបីរបស់ J. Spiropoulos អ្នករាយការណ៍ពិសេស ឯកសារលេខ A/CN.4/85 បោះពុម្ពផ្សាយនៅក្នុង *ទស្សនាវដ្តីប្រចាំឆ្នាំរបស់គណៈកម្មការច្បាប់អន្តរជាតិ ឆ្នាំ ១៩៥៤ Vol. II* ទំព័រ១១២-១២១ (អង់គ្លេស)។ សូមមើលផងដែរ សូមមើលការបដិសេធចោលរបស់មហាសន្និបាត៖ សេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៨៩៧ (IX), ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ១៩៥៤។

[៣០៣] *សេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ* របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិស្តីពីការងាររបស់ខ្លួននៅក្នុងសម័យប្រជុំលើកទី៤៨ ពីថ្ងៃទី ៦ ខែ ឧសភា ដល់ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ឯកសារលេខ A/51/10 បោះពុម្ពសាជាថ្មីនៅក្នុង *ទស្សនាវដ្តីប្រចាំឆ្នាំរបស់គណៈកម្មការច្បាប់អន្តរជាតិ* ឆ្នាំ១៩៩៦ Vol. II (ផ្នែកទី២) ទំព័រ១៥-៥៦ (អង់គ្លេស) ជាពិសេសអត្ថបទលេខ១៨ ទំព័រ៤៧ (អង់គ្លេស)។

ប្រឆាំងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ មានភាពខ្វះខាតទេ ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ គោលបំណងរបស់ ILC នៅក្នុងមាត្រា១ នៃលក្ខន្តិកៈរបស់ខ្លួនគឺថា "លើកស្ទួយដំណើរការវិវត្តន៍នៃច្បាប់អន្តរជាតិ និងចងក្រងជាច្បាប់អន្តរជាតិ" ហើយបើតាមមាត្រា១៥ នៃលក្ខន្តិកៈនេះ ការងារចងក្រងរបស់ ILC ពាក់ព័ន្ធនឹង "ការបង្កើត និងការរៀបចំជាប្រព័ន្ធ*ឲ្យកាន់តែបានច្បាស់*នៃវិធានច្បាប់អន្តរជាតិ ក្នុងវិស័យ*ដែលមាន*ជាការអនុវត្តន៍របស់រដ្ឋ*រួចទៅហើយ*ទាំងយុត្តិសាស្ត្រ និងទ្រឹស្តី"[៣០៤]។ ការពិត ILC មិនអាចយល់ស្របទៅលើការបង្កើត"ឲ្យកាន់តែបានច្បាស់" សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាងអ្វីដែលត្រូវបានចែងនៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ មិនបានបង្ហាញថា និយមន័យដែលមានរួចមកហើយនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក មិនមានភាពជាក់លាក់គ្រប់គ្រាន់ និងជាការរំលោភដល់គោលការណ៍នីត្យានុកូលភាព។ ជាងនេះទៀត ការមិនយល់ស្របរបស់ ILC អាចបណ្តាលមកពីការខិតខំប្រឹងប្រែងស្វែងរកដំណើរការវិវត្តន៍នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ខុសពីនិយមន័យនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្រោយសង្គ្រាមលោកលើកទី២។

១៣២. អង្គបុរេជំនុំជម្រះមិនយល់ស្របថា ការខកខានរបស់សហគមន៍អន្តរជាតិ ចាប់តាំងពីមានគោលការណ៍ Nuremberg ដើម្បីអនុម័តអនុសញ្ញាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបង្ហាញថា និយមន័យរឹងមាំច្បាស់លាស់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាបញ្ហាមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ មានភាពខ្វះខាតនៅមុនពេលមានយុត្តាធិការនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ("ICTR") ដែលបានចាប់ផ្តើមនៅទសវត្សរ៍ឆ្នាំ ១៩៩០ នោះទេ។ មានមូលហេតុនានាជាច្រើន រួមទាំងមូលហេតុនយោបាយផងដែលធ្វើឲ្យបណ្តារដ្ឋជាសមាជិកខកខានមិនអាចអនុម័តច្បាប់សន្ធិសញ្ញាបាន។ ជាងនេះទៀត ទោះបីសន្ធិសញ្ញាត្រូវបានអនុម័តក៏ដោយ ក៏វាមិនឆ្លុះបញ្ចាំងនូវសភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរ ទាក់ទិននឹងសាច់រឿងនៅពេលដែលសន្ធិសញ្ញាទាំងនោះត្រូវបានអនុម័ត។

១៣៣. ជាចុងក្រោយ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា និយមន័យ រួមទាំងធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានចែងនៅឆ្នាំ១៩៥០ ក្នុងគោលការណ៍ Nuremberg មានភាពជាក់លាក់គ្រប់

[៣០៤] *ទស្សនាវដ្តីប្រចាំឆ្នាំរបស់គណៈកម្មការច្បាប់អន្តរជាតិ* ឆ្នាំ១៩៧៩ Vol. II (ផ្នែកទី១) ឯកសារលេខ A/CN.4/325 កថាខណ្ឌ ១០២ និង *ដូចដើងទំព័រខាងលើ* ឆ្នាំ ១៩៩៦ (អង់គ្លេស) vol. II (ផ្នែកទី២) កថាខណ្ឌ១៥៦ និង១៥៧ (គូសបញ្ជាក់បន្ថែម)។

គ្រាន់តែលថា ពាក្យពេចន៍ស្ទើរតែទាំងស្រុងនៃធាតុផ្សំរបស់វា ត្រូវបានអនុម័តបញ្ចូលទៅក្នុងលក្ខន្តិកៈ តុលាការ ICTY និង ICTR នៅឆ្នាំ ១៩៩៣ និង ឆ្នាំ ១៩៩៤ អនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ[៣០៥]។ ទោះបីមានភាពខុសគ្នាខ្លះៗ ជាពិសេសទាក់ទិននឹងលក្ខន្តិកៈតុលាការ ICTR ដែលលុបចេញនូវលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ និងដាក់បញ្ចូលនូវធាតុផ្សំរួមនៃលក្ខខណ្ឌតម្រូវនៃ *ចេតនាទុច្ចរិត (animus)* ក៏ដោយ ក៏ភាពខុសគ្នាទាំងនេះជាលក្ខណៈជាក់លាក់សម្រាប់យុត្តាធិការរបស់តុលាការ *មិនអចិន្ត្រៃយ៍*ទាំងនេះប៉ុណ្ណោះ ហើយមិនចាំបាច់តម្រូវឱ្យឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ។ ការពិត ការផ្លាស់ប្តូរមួយចំនួនចំពោះនិយមន័យ ជាពិសេសគឺការលុបចេញនូវលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ និងការដាក់បញ្ចូលនូវអំពើជាមូលដ្ឋានកាន់តែច្រើនឡើង[៣០៦] ត្រូវបានបកស្រាយ និងយកទៅអនុវត្តដើម្បីឆ្លុះបញ្ចាំងពីការវិវឌ្ឍន៍នានានៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចាប់តាំងពីមានការវិនិច្ឆ័យទោសលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោយមសង្គ្រាមលោកលើកទី២ មក។ បន្ថែមលើសនេះទៀត ទោះបីយុត្តិ-សាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍*បានដើរតួនាទីយ៉ាងច្បាស់ ក្នុងការកំណត់ពីធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលមានចែងនៅក្នុងគោលការណ៍ Nuremberg ក៏ដោយ អង្គបុរេជំនុំជម្រះមិនយល់ថា ហេតុការណ៍នេះបង្ហាញថា និយមន័យនៅក្រោយសម័យសង្គ្រាមលោកលើកទី២ មិនមានភាពច្បាស់លាស់ពេញលេញឡើយ។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងនៅក្នុងគោលការណ៍ Nuremberg មានលក្ខណៈជាក់លាក់ពេញលេញក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលថា ដើមបណ្តឹងឧទ្ធរណ៍អាចប្រមើលមើលដឹងថាមានច្បាប់ចែង និងដឹងថាជាមុនថា ខ្លួនអាចនឹងត្រូវផ្តន្ទាទោសពីបទល្មើសទាំងនេះជាក់ជាមិនខាន។

---

[៣០៥] លក្ខន្តិកៈកែសម្រួលនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលបានអនុម័តនៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ១៩៩៣ ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ៨២៧ (ឆ្នាំ ១៩៩៣) ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៩ ("លក្ខន្តិកៈតុលាការ ICTY") មាត្រា៥, លក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសរវ៉ាន់ដា ដែលបានអនុម័តដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ៩៥៥ (ឆ្នាំ ១៩៩៤) ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១០ ("លក្ខន្តិកៈតុលាការ ICTR Statute") មាត្រា៣។

[៣០៦] លក្ខន្តិកៈទាំងពីររួមមានការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការរំលោភលើផ្លូវភេទ ជាអំពើជាមូលដ្ឋានបន្ថែមទៀត (សូមមើលលក្ខន្តិកៈតុលាការ ICTY មាត្រា៥(ង)-(ឆ), លក្ខន្តិកៈតុលាការ ICTR មាត្រា៣(ង)-(ឆ))។ ទោះជាយ៉ាងណាក្តី អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា អំពើទាំងនេះក៏ត្រូវបានបញ្ចូលផងដែរទៅក្នុងច្បាប់របស់ក្រុមប្រឹក្សាគ្រប់គ្រង មាត្រា II (១)(ក)...។

00686544

(ii) បញ្ហាថាការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បានបញ្ចូលលក្ខខណ្ឌតម្រូវនៃ "ចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ" ដែរឬទេ

១៣៤. បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ បានលើកជាទឡ្ហីករណ៍បន្ថែមទៀតថា ក.ស.ច.ស មានការភ័ន្តច្រឡំក្នុងការទទួលស្គាល់យុត្តាធិការរបស់ អ.វ.ត.ក ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមមាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដោយសារ "ទោះបីជាអត្ថិភាពនៃជម្លោះប្រដាប់អាវុធត្រូវបានកំណត់ជាធាតុផ្សំនៃនិយមន័យដូចបានចែងក្នុងមាត្រា៦(គ) នៃធម្មនុញ្ញតុលាការយោធាអន្តរ-ជាតិក្តី ក៏សហចៅក្រមស៊ើបអង្កេតមិនបានប្រកាន់យកលក្ខខណ្ឌតម្រូវក្នុងនិយមន័យនៃ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ដែលបានកំណត់ក្នុងដីកាដំណោះស្រាយឡើយ"[៣០៧]។ អាស្រ័យហេតុនេះ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះ មិនអាចត្រូវបានប្រមើលមើលដឹងថាមានការកំណត់និយមន័យតាមផ្លូវច្បាប់ និងដឹងជាមុនថាទង្វើទាំងនោះគឺជាបទឧក្រិដ្ឋ នៅក្នុងពេលដែលពាក់ព័ន្ធពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[៣០៨] នោះទេ។

១៣៥. ដូចបានកត់សម្គាល់ខាងលើរួចមកហើយ អង្គបុរេជំនុំជម្រះសូមរំឭកឡើងវិញថា និយមន័យនៃឧក្រិដ្ឋ-កម្មប្រឆាំងមនុស្សជាតិត្រូវបានចែងជាលើកដំបូងនៅក្នុងច្បាប់អន្តរជាតិ ក្នុងមាត្រា៦(គ) នៃធម្មនុញ្ញតុលាការ (IMT)។ នៅក្នុងនិយមន័យនោះ មានការបង្កប់ន័យនូវពាក្យថា លក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ដែលចែងថា អំពើជាមូលដ្ឋានដែលបង្កើតឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើង "ដោយការអនុវត្ត ឬដោយមានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្មដែលនៅក្នុងយុត្តាធិការរបស់តុលាការនេះ"[៣០៩]។ បញ្ញត្តិនេះបានបញ្ចូលជាលក្ខខណ្ឌតម្រូវមួយដែលថា មានទំនាក់

---

[៣០៧] បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ៦១។ ទោះបី នួន ជា មិនបានលើកបញ្ហានេះជាមូលដ្ឋានដោយឡែកនៃបណ្ដឹងឧទ្ធរណ៍ក៏ដោយ ក៏នៅផ្នែក "ច្បាប់ដែលពាក់ព័ន្ធ" នៃបណ្ដឹងឧទ្ធរណ៍របស់ នួន ជា បានកត់សម្គាល់ស្រដៀងគ្នានេះថា "នៅចុងឆ្នាំ ១៩៩៤ ចៅក្រម Meron បានកត់សម្គាល់ថា វាមានការលំបាកក្នុងការរកជំហរឲ្យស្របគ្នាមួយថា តើបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ នៅមានចំណងនឹងគ្នាដែរឬទេ។ នៅក្នុងឆ្នាំបន្ទាប់តែប៉ុណ្ណោះ ទើបអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានប្រកាសថា ចំណងនេះបានកាត់ផ្តាច់រួចទៅហើយ" (បណ្ដឹងឧទ្ធរណ៍របស់ នួន ជា កថាខណ្ឌ១១)។

[៣០៨] បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ៦២។

[៣០៩] ធម្មនុញ្ញតុលាការ (IMT), មាត្រា៦(គ)។

00686545

ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឬឧក្រិដ្ឋសង្គ្រាម ដូចដែលមានចែងនៅក្នុងកថាខណ្ឌពីរខាងដើម នៃមាត្រាដែលនេះ។ លក្ខខណ្ឌតម្រូវនេះក៏មានចែងផងដែរនៅក្នុងគោលការណ៍ Nuremberg[៣១០]។

១៣៦. ត្រង់ចំណុចនេះ យុត្តិសាស្ត្រតុលាការ ICTY បានសម្រេចថា លក្ខខណ្ឌតម្រូវជាក់លាក់នៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់នៅក្នុងធម្មនុញ្ញតុលាការ Nuremberg និងគោលការណ៍ Nuremberg វាជាលក្ខណៈពិសេសនៃយុត្តាធិការតុលាការ IMT[៣១១] ដោយសារតុលាការនេះត្រូវបានបង្កើតឡើងជាពិសេស "សម្រាប់ជំនុំជម្រះទោស និងផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាមចម្បងនៃបណ្តាប្រទេសអាក្សីស៍នៅអឺរ៉ុបឲ្យបានយុត្តិធម៌ និងត្រឹមត្រូវ"[៣១២]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY លើរឿងក្តី *Tadić* បានសម្រេចថា "លក្ខខណ្ឌតម្រូវនេះមិនមានភាពតក្កវិទ្យា និងមិនមានមូលដ្ឋានច្បាប់ទេ ហើយនៅក្នុងការអនុវត្តរបស់រដ្ឋ វាត្រូវបានបោះបង់ចោល ដោយគោរពទៅតាមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[៣១៣]។

១៣៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ទោះបីអាចមានករណីបែបនេះកើតឡើងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលចេញសាលដីកាសម្រេចលើរឿងក្តី *Tadić* ឆ្នាំ ១៩៩៥ ក៏ដោយ ក៏អង្គបុរេជំនុំជម្រះត្រូវសម្រេចថា តើលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធនៅមានអត្ថិភាពឬទេពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ សម្រាប់សំអាងហេតុដូចខាងក្រោមនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ដោយសារវាជាបញ្ហានៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ វាមិនមានភាពច្បាស់លាស់ទេដែលថា តើលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធមានភាពធ្ងន់ធ្ងរឬទេ នៅមុនពេល ឬក្នុងអំឡុងពេល នៃយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក នោះ។

---

[៣១០] គោលការណ៍ Nuremberg, គោលការណ៍ VI(គ)។

[៣១១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić*, សំណុំរឿងលេខ IT-94-1-AR72, "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ហិរបស់មេធាវីការពារក្តីទៅលើយុត្តាធិការ" ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៥ កថាខណ្ឌ១៤០។

[៣១២] មាត្រា I, ធម្មនុញ្ញតុលាការ IMT, *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić*, សំណុំរឿងលេខ IT-94-1-T, "សេចក្តីសម្រេចលើបណ្តឹងរបស់មេធាវីការពារក្តីទៅលើយុត្តាធិការ" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៥ កថាខណ្ឌ៧៨។

[៣១៣] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadic*, សំណុំរឿងលេខ IT-94-1-AR72, "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ហិរបស់មេធាវីការពារក្តីទៅលើយុត្តាធិការ" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៥

១៣៨. អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY លើរឿងក្តី *Tadić* បានដកស្រង់រឿងក្តី *Einsatzgruppen* របស់តុលាការយោធា Nuremberg ("NMT") នៅក្នុងតំបន់ដែលគ្រប់គ្រងដោយសហរដ្ឋអាមេរិក ដើម្បីគាំទ្រដល់សំណើដែលថា បន្ទាប់ពីមានធម្មនុញ្ញតុលាការ IMT និងយុត្តិសាស្ត្រតុលាការនេះមក ច្បាប់របស់ក្រុមប្រឹក្សាគ្រប់គ្រង និងយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សានេះបានដកចេញនូវលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ "ដើម្បីឱ្យតុលាការ [យោធា Nuremberg] មានយុត្តាធិការក្នុងការជំនុំជម្រះទោសរាល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់ *ដែលត្រូវបានស្គាល់ និងយល់ដឹងជាយូរយារមកហើយ តាមគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ*"[៣១៤]។ ជាលក្ខណៈប្រយោល ដំណើរការនេះគឺជាសំណើដែលថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលរៀបចំមុនមានការចងក្រងនូវនិយមន័យនេះនៅក្នុងធម្មនុញ្ញតុលាការ IMT មិនបានបញ្ចូលលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធទេ។

១៣៩. ទោះជាយ៉ាងណាក្តី មុនពេលមានចែងពីបញ្ញត្តិនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បុព្វកថានៃសេចក្តីប្រកាសនៅទីក្រុង St. Petersburg ឆ្នាំ ១៨៦៨[៣១៥] និង Martens Clause នៅក្នុងអនុសញ្ញាទីក្រុងឡាអេឆ្នាំ ១៨៩៩[៣១៦] និង ឆ្នាំ ១៩០៧[៣១៧] ដែលបានអំពាវនាវឱ្យមាន "ច្បាប់មនុស្សធម៌" ជាការ

---

[៣១៤] *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Otto Ohlendorf និងអ្នកដទៃទៀត* ថ្ងៃទី ៨ និង ទី ៩ ខែ មេសា ឆ្នាំ ១៩៤៨ បោះពុម្ពសាជាថ្មីនៅក្នុង សវនាការឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg តាមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង, United States Government Printing Office, ឆ្នាំ ១៩៤៩-១៩៥២ ("*សវនាការនៅតុលាការ NMT* "), Vol. IV, ទំព័រ៣ (អង់គ្លេស) ("រឿងក្តី *Einsatzgruppen*"), ត្រង់ Vol. IV, ទំព័រ៤៩៩ (អង់គ្លេស) (គូសបញ្ជាក់បន្ថែម*), រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić*, សំណុំរឿងលេខ IT-94-1-T, "សេចក្តីសម្រេចលើបណ្តឹងរបស់មេធាវីការពារក្តីទៅលើយុត្តាធិការ" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៥ កថាខណ្ឌ៧៩។

[៣១៥] *សេចក្តីប្រកាសពីការលះបង់មិនប្រើប្រាស់នូវការបាញ់ផ្លោងអាវុធដែលបំផ្ទុះដែលមានទម្ងន់ក្រោម៤០០ក្រាម នៅពេលមានសង្គ្រាម (Declaration Renouncing the Use, in Time of War, of Explosive Projectiles Under 400 Grammes Weight)* (អនុម័តថ្ងៃទី ២៩ ខែ វិច្ឆិកា/ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៨៦៨ ចូលជាធរមាននៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៨៦៨) បោះពុម្ពសាជាថ្មីនៅ D. Schindler and J. Toman (eds), *The Laws of Armed Conflicts*, Martinus Nihjoff Publisher ឆ្នាំ ១៩៨៨ ទំព័រ១០២ (អង់គ្លេស) (បុព្វកថា៖ "... អាស្រ័យហេតុនេះ ការប្រើប្រាស់អាវុធបែបនេះ *ផ្ទុយនឹងច្បាប់មនុស្សធម៌*" (គូសបញ្ជាក់បន្ថែម)។

[៣១៦] *អនុសញ្ញាទីក្រុងឡាអេទី (II) ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក* ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩ ("អនុសញ្ញាទីក្រុងឡាអេទី II ឆ្នាំ ១៨៩៩") បុព្វកថា។

[៣១៧] *អនុសញ្ញាទីក្រុងឡាអេទី (IV) ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក* អនុម័តថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧ ("អនុសញ្ញាទីក្រុងឡាអេទី IV ឆ្នាំ ១៩០៧") បុព្វកថា។

ការពារបន្ទាប់បន្សំបន្ថែមទៀត ប្រឆាំងនឹងអំពើដែលមិនត្រូវបានហាមឃាត់ជាក់លាក់ នៅក្នុងអត្ថបទនៃអនុសញ្ញាទីក្រុងឡាអេ នីមួយៗ ដែលផ្អែកជាសំខាន់ទៅលើច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាម។ អាស្រ័យហេតុនេះ អ្នករៀបរៀងសេចក្តីព្រាងធម្មនុញ្ញតុលាការ IMT បានធានាឱ្យមានទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធ ដើម្បីបញ្ចៀសការចោទប្រកាន់ដែលបណ្តាលឱ្យការផ្តន្ទាទោសចេញហួសឆ្ងាយពីអ្វីដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់អនុសញ្ញា[៣១៨]។ អាស្រ័យហេតុនេះ ចាប់ពីពេលដែលបង្កើតបញ្ញត្តិនេះមក ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឱ្យមានចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ។

១៤០. បន្ថែមទៅលើសនេះទៀត ទោះបីច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងបានលុបចោលនូវចំណុចនេះក៏ដោយ ក៏ករណីបន្តបន្ទាប់ដែលត្រូវបានយកមកជំនុំជម្រះ និងសម្រេចតាមច្បាប់របស់ក្រុមប្រឹក្សាចាប់ពីខែ តុលា ឆ្នាំ ១៩៤៦ រហូតដល់ខែ មេសា ឆ្នាំ ១៩៤៩ មុនពេលមានយុត្តិសាស្ត្ររបស់តុលាការយោធា Nuremberg ("NMT") នៅបន្តយកមកអនុវត្តដដែល[៣១៩]។ ជាងនេះទៀត ទោះបីអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨ ត្រូវបានអនុម័តជាឯកច្ឆន្ទ ដោយមហាសន្និបាតអង្គការសហប្រជាជាតិក៏ដោយ[៣២០] ក៏និយមន័យនៃអំពើប្រល័យពូជសាសន៍នៅទីនេះ ដែលមិនបានបញ្ចូលលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ចេញឆ្ងាយពីលំនាំដើមរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើប្រល័យពូជសាសន៍ ដោយតម្រូវឱ្យមានចេតនាយ៉ាងពិសេសមួយដែលមិនមានចែងនៅក្នុងធម្មនុញ្ញតុលាការ IMT[៣២១]។ ទោះបីជាអំពើប្រល័យពូជសាសន៍ត្រូវបានចាត់ទុកថាជាផ្នែករងមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅឆ្នាំ ១៩៤៨ ក៏ដោយ ក៏អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ គ្រាន់តែលុបចោលលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ

---

[៣១៨] Cherif Bassiouni, *Crimes Against Humanity in International Criminal Law*, Kluwer Law International, ឆ្នាំ ១៩៩៩ ទំព័រ២៣-២៥, ២៩-៣០, ៤៣ (អង់គ្លេស)។

[៣១៩] *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Friedrich Flick និងអ្នកដទៃទៀត* ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៤៧ បោះពុម្ពសាជាថ្មីនៅក្នុង *NMT Trials*, Vol. VI, ទំព័រ៣ (អង់គ្លេស) ("រឿងក្តី *Flick*"), ត្រង់ Vol VI, ទំព័រ១២១៣; *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Ernst von Weizsaecker និងអ្នកដទៃទៀត* ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៤៩ បោះពុម្ពសាជាថ្មីនៅក្នុង *NMT Trials*, Vols XIII – XIV ("រឿងក្តី*រដ្ឋមន្ត្រី*"), ត្រង់ Vol XIVទំព័រ៥៥៨ (អង់គ្លេស)។

[៣២០] អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មាត្រា១៖ "ទោះបីប្រព្រឹត្តនៅពេលមានសន្តិភាព ឬនៅពេលមានសង្គ្រាមក្តី ..."។

[៣២១] អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មាត្រា២៖ "... ត្រូវបានធ្វើឡើងក្នុងបំណងបំផ្លាញទោះទាំងស្រុងក្តី ឬក៏ខ្លះៗក្តីដល់ប្រជាជាតិមួយ ពូជសាសន៍មួយ ឬក្រុមសាសន៍មួយ ឬក្រុមសាសន៍មួយ ..."។

សម្រាប់អំពើប្រល័យពូជសាសន៍ដោយជាក់លាក់តែប៉ុណ្ណោះ តែមិនសំដៅដល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀតទាំងអស់ទេ។ ការពិត ដូចបានលើកឡើងមកខាងដើមរួចមកហើយថា គោលការណ៍ Nuremberg ឆ្នាំ ១៩៥០ ដែលបានឆ្លុះបញ្ចាំងនូវគោលការណ៍នៃច្បាប់អន្តរជាតិនាពេលនោះ បានបញ្ចូលចំណុចនេះដែរនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

១៤១.អង្គបុរេជំនុំជម្រះបានកត់សម្គាល់បន្ថែមទៀតថា មហាសន្និបាតអង្គការសហប្រជាជាតិមិនបានទទួលយកសេចក្តីព្រាង នៃនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលគ្មានលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ នៅក្នុងសេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិឆ្នាំ ១៩៥៤ របស់ ILC ទេ[៣២២]។ មកត្រឹមថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មានប្រទេសចំនួនត្រឹមតែ១៨ ប៉ុណ្ណោះ ក្នុងចំណោមប្រទេសសរុបចំនួន១៣៤ ដែលជាសមាជិកអង្គការសហប្រជាជាតិ ដែលបានចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬចូលជាភាគីនៃអនុសញ្ញាស្តីពីអាជ្ញាយុកាលឆ្នាំ ១៩៦៨[៣២៣] ហើយមានតែរដ្ឋមួយបន្ថែមទៀតប៉ុណ្ណោះដែលផ្តល់សច្ចាប័នដល់លក្ខន្តិកៈនេះ ក្នុងយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក[៣២៤]។ ទោះបីអង្គបុរេជំនុំជម្រះទទួលស្គាល់ថាការអនុវត្តរបស់រដ្ឋមិនចាំបាច់មានលក្ខណៈដូចៗគ្នា ដែលអាចចាត់ទុកជាការអនុវត្តទូទៅក៏ដោយ ក៏គេមិនអាចនិយាយបានថា លក្ខន្តិកៈនៃអនុសញ្ញាស្តីពីការមិនអាចយកមកអនុវត្តយុត្តាធិការឆ្នាំ ១៩៦៨ ស្របទៅនឹងកម្រិតនៃការទទួលយកមួយ ដើម្បីក្លាយជាការអនុវត្តជាទូទៅបានទេ។ ជាងនេះទៅទៀត នៅឆ្នាំ ១៩៦៨ អ្នកតំណាងដែលបានចូលរួមអនុម័តអនុសញ្ញាស្តីពីអាជ្ញាយុកាលឆ្នាំ ១៩៦៨ ត្រូវបាន

---

៣២២ សូមមើលការបដិសេធចោលរបស់មហាសន្និបាត៖ សេចក្តីព្រាងក្រមស្តីពីការប្រព្រឹត្តបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ៨៩៧ (IX) ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ១៩៥៤។

៣២៣ *អនុសញ្ញាស្តីពីការមិនអនុវត្តច្បាប់អាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* (អនុម័តនៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៦៨ ចូលជាធរមាននៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៧០) សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 2391 (XXIII), U.N. GAOR, 23d Sess., Supp. No. 18, at 40, U.N. Doc. A/7218 (ឆ្នាំ ១៩៦៨) 754 U.N.T.S. 73 មាត្រា១(ខ)"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទោះបីប្រព្រឹត្តនៅពេលមានសង្គ្រាម ឬនៅពេលមានសន្តិភាពក៏ដោយ"។

៣២៤ សម្ព័ន្ធសន្និសញ្ញារបស់អង្គការសហប្រជាជាតិ MTDSG Database, "Status of Treaties", ជំពូកទី IV.6។

បែងចែកស្មើរតែស្មើគ្នា រវាងអ្នកគាំទ្រមិនឱ្យបញ្ចូលចំណងពាក់ព័ន្ធនៃជម្លោះប្រដាប់អាវុធ និងអ្នកប្រឆាំងនឹងទង្វើបែបនេះ[៣២៥]។

១៤២.ស្រដៀងគ្នានេះដែរ មកត្រឹមថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មានប្រទេសត្រឹមតែ២៥ ប៉ុណ្ណោះដែលបានចុះហត្ថលេខាផ្តល់សច្ចាប័ន ឬចូលជាភាគី នៃអនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍ ដែលកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការប្រកាន់ពូជសាសន៍ ដោយមិនមានលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធ[៣២៦] ក្នុងចំណោមប្រទេសសរុប១៣៤ ដែលជាសមាជិកអង្គការសហប្រជាជាតិ។ មានប្រទេសចំនួន៣២ បន្ថែមទៀតដែលបានចុះហត្ថលេខាក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ក្នុងចំណោមប្រទេសជាសមាជិកបានកើនឡើងរហូតដល់ចំនួន១៤៨[៣២៧]។ ចំណុចនេះមិនបានរាប់បញ្ចូលនូវការអនុវត្តជាទូទៅរបស់រដ្ឋនានាទេ។ ហេតុនេះ ដូចបានកត់សម្គាល់ទាក់ទិននឹងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨ រួចមកហើយគឺថា ការដកចេញនូវលក្ខខណ្ឌនៃចំណងពាក់ព័ន្ធនៃជម្លោះប្រដាប់អាវុធ ចំពោះការប្រកាន់ពូជសាសន៍មិនបានផ្លាស់ប្តូរលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធមួយ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់ផ្សេងទេ។ បន្ថែមទៅទៀត បើតាមអ្វីដែលអង្គបុរេជំនុំជម្រះអាចស្វែងរកបានគឺថា មានឧទាហរណ៍មួយចំនួនតូចនៅក្នុងច្បាប់ជាតិ ដែលកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយពុំចាំបាច់មានលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនេះ។

១៤៣.ជាចុងក្រោយ នៅពេល ILC ផ្តល់អនុសាសន៍ម្តងទៀតឱ្យអនុម័តនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយមិនមានលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធឆ្នាំ ១៩៨៤ នោះមក ការពិភាក្សាដេញ

[៣២៥] គណៈកម្មការសិទ្ធិមនុស្ស របាយការណ៍សម័យប្រជុំលើកទី២៣ ពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៦៧ ដល់ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៦៧ កថាខណ្ឌ១៤៤-១៤៥ នៅក្នុងកំណត់ហេតុផ្លូវការរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម សម័យប្រជុំលើកទី៤២ Supp. No. 6។

[៣២៦] *អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប និងការផ្តន្ទាទោស ចំពោះឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍* (ចូលជាធរមាននៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៦) (អនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍ ឆ្នាំ ១៩៧៤) សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 3068 (XXVIII), 28 U.N. GAOR Supp. (No. 30) at 75, U.N. Doc. A/9030 (ឆ្នាំ ១៩៧៤) 1015 U.N.T.S. 243។ កំណត់សម្គាល់នៃបុព្វកថានៅក្នុងកថាខណ្ឌ៦ និង៧ នៅពេលដែលការប្រកាន់ពូជសាសន៍ត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងមាត្រា II នៅពេលដែល *ចំណងពាក់ព័ន្ធ* ត្រូវបានលុបចោល នៅក្នុងនិយមន័យនៃការប្រកាន់ពូជសាសន៍។

[៣២៧] សម្ងហកម្មសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ MTDSG Database, "Status of Treaties" ជំពូកទី IV, 7។

ដោលក្នុងចំណោមអ្នកតំណាងរដ្ឋជាសមាជិកបង្ហាញឱ្យឃើញថា ទំនងជានឹងមានចរន្តនៃទស្សនៈរបស់រដ្ឋជាសមាជិកឱ្យដកចេញនូវលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធ បន្ទាប់ពីអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក មក[៣២៨]។ ទោះជាយ៉ាងណាក្តី មហាសន្និបាតអង្គការសហប្រជាជាតិមិនបានអនុម័តយកនិយមន័យនៅក្នុងសេចក្តីព្រាងនេះទេ។ ជាងនេះទៀត ដូចបានរៀបរាប់ខាងលើរួចមកហើយគឺថា ទោះបីក្រុមប្រឹក្សាសន្តិសុខបានលុបចោលនូវចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធនៅក្នុងលក្ខន្តិកៈតុលាការ ICTR ឆ្នាំ ១៩៩៤ ក៏ដោយ ក៏ក្រុមប្រឹក្សានេះបានបញ្ចូលចំណុចនេះនៅក្នុងនិយមន័យដំបូងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានចងក្រងជាបញ្ហាមួយនៃច្បាប់អន្តរជាតិនៅក្នុងលក្ខន្តិកៈតុលាការ ICTY ឆ្នាំ ១៩៩៣ ដែរ ចាប់តាំងពីមានគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ មក។ ជាចុងក្រោយ ការខ្វែងយោបល់គ្នាទៅលើលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធនៅមាន រហូតដល់មានសន្និសីទដើម្បីបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ[៣២៩] ដែលត្រូវបានសម្រេចជាចុងក្រោយនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមឆ្នាំ ១៩៩៨ ដែលមិនតម្រូវឱ្យមានចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធទេ[៣៣០]។

---

[៣២៨] សូមមើល៖ យោបល់ និងការសង្កេតដែលទទួលបានពីរដ្ឋាភិបាលនានា អនុលោមតាម សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ៣៦/១០៦ ខែ ឧសភា ឆ្នាំ ១៩៨២ ឯកសារលេខ U.N. Doc. A/CN.4/358 និង Add. 1-4, ទំព័រ ២៧៤-២៧៥ (អង់គ្លេស) (បេឡារុស), ២៧៥ (ឆេកូស្លូវ៉ាគី), ២៧៦ (អាល្លឺម៉ង់ខាងកើត), ២៧៧ (អ៊ុយក្រែន), ២៧៩ (សហភាពសូវៀត), ២៨០ (អ៊ុយរ៉ាហ្គាយ); យោបល់ និងការសង្កេតដែលទទួលបានពីរដ្ឋាភិបាលនានា អនុលោមតាម សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 37/102, ខែ ឧសភា ឆ្នាំ ១៩៨៣ ឯកសារលេខ U.N. Doc. A/CN.4/369 និង Add. 1 and 2, ទំព័រ១៥៤ (អង់គ្លេស) (ស៊ូរីណាម); ការសង្កេតរបស់រដ្ឋជាសមាជិក និងអង្គការអន្តររដ្ឋាភិបាលដែលបានទទួល អនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 39/80 ខែ ឧសភា ឆ្នាំ ១៩៨៥ ឯកសារលេខ A/CN.4/392 និង Add.1 & 2, ទំព័រ៨៦ (អង់គ្លេស) (ម៉ុងហ្គោលី)។

[៣២៩] Herman von Hebel និង Darryl Robinson, "Crimes within the Jurisdiction of the Court" in Roy Lee (ed), *The International Criminal Court: The Making of the Rome Statute: Issues, Negotiations, Results*, ឆ្នាំ ១៩៩៩ ទំព័រ៧៩ ត្រង់ទំព័រ៩២ (អង់គ្លេស)។

[៣៣០] *លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ* លេខ 2187 U.N.T.S. 3 (អនុញ្ញាតឱ្យចុះហត្ថលេខានៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ចូលជាធរមាននៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០២) មាត្រា៧ (និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានលុបចោលលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធ) មានប្រទេសចំនួន ៧១ បានក្លាយជាភាគីហត្ថលេខីភ្លាមនៅឆ្នាំ ១៩៩៨ ហើយបានកើនចំនួន ១៣៩ ប្រទេស នៅឆ្នាំ ២០១០ ដោយមានរដ្ឋចំនួន ១១៤ បានផ្តល់សច្ចាប័នទៅលើសន្និសញ្ញានេះ)។

00686551

១៤៤. សរុបមក ក្នុងករណីមិនមានការអនុវត្តច្បាស់លាស់របស់រដ្ឋនានា និង *ទស្សនៈច្បាប់* (*opinio juris*) ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលបង្ហាញឱ្យឃើញពីការផ្តាច់ចេញនូវលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ គោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* (*in dubio pro reo*) អះអាងថា ភាពមិនច្បាស់លាស់ត្រូវតែដោះស្រាយដោយផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ។ ហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់អន្តរជាតិ បានបញ្ចូលនូវលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ដូចដែលមានចែងនៅក្នុងធម្មនុញ្ញតុលាការ Nuremberg និងគោលការណ៍ Nuremberg ដូចដែលតម្រូវឱ្យមានទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងសន្តិភាពដែរ មានន័យថា ទំនាក់ទំនងរវាងអំពើជាមូលដ្ឋានដែលត្រូវបានចោទប្រកាន់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ។ ជាងនេះទៀត ការបំពារបំពានធ្ងន់ធ្ងរ និងឧក្រិដ្ឋកម្មសង្គ្រាមធ្ងន់ធ្ងរតាមអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ត្រូវបានហាមឃាត់ជាបញ្ហាមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលទាក់ទិននឹងជម្លោះប្រដាប់អាវុធអន្តរជាតិផង និងផ្ទៃក្នុងប្រទេសផង នាពេលនោះ ចំណងពាក់ព័ន្ធចាំបាច់ចំពោះជម្លោះប្រដាប់អាវុធអន្តរជាតិផង និងផ្ទៃក្នុងប្រទេសផង[៣៣១]។ ទោះបីអង្គជំនុំជម្រះសាលាដំបូងមិនបានធ្វើការសន្និដ្ឋានក្នុងសាលក្រមលើរឿងក្តី *ឌុច*[៣៣២] ទាក់ទិននឹងការណ៍ដែលអង្គជំនុំជម្រះនេះយកឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមកអនុវត្តនៅក្នុងករណីនោះក៏ដោយ ក៏អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បញ្ហាអត្ថិភាពនៃលក្ខខណ្ឌតម្រូវជម្លោះប្រដាប់អាវុធ មិនត្រូវបានជំទាស់ជាក់លាក់ដោយជនជាប់ចោទទេ ហេតុនេះហើយវាមិនមែនជាបញ្ហាដែលអង្គបុរេជំនុំជម្រះត្រូវដោះស្រាយឡើយ។ ផ្អែកទៅលើអំណះអំណាងដែលមានពីមុនៗ អង្គបុរេជំនុំជម្រះទទួលយកផ្នែកនេះនៃមូលដ្ឋានទីបួន នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និងសម្រេចថា ក.ស.ច.ស មានការភ័ន្តច្រឡំដោយខកខានមិនបានបញ្ចូលលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ជាផ្នែកនៃនិយមន័យរបស់វា នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

---

[៣៣១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić*, សំណុំរឿងលេខ IT-94-1-T, "សេចក្តីសម្រេចលើពាក្យសុំរបស់មេធាវីការពារក្តីទៅលើយុត្តាធិការ" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១០ សីហា ឆ្នាំ ១៩៩៥ កថាខណ្ឌទី ២។

[៣៣២] សាលក្រមលើរឿងក្តី *ឌុច* កថាខណ្ឌ២៩១-២៩២។

១៤៥. បើត្រឡប់មកពិចារណាថា តើគេអាចបន្ថែមលក្ខខណ្ឌតម្រូវនេះទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឬទេ និង តើអាចរក្សាការចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានរួចមកហើយឬទេនោះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដីកាដែលរងការជំទាស់មិនបានពណ៌នាជាក់លាក់ពីអង្គហេតុចាំបាច់ទាក់ទិននឹងលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធទេ ដោយសារ ក.ស.ច.ស យល់ឃើញថា នៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មិនតម្រូវឱ្យមានលក្ខខណ្ឌតម្រូវនេះទេ។ ទោះជាយ៉ាងណាក្ដី ចំពោះបញ្ហាអង្គហេតុមួយ ក.ស.ច.ស ពិតជាបានយល់ឃើញថា៖

> ជម្លោះប្រដាប់អាវុធជាអន្តរជាតិមួយដែលជាការប្រឈមមុខដាក់គ្នា រវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និងកម្ពុជាប្រជាធិបតេយ្យ បានផ្ទុះឡើងសឹងតែភ្លាមៗ បន្ទាប់ពីកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ("CPNLAF") បានចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ ជម្លោះប្រដាប់អាវុធនេះបានអូសបន្លាយយ៉ាងហោចណាស់ រហូតដល់ពេលដែលកងទ័ពវៀតណាមបានវាយចូលដល់ទីក្រុងភ្នំពេញនាថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩ និងនៅពេលក្រោយៗមកទៀត[៣៣៣]។

១៤៦. ជាងនេះទៀត នៅក្នុងសំអាងហេតុរបស់ខ្លួនស្ដីពីសហឧក្រិដ្ឋកម្មរួម ក.ស.ច.ស យល់ឃើញថា "មេដឹកនាំរបស់បក្សកុម្មុយនីស្ដកម្ពុជាមានផែនការរួម ដើម្បីបង្កើតនៅក្នុងប្រទេសកម្ពុជានូវបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័ស តាមរយៈគ្រប់មធ្យោបាយចាំបាច់ តាម "សន្ទុះមហាលោតផ្លោះ" និងដើម្បីការពារបក្ស ប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ" រួមទាំងតាមរយៈ "ការកម្ទេច "ខ្មាំង" ដែលត្រូវបានរកឃើញទាំងនៅក្នុង និងនៅក្រៅបក្ស"[៣៣៤]។

១៤៧. សហព្រះរាជអាជ្ញាក៏បានលើកជាទឡ្ហីករណ៍ស្របគ្នាផងដែរថា មិនចាំបាច់ឱ្យមានចំណងពាក់ព័ន្ធទេ តែបានបន្ថែមថា នៅគ្រប់ករណីទាំងអស់ ចំណងពាក់ព័ន្ធទាំងនោះតែងមានអត្ថិភាពជាដរាប[៣៣៥]។

* អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE * E.C.C.C * C.E.T.C

---

[៣៣៣] ដីកាដែលរងការជំទាស់ កថាខណ្ឌ១៥០។ សូមមើលផងដែរ កថាខណ្ឌ១៥១-១៥៥។

[៣៣៤] ដីកាដែលរងការជំទាស់ កថាខណ្ឌទី១៥៦, ១៥៧។

[៣៣៥] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌទី១៨០។

00686553

១៤៨. ទោះបីជាអាចមានការតម្រូវឱ្យមានលក្ខណៈពិសេសដោយឡែក ដើម្បីជូនដំណឹងដល់ជនជាប់ចោទឱ្យបានពេញលេញពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ប្រឆាំងនឹងខ្លួនគេក៏ដោយ[៣៣៦] ក៏ចំណុចនេះអាចធ្វើបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងមិនត្រូវរារាំងឱ្យអង្គបុរេជំនុំជម្រះរក្សាទុកនូវការចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងដំណាក់កាលនេះនៅក្នុងកិច្ចដំណើរការនីតិវិធីទេ ទោះបីមានបន្ថែមនូវ "អត្ថិភាពនៃចំណងពាក់ព័ន្ធរវាងអំពើនានាជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធ" ទៅក្នុងលក្ខខណ្ឌតម្រូវនៃ "ធាតុផ្សំរួម" នៅក្នុងជំពូកទី៤ (ក) នៃផ្នែកទី៣ នៅក្នុងដីកាដំណោះស្រាយក៏ដោយ។

(iii) បញ្ហាថាតើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បានបញ្ចូលការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរឬទេ

១៤៩. នៅក្នុងដីកាដែលរងការជំទាស់ សហចៅក្រមស៊ើបអង្កេតបានសម្រេចថា "មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់នៃការរំលោភលើផ្លូវភេទ នៅក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"[៣៣៧]។ បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ បានជំទាស់ថា ដោយសារការរំលោភលើផ្លូវភេទមិនត្រូវបានបញ្ចូលឱ្យបានច្បាស់លាស់ទៅក្នុងធម្មនុញ្ញតុលាការ IMT ធម្មនុញ្ញតុលាការ IMTFE ឬគោលការណ៍ Nuremberg ការរំលោភលើផ្លូវភេទមិនត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ទេ[៣៣៨]។ បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ បានអះអាងបន្ថែមទៀតនៅជើងទំព័រថា ការរំលោភលើផ្លូវភេទត្រឹមតែត្រូវបានទទួលស្គាល់ជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយនៅឆ្នាំ ១៩៩៨ ប៉ុណ្ណោះ ដោយតុលាការ ICTR នៅក្នុង*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Akayesu*[៣៣៩]។ ហេតុនេះ រវាងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដើមបណ្តឹងឧទ្ធរណ៍មិនអាចប្រមើលមើល ឬដឹងថាមានច្បាប់ចែងជា

[៣៣៦] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា៣៥ (ថ្មី) (១)(ក)។

[៣៣៧] ដីកាដែលរងការជំទាស់ កថាខណ្ឌទី១៤៣០។

[៣៣៨] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌទី៦១។

[៣៣៩] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌទី៦៤។

មុនបានថា និងដឹងថាខ្លួននឹងត្រូវយកទៅផ្តន្ទាទោសពីបទរំលោភលើផ្លូវភេទ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយឡើយ[៣៨០]។

១៥០. អង្គបុរេជំនុំជម្រះយល់ស្របទៅនឹងអង្គជំនុំជម្រះសាលាដំបូង ICTY ក្នុង *រឿងក្តី* *Kunarac* នៃតុលាការដែលបានសម្រេចថា "ការរំលោភលើផ្លូវភេទជាការឈឺចាប់មួយដ៏ធ្ងន់ធ្ងរបំផុត ក្នុងចំណោមការឈឺចាប់ធ្ងន់ធ្ងរដទៃទៀត ដែលមនុស្សម្នាក់អាចធ្វើទៅលើមនុស្សម្នាក់ទៀត"[៣៨១]។ អំពើរំលោភលើផ្លូវភេទជាអំពើគួរឱ្យស្អប់ខ្ពើម និងធ្វើឱ្យរន្ធត់ជាខ្លាំងដល់មនុស្សគ្រប់រូប។ ការរំលោភលើផ្លូវភេទបង្កើតជាការរំលោភធ្ងន់ធ្ងរដល់បូរណភាពរាងកាយរបស់ជនរងគ្រោះ បន្ថែមទៅលើការដែលបណ្តាលឱ្យមានផលវិបាកធ្ងន់ធ្ងរអស់មួយជីវិតទៅលើផ្លូវចិត្តរបស់ជនរងគ្រោះផងដែរ។ ទោះជាយ៉ាងណាក្តី ដូចដែលចៅក្រម Robertson បានបញ្ចេញទស្សនៈជំទាស់របស់ខ្លួនរួចមកហើយ នៅក្នុងតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនក្នុង*រឿងក្តីទាហានជាកុមារ* ថា "វាជាការច្បាស់លាស់ណាស់នៅពេលដែលអំពើទាំងនោះមានលក្ខណៈគួរឱ្យស្អប់ខ្ពើម និងគួរឱ្យរន្ធត់ខ្លាំងពេកដែលថា គោលការណ៍នីត្យានុកូលភាពត្រូវតែយកមកអនុវត្តឱ្យបានតឹងរ៉ឹងបំផុត ដើម្បីធានាថា ចុងចោទមិនត្រូវបានផ្តន្ទាទោសដោយសារការស្អប់ខ្ពើម ជាជាងមានភស្តុតាងគ្រប់គ្រាន់ ឬពីបទល្មើសដែលមិនមានរូបរាង"[៣៨២]។ អាស្រ័យហេតុនេះ ទោះបីការរំលោភលើផ្លូវភេទត្រូវបានកំណត់យ៉ាងច្បាស់តាមមាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏អង្គបុរេជំនុំជម្រះត្រូវពិចារណាថា តើអំពើនេះត្រូវបានកំណត់ជាបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឬទេ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

---

[៣៨០] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌទី៦១-៦២។

[៣៨១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកដទៃទៀត*, សំណុំរឿងលេខ IT-96-23-T និង IT-96-23/1-T, "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌទី៦៥៥, ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី១៩០។

[៣៨២] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Norman*, សំណុំរឿងលេខ SCSL-04-14-AR72(E), "យោបល់ជំទាស់របស់ចៅក្រម Robertson ទៅលើពាក្យសុំបឋមដោយផ្អែកលើកង្វះយុត្តាធិការ (ការជ្រើសរើសកុមារឱ្យធ្វើការ)" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៤ កថាខណ្ឌ១៣។

១៥១. បទល្មើសរំលោភលើផ្លូវភេទត្រូវបានហាមឃាត់តាំងពីយូរយារណាស់មកហើយ ដោយសារថាជាឧក្រិដ្ឋកម្មសង្គ្រាម ដែលមានចាប់តាំងពីយ៉ាងហោចណាស់ក៏នៅពេលបង្កើត Lieber Code ឆ្នាំ ១៨៦៣ ដែរ[៣៤៣]។ បញ្ញត្តិ Oxford Manual ដែលត្រូវបានតាក់តែងសេចក្តីព្រាងដោយវិទ្យាស្ថានច្បាប់អន្តរជាតិនាឆ្នាំ ១៨៨០ ដែលចែងថា "កិត្តិយស និងសិទ្ធិរបស់ក្រុមគ្រួសារ" ដែលជាពាក្យសម្រាលសំដៅដល់ការហាមឃាត់មិនឱ្យមានការរំលោភលើផ្លូវភេទ[៣៤៤] និងការវាយប្រហារផ្លូវភេទត្រូវតែគោរពនិងចាត់ទុកជាផ្នែកមួយនៃច្បាប់ និងទំនៀមទម្លាប់សង្គ្រាម[៣៤៥]។ អនុសញ្ញាទីក្រុងឡាអេ ឆ្នាំ ១៨៩៩[៣៤៦] និងឆ្នាំ ១៩០៧[៣៤៧] បានកំណត់លក្ខខណ្ឌតម្រូវដូចៗគ្នា ហើយត្រូវបានពង្រឹងដោយការការពារទូទៅនៅក្នុង Martens Clause[៣៤៨]។ បន្ទាប់មក ការរំលោភលើផ្លូវភេទត្រូវបានហាមឃាត់ជាក់លាក់នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩[៣៤៩] ពិធីសារបន្ថែមទី I ឆ្នាំ ១៩៧៧[៣៥០] និង ពិធី

[៣៤៣] Lieber Code មាត្រា៤៤៖ "អំពើហិង្សាសាហាវព្រៃផ្សៃដែលបានប្រព្រឹត្តប្រឆាំងនឹងមនុស្សនៅក្នុងប្រទេសដែលត្រូវបានលុកលុយ ... រាល់ *ការរំលោភលើផ្លូវភេទ* ការធ្វើឱ្យរបួស ការធ្វើឱ្យពិការ ឬការសម្លាប់ប្រជាជនទាំងនោះ ត្រូវបានហាមឃាត់ដោយបញ្ញត្តិនៃទោសប្រហារជីវិត ឬការផ្តន្ទាទោសធ្ងន់ធ្ងរដទៃទៀត ដែលអាចសមរម្យចំពោះស្ថានទម្ងន់នៃបទល្មើសនោះ" (គូសបញ្ជាក់បន្ថែម)។

[៣៤៤] Chrif Bassiouni, *Crimes Against Humanity in International Criminal Law*, Kluwer Law International, The Hague: ឆ្នាំ ១៩៩៩ ទំព័រ៣៤៨ (អង់គ្លេស)។

[៣៤៥] *ច្បាប់ស្តីពីសង្គ្រាមលើដីគោក* អនុម័តដោយវិទ្យាស្ថានច្បាប់អន្តរជាតិ Oxford ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ១៨៨០ ("Oxford Manual") មាត្រា៤៩៖ "កិត្តិយស និងសិទ្ធិរបស់ក្រុមគ្រួសារ ជីវិតរស់នៅរបស់បុគ្គល រួមទាំងជំនឿ និងការគោរពប្រណិប័តន៍សាសនាត្រូវតែគោរព"។

[៣៤៦] *បទបញ្ញត្តិទីក្រុងឡាអេ ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក និងឧបសម្ព័ន្ធនៃអនុសញ្ញា (II) ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក* ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩ ("បទបញ្ញត្តិទីក្រុងឡាអេឆ្នាំ ១៨៩៩") មាត្រា៤៦៖ "កិត្តិយស និងសិទ្ធិរបស់ក្រុមគ្រួសារ ជីវិតរស់នៅ និងទ្រព្យសម្បត្តិឯកជនរបស់បុគ្គល រួមទាំងជំនឿ និងសេរីភាពខាងសាសនាត្រូវតែគោរព"។

[៣៤៧] *បទបញ្ញត្តិទីក្រុងឡាអេ ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក និងឧបសម្ព័ន្ធនៃអនុសញ្ញា (IV) ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដីគោក* ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧ ("បទបញ្ញត្តិទីក្រុងឡាអេឆ្នាំ ១៩០៧") មាត្រា៤៦៖ "កិត្តិយស និងសិទ្ធិរបស់ក្រុមគ្រួសារ ជីវិតរស់នៅរបស់បុគ្គល និងទ្រព្យសម្បត្តិឯកជន រួមទាំងជំនឿ និងការគោរពប្រណិប័តន៍សាសនាត្រូវតែគោរព"។

[៣៤៨] អនុសញ្ញាទីក្រុងឡាអេ (II) បុព្វកថា។

[៣៤៩] អនុសញ្ញាទីក្រុងហ្សឺណែវទី IV មាត្រា២៧ (២)។

[៣៥០] ពិធីសារបន្ថែមទី I មាត្រា៧៦(១) (អនុម័តជាឯកច្ឆន្ទ)។

សារបន្ថែមទី II ឆ្នាំ ១៩៧៧[៣៥១]។ ហេតុនេះ វាជាការច្បាស់លាស់ណាស់ដែលថា ការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មសង្គ្រាមមុនឆ្នាំ ១៩៧៥ ហើយត្រូវបានបញ្ជាក់បែបនេះដោយពិធីសារបន្ថែម ក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ទៀតផង។

១៥២. មុនឆ្នាំ ១៩៧៥ ការរំលោភលើផ្លូវភេទត្រូវបានកំណត់ជាបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមមាត្រា II (១)(គ) នៃច្បាប់របស់ក្រុមប្រឹក្សាគ្រប់គ្រង ទោះបីមិនមានឧទាហរណ៍នៃការផ្តន្ទាទោសលើការរំលោភលើផ្លូវភេទ អនុលោមតាមច្បាប់នេះ នៅចំពោះមុខតុលាការ NMTs ក៏ដោយ[៣៥២]។ ដូចបានកត់សម្គាល់ខាងលើរួចមកហើយគឺថា ទាំងធម្មនុញ្ញតុលាការ IMT និងធម្មនុញ្ញតុលាការ IMTFE សុទ្ធតែបានបញ្ចូលការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ភស្តុតាងនៃការរំលោភលើផ្លូវភេទត្រូវបានអានដោយរដ្ឋអាជ្ញាបារាំង និងសូវៀត ដើម្បីបញ្ចូលក្នុងកំណត់ហេតុនៅតុលាការ IMT[៣៥៣] ទោះជាយ៉ាងណាក្តី មិនមានចំណុចណាមួយនៅក្នុងសាលក្រមតុលាការ Nuremberg (IMT) និយាយពីការរំលោភលើផ្លូវភេទ ហើយមិនមានចុងចោទត្រូវបានផ្តន្ទាទោសពីបទល្មើសរំលោភលើផ្លូវភេទជាបទឧក្រិដ្ឋណាមួយឡើយ កុំថាឡើយដល់ទៅចាត់ទុកថាវាជាឧក្រិដ្ឋកម្មប្រឆាំង

---

[៣៥១] ពិធីសារបន្ថែមទី II មាត្រា៤(២)(ង) (អនុម័តជាឯកច្ឆន្ទ)។

[៣៥២] សម្រាប់ការលើកឡើងនូវបទល្មើសលើផ្លូវភេទដទៃទៀត សូមមើល៖ *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Karl Brandt និងអ្នកដទៃទៀត* ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៤៧ បោះពុម្ពសាជាថ្មីនៅក្នុង *NMT Trials*, Vols I-II ទំព័រទី ៣ ("រឿងក្តី *គ្រូពេទ្យ*") ត្រង់ Vol. I ទំព័រ៦៩៤-៧៣៨ Vol. II ទំព័រ១៧៧ (អង់គ្លេស) (ការធ្វើមិនឱ្យមានកូនដោយបង្ខំ និងការក្រៀវ), *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Oswald Pohl និងអ្នកដទៃទៀត* ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ១៩៤៧ បោះពុម្ពសាជាថ្មីនៅក្នុង *NMT Trials,* Vol. V ទំព័រ១៩៥ (អង់គ្លេស) ("រឿងក្តី *Pohl*") ត្រង់ Vol. V ទំព័រ៩៨៣ ១១០៥ ១១០៨ (ភស្តុតាងនៃការពន្លូតកូនដោយបង្ខំ និង "កន្លែងសោភីនី" នៅក្នុងជំរំប្រមូលផ្តុំ), *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Ulrich Greifelt និងអ្នកដទៃទៀត* ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៤៨ បោះពុម្ពសាជាថ្មីនៅក្នុង *NMT Trials,* Vol. . IV – V ទំព័រ៥៩៩ (អង់គ្លេស) ("រឿងក្តី RuSHA")

(ការពន្លូតកូនដោយបង្ខំ ការធ្វើទុក្ខបុកម្នេញដោយការបញ្ញាភេទ និងឧក្រិដ្ឋកម្មទៅលើការបន្តពូជ)។

[៣៥៣] សូមមើល សាលក្រមតុលាការយោធាអន្តរជាតិ ត្រង់ Vol 6 ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ទំព័រ៤០៤-៤០៧ (អង់គ្លេស) Vol 7 ប្រតិចារឹក ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៤៦ ទំព័រ ៤៥៦-៤៥៧ (អង់គ្លេស) (អានជាភស្តុតាងនៅក្នុង "កំណត់ហេតុរបស់ Molotov" ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៤២)។

មនុស្សជាតិនោះ[៣៥៤]។ ហេតុនេះ មហាសន្និបាតអង្គការសហប្រជាជាតិមិនបានទទួលស្គាល់ថា ការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ នៅពេលដែលមហាសន្និបាតនេះបញ្ជាក់ទទួលស្គាល់នូវគោលការណ៍ Nuremberg នោះ។ សាលក្រមតុលាការ IMTFE បានរកឃើញថា Iwane Matsui និង Kōki Hirota មានពិរុទ្ធភាពដោយខកខានមិនបានទប់ស្កាត់មិនឱ្យមានការរំលោភលើផ្លូវភេទទៅលើស្ត្រីប្រមាណ ២០.០០០ នាក់នៅក្រុងណានគីង ប៉ុន្តែការរំលោភលើផ្លូវភេទត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មសង្គ្រាម មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ[៣៥៥]។ ក.ស.ច.ស[៣៥៦] មិនបានបង្ហាញប្រភពណាមួយដល់អង្គបុរេជំនុំជម្រះ ដែលចាត់ទុកការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជាបទល្មើសមានលក្ខណៈទំនៀមទម្លាប់នៅមុនពេល ឬក្នុងអំឡុងពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ ហើយនៅក្នុងចម្លើយតបរួមរបស់ខ្លួន សហព្រះរាជអាជ្ញាក៏មិនមានបង្ហាញប្រភពទាំងនេះដែរ[៣៥៧]។

១៥៣.សហព្រះរាជអាជ្ញាលើកជាទឡ្ហីករណ៍ថា ដោយសារការរំលោភលើផ្លូវភេទត្រូវបានកំណត់ជាបទល្មើសតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ នោះ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ អៀង ធីរិទ្ធ អាចប្រមើលមើល

---

[៣៥៤] Kelly Askin, "Prosecuting Wartime Rape and Other Gender-Related Crimes under International Law: Extraordinary Advances, Enduring Obstacles", *Berkeley Journal of International Law*,ឆ្នាំ ២០០៣ ទំព័រ៣០១ (អង់គ្លេស)។

[៣៥៥] សម្រាប់ផ្នែកស្តីពី "ការរំលោភលើផ្លូវភេទនៅទីក្រុងណានគីង" និងការរំលោភលើផ្លូវភេទជាទូទៅ សូមមើលសាលក្រមតុលាការ IMTFE ទំព័រ៥៣៥-៥៤១, ៥៤៦, ៥៤៨-៥៤៩, ៦០៤ ៦១១-៦១២ (អង់គ្លេស); សូមមើលផងដែរ *ការជំនុំជម្រះទោសឧត្តមសេនីយ៍ Tomoyuki Yamashita* សំណុំរឿងលេខ២១ សាលក្រមរបស់តុលាការយោធាសហរដ្ឋអាមេរិក ក្រុងម៉ានីល ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ១៩៤៥ ដល់ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ១៩៤៥ បោះពុម្ពសាជាថ្មីនៅក្នុង *របាយការណ៍នៃការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាម,* ជ្រើសរើស និងរៀបចំដោយគណៈកម្មការឧក្រិដ្ឋសង្គ្រាមរបស់អង្គការសហប្រជាជាតិ ក្រុងឡុងដ៍ HMSO, ឆ្នាំ ១៩៤៨ Vol. IV ("សាលក្រមលើរឿងក្តី *Yamashitat*"; *In re Yamashita,* តុលាការកំពូលសហរដ្ឋអាមេរិក, សាលដីកា ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ១៩៤៦ សំណុំរឿងលេខ 327 US 1, 66 S.Ct. 340, 90 L.Ed. 499 (ឆ្នាំ ១៩៤៦) បោះពុម្ពសាជាថ្មីដោយផ្នែក នៅក្នុងរបាយការណ៍នៃការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាម, ជ្រើសរើស និងរៀបចំដោយគណៈកម្មការឧក្រិដ្ឋសង្គ្រាមរបស់អង្គការសហប្រជាជាតិ ក្រុងឡុងដ៍ HMSO, ឆ្នាំ ១៩៤៨ Vol. IV ("សាលដីកាតុលាការកំពូលសហរដ្ឋអាមេរិកលើរឿងក្តីYamashita")។

[៣៥៦] ដីកាដែលរងការជំទាស់ ជើងទំព័រលេខ២៥៧០ និង២៥៧១។

[៣៥៧] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ជើងទំព័រលេខ៤៨៥-៤៩៤។

ដឹងថា ការរំលោភលើផ្លូវភេទបានបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយ[៣៥៨]។ អង្គបុរេជំនុំជម្រះសូមរំឮកថា ប្រភពមួយទៀតនៃច្បាប់អន្តរជាតិគឺ "គោលការណ៍ទូទៅរបស់ច្បាប់ដែលត្រូវបានទទួលស្គាល់ដោយបណ្តាប្រជាជាតិដែលមានអារ្យធម៌ខ្ពង់ខ្ពស់"[៣៥៩]។ នៅពេលវេលាដែលពាក់ព័ន្ធ ការរំលោភលើផ្លូវភេទស្ទើរតែត្រូវបានចាត់ទុកជាបទល្មើសជាសកលទៅហើយ នៅក្នុងច្បាប់ព្រហ្មទណ្ឌថ្នាក់ជាតិ ទោះបីមានការប្រើប្រាស់និយមន័យនៃពាក្យថារំលោភលើផ្លូវភេទនេះខុសៗគ្នាក៏ដោយ[៣៦០]។ ទោះបីជាយ៉ាងណាក្តី ការរំលោភលើផ្លូវភេទ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមានធាតុផ្សំទាំងអស់ដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ដូចជាលក្ខខណ្ឌតម្រូវដែលជាផ្នែកមួយនៃ "ការវាយប្រហារយ៉ាងទូលំទូលាយ ឬជាប្រព័ន្ធ"[៣៦១]។ ការរំលោភលើផ្លូវភេទដែលច្បាប់ព្រហ្មទណ្ឌថ្នាក់ជាតិកំណត់និយមន័យ មិនមានធាតុផ្សំបែបនេះទេ។ អង្គហេតុនានាដែលនាំឲ្យការរំលោភលើផ្លូវភេទក្លាយជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចនឹងគាំទ្រដល់ការចោទប្រកាន់ទោសចំពោះការរំលោភលើផ្លូវភេទតាមច្បាប់ជាតិដែរ តែការរំលោភលើផ្លូវភេទនៅក្នុងច្បាប់ថ្នាក់ជាតិមិនបានគាំទ្រដល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ដោយសារថា ព្រឹត្តិការណ៍ដាច់ដោយឡែកដែលមិនពាក់ព័ន្ធនឹងអំពើដែលគួរឲ្យរន្ធត់ធំៗ មិនអាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានទេ។ នៅក្នុងបរិបទមួយទៀត

---

[៣៥៨] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ១៩០។

[៣៥៩] លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិ មាត្រា៣៨(១)(គ)។

[៣៦០] សូមមើលជាឧទាហរណ៍៖ *ក្រមព្រហ្មទណ្ឌ* (ឆ្នាំ ១៩៥៦) មាត្រា៤៤៣ (កម្ពុជា), *ក្រមព្រហ្មទណ្ឌ* (ឆ្នាំ ១៨១០) មាត្រា៣៣១-៣៣៣ (បារាំង), *ក្រមព្រហ្មទណ្ឌ* (ច្បាប់លេខ៤៥ ឆ្នាំ ១៩០៧) មាត្រា១៧៧-១៧៨ (ជប៉ុន), ក្រមព្រហ្មទណ្ឌ (ordinance 4 of 1871; 1970 Ed. Cap. 103), មាត្រា ៣៧៥ (សិង្ហបុរី) *ក្រមព្រហ្មទណ្ឌឥណ្ឌា* (ច្បាប់លេខ៤៥ ឆ្នាំ ១៨៦០) មាត្រា៣៧៥ (ឥណ្ឌា), *ក្រមព្រហ្មទណ្ឌ* (លេខ៥៨ ឆ្នាំ ១៩៣៧) មាត្រា២៦៧-២៦៨ (អេហ្ស៊ីប), *ក្រមព្រហ្មទណ្ឌ* (ច្បាប់លេខ២៩ ឆ្នាំ ១៩៦០) ផ្នែក៩៨ (ហ្គាណា), *ក្រមព្រហ្មទណ្ឌ RSFSR* (ឆ្នាំ ១៩៦០ ត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី ១ ខែ មីនា ឆ្នាំ ១៩៧២) មាត្រា១១៧ (សាធារណរដ្ឋសង្គមនិយមសហព័ន្ធសូវៀតនៃរុស្ស៊ី ស.ស.ស.ស), *Código Penal* (Decreto-Lei No. 2.848 de 1940) មាត្រា២១៣-២១៥ (ប្រេស៊ីល), *ច្បាប់ព្រហ្មទណ្ឌ* (ច្បាប់សាធារណៈលេខ៤៣ ឆ្នាំ១៩៦១) ផ្នែក១២៨ (ញូវហ្សេលែន), *ច្បាប់ស្តីពីក្រមព្រហ្មទណ្ឌឆ្នាំ ១៨៩៩* ផ្នែក៣៤៩ (Queensland, អូស្ត្រាលី), *ក្រមព្រហ្មទណ្ឌរដ្ឋ California* (ឆ្នាំ ១៨៧៣) ផ្នែក ២៦១-២៦៩ (California, សហរដ្ឋអាមេរិក)។

[៣៦១] សាលក្រមលើ*សំណុំរឿង ឌុច* កថាខណ្ឌទី៣០០។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សំណុំរឿងលេខ IT-94-1-T "ទស្សនៈ និងសាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៩៧ កថាខណ្ឌ៦៤៦-៦៤៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Akayesu* សំណុំរឿងលេខ ICTR-96-4-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ៥៧៩។

E.C.C.C * C.E.T.C
PRE-TRIAL CHAMBER

00686559

អង្គបុរេជំនុំជម្រះធ្លាប់បានពិចារណាថាតើ បទល្មើសជាតិ និងបទល្មើសអន្តរជាតិអាចត្រូវបានចាត់ទុកថាមានន័យដូចគ្នាឬទេ។ អង្គបុរេជំនុំជម្រះបានសម្រេចថា ដោយសារធាតុផ្សំនៃបទល្មើសទាំងពីរប្រភេទមិនដូចគ្នាបេះបិទនោះ បទល្មើសជាតិ និងបទល្មើសអន្តរជាតិត្រូវបានចាត់ទុកជាបទល្មើសដាច់ពីគ្នា[៣៦២]។ អាស្រ័យហេតុនេះ ការរំលោភលើផ្លូវភេទតែឯកឯងមិនអាចបញ្ចូលទៅក្នុងច្បាប់អន្តរជាតិ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានទេ ដោយសារគោលការណ៍ទូទៅរបស់ច្បាប់ ដែលត្រូវបានទទួលស្គាល់ដោយបណ្ដាប្រជាជាតិដែលមានអារ្យធម៌ខ្ពង់ខ្ពស់។ ផ្ទុយទៅវិញ គោលការណ៍ទាំងនេះអាចត្រឹមតែជួយបញ្ជាក់ឲ្យបានច្បាស់ពី *កត្តាសត្យានុម័ត* និង*កត្តាអត្តនោម័ត* នៃការរំលោភលើផ្លូវភេទតែប៉ុណ្ណោះ នៅពេលដែលអត្ថិភាពនៃធាតុផ្សំរួមនៃបទល្មើសត្រូវបានបង្កើតឡើងរួចហើយ[៣៦៣]។

១៥៤. អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ក.ស.ច.ស មានការភ័ន្តច្រឡំក្នុងការចោទប្រកាន់ការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដែលមានរៀបរាប់ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៣៦៤]។ ហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចលុប "ការរំលោភលើផ្លូវភេទ" ចេញពីកថាខណ្ឌ១៦១៣ នៃដីកាដំណោះស្រាយ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ កថាខណ្ឌ(ញ))។ ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះយល់ស្របជាមួយសហ

---

[៣៦២] *ករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច"* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស (អបជ០២) "សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារលេខ D99/3/42 កថាខណ្ឌទី ៧២ និង៨៤។

[៣៦៣] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Furundžija* សំណុំរឿងលេខ IT-95-17/1-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨ កថាខណ្ឌ១៧៧៖ "ការសម្រេចយកនិយមន័យនៃការរំលោភលើផ្លូវភេទ គឺផ្អែកលើគោលការណ៍ច្បាប់ព្រហ្មទណ្ឌនៃភាពជាក់លាក់ ... វាជាការចាំបាច់ដែលត្រូវមើលទៅលើគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌរួម នៃប្រព័ន្ធច្បាប់ធំៗនៅលើពិភពលោក"។ សូមមើលផងដែរ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកដទៃទៀត* សំណុំរឿងលេខ IT-96-23-T និងលេខ IT-96-23/1-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ៤៣៩-៤៦០។

[៣៦៤] អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង មិនបានសម្រេចចេញសេចក្ដីសន្និដ្ឋាននេះ នៅក្នុងសាលក្រមលើសំណុំរឿង *ឌុច* ទេ នៅពេលមានការកំណត់ថាច្បាប់ដែលមានជាធរមានចាត់ទុកការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (សូមមើល កថាខណ្ឌ២៩៣, ៣៦១)។ ទោះជាយ៉ាងណា ទាក់ទិននឹងលក្ខខណ្ឌតម្រូវនៃចំណាងពាក់ព័ន្ធនៃជម្លោះប្រដាប់អាវុធវិញ បញ្ហានៃការរំលោភលើផ្លូវភេទត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងនៃយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក មិនត្រូវបានជំទាស់ជាពិសេសដោយជនជាប់ចោទទេ ហេតុនេះការជំទាស់នេះមិនអាចធ្វើបាននៅចំពោះមុខអង្គជំនុំជម្រះនេះឡើយ។

E.C.C.C. C.E.T.C. PRE-TRIAL CHAMBER

ចៅក្រមស៊ើបអង្កេតដែលថា "អង្គហេតុនានាដែលចាត់ទុកការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងអំពើអមនុស្សផ្សេងៗទៀត"[៣៦៥] ហើយអាស្រ័យហេតុនេះ អង្គហេតុទាំងនេះត្រូវបានចោទប្រកាន់ជាបទឧក្រិដ្ឋទាំងនោះ។

(iv) <u>បញ្ហាថាតើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បានបញ្ចូលការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ និងការបាត់ខ្លួនដោយបង្ខំ ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ដែរឬទេ</u>

១៥៩. បញ្ហាចុងក្រោយនៅក្នុងមូលដ្ឋាននេះនៃបណ្ដឹងឧទ្ធរណ៍ ដែលបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះគឺថា តើ ក.ស.ច.ស មានការភ័ន្តច្រឡំឬទេ នៅពេលខ្លួនយល់ឃើញថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឬទេ ដែលរួមមានការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[៣៦៦] អំពើហិង្សាផ្លូវភេទ[៣៦៧] និងការបាត់ខ្លួនដោយបង្ខំ[៣៦៨]។ បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ បានបដិសេធថា អំពើដែលបង្កើតជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ទាំងនេះ មិនបានទទួលឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេត្រឹមឆ្នាំ ១៩៧៥[៣៦៩] ទេ។ បន្ថែមទៅទៀត បណ្ដឹងឧទ្ធរណ៍នេះលើកឡើងជាទឡ្ហីករណ៍ថា ប្រភេទខុសគ្នានៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" មិនអាចត្រូវបានចាត់ទុកថា "បទប្បញ្ញត្តិគ្របដណ្ដប់ទាំងអស់" ឡើយ[៣៧០]។ ផ្ទុយទៅវិញ យុត្តាធិការតុលាការ ICTY បានសន្និដ្ឋានថា រង្វាស់រង្វាល់សម្រាប់បកស្រាយនូវអ្វីដែលបង្កើតជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" គួរតែត្រូវឱ្យស្របទៅនឹងបទដ្ឋានអន្តរជាតិ ស្ដីពីសិទ្ធិមនុស្សដូចជាអ្វីដែលបានរកឃើញនៅក្នុងអនុសញ្ញាអន្តរជាតិដែរ[៣៧១]។ ហេតុនេះ បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ បដិសេធថា ដោយសារគ្មានអនុសញ្ញាអន្តរជាតិចាត់ទុកការរៀបពិពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ ឬការបាត់ខ្លួនដោយ

[៣៦៥] ដីកាដែលរងការជំទាស់ កថាខណ្ឌ១៣៣៤។

[៣៦៦] ដីកាដែលរងការជំទាស់ កថាខណ្ឌ១៣១៤, ១៤៤២-៤៧។

[៣៦៧] ដីកាដែលរងការជំទាស់ កថាខណ្ឌ១៣១៤, ១៤៣០-៣៣។

[៣៦៨] ដីកាដែលរងការជំទាស់ កថាខណ្ឌ១៣១៤, ១៤៧០-៧៨។

[៣៦៩] បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ៦១។

[៣៧០] បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ៦១។

[៣៧១] បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ៦១ (ដកស្រង់ពី*រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Kupreskić* សំណុំរឿងលេខ IT-96-16-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ៥៦៦)។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

បង្ខំជាបទល្មើសនោះ និងដោយសារមិនមានច្បាប់ក្នុងស្រុកណាមួយបានចាត់ទុកអំពើទាំងនេះជាបទល្មើសពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះ ក.ស.ច.ស មានការភ័ន្តច្រឡំក្នុងការចោទប្រកាន់អ្នកជាប់ចោទពីអំពើទាំងនេះ ហើយបានរំលោភដល់គោលការណ៍នីត្យានុកូលភាព[៣៧២]។

១៥៦. ទីមួយ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា តាំងពីដំបូងមក "អំពើអមនុស្សធម៌ផ្សេងៗទៀត" *តែឯកឯង* គឺជាបទល្មើសមួយរួចទៅហើយតាមច្បាប់អន្តរជាតិ[៣៧៣]។ ហេតុនេះ អង្គបុរេជំនុំជម្រះមិនយល់ស្រប ជាមួយដើមបណ្តឹងឧទ្ធរណ៍ ដែលតម្រូវឱ្យ ក.ស.ច.ស រៀបរាប់នៅក្នុងដីកាដំណោះស្រាយថា អំពើហិង្សាផ្លូវភេទ ការរៀបពិពាហ៍ពិពាហ៍ដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលអំពើនីមួយៗត្រូវបានកំណត់ជាបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែកពីគ្នា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះ។ ប្រការដែលតម្រូវថា ប្រភេទរងនីមួយៗនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" បង្ហាញពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលតាមច្បាប់អន្តរជាតិ គឺត្រូវបង្ហាញប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" នោះជាការឥតប្រយោជន៍ទេ។ មានន័យថា ការប្រព្រឹត្តដែលអាចត្រូវបានចាត់ទុកជាបទល្មើសអន្តរជាតិតាមទំហំនៃបទល្មើសនោះ ដោយមិនពាក់ព័ន្ធនឹងករណីដែលថា តើការប្រព្រឹត្តនោះត្រូវ ឬមិនត្រូវបានចាត់ទុកជាបទល្មើសមួយជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" មួយទេ។ សម្រាប់សំអាងហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌតម្រូវដែលចាត់ទុកជាបទល្មើសត្រូវភ្ជាប់ជាមួយនឹងប្រភេទ

[៣៧២] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ៦១។

[៣៧៣] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Blagojević *និង Jokić*, សំណុំរឿងលេខ IT-02-60-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង I, ផ្នែក ក, ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ៦២៤ (គូសបញ្ជាក់បន្ថែម); សូមមើលផងដែរ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brima, Kamara និង Kanu* ('រឿងក្តីនៅអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ AFRC'), សំណុំរឿងលេខ SCSL-2004-16-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង II, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧, កថាខណ្ឌ៦៩៧-៦៩៨; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brima, Kamara និង Kanu* ('រឿងក្តីនៅតុលាការ AFRC'), សំណុំរឿងលេខ SCSL-2004-16-A, "សាលដីកា", អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨, កថាខណ្ឌ១៨៣, ១៩៧-១៩៨; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kayeshima និង Ruzindana*, សំណុំរឿងលេខ ICTR-95-1-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌទី៥៨៣; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stakić*, សំណុំរឿងលេខ IT-97-24-A, "សាលដីកា", អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ៣១៦-៣១៧; cf. *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stakić*, សំណុំរឿងលេខ IT-97-24-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង II, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣, កថាខណ្ឌទី៧១៩។

នៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" នោះ ហើយមិនភ្ជាប់ជាមួយការប្រព្រឹត្តជាមូលដ្ឋានដែលបង្កើតជាអំពើអមនុស្សធម៌ផ្សេងៗទៀតទេ។

១៥៧. អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសូមរំឭកថា អង្គបុរេជំនុំជម្រះធ្លាប់បានយល់ឃើញពីលើកមុននៅក្នុងដីកាសម្រេចនេះរួចមកហើយថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានកំណត់ជាបទល្មើសជាបញ្ញាមួយក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដូចដែលមានចែងនៅក្នុងគោលការណ៍ Nuremburg ឆ្នាំ ១៩៥០[៣៧៤]។ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនីមួយៗដែលមានចែង និងយកមកអនុវត្តមុនគោលការណ៍ Nuremburg តាមធម្មនុញ្ញតុលាការ IMT ធម្មនុញ្ញតុលាការ IMTFE និងច្បាប់របស់ក្រុមប្រឹក្សាគ្រប់គ្រង បានចែងជាអំពើមូលដ្ឋានមួយចំនួន ដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបញ្ចូលប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត"[៣៧៥]។ បន្ថែមលើសនេះទៀត ដូចដែលនឹងកត់សម្គាល់ខាងក្រោមដែរគឺថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានជំនុំជម្រះទោសនៅតុលាការ IMT និងនៅក្នុងករណីនៅតុលាការ NMT។ ហេតុដូចនេះ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ត្រូវបានបញ្ចូលទៅក្នុងនិយមន័យដែលចងក្រងក្នុងគោលការណ៍ Nuremburg នៅឆ្នាំ ១៩៥០។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" នេះជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានកំណត់ជាបញ្ញាមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥[៣៧៦]។

១៥៨. ទីពីរ អង្គបុរេជំនុំជម្រះមិនយល់ស្របជាមួយដើមបណ្ដឹងឧទ្ធរណ៍ទេដែលថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" មិនត្រូវចាត់ទុកដូចជាប្រភេទបទល្មើសនៅសេសសល់ ដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ។ ដូចបានកត់សម្គាល់ខាងលើរួចមកហើយ[៣៧៧] អង្គបុរេជំនុំជម្រះសូមរំឭកថា និយមន័យនៃអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានចងក្រងតាមគោលការណ៍ VI(គ) នៃគោលការណ៍ Nuremberg គឺដកស្រង់ចេញពីបុព្វកថានៃសេចក្ដីប្រកាសនៅទីក្រុង St. Petersburg នៅឆ្នាំ ១៨៦៨ និង Martens Clause នៅក្នុងអនុសញ្ញាទីក្រុងឡាអេឆ្នាំ

[៣៧៤] សូមមើល ផ្នែក IV(D)(2)(i)។

[៣៧៥] សូមមើល ផ្នែក IV(D)(2)(i) និងអត្ថបទដកស្រង់ពីផ្នែកនោះ។

[៣៧៦] សាលក្រមលើ *សំណុំរឿង ឌុច* កថាខណ្ឌទី២៨៣, ៣៦៧។

[៣៧៧] សូមមើល ផ្នែក IV(D)(ii)។

១៨៩៩ និង ឆ្នាំ ១៩០៧ ដែលបានអំពាវនាវឱ្យ "ប្រើប្រាស់ទំនៀមទម្លាប់ដែលបានបង្កើតឡើងដោយប្រជាជនដែលមានអារ្យធម៌ខ្ពង់ខ្ពស់ ពីច្បាប់មនុស្សធម៌ និងការបង្គាប់បញ្ជានៃមនសិការសាធារណៈ"[៣៧៨] ជាការការពារបន្ទាប់បន្សំប្រឆាំងនឹងអំពើ ដែលមិនត្រូវបានហាមឃាត់ជាក់លាក់នៅក្នុងអត្ថបទនៃអនុសញ្ញាទីក្រុងឡាអេទ[៣៧៩]។ ទោះបីគោលការណ៍ VI(គ) បានចែងពីអំពើជាក់លាក់ដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងនឹងច្បាប់មនុស្សជាតិក៏ដោយ តែគោលការណ៍បានចែងរៀបរាប់ជាច្រើនចំណុច និងបានរួមបញ្ចូល "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាប្រភេទដែលនៅសេសសល់ ដើម្បីបញ្ចៀសមិនឱ្យមានការផ្លាស់ប្តូរច្បាប់មនុស្សធម៌ទេ នៅក្នុងស្មារតីនៃ Martens Clause[៣៨០]។

១៥៩. ទីបី ដូចដែលបានរៀបរាប់រួចមកហើយ អង្គបុរេជំនុំជម្រះយល់ឃើញថា គោលការណ៍នីត្យានុកូលភាពតម្រូវថា គេត្រូវសម្រេចថាតើមាននិយមន័យដែលមានភាពជាក់លាក់គ្រប់គ្រាន់នៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលមានអត្ថិភាពតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដោយបានបញ្ជាក់ឱ្យបានច្បាស់ នៅពេលដែលការប្រព្រឹត្តណាមួយឡើងដល់កម្រិតនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលអាចឱ្យគេប្រមើលមើលដឹងថាមានច្បាប់ចែង និងដឹងថាទង្វើនោះគឺជាបទឧក្រិដ្ឋ និងដឹងជាមុនថា អំពើនេះអាចនឹងត្រូវជំនុំជម្រះទោសដែលនឹងត្រូវផ្តន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបាន។

១៦០. អង្គបុរេជំនុំជម្រះយល់ឃើញថា នៅពេលគេមើលទៅលើន័យធម្មតានៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ពាក្យថា "ផ្សេងៗទៀត" ទាញចេញពី *គោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយ នូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)* នៃវិធានក្នុងការបកស្រាយ ដែលក្នុងន័យនោះ "អំពើ

---

[៣៧៨] អនុសញ្ញាទីក្រុងឡាអេទី IV ឆ្នាំ ១៨៩៩ បុព្វកថា។ សូមមើលផងដែរ អនុសញ្ញាទីក្រុងឡាអេទី II ឆ្នាំ ១៩០៧ បុព្វកថា។

[៣៧៩] សូមមើលផងដែរ *ICRC Commentary on the IVth Geneva Convention Relative to the Protection of Civilian Persons in Time of War* ក្រុងហ្សឺណែវ ឆ្នាំ ១៩៥៨ បោះពុម្ពសាជាថ្មីនៅឆ្នាំ ១៩៩៤ ទំព័រទី៣៩ (ទាក់ទិននឹង "ការប្រព្រឹត្តបែបអមនុស្សធម៌" នៅក្នុងមាត្រា៣ រួម នៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ឯកសារនេះបានអះអាងថា៖ "ទោះជាមានការយកចិត្តក្នុងការកំណត់ពីទម្រង់ផ្សេងៗនៃការធ្វើបាបក៏ដោយ ក៏គេមិនអាចប្រមើលមើលបានដឹងអស់ពីអ្នកដែលនឹងធ្វើទារុណកម្មនាពេលអនាគត ដែលធ្វើតាមចិត្តខ្លួនដែរ ហើយប្រសិនបើបញ្ជីនោះកាន់តែមានភាពជាក់លាក់ និងពេញលេញពេក នោះកាន់តែធ្វើឱ្យមានការកំហិតកាន់តែតឹងរ៉ឹងទេ")។

[៣៨០] សាលក្រមលើ*សំណុំរឿង ឌុច* កថាខណ្ឌទី ៣៦៧។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kupreškić និងអ្នកដទៃទៀត* សំណុំរឿងលេខ IT-96-16-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌទី ៥៦៣។

អមនុស្សធម៌ផ្សេងៗទៀត" អាចត្រឹមតែរួមបញ្ចូលអំពើនានាដែលមានភាព "អមនុស្សធម៌" និង មាន "លក្ខណៈ និងស្ថានទម្ងន់ស្រដៀងគ្នា" ទៅនឹងអំពើដែលមានចែងជាក់លាក់ពោលគឺ៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ និងការនិរទេស[៣៨១]។ ការបកស្រាយចំពោះ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងយុត្តិសាស្ត្រតុលាការ NMT ដែលចៅក្រមនៃតុលាការនេះបានប្រើប្រាស់ទ្រឹស្តីនៃ *គោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយ នូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)* ដើម្បីបញ្ជាក់ឱ្យបានច្បាស់ថា តើការដកហូតយកទ្រព្យសម្បត្តិត្រូវស្ថិតនៅក្នុងនិយមន័យរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាអំពើដែលមិនបានកំណត់ដោយច្បាប់។ ឧទាហរណ៍ នៅក្នុងរឿងក្តី *Flick* និងបន្ទាប់មកគឺនៅក្នុងរឿងក្តី *I. G. Farben* តុលាការបានសម្រេចថា បទល្មើសដែលមានចែងនៅក្នុងបញ្ញត្តិស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងច្បាប់របស់ក្រុមប្រឹក្សាគ្រប់គ្រងគឺជាបទល្មើសទាំងអស់ដែលប្រឆាំងនឹងមនុស្ស ហើយហេតុនេះ "ត្រូវតែចាត់ទុកថាបានបញ្ចូលត្រឹមតែការប៉ះពាល់ទៅដល់ជីវិត និងសេរីភាពរបស់មនុស្សដែលត្រូវគេសង្កត់សង្កិនតែប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្តីការដកហូតយកទ្រព្យសម្បត្តិឧស្សាហកម្មចាំបាច់ មិនស្ថិតនៅក្នុងប្រភេទនេះទេ"[៣៨២]។ នៅក្នុង*រឿងក្តី* *Eichmann* តុលាការកំពូលអ៊ីស្រាអែលបានសម្រេចថា "ការបណ្តាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរដល់រាងកាយ និងផ្លូវចិត្ត" អាចចាត់ទុកជាអំពើអមនុស្សធម៌មួយទៀតដែលបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិល ដែលកំណត់ដោយពួកណាហ្ស៊ី និងច្បាប់ (ការផ្តន្ទាទោស) ស្តីពីអ្នកសហការណាហ្ស៊ី ផ្នែក១(ក) ដែលបង្កើតឡើងវិញនូវ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងធម្មនុញ្ញតុលាការ Nuremberg (IMT)[៣៨៣]។ តុលាការកំពូលនេះក៏បានសម្រេចផងដែរថា ការរឹបអូសទ្រព្យសម្បត្តិអាចត្រូវបានចាត់ទុកជាអំពើអមនុស្សធម៌មួយ នៅក្នុងន័យនៃនិយមន័យរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅពេលដែល ក្នុងចំណោមចំណុចដទៃទៀត "វាមានទំនាក់ទំនង

---

[៣៨១] រឿងក្តី *Flick,* Vol. VI ទំព័រ១២១៥ (អង់គ្លេស), *Ternek Elsa* (តុលាការក្រុង Tel Aviv ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៥១) 5 *Pesakim Mehoziim* (ឆ្នាំ១៩៥១-២) ទំព័រ១៤២-១៥២ (អង់គ្លេស) (Hebrew), 18 ILR 1951 ទំព័រ៥៤០ (អង់គ្លេស) (អត្ថបទសង្ខេបជាភាសាអង់គ្លេស កត់សម្គាល់ពីការរៀបរាប់ខុសថាជា "Tarnek"), *Enigster Yehezkel Ben Alish* (តុលាការក្រុង Tel Aviv ថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៥២) 5 Pesakim Mehoziim (ឆ្នាំ១៩៥១-២) ទំព័រ១៥២-១៨០ (អង់គ្លេស) (Hebrew); 18 I.L.R. (ឆ្នាំ១៩៥១) ទំព័រ៥៤១-៥៤២ (អង់គ្លេស) (អត្ថបទសង្ខេបជាភាសាអង់គ្លេស)។

[៣៨២] រឿងក្តី *Flick,* Vol. VI ទំព័រ១២១៥ ត្រូវបានគាំទ្រនៅក្នុង *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Carl Krauch និងអ្នកដទៃទៀត* ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៤៨ បោះពុម្ពសាជាថ្មីនៅក្នុង *NMT Trials,* Vols VII-VIII ទំព័រទី១ ("រឿងក្តី *I. G. Farben*") Vol. VIII ទំព័រ១១៣០ (អង់គ្លេស)។

[៣៨៣] រឿងក្តី *Eichmann* កថាខណ្ឌទី ២០៤។

ទៅនឹងអំពើហិង្សាដទៃទៀតដែលកំណត់ដោយច្បាប់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬដែលជាលទ្ធផលណាមួយនៃអំពើណាមួយនៃអំពើទាំងនោះ មានន័យ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការបង្អត់អាហារ ឬ ការនិរទេសប្រជាជនស៊ីវិល ដែលការរឹបអូសទ្រព្យសម្បត្តិគឺត្រឹមតែជាផ្នែកមួយនៃដំណើរការទូទៅប៉ុណ្ណោះ"[៣៨៤]។ ក្នុងរឿងក្តីនោះ Eichmann ត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសពីបទរឹបអូសទ្រព្យសម្បត្តិរបស់ជនជាតិជ្វីហ្វ ដែលជាផ្នែកមួយនៃនីតិវិធីនៃការបំបរបង់មនុស្ស ដែលតុលាការកំពូលនេះសម្រេចថា ត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងទម្រង់ ឬជាអំពើអមនុស្សធម៌ផ្សេងទៀត[៣៨៥]។

១៦១.ក្នុងការសន្និដ្ឋានថាទ្រឹស្តីនៃ *គោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយ នូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)* មានភាពពាក់ព័ន្ធក្នុងការសម្រេចពីខ្លឹមសារនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" អង្គបុរេជំនុំជម្រះសង្កត់ធ្ងន់ថា វាមិនរំលោភដល់វិធានប្រឆាំងនឹងគោលការណ៍សទិសភាពដែលមាននៅក្នុងយុត្តាធិការផ្នែករដ្ឋប្បវេណីទេ[៣៨៦]។ ចំពោះ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ការយកបទល្មើសមួយតាមរយៈសទិសភាពមកអនុវត្ត ចំពោះការប្រព្រឹត្តដែលមិនមានចែងក្នុងច្បាប់ *(គោលការណ៍ analogia lexis)* ខុសប្លែកពីការយកប្រភេទរងមួយនៅក្នុងបទល្មើសមួយតាមរយៈសទិសភាព មកអនុវត្តចំពោះប្រភេទរងមួយទៀតនៅក្នុងបទល្មើសនោះ ក្នុងគោលបំណងបញ្ជាក់ឱ្យបានច្បាស់ពីនិយមន័យនៃប្រភេទរងមួយទៀតនោះ។ នៅក្នុងយន្តការទីពីរនេះ ប្រសិនបើការប្រព្រឹត្តដែលកំពុងពិភាក្សានោះ ស្ថិតទៅក្នុងនិយមន័យរបស់បទល្មើសនោះ ហេតុនេះការពិតវាជាការប្រព្រឹត្ត *ដែលមានចែងក្នុងច្បាប់* ហេតុនេះសំអាងហេតុនៃវិធានប្រឆាំងនឹងគោលការណ៍សទិសភាពមិនត្រូវយកមកអនុវត្តទេ។ ភាពខុសគ្នានេះមិនអាចចៀសវាងបានទេ នៅពេលដែលត្រូវពិចារណាបន្ថែមទៀតថា ប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបាន

---

[៣៨៤] រឿងក្តី *Eichmann* កថាខណ្ឌទី ២០៤។

[៣៨៥] រឿងក្តី *Eichmann* កថាខណ្ឌ២០៤-២០៥។ សូមមើលផងដែរ រឿងក្តី *រដ្ឋមន្ត្រី* ដោយយោងទៅរឿងក្តី *Eichmann,* Vol. XIV ទំព័រទី៦៨០-៦៨១ (អង់គ្លេស) (ដែលរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ Schwerin von Krosigk ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ចំពោះការរឹបអូសទ្រព្យសម្បត្តិរបស់ជនជាតិជ្វីហ្វនៅពេលបណ្តេញពួកគេចេញពីលំនៅដ្ឋាន)។

[៣៨៦] សូមមើល បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ កថាខណ្ឌទី៤៩-៥១ ដែលបានលើកជាទឡ្ហីករណ៍សំអាងថា "អំពើហិង្សាផ្លូវភេទ" និង "ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនអាចកំណត់ថាជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" តាមបែបសទិសភាព ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានការទទួលស្គាល់នោះទេ"។

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ចែងដាក់លាក់ជាបទល្មើសមួយសេសសល់ ដើម្បីបញ្ចៀសនូវភាពចន្លោះប្រហោងនៅក្នុងច្បាប់ ហើយថាពាក្យនេះមិនមានន័យប្រសិនបើមិនយក *គោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយ នូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)* មកអនុវត្ត។ ដូចនេះ វិធានប្រឆាំងនឹងគោលការណ៍សទិសភាពមិនអាចអនុវត្តបានទេចំពោះ "អំពើអមនុស្សធម៌ផ្សេងទៀត"[៣៨៧]។

១៦២. បន្ថែមលើការប្រើប្រាស់ទ្រឹស្តីនៃ *គោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយ នូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)* ដែលទាក់ទិននឹងអំពើដែលបានកំណត់នៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា និយមន័យនេះក៏មានភាពច្បាស់លាស់ផងដែរនៅក្នុងយុត្តិសាស្ត្ររបស់តុលាការ Nuremberg ក្នុងការដោះស្រាយជាប្រចាំចំពោះបញ្ហាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរួមគ្នា តុលាការទាំងនេះបានពឹងផ្អែកលើវិសាលភាពនៃឧក្រិដ្ឋកម្មសង្គ្រាមដែលបានកំណត់នៅក្នុងច្បាប់អន្តរជាតិ ដើម្បីបញ្ជាក់ពីខ្លឹមសារនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមទាំង "អំពើអមនុស្សធម៌ផ្សេងៗទៀត" ប្រឆាំងនឹងជនជាតិអាល្លឺម៉ង់ ឬប្រជាជនស៊ីវិល នៅក្នុងទឹកដីដែលកាន់កាប់ដោយពួកណាហ្ស៊ី។ ឧទាហរណ៍ នៅក្នុងផ្នែកស្តីពី "ច្បាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" នៃសាលក្រមតុលាការ IMT ចៅក្រមយល់ឃើញថា ឧក្រិដ្ឋកម្មសង្គ្រាមតាមមាត្រា៦(ខ) នៃធម្មនុញ្ញតុលាការ IMT ត្រូវបានចាត់ទុកជាបទល្មើសយ៉ាងច្បាស់ តាមអនុសញ្ញាទីក្រុងឡាអេឆ្នាំ ១៩០៧ និងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩២៩ ហើយថា "ចាប់ពីពេលសង្គ្រាមបានផ្ទុះឡើងនាឆ្នាំ ១៩៣៩ មក ឧក្រិដ្ឋកម្មសង្គ្រាមត្រូវបានប្រព្រឹត្តជាទ្រង់ទ្រាយធំ *ហើយឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ត្រូវបានប្រព្រឹត្តឡើងផងដែរ*"[៣៨៨]។ នៅក្នុងរឿងក្តី *គ្រូពេទ្យ* ឧក្រិដ្ឋកម្មសង្គ្រាមស្តីពីការប្រព្រឹត្ត "ការពិសោធន៍វេជ្ជសាស្ត្រ" ដោយគ្មានការព្រមព្រៀងប្រឆាំងនឹងប្រជាជនដែលមិនមែនជាជនជាតិអាល្លឺម៉ង់ និងកងកម្លាំងប្រដាប់អាវុធ ក៏ត្រូវបានចោទប្រកាន់ និងរកឃើញពិរុទ្ធភាពផងដែរ ដើម្បីបង្កើតជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាឧក្រិដ្ឋកម្ម

---

[៣៨៧] មានអ្នកធ្វើអត្ថាធិប្បាយផ្នែកច្បាប់ ជាច្រើនបានចាត់ទុក *គោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយ នូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)* ជាករណីលើកលែងមួយប្រឆាំងនឹងវិធាននៃសទិសភាព។ សូមមើលជាឧទាហរណ៍ Antonio Cassese, *International Criminal Law*, Oxford University Press, ឆ្នាំ ២០០៣ ទំព័រទី១៥៣-១៥៦ (អង់គ្លេស)។

[៣៨៨] សាលក្រមរបស់តុលាការ IMT ទំព័រ២៥៣ (អង់គ្លេស) (គូសបញ្ជាក់បន្ថែម) (ដកស្រង់មាត្រា៤៦, ៥០, ៥២ និង ៥៦ នៃអនុសញ្ញាទីក្រុងឡាអេឆ្នាំ ១៩០៧ និងមាត្រា២, ៣, ៤, ៤៦ និង ៥១ នៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩២៩)។ សូមមើលផងដែរ ទំព័រទី២២៦-២២៧ (អង់គ្លេស) ដែលបានចាត់ទុកឧក្រិដ្ឋសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាអំពើឧក្រិដ្ឋ។

ប្រឆាំងមនុស្សជាតិ ប្រឆាំងនឹងជនជាតិអាល្លឺម៉ង់[៣៨៩]។ ដូចគ្នាផងដែរ នៅក្នុងរឿងក្ដី *ចៅក្រម* ចុងចោទត្រូវបានចោទប្រកាន់ និងផ្ដន្ទាទោសពីបទ "ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និងការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ និងអំពើព្រៃផ្សៃ អំពើសាហាវឃោរឃៅ និងអំពើអមនុស្សធម៌ផ្សេងៗទៀតប្រឆាំងនឹងមនុស្សរាប់ពាន់នាក់" ជាឧក្រិដ្ឋកម្មសង្គ្រាម និងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ[៣៩០]។ ក្នុងករណីនោះ នៅពេលដែលឆ្លើយទៅនឹងបញ្ហាដែលថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាការរំលោភច្បាប់អន្តរជាតិ ចៅក្រមទាំងនោះបានអះអាងថា "ជាសង្ខេប ការចោទប្រកាន់ទោសគឺសំដៅដល់ការចូលរួមផ្នែកមនសិការទៅក្នុងប្រព័ន្ធនៃអំពើសាហាវឃោរឃៅ និងអយុត្តិធម៌ដែលមានរចនាសម្ព័ន្ធគ្រប់គ្រងទូទាំងប្រទេស *ក្នុងការរំលោភដល់ច្បាប់ស្ដីពីសង្គ្រាម និងច្បាប់ស្ដីពីមនុស្សធម៌*"[៣៩១]។ ជាចុងក្រោយ នៅក្នុងរឿងក្ដីរដ្ឋមន្ត្រី ចុងចោទត្រូវបានចោទប្រកាន់ និងផ្ដន្ទាទោសតាមបទចោទទី៥ ពីបទ៖

> ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលពួកគេបានចូលរួមក្នុងអំពើឃោរឃៅ និងបទល្មើសផ្សេងទៀត រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការសម្លាប់ចំណាប់ខ្មាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា និងអំពើអមនុស្សធម៌ និងអំពើឧក្រិដ្ឋផ្សេងៗទៀត ប្រឆាំងនឹងជនជាតិអាល្លឺម៉ង់ និងសមាជិកនៃប្រជាជនស៊ីវិលនៃបណ្ដាប្រទេស និងទឹកដីដែលស្ថិតក្រោមការកាន់កាប់បែបប្រទូស្តរាយ ឬដែលបានត្រួតត្រាតាមវិធីផ្សេងទៀតដោយប្រទេសអាល្លឺម៉ង់ [...][៣៩២]។

[៣៨៩] រឿងក្ដី *គ្រូពេទ្យ* Vol. I ទំព័រទី ១១,១៦ (អង់គ្លេស) Vol. II ទំព័រទី ១៧៤-១៨១, ១៩៨ (អង់គ្លេស)។

[៣៩០] *រឿងក្ដី សហរដ្ឋអាមេរិក តទល់នឹង Josef Altstoetter និងអ្នកដទៃទៀត* ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ១៩៤៧ បោះពុម្ពសាជាថ្មីនៅក្នុង *NMT Trials*, Vol. III "រឿងក្ដី *ចៅក្រម*" ត្រង់ Vol. III ទំព័រទី ៣-៤, ១៩, ២៣ (អង់គ្លេស)។

[៣៩១] រឿងក្ដី *ចៅក្រម* Vol. III ទំព័រ៩៨៥ (អង់គ្លេស)។

[៣៩២] រឿងក្ដី *រដ្ឋមន្ត្រី* Vol. XIV ទំព័រទី ៤៦៧-៦៨ (អង់គ្លេស)។ សូមមើលផងដែរ *ការជំនុំជម្រះទោស Wilhelm Von Leeb និងមនុស្ស១៣នាក់ដទៃទៀត* ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៤៨ បោះពុម្ពសាជាថ្មីនៅក្នុង *NMT Trials*, Vols X – XI ("រឿងក្ដី *មេបញ្ជាការជាន់ខ្ពស់*") ត្រង់ Vol. X ទំព័រទី២៩ (អង់គ្លេស), ៣៦, Vol. XI ទំព័រទី ៤៦៣-៤៦៥ (អង់គ្លេស)។

១៦៣. នៅក្នុងទិដ្ឋភាពនេះ នៅមកត្រឹមឆ្នាំ ១៩៧៥ គេអាចប្រមើលមើលជាមុនថា អំពើអមនុស្សធម៌នានាត្រូវបានចាត់ទុកជាបទឧក្រិដ្ឋដោយច្បាប់សង្គ្រាមអន្តរជាតិ ក៏នឹងត្រូវបានចាត់ទុកស្រដៀងគ្នានេះ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ ដោយផ្អែកលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ និយមន័យនៃពាក្យថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ទំនងជាសំដៅដល់អំពើនានាដែលនឹងត្រូវចាត់ទុកជាការរំលោភធ្ងន់ធ្ងរ ឬការបំពារបំពានធ្ងន់ធ្ងរ *ដែលក្នុងចំណោមនោះ* មានបទប្បញ្ញត្តិទីក្រុងឡាអេឆ្នាំ ១៨៩៩ បទប្បញ្ញត្តិទីក្រុងឡាអេឆ្នាំ ១៩០៧ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩២៩ និង អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ដែលចែងថា អំពើទាំងនោះស្របទៅនឹងលក្ខខណ្ឌតម្រូវជាក់លាក់ដទៃទៀតនៅក្នុងលិខិតុបករណ៍ទាំងនេះ។

១៦៤. អាស្រ័យហេតុនេះ ដោយសារត្រឹមពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ មានចែងពី ធាតុផ្សំ *រួម* និងធាតុផ្សំ *សត្យានុម័ត* អង្គបុរេជំនុំជម្រះយល់ឃើញថា បទល្មើសសកម្ម ឬអកម្មមួយដែលរងការជំទាស់បានបង្កើតជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" មួយជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅពេលដែលអំពើនោះមានលក្ខណៈ និងស្ថានទម្ងន់ស្រដៀងគ្នា ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ឬការនិរទេសដែល៖ ១)វាមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅនឹងជីវិត ឬសេរីភាពរបស់មនុស្ស រួមមានការធ្វើបាបដែលបណ្តាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរដល់រាងកាយ និងផ្លូវចិត្តទៅលើមនុស្ស ឬ ២)មានទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិណាមួយដែលបានរៀបរាប់ តាមវិធីផ្សេងទៀត។ ក្នុងការសម្រេចថាអ្វីមួយអាចបង្កើតជាការប្រព្រឹត្ត "បែបអមនុស្សធម៌" បាន គេត្រូវយោងទៅដល់ចំណុចនានាដូចជា៖ ១)ការបំពារបំពានធ្ងន់ធ្ងរទៅលើច្បាប់អន្តរជាតិ ដែលគ្រប់គ្រងជម្លោះប្រដាប់អាវុធពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ រួមទាំងបទប្បញ្ញត្តិស្តីពីការរំលោភអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ឬ ២)ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើបទដ្ឋាននៃសិទ្ធិជាសារវន្តរបស់មនុស្ស ដែលត្រូវបានការពារតាមច្បាប់អន្តរជាតិនៅពេលវេលាដែលពាក់ព័ន្ធ។

១៦៥. អង្គបុរេជំនុំជម្រះយល់ឃើញថា និយមន័យនៃធាតុផ្សំអត្តនោម័តនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ មានភាពជាក់លាក់ពេញលេញ ដែលដើមបណ្តឹងឧទ្ធរណ៍អាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងដឹងថាមានច្បាប់ចែង និងដឹងជាមុនថា ការប្រព្រឹត្តជាក់លាក់

ទាំងនេះក្រៅពីការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ឬការនិរទេស អាច នឹងត្រូវបានចាត់ទុកជាបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនខាន។

១៦៦. ទាក់ទិននឹងបញ្ហាចុងក្រោយដែលថា តើសហចៅក្រមស៊ើបអង្កេតមាន ឬមិនមានការភ័ន្តច្រឡំក្នុងការ ចោទប្រកាន់ទោសពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ និងការបាត់ខ្លួនដោយបង្ខំ តាមនិយមន័យ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលបានរៀបរាប់ពីមុននោះ អង្គបុរេជំនុំជម្រះ យល់ឃើញថា ចំណុចនេះបានបង្កើតឲ្យមានបញ្ហាច្របូកច្របល់គ្នារវាងអង្គច្បាប់ និងអង្គហេតុ។ ក្នុង ទិដ្ឋភាពនេះ វាមិនមែនជាបញ្ហាផ្នែកយុត្តាធិការដែលត្រូវសម្រេចដោយអង្គបុរេជំនុំជម្រះអនុលោម តាមវិធាន៧៤(៣)(ក)ទេ តែវាជាបញ្ហាមួយដែលអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចនៅក្នុង សវនាការ។

១៦៧. ផ្អែកទៅលើអំណះអំណាងដែលមានពីមុនៗ មូលដ្ឋានទីបួន នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវ បានទទួលយកក្នុងផ្នែកដែលបានរៀបរាប់នៅក្នុងផ្នែកទី៤ ឃ(ii) ដែលទាក់ទិននឹងលក្ខខណ្ឌតម្រូវនៃ ចំណងពាក់ព័ន្ធ និងច្រានចោលផ្នែកផ្សេងៗទៀត។

ង. <u>បញ្ហាថាតើវាជាការភ័ន្តច្រឡំ និងមានការរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព និងសិទ្ធិ ស្មើភាពគ្នានៅចំពោះមុខច្បាប់ដែរឬទេ នៅពេលដាក់បញ្ចូលទៅក្នុងវិសាលភាពនៃយុត្តាធិការលើរឿងក្តី របស់ អ.វ.ត.ក នូវបទល្មើសជាតិតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ (មូលដ្ឋានទីប្រាំ នៃបណ្តឹង ឧទ្ធរណ៍របស់ អៀង ធីរិទ្ធ)</u>

១. <u>សារណានានា</u>

១៦៨. តាមមូលដ្ឋានទីប្រាំនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដើមបណ្តឹងឧទ្ធរណ៍បដិសេធថា ក.ស.ច.ស មានការភ័ន្តច្រឡំនៅក្នុងដីកាដែលរងការជំទាស់ នៅពេលដែលខ្លួនបានបញ្ជាក់ពីយុត្តាធិការទៅលើបទ ចោទប្រកាន់ពីបទល្មើសជាតិ តាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដោយមិនបានយោងទៅដល់ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីអាជ្ញាយុកាលបទល្មើសជាតិ ក្នុងសំណុំរឿងលេខ

០០១ នៅចំពោះមុខ អ.វ.ត.ក[៣៩៣]។ នៅក្នុងករណីនោះ អង្គជំនុំជម្រះសាលាដំបូង "បានសម្រេចថា ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ស្ថិតនៅជាធរមាន ក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក"[៣៩៤]។ ទោះជាយ៉ាងណាក្តី ដោយសារ "ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៧៦ បានចែងពីអាជ្ញាយុកាល ហើយអាជ្ញាយុកាលនេះបានហាមឃាត់មិនឱ្យមានការចោទប្រកាន់បទឧក្រិដ្ឋដែលចែងក្នុងច្បាប់នេះ ក្រោយរយៈពេលដប់ឆ្នាំ គិតចាប់ពីពេលនៃការប្រព្រឹត្តបទល្មើស"[៣៩៥] ហើយ "ចៅក្រមអង្គជំនុំជម្រះសាលាដំបូង មិនបានសម្រេចតាមសំឡេងភាគច្រើនលើករណីនេះទេ" ទៅលើករណីថា តើអាជ្ញាយុកាលបានកន្លងហួសឬទេ មុនពេលច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានពន្យារអាជ្ញាយុកាលនេះ ហើយពួកគេ "មិនអាចចោទប្រកាន់ ឌុច ពីបទល្មើសជាតិទាំងនេះដែរ"[៣៩៦]។

១៦៩. បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ បានសន្និដ្ឋានបន្ថែមទៀតថា ក.ស.ច.ស មានការភ័ន្តច្រឡំ ដោយសារ "ការវិនិច្ឆ័យទោសពីបទល្មើសជាតិត្រូវបានរាំងដោយអាជ្ញាយុកាល" ហើយមាត្រា៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលពន្យារពេលបន្ថែម ៣០ឆ្នាំទៀត ទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា "ជាការបំពានលើគោលការណ៍ទូទៅស្តីពីនីតិព្រហ្មទណ្ឌ៖ *គ្មានបទល្មើសបើគ្មានច្បាប់ចែង*"[៣៩៧]។

២. ការពិភាក្សា

១៧០. អង្គបុរេជំនុំជម្រះរំឭកឡើងវិញថា បើតាមមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក, អ.វ.ត.ក មានយុត្តាធិការក្នុងការជំនុំជម្រះទោសជនជាប់ចោទពីពីបទមនុស្សឃាត អំពើទារុណកម្ម និងការវាយប្រហារសាសនា តាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[៣៩៨]។ ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ នៅជាធរមាន ចំពោះអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ពោលគឺពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥

---

[៣៩៣] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌទី ៧៤។

[៣៩៤] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌទី៧៥។

[៣៩៥] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌទី៧៥។

[៣៩៦] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌទី៧៤។

[៣៩៧] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌទី ៧៦, ៧៧។

[៣៩៨] មាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក។

រហូតដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩[៣៩៩]។ “មាត្រា១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ កំណត់ចិរវេលានៃអាជ្ញាយុកាលចំនួន១០ឆ្នាំចំពោះបទឧក្រិដ្ឋ ០៥ឆ្នាំចំពោះបទមជ្ឈិម និង០១ឆ្នាំចំពោះបទលហុ។ អាជ្ញាយុកាលទាំងនេះចាប់ផ្តើមរាប់ពីពេលដែលប្រព្រឹត្តបទឧក្រិដ្ឋ និងត្រូវបានផ្តាច់ ដោយការផ្តើមកិច្ចស៊ើបសួររបស់តុលាការ”[៤០០]។ “ផ្អែកតាមការអានធម្មតាចំពោះមាត្រា១០៩ ដល់មាត្រា ១១៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ [...] នៅក្នុងករណីដែលមិនមានកិច្ចស៊ើបសួរ ឬការចោទប្រកាន់ដែលផ្តាច់ចិរវេលានៃអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋតាមច្បាប់ជាតិ”[៤០១] ចិរវេលានៃអាជ្ញាយុកាលនឹងផុតរលត់ បន្ទាប់ពីមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពោលគឺចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៨៥ រហូតដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៨៩[៤០២]។ ជាចុងក្រោយ “មាត្រា៣ និងមាត្រា៣ (ថ្មី) ដែលត្រូវបានប្រកាសឲ្យប្រើនៅឆ្នាំ ២០០១ និងឆ្នាំ ២០០៤ ដំបូងបានបន្ថែមចិរវេលានៃអាជ្ញាយុកាល២០ឆ្នាំ និងក្រោយមកទៀត បានបន្ថែមចិរវេលានៃអាជ្ញាយុកាល៣០ឆ្នាំ។ សរុបទៅ ចិរវេលានៃអាជ្ញាយុកាលគឺ៥០ឆ្នាំ”[៤០៣]។

១៧១.នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនស្តីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ នៅក្នុងសំណុំរឿងលេខ០០១ អង្គជំនុំជម្រះសាលាដំបូងបានយល់ស្របជាឯកច្ឆន្ទថា “អង្គជំនុំជម្រះយល់ឃើញថាមិនមានភស្តុតាងគ្រប់គ្រាន់ដែលបង្ហាញថា ចិរវេលានៃអាជ្ញាយុកាលត្រូវបានផ្តាច់” ដោយសារ “បទឧក្រិដ្ឋតាមច្បាប់ជាតិដែលចោទប្រកាន់ជនជាប់ចោទត្រូវបានស៊ើបអង្កេត ឬចោទប្រកាន់មុន” ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៨៩[៤០៤]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះនេះក៏បានយល់ស្របផងដែរថា “ក្នុងចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ប្រព័ន្ធច្បាប់ ឬប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាមិនមាននោះទេ [...]

---

[៣៩៩] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌ១២។

[៤០០] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌ១០។

[៤០១] មាត្រា១១២-១១៤ នៃ ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ចែងថា កិច្ចស៊ើបសួរ និងការចោទប្រកាន់ ផ្តាច់ចិរវេលានៃអាជ្ញាយុកាល ដែលចិរវេលានេះចាប់ផ្តើមរាប់សាជាថ្មីចំនួន១០ឆ្នាំវិញ ក្រោយពីកិច្ចនៃការផ្តាច់ចុងក្រោយ (នៅក្នុងករណីបទឧក្រិដ្ឋ)”) សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ជើងទំព័រលេខ១៣ ។

[៤០២] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌ១២។

[៤០៣] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌ ១៣។ មាត្រា៣៣ (ថ្មី) (២) នៃច្បាប់ អ.វ.ត.ក។

[៤០៤] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌ១២។

00686572

ការស៊ើបសួរ ឬការចោទប្រកាន់ពីបទព្រហ្មទណ្ឌមិនអាចធ្វើឡើងបានទេនៅក្នុងអំឡុងពេលនោះ”[៤០៥]។ អាស្រ័យហេតុនេះ ការកំណត់ចិរវេលាអាជ្ញាយុកាលរយៈពេល១០ ឆ្នាំ “មិនបានចាប់ផ្តើមរាប់ក្នុងអំឡុងពេលនោះឡើយ”[៤០៦]។ អ្វីដែលអង្គជំនុំជម្រះនេះមិនអាចយល់ស្របគឺបញ្ហានៃអង្គហេតុ “ថាតើចិរវេលាអាជ្ញាយុកាលត្រូវបានផុតរលត់ទៅហើយ ឬយ៉ាងណា នៅពេលការស៊ើបអង្កេតដោយ អ.វ.ត.ក លើជនជាប់ចោទចំពោះបទល្មើសជាតិត្រូវបានចាប់ផ្តើមនោះ”[៤០៧]។ និយាយម្យ៉ាងទៀតគឺថា អង្គជំនុំជម្រះនេះ “មិនបានឈានដល់ការឯកភាពគ្នា ថាតើចិរវេលានៃអាជ្ញាយុកាលដែលអាចអនុវត្ត ត្រូវបានព្យួរ ឬមិនបានព្យួរ ក្នុងចន្លោះឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩៣ ហើយថាតើរយៈពេលនេះត្រូវបានផុតរលត់ មុនពេលដែលមាត្រា៣ និង មាត្រា៣ (ថ្មី) ត្រូវបានប្រកាសឱ្យប្រើដែរឬទេ”[៤០៨]។

១៧២.មតិភាគច្រើនពីចៅក្រមជាតិគឺចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម ធូ មណី យល់ឃើញថា “ចាប់តាំងពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨២ ប្រព័ន្ធតុលាការនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាមិនមានដំណើរការទាល់តែសោះ” ហើយ “រហូតមកទល់នឹងពេលដែលព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ បញ្ហាប្រវត្តិសាស្ត្រ និងបរិការណ៍បានរាំងដល់លទ្ធភាពក្នុងការចោទប្រកាន់ និងការស៊ើបសួរ”[៤០៩]។ អាស្រ័យហេតុនេះចៅក្រមទាំងនោះបានសន្និដ្ឋានថា “ចិរវេលាអាជ្ញាយុកាលពាក់ព័ន្ធទៅនឹងបទល្មើសជាតិ [...] ចាប់ផ្តើមរាប់ពីថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣”[៤១០]។ អាស្រ័យហេតុនេះ ការពន្យារចិរវេលាអាជ្ញាយុកាលរយៈពេល១០ ឆ្នាំ ទៅ ២០ ឆ្នាំ តាមមាត្រា៣ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នៅឆ្នាំ ២០០១ មុនពេលដែលចិរវេលាអាជ្ញាយុកាលផុតរលត់ទៅនៅឆ្នាំ ២០០៣ បានអនុញ្ញាតឱ្យធ្វើការចោទប្រកាន់ពីបទល្មើសជាតិតាម ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦។

[៤០៥] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌ១៤។

[៤០៦] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌ១៤។

[៤០៧] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌ១៣-១៤។

[៤០៨] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌ១៤។

[៤០៩] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌ១៩, ២០។

[៤១០] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌ២៥។

១៧៣. ផ្ទុយទៅវិញ ចៅក្រមអន្តរជាតិពីររូបគឺចៅក្រម SILVIA CARTWRIGHT និង ចៅក្រម JEAN-MARC LAVERGNE យល់ឃើញថា "ទោះបីរបបកម្ពុជាប្រជាធិបតេយ្យធ្វើឱ្យទន់ខ្សោយដល់ប្រព័ន្ធតុលាការជាតិ" ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩៣ ក៏ដោយ ក៏ចៅក្រមទាំងនេះមិនអាចសន្និដ្ឋានបានថា "ការចោទប្រកាន់ ឬការស៊ើបសួរណាមួយ មិនអាចនឹងធ្វើបាននៅក្នុងអំឡុងពេលពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩៣ នោះទេ"[៤១១]។ អាស្រ័យហេតុនេះ ចៅក្រមទាំងនេះយល់ឃើញថា "ចិរវេលាអាជ្ញាយុកាលនេះបានផុតរលត់រួចទៅហើយ" នៅឆ្នាំ ១៩៨៩ មុនពេលអនុម័តច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឆ្នាំ ២០០១ ហើយបើតាមមាត្រា៣ "អាជ្ញាយុកាលមិនអាច "ពន្យារ" បានទេ"[៤១២]។ បន្ថែមទៅទៀត ចៅក្រមទាំងនេះមិនអាច "សន្និដ្ឋានថា អង្គនីតិបញ្ញត្តិកម្ពុជាមិនដែលបង្ហាញពីចេតនា ដើម្បីពន្យារចិរវេលានៃអាជ្ញាយុកាល ឬប្រតិសកម្មសិទ្ធិដើម្បីចោទប្រកាន់បទល្មើសជាតិ ក្រោយពេលផុតរលត់អាជ្ញាយុកាលទាល់តែសោះ"[៤១៣]។ ហេតុនេះ ចៅក្រម CARTWRIGHT និង ចៅក្រម LAVERGNE សម្រេចថា បទល្មើសជាតិត្រូវបានហាមឃាត់ដោយក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ហើយមិនអាចយកមកចោទប្រកាន់នៅ អ.វ.ត.ក បានទេ។

១៧៤. ជាលទ្ធផលនៃការយល់ឃើញផ្ទុយគ្នាបែបនេះ ទោះបីចៅក្រមជាតិបីរូបមានមតិភាគច្រើនយល់ឃើញថា ចិរវេលាអាជ្ញាយុកាលរយៈពេល១០ ឆ្នាំ នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ មិនទាន់ផុតរលត់មុនពេលត្រូវបានពន្យារមាត្រាមាត្រា៣ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ហើយថា ការចោទប្រកាន់ជាការសមរម្យក៏ដោយ ក៏អង្គជំនុំជម្រះនេះមានឧបសគ្គផ្នែកនីតិវិធីមិន "អនុញ្ញាតឱ្យបន្តការវិនិច្ឆ័យលើជនជាប់ចោទ ចំពោះបទល្មើសជាតិ" ទេ[៤១៤]។ ករណីនេះកើតឡើងដោយសារ មាត្រា ១៤ (ថ្មី)(១)(ក) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក តម្រូវថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងមិនអាចសម្រេចបានមតិជាឯកច្ឆន្ទទៅលើសេចក្តីសម្រេចណាមួយបានទេ "ការសម្រេចសេចក្តីដោយអង្គ

[៤១១] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌ៣២។

[៤១២] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌ៤៤។

[៤១៣] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌ៤៥។

[៤១៤] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌ៥៦។

ជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង តម្រូវឱ្យឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រម *ប្តូរ*បយ៉ាងតិច"[៤១៥]។

១៧៥. នៅក្នុងដីកាដែលរងការជំទាស់ ក.ស.ច.ស បានបង្គាប់ថា ដើមបណ្តឹងឧទ្ធរណ៍ត្រូវបញ្ជូន "ទៅជំនុំជម្រះនៅមុខអង្គជំនុំជម្រះសាលាដំបូង ក្រោមបទចោទប្រកាន់នៃអំពើមនុស្សឃាត អំពើទារុណកម្ម និងវាយប្រហារលើសាសនា ដែលជាឧក្រិដ្ឋកម្មដែលមានចែង និងផ្តន្ទាទោសដោយក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦"[៤១៦]។ ផ្ទុយពីការអះអាងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ បន្ទាប់ពីបានពិចារណាយ៉ាងល្អិតល្អន់ទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីអញ្ញត្រកម្ម ទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិនៅក្នុងសំណុំរឿងលេខ០០១ រួចមក ក.ស.ច.ស បានធ្វើការសន្និដ្ឋានបែបនេះ ដោយកត់សម្គាល់ថា "អង្គជំនុំជម្រះសាលាដំបូងមិនបានមានមតិឯកភាពគ្នាលើបញ្ហាដែលពាក់ព័ន្ធនឹងការកាត់ផ្តាច់ ឬការបង្អង់ថិរវេលាអាជ្ញាយុកាលក្នុងចន្លោះពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩៣ នោះឡើយ"[៤១៧] ហើយ "ដោយមិនមានការទទួលបានសំឡេងភាគច្រើនលើសលប់ [...] មិនអាចមានការសម្រេចបែបណាមួយលើពិរុទ្ធភាពរបស់ជនជាប់ចោទ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលមានចែង និងផ្តន្ទាទោសដោយក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ នោះទេ"[៤១៨]។ ទាក់ទិននឹងសេចក្តីសម្រេចនេះ ក.ស.ច.ស កំពុងប្រឈមនឹង "បញ្ហានីតិវិធីដែលមិនអាចដោះស្រាយបាន" លើការតាក់តែងនូវគោលជំហររួមមួយស្តីអំពីបញ្ហានៃ "ថិរវេលាអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលពាក់ព័ន្ធ"[៤១៩]។ ដោយមិនបានដោះស្រាយបញ្ហាដែលមិនអាចដោះស្រាយបាននេះ ក.ស.ច.ស នៅតែ "បានសម្រេចឯកភាពទទួលយកសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយទុកលទ្ធភាពឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការវាយតម្លៃ អំពីចំណាត់ការបន្តនៃនីតិវិធីដែលពាក់ព័ន្ធនឹងបទល្មើសក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ទាំងនោះ"[៤២០]។

---

[៤១៥] មាត្រា១៤ (ថ្មី)(១)(ក) នៃវិធានផ្ទៃក្នុង (គូសបញ្ជាក់បន្ថែម)។

[៤១៦] ដីកាដែលរងការជំទាស់ កថាខណ្ឌទី ១៥៧៦។

[៤១៧] ដីកាដែលរងការជំទាស់ កថាខណ្ឌទី ១៥៦៨។

[៤១៨] ដីកាដែលរងការជំទាស់ កថាខណ្ឌទី ១៥៧១។

[៤១៩] ដីកាដែលរងការជំទាស់ កថាខណ្ឌទី ១៥៧៤។

[៤២០] ដីកាដែលរងការជំទាស់ កថាខណ្ឌទី ១៥៧៥។

១៧៦.ផ្អែកលើសំអាងហេតុខាងក្រោម អង្គបុរេជំនុំជម្រះពុំយល់ឃើញថា ការបញ្ជាក់ពីយុត្តាធិការនេះដែលទាក់ទិននឹងបទល្មើសជាតិ តាមមាត្រា៣ (ថ្មី) និងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ជាការភ័ន្តច្រឡំឡើយ។ ហើយចំណុចនេះក៏មិនរំលោភដល់គោលការណ៍នីត្យានុកូលភាពដែរ។

(i) សេចក្ដីសម្រេចស្ដីពីអញ្ញត្រកម្ម ទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ នៅក្នុងសំណុំរឿងលេខ០០១

១៧៧. ដំបូង អង្គបុរេជំនុំជម្រះពិចារណាទៅលើការជំទាស់របស់ដើមបណ្ដឹងឧទ្ធរណ៍ដែលថា ក.ស.ច.ស មានការភ័ន្តច្រឡំ ដោយសារពួកគេមិនបានយោងទៅដល់សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីអញ្ញត្រកម្ម ទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិនៅក្នុងសំណុំរឿងលេខ០០១ នៅពេលខ្លួនបញ្ជាក់ពីការចោទប្រកាន់លើបទល្មើសជាតិនោះ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា អំណះអំណាងដែលបានធ្វើឡើងនៅក្នុងប្រយោគចុងក្រោយនៃកថាខណ្ឌ៧៤ នៅក្នុងមូលដ្ឋានទីប្រាំនៃបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ អាចបកស្រាយមានន័យថា ម្ចាស់បណ្ដឹងឧទ្ធរណ៍យល់ឃើញស្រដៀងគ្នានឹងអង្គជំនុំជម្រះសាលាដំបូងដែរ គឺថា ក.ស.ច.ស គួរយល់ឃើញថាខ្លួនមានឧបសគ្គផ្នែកនីតិវិធីក្នុងការចោទប្រកាន់ពីបទល្មើសជាតិ ដោយសារពួកគេមិនអាចព្រមព្រៀងជារួម ទៅលើបញ្ហាចិរវេលាអាជ្ញាយុកាលដែលមានជាធរមាន និងពីអានុភាពនៃសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្ដីពីចិរវេលានោះ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អំណះអំណាងនេះទំនងជាមានន័យបែបនេះ ដូចដែល ក.ស.ច.ស បានដកស្រង់យ៉ាងទូលាយនៅក្នុងដីកាដែលរងការជំទាស់ ចំពោះសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីអញ្ញត្រកម្ម ទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិនៅក្នុងសំណុំរឿងលេខ០០១នេះ។

១៧៨.អង្គបុរេជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍នេះជាការភ័ន្តច្រឡំ។ ក.ស.ច.ស មិនមានតួនាទីដូចចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងលេខ០០១ គឺថា ក្នុងករណីមិនទទួលបានការសម្រេចដោយមតិភាគច្រើននោះ ពួកគាត់មិនមានជម្រើសតាមនីតិវិធីទេ តែបើតាមវិធានផ្ទៃក្នុង ពួក

គេត្រូវផ្អាកលែងចោទប្រកាន់ពីបទល្មើសបែបនោះតែម្តង[៤២១]។ ដោយខ្លួនសម្រេចបញ្ចូលបទចោទពីបទល្មើសជាតិទៅក្នុងដីកាដែលរងការជំទាស់ ទោះបីមានការខ្វែងយោបល់គ្នាក៏ដោយ នេះមានន័យថា ក.ស.ច.ស ពិតជាបានបញ្ជាក់ពីយុត្តាធិការទៅលើបទល្មើសទាំងនេះ ហើយសំណួរពិតប្រាកដដែលអង្គបុរេជំនុំជម្រះត្រូវដោះស្រាយនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ គឺថាតើការបញ្ជាក់នេះជាកំហុសឆ្គងលើអង្គសេចក្តី ឬយ៉ាងណា។ ទាក់ទិននឹងបញ្ហានោះ ដើមបណ្តឹងឧទ្ធរណ៍សន្និដ្ឋានថា ក.ស.ច.ស មានកំហុសឆ្គងក្នុងការបញ្ជាក់ពីយុត្តាធិការប្រឆាំងនឹងបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដោយសារ "ការចោទប្រកាន់ពីបទល្មើសថ្នាក់ជាតិ ត្រូវបានរារាំងដោយចិរវេលាអាជ្ញាយុកាល"[៤២២]។ កថាខណ្ឌចំនួន៤ ខាងក្រោមដែលបានបង្កើតជាទឡ្ហីករណ៍ទាំងមូលនៅក្នុងការគាំទ្រអំណះអំណាងនេះ ត្រូវបានរៀបរៀងដូចខាងក្រោម (ជើងទំព័រត្រូវបានលុបចោល)៖

៧៤. ក្នុងរឿងក្តី *ឌុច* ចៅក្រមអង្គជំនុំជម្រះសាលាដំបូងមិនបានសម្រេចតាមសំឡេងភាគច្រើនលើករណីនេះទេ ហើយក៏មិនអាចចោទប្រកាន់ ឌុច ពីបទល្មើសជាតិទាំងនេះដែរ។ សហព្រះរាជអាជ្ញាមិនបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះទេ ដោយសារពួកគេបានយល់ស្របតាមសំអាងហេតុតាមផ្លូវច្បាប់បែបនេះ។ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាតាមវិធាន៦៦ មិនបានយោងទៅរកសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងលេខ០០១ នេះទេ ហើយសហព្រះរាជអាជ្ញាមិនបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះទេ។ សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការសន្និដ្ឋាន អំពីយុត្តាធិការនៃប្រភេទបទល្មើសទាំងនេះ ដោយមិនបានយោងទៅរកសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ឌុច។

៧៥. ក្នុងរឿងក្តី ឌុច អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ស្ថិតនៅជាធរមានក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ បានចែងពីអាជ្ញាយុកាល ហើយអាជ្ញាយុកាលនេះបានហាមឃាត់

[៤២១] នៅក្នុងករណី ក.ស.ច.ស មានជម្រើសមួយទៀតសម្រាប់ពួកគាត់។ ពួកគាត់អាចជ្រើសរើសប្រើប្រាស់នីតិវិធីនៅក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុង ដើម្បីដោះស្រាយការខ្វែងមតិគ្នាក្នុងចំណោមពួកគាត់ក៏បាន។ តែ ក.ស.ច.ស មិនបានជ្រើសរើសអនុវត្តវិធាននេះទេ។ អង្គបុរេជំនុំជម្រះមិនចាំបាច់សម្រេចសេចក្តីនៅក្នុងបណ្តឹងឧទ្ធរណ៍នេះថា តើជាការសមស្រប ឬមិនសមស្រប ដែល ក.ស.ច.ស ជ្រើសរើសដំណោះស្រាយបែបនោះនោះទេ ឬថា តើពួកគាត់បាន ឬមិនបាននាំយកបញ្ហានេះមកអង្គបុរេជំនុំជម្រះ ដើម្បីដោះស្រាយនោះទេ។ ដើមបណ្តឹងឧទ្ធរណ៍មិនបានផ្តល់នូវទឡ្ហីករណ៍ណាមួយនៅចំពោះមុខអង្គបុរេជំនុំជម្រះ ទាក់ទិននឹងបញ្ហានេះទេ។

[៤២២] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌទី ៧៧។

មិនឲ្យមានការចោទប្រកាន់បទឧក្រិដ្ឋដែលចែងក្នុងច្បាប់នេះ ក្រោយរយៈពេលដប់ឆ្នាំ គិតពីពេលនៃការប្រព្រឹត្តបទល្មើស។

៧៦. មាត្រា៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា "អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលទាក់ទងដល់បទល្មើសខាងលើ ត្រូវបានពន្យារពេលបន្ថែម៣០ឆ្នាំទៀត ទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើ ដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ"។

៧៧. មេធាវីការពារក្តីសូមបញ្ជាក់ថា ការចោទប្រកាន់ពីបទល្មើសជាតិត្រូវបានរារាំងដោយចិរវេលាអាជ្ញាយុកាល ហើយការពន្យារអាជ្ញាយុកាលដែលអនុញ្ញាតឲ្យមានការចោទប្រកាន់ គឺជាការបំពានលើគោលការណ៍ទូទៅស្តីពីនីតិវិធីព្រហ្មទណ្ឌ៖ *គ្មានបទល្មើសបើគ្មានច្បាប់ចែង*។ ប្រការគួរឲ្យចាប់អារម្មណ៍គឺ មាត្រា៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ខ្លួនឯងហាមឃាត់មិនឲ្យអនុវត្តច្បាប់បែបប្រតិសកម្ម។

១៧៩. អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងដែលជំទាស់នឹងដីកាដែលរងការជំទាស់ជាដីកាខ្លីពេក និងមិនមានរៀបរាប់ឲ្យបានក្បោះក្បាយ ចំពោះការចោទប្រកាន់ពីបទល្មើសជាតិ និងបានរារាំងអង្គបុរេជំនុំជម្រះមិនឲ្យពិចារណា ទៅលើអង្គសេចក្តីនៃមូលដ្ឋាននេះក្នុងបណ្តឹងឧទ្ធរណ៍បាន។ ទោះបីនៅក្នុងអត្ថបទដកស្រង់ពីមុន គេបានលុបជើងទំព័រចេញក៏ដោយ ក៏មិនមានឯកសារយោង ឬយុត្តិសាស្ត្រណាមួយនៅក្នុងជើងទំព័រទាំងនោះ ដើម្បីគាំទ្រដល់ការទាមទារដែលមានរៀបរាប់នៅក្នុងប្រយោគទីមួយនៃកថាខណ្ឌ៧៧ ឡើយ ដែលថា "ការចោទប្រកាន់បទល្មើសជាតិត្រូវបានរារាំងដោយអាជ្ញាយុកាល"។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយគឺជាឱកាសមួយសម្រាប់ឲ្យជនជាប់ចោទ ជំទាស់ទៅនឹងសំអាងហេតុតាមផ្លូវច្បាប់ទៅលើយុត្តាធិការដែលបានសម្រេចដោយ ក.ស.ច.ស។ ដើមបណ្តឹងឧទ្ធរណ៍បានជ្រើសរើសវិធីបែបនេះដោយមិនបានកែសម្រួលទឡ្ហីករណ៍ណាមួយតាមផ្លូវច្បាប់ទេ ហើយក៏មិនបានលើកជាឯកសារសំអាងតាមផ្លូវច្បាប់ដែរ។ បើតាមវិសាលភាពដែលដើមបណ្តឹងឧទ្ធរណ៍ពឹងផ្អែកលើ កថាខណ្ឌ ៧៤-៧៦ ដើម្បីគាំទ្រដល់សំណើរបស់ខ្លួននោះ[៤២៣] អង្គបុរេជំនុំជម្រះយល់ឃើញថា សញ្ញាណទាំងនេះជា

[៤២៣] សូមមើលកថាខណ្ឌទី ៧៩ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលអះអាងក្នុងអត្ថន័យទាំងស្រុងថា "អង្គបុរេជំនុំជម្រះត្រូវតែបដិសេធចោលការអនុវត្តមាត្រា៣ (ថ្មី) ដោយផ្អែកលើមូលដ្ឋានទាំងនេះ"។ តាមរយៈអំណាចធម្មតានូវសំណូមពរនេះបង្ហាញឲ្យច្បាស់ថា មូលដ្ឋានដែលលើកមកសំអាងនេះគឺមាននៅក្នុងកថាខណ្ឌទី ៧៤-៧៧។ អង្គបុរេជំនុំជម្រះបានចេញសេចក្តី

សំអាងហេតុមួយដែលមាននៅក្នុងសំណុំរឿងលេខ០០១ ជាអង្គហេតុដែលភាគីម្ខាងទៀតមិនបានប្តឹងឧទ្ធរណ៍ ទៅនឹងសំអាងហេតុមួយនៅក្នុងសំណុំរឿងលេខ០០១ និងការលើកឡើងនូវអត្ថបទច្បាប់ចំនួនពីរដែលមានជាធរមាននៅ អ.វ.ត.ក (ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក) គឺគ្រាន់តែជាការលើកឡើង តែមិនបានបង្ហាញថា ឯកសារយោងទាំងនេះពាក់ព័ន្ធនឹងការទាមទាររបស់ដើមបណ្តឹងឧទ្ធរណ៍ និងពីរបៀបដែល ក.ស.ច.ស មានការភ័ន្តច្រឡំឆ្គងនោះទេ។

១៨០. ជាងនេះទៅទៀត ទឡ្ហីករណ៍តែមួយគត់ដែលបានលើកឡើងនៅក្នុងសារណាតបរបស់ អៀង ធីរិទ្ធ គឺជានិយាយច្រំដែលនូវអំណះអំណាងដែលថា ក.ស.ព មិនបានប្តឹងឧទ្ធរណ៍ចំពោះសំអាងហេតុមួយរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿងលេខ០០១។ ទោះជាតាមវិធីណាក៏ដោយ អំណះអំណាងនេះ មិនបណ្តាលឱ្យអង្គបុរេជំនុំជម្រះធ្វើការសន្និដ្ឋានថា ក.ស.ច.ស មានការភ័ន្តច្រឡំ នៅពេលបញ្ជាក់ពីយុត្តាធិការលើដើមបណ្តឹងឧទ្ធរណ៍ទេ។

១៨១. សរុបមក តាមមូលដ្ឋាននេះនៃបណ្តឹងឧទ្ធរណ៍ ដើមបណ្តឹងឧទ្ធរណ៍ខកខានមិនបានលើកសំអាងដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ទៅលើការវិភាគផ្នែកច្បាប់ណាមួយដែលបានធ្វើឡើងដោយចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ទៅលើបញ្ហាថិរវេលាអាជ្ញាយុកាលដែលមានជាធរមានទេ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការគ្រាន់តែលើកពីអង្គហេតុមួយដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចនេះដែលថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនអាចស្វែងរកបានមតិភាគច្រើន ដែលនាំឱ្យមិនអាចចោទប្រកាន់បាន ជាការមិនអាចទទួលយកបានទេ ជំនួសឱ្យឯកសារយោងនានា ការស្រាវជ្រាវ ឬការសម្រេចនានាដែលទាក់ទិននឹងទស្សនៈ ដែលមាននៅក្នុងសេចក្តីសម្រេចនោះផង ឬទស្សនៈពីរដាច់ពីគ្នារបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងផង។ ហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ខ្លួនមិនអាចពិចារណាថែមទៀតទៅលើអង្គសេចក្តីនៃមូលដ្ឋាននេះនៃបណ្តឹងឧទ្ធរណ៍ទេ ដោយសារដើមបណ្តឹងឧទ្ធរណ៍មិនមានដាក់សារណាដែលមានលក្ខណៈសមស្របតាមផ្លូវច្បាប់ ទៅលើបញ្ហាបទល្មើសជាតិ និងថិរវេលាអាជ្ញាយុកាលដែលមានជាធរមាន។

សម្រេចរួចទៅហើយនៅក្នុងផ្នែកទី III (ក) ខាងលើដែលថា ទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី ៧៨ មិនត្រូវបានទទួលយកទេ នៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី។

(ii) <u>គោលការណ៍នីត្យានុកូលភាព</u>

១៨២. អង្គបុរេជំនុំជម្រះក៏បានយល់ឃើញផងដែរថា ការណ៍ដែលដើមបណ្តឹងឧទ្ធរណ៍មិនបានកែសម្រួលបណ្តឹងឧទ្ធរណ៍របស់ខ្លួនជំទាស់ទៅនឹងដីកាដែលរងការជំទាស់ ចំពោះការចោទប្រកាន់ពីបទល្មើសជាតិដោយសំអាងថា ការពន្យារពេលនៃអាជ្ញាយុកាលនឹងរំលោភដល់គោលការណ៍នីត្យានុកូលភាពនោះ បានរារាំងអង្គបុរេជំនុំជម្រះមិនឱ្យពិចារណាឱ្យបានសមស្របពីអង្គសេចក្តីនៃមូលដ្ឋាននេះនៃបណ្តឹងឧទ្ធរណ៍។ ដើមបណ្តឹងឧទ្ធរណ៍គ្រាន់តែអះអាងថា "ការពន្យារអាជ្ញាយុកាលដែលអនុញ្ញាតឱ្យមានការចោទប្រកាន់ គឺជាការបំពានលើគោលការណ៍ទូទៅស្តីពីនីតិវិធីព្រហ្មទណ្ឌ៖ *គ្មានបទល្មើសបើគ្មានច្បាប់ចែង*"។ ដូចបានលើកឡើងខាងលើរួចមកហើយគឺថា នៅក្នុង*ន័យចង្អៀត*របស់វា គោលការណ៍នីត្យានុកូលភាពតម្រូវឱ្យ អ.វ.ត.ក ត្រូវបានមានយុត្តាធិការទៅលើរឿងក្តី ដែលពាក់ព័ន្ធនឹងបទល្មើសដែលបានចោទប្រកាន់ ដែលបទល្មើសទាំងនោះត្រូវតែមានចែងក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ថែមទាំងមានចែងនៅក្នុងច្បាប់អន្តរជាតិ និងច្បាប់ជាតិផងដែរ នៅពេលដែលការប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់នោះ ដែលថាការចោទប្រកាន់ត្រូវតែស្របទៅនឹងគោលការណ៍នីត្យានុកូលភាព។ ត្រង់ចំណុចនេះ ជាការពិត បទល្មើសជាតិដែលត្រូវបានចោទប្រកាន់នោះមានចែងយ៉ាងច្បាស់នៅក្នុងមាត្រា៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងត្រូវបានហាមឃាត់ដោយក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលនៅមានជាធរមានក្នុងពេលវេលាដែលពាក់ព័ន្ធនោះ។ អាស្រ័យហេតុនេះ អៀង ធីរិទ្ធ អាចប្រមើលមើលដឹងថាមានច្បាប់ចែង និងដឹងជាមុនយ៉ាងពេញលេញថាការប្រព្រឹត្តរបស់ខ្លួននឹងត្រូវចោទប្រកាន់ជាបទល្មើសដែលនឹងត្រូវផ្តន្ទាទោស ហើយការចោទប្រកាន់រូបគាត់ពីបទល្មើសជាតិតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ មិនរំលោភលើគោលការណ៍នីត្យានុកូលភាពទេ។

១៨៣. អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា ដើមបណ្តឹងឧទ្ធរណ៍មិនបានផ្តល់ការពន្យល់ណាមួយឬដកស្រង់អត្ថបទណាមួយ ដែលនឹងគាំទ្រដល់ការឃ្លាតចេញពី*ន័យចង្អៀត*ខាងលើនៃគោលការណ៍នីត្យានុកូលភាពដែលបានលើកឡើងខាងលើឡើយ។ ពាក្យពេចន៍ធម្មតានៃមាត្រា១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏មិនមានមូលដ្ឋានដើម្បីពង្រីកវិសាលភាពនៃគោលការណ៍នីត្យានុកូលភាព ដើម្បីគ្រប់គ្រងលក្ខខណ្ឌនៃការចោទប្រកាន់ ហួសឆ្ងាយពីការផ្លាស់ប្តូរបែបប្រតិសកម្ម រហូតដល់សារធាតុនៃបទល្មើស ឬទោសទណ្ឌរវាងពេលវេលាដែលបទល្មើសបាន

ប្រព្រឹត្ត និងបានចោទប្រកាន់នោះដែរ[៤២៤]។ ដូចដែលបានកត់សម្គាល់ដោយចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿងលេខ០០១ រួចមកហើយគឺថា គោលការណ៍នីត្យានុកូលភាពតាមមាត្រា១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធពលរដ្ឋ និងសិទ្ធិនយោបាយមិនបាន "សំដៅដោយផ្ទាល់ចំពោះថិរវេលានៃអាជ្ញាយុកាលទេ។ ដូច្នេះប្រភពទាំងនេះពុំបានបកស្រាយច្បាស់លាស់អំពីដែនកំណត់នៃគោលការណ៍ជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលទាក់ទងនឹងការពិចារណាអំពីប្រតិសកម្មនៃច្បាប់ ឬលុបចោលអាជ្ញាយុកាលនោះទេ"[៤២៥]។ នៅក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះមិនចាំបាច់វិភាគអ្វីឲ្យហួសឆ្ងាយពីទឡ្ហីករណ៍ដែលបានលើកឡើងដោយដើមបណ្តឹងឧទ្ធរណ៍ ទាក់ទិននឹងគោលការណ៍នីត្យានុកូលភាព ទៅតាម*ន័យចង្អៀត* ដូចដែលបានលើកឡើងខាងលើនេះទេ។ គោលបំណងជាមូលដ្ឋាននៃគោលការណ៍នីត្យានុកូលភាពក្នុងការការពារភាពយុត្តិធម៌ និងសច្ចភាពនៅក្នុងច្បាប់តម្រូវថា ជនជាប់ចោទអាចប្រមើលមើលដឹងថាមានច្បាប់ចែង និងដឹងថាទង្វើរបស់ខ្លួនគឺជាបទឧក្រិដ្ឋជាមុនយ៉ាងពេញលេញថា ទង្វើរបស់ខ្លួនជាបទល្មើសនៅពេលដែលប្រព្រឹត្តនោះ ដែលនឹងត្រូវផ្តន្ទាទោស។ តាម*ន័យចង្អៀត*របស់វា គោលការណ៍នីត្យានុកូលភាពមិនតម្រូវថា ជនជាប់ចោទត្រូវតែអាចប្រមើលមើលដឹងថាមានច្បាប់ចែង និងដឹងទង្វើរបស់ខ្លួនគឺជាបទឧក្រិដ្ឋ និងដឹងជាមុនយ៉ាងពេញលេញថា ខ្លួនអាច និងឬមិនអាចត្រូវបានចោទប្រកាន់ ដោយផ្អែកលើថិរវេលាអាជ្ញាយុកាលដែលមានជាធរមានទេ ហើយក៏មិនតម្រូវថា តើថិរវេលាអាជ្ញាយុកាលនោះនឹងត្រូវ ឬមិនត្រូវព្យួរ ឬលើកចោល នាពេលអនាគតនោះដែរ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍ដែលបានលើកឡើងដោយដើមបណ្តឹងឧទ្ធរណ៍ មិនមានអង្គសេចក្តីទេ។

១៨៤. អង្គបុរេជំនុំជម្រះសូមរំឭកឡើងវិញថា អង្គជំនុំជម្រះនេះបានទទួលបណ្តឹងឧទ្ធរណ៍ដាច់ពីគ្នា ពីជនជាប់ចោទ អៀង សារី ដែលប្រឆាំងនឹងដីកាដំណោះស្រាយ ដែលជនជាប់ចោទរូបនេះក៏បានជំទាស់ផងដែរទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក លើបទល្មើសជាតិ ដោយផ្អែកលើការភ័ន្តច្រឡំស្រដៀងគ្នាដែលបានធ្វើឡើងដោយ ក.ស.ច.ស។ ផ្ទុយពីដើមបណ្តឹងឧទ្ធរណ៍នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ អៀង សារី បានពន្យល់ពីសំអាងហេតុមួយដែលគាំទ្រទឡ្ហីករណ៍របស់ខ្លួនដែលថា មានការភ័ន្តច្រឡំនៅពេល

[៤២៤] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌទី ៤២-៤៣, ៥០។

[៤២៥] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ កថាខណ្ឌទី ៤២។

បញ្ជូនជនជាប់ចោទទៅជំនុំជម្រះ ទោះបីមិនមានការព្រមព្រៀងគ្នាក៏ដោយ[៤២៦] ហើយថា ការពន្យារ ចិរវេលាអាជ្ញាយុកាលដោយមាត្រា៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ជាការរំលោភលើ គោលការណ៍នីត្យានុកូលភាព[៤២៧]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា អង្គជំនុំជម្រះបានឆ្លើយ តបនឹងទឡ្ហីករណ៍ទាំងនេះបន្ថែម នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹង ដីកាដំណោះស្រាយ។ ដោយសារបញ្ហាយុត្តាធិការដែលអាចប្តឹងជំទាស់ក្នុងដំណាក់កាលនេះជាចំណុច សំខាន់ អង្គបុរេជំនុំជម្រះយល់ឃើញថា អង្គជំនុំជម្រះនេះត្រូវចេញសេចក្តីសម្រេចរបស់ខ្លួនអនុវត្ត ចំពោះជនជាប់ចោទទាំងអស់ នៅក្នុងសំណុំរឿងលេខ ០០២ ទាំងអស់តែម្តង។ អាស្រ័យហេតុនេះ អង្គ បុរេជំនុំជម្រះយល់ឃើញថា ការចោទប្រកាន់ពីបទល្មើសជាតិត្រូវតែតម្កល់ នៅក្នុងសេចក្តីសន្និដ្ឋាន របស់ខ្លួនលើបញ្ហានេះ នៅក្នុងសាលដីការបស់ខ្លួនសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ។

ច. <u>**បញ្ហាតើវាជាការភ័ន្តច្រឡំ និងមានការរំលោភបំពានលើគោលការណ៍នីត្យានុកូលភាពដែរឬទេ នៅពេល ដាក់បញ្ចូលយុត្តាធិការលើរឿងក្តីនៃទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើទាក់ទិននឹងការចោទប្រកាន់ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅក្នុងវិសាលភាពនៃយុត្តាធិការរបស់ អ.វ.ត.ក (មូលដ្ឋានទី៧ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ)**</u>

១៨៥. នៅក្នុងមូលដ្ឋានទី៧ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដើមបណ្តឹងឧទ្ធរណ៍បានលើកទឡ្ហីករណ៍ ពីរដើម្បីគាំទ្រដល់ការអះអាងរបស់លោកស្រីដែលថា ក.ស.ច.ស មានការភ័ន្តច្រឡំនៅក្នុងដីកា ដំណោះស្រាយ នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានបញ្ជាក់យុត្តាធិការលើការទទួលខុសត្រូវ

[៤២៦] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ ឯកសារលេខ D427/1/6 កថាខណ្ឌទី ១៧៤-១៧៥។

[៤២៧] សូមមើលដោយឡែកនៅក្នុង បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌទី ១៥៩ (ដែល អៀង សារី បានអះអាងថា "បញ្ហា នៅត្រង់ថា លទ្ធភាពនៃការចោទប្រកាន់បទល្មើសទាំងនេះ ក្នុងរយៈពេលជាង ៣០ ឆ្នាំ នៅអនាគត មិនបានចែងក្នុងច្បាប់កម្ពុជា ក្នុងរយៈពេលដែលពាក់ព័ន្ធ" ហើយថា គោលការណ៍នីត្យានុកូលភាពដែលមានចែងនៅក្នុងមាត្រា១៥(១) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានហាមឃាត់មិនឱ្យអនុវត្តច្បាប់បែបប្រតិសកម្ម ហេតុនេះហើយ គោលការណ៍នេះបាន ការពារមិនឱ្យមានការពន្យារចិរវេលាអាជ្ញាយុកាលដែលបានកន្លងផុត)។

របស់ថ្នាក់លើជា "ទម្រង់នៃការទទួលខុសត្រូវ ដែលទាក់ទិនទៅនឹងបទឧក្រិដ្ឋបី ដែលកំណត់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[៤២៨]។

១៨៦.ទីមួយ បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ លើកឡើងថា "ក្នុងច្បាប់អន្តរជាតិ គ្មានមូលដ្ឋានទំនៀមទម្លាប់ដែលគាំទ្រការអនុវត្តទ្រឹស្តីនេះទេ ក្នុងអំឡុងពេលចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយនៅក្នុងដីកាដំណោះស្រាយ ក.ស.ច.ស ក៏មិនបានផ្តល់មូលដ្ឋានគាំទ្រនូវការអនុវត្តនេះទេ។ ដូច្នេះការចោទប្រកាន់ពីការទទួលខុសត្រូវរបស់ថ្នាក់លើ គឺជាការរំលោភបំពានលើគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង (nullum crimen sine lege)* [...][៤២៩]។ ទីពីរ "ជាជម្រើសមួយផ្សេងវិញ ក្រុមមេធាវីការពារក្តីសន្និដ្ឋានថា នៅក្នុងអំឡុងពេលដែលពាក់ព័ន្ធ ការទទួលខុសត្រូវរបស់ថ្នាក់លើ អាចត្រូវបានគេយកមកចោទប្រកាន់លើឧក្រិដ្ឋកម្មសង្គ្រាមតែប៉ុណ្ណោះ" និងដោយសារតែ "ដើមបណ្តឹងឧទ្ធរណ៍ត្រូវបានចោទប្រកាន់ពីការទទួលខុសត្រូវរបស់ថ្នាក់លើ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ [...] តុលាការមិនមានយុត្តាធិការចោទប្រកាន់លោកស្រីពីការទទួលខុសត្រូវរបស់ថ្នាក់លើឡើយ"[៤៣០]។

២. <u>ការពិភាក្សា</u>

១៨៧.អង្គបុរេជំនុំជម្រះរំឭកថា នៅក្នុងដីកាដំណោះស្រាយ ក.ស.ច.ស បានសម្រេចថា ផ្អែកតាមមាត្រា ២៩(ថ្មី) នៃច្បាប់អ.វ.ត.ក, អ.វ.ត.ក មានយុត្តាធិការលើការទទួលខុសត្រូវរបស់ថ្នាក់លើ ជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែល ក.ស.ច.ស បានបកស្រាយនៅក្នុងផ្នែកដែលពាក់ព័ន្ធ ដូចខាងក្រោម ៖

> ថ្នាក់លើត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលឋិតនៅក្នុងសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក. ដែលប្រព្រឹត្តដោយអ្នកក្រោមបង្គាប់ នៅពេលដែលថ្នាក់លើបានដឹង ឬមានហេតុផលដែលត្រូវដឹងថាថ្នាក់ក្រោមបានប្រព្រឹត្តិឧក្រិដ្ឋកម្មណាមួយក្នុងចំណោមនោះ និងនៅក្នុងក្របខ័ណ្ឌ នៃការអនុវត្តអំណាចគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើអ្នកក្រោមបង្គាប់ ហើយថ្នាក់លើមិនបានចាត់វិធានការចាំ

---

[៤២៨] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌទី ៨១។

[៤២៩] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌទី ៨៤។

[៤៣០] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌទី ៨០, ៨២។

00686583

បាច់ និងសមរម្យ ដើម្បីរារាំង ឬបង្ក្រាបការប្រព្រឹត្តអំពើទាំងនោះ។ ទម្រង់នៃការទទួលខុសត្រូវនេះ ក៏អនុវត្តផងដែរចំពោះថ្នាក់លើក្នុងស្ថាប័នស៊ីវិល ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយថ្នាក់ក្រោមបង្គាប់របស់ខ្លួន[៤៣១]។

ការទទួលខុសត្រូវរបស់ថ្នាក់លើគឺជាទម្រង់នៃការទទួលខុសត្រូវមួយ ដែលជាលទ្ធផលនៃការខកខានករណីកិច្ចក្នុងការទប់ស្កាត់ការប្រព្រឹត្តឧក្រិដ្ឋកម្មមួយ ឬក្នុងការដាក់ទោសចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម [...]។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ថ្នាក់លើអនុវត្តទៅលើថ្នាក់លើទាំងផ្នែកយោធា ទាំងផ្នែកស៊ីវិល ហើយការលើកឡើងអំពីឋានានុក្រមជាផ្លូវការពុំចាំបាច់ឡើយ ក្នុងការចាត់ទុកបុគ្គលណាម្នាក់ ថាជាអ្នកទទួលខុសត្រូវក្នុងឋានៈជាថ្នាក់លើនោះ[៤៣២]។

១៨៨. លើសពីនេះទៀត ក.ស.ច.ស បានសម្រេចថា "ទម្រង់នៃការទទួលខុសត្រូវទាំងអស់ ដែលមានរៀបរាប់នៅក្នុងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. សុទ្ធតែត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិដែលអនុវត្តនៅកម្ពុជា ក្នុងពេលដែលអង្គហេតុបានកើតឡើង"[៤៣៣]។ ជាពិសេស ទាក់ទិនទៅនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ ក.ស.ច.ស បានរកឃើញថា ការទទួលខុសត្រូវរបស់ថ្នាក់លើ "ត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ ឆ្លងតាមរយៈការជំនុំជម្រះនានាដែលត្រូវបានរៀបចំឡើង បន្ទាប់ពីសង្គ្រាមលោកលើកទីពីរបានបញ្ចប់។ ដូច្នេះ ទម្រង់នៃការទទួលខុសត្រូវទាំងនេះត្រូវបានចាត់ទុកថា បានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដល់ជនត្រូវចោទ"[៤៣៤]។ ដូច្នេះ ក.ស.ច.ស បានសន្និដ្ឋានថា ការកំណត់និយមន័យរបស់ខ្លួនអំពីការទទួលខុសត្រូវរបស់ថ្នាក់លើជាទម្រង់នៃការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ គឺស្របទៅនឹងគោលការណ៍នីត្យានុកូលភាព[៤៣៥]។

១៨៩. លើសពីនេះទៀត នៅពេលយកនិយមន័យនៃទ្រឹស្តីការទទួលខុសត្រូវរបស់ថ្នាក់លើនេះ មកអនុវត្តជាពិសេសលើ អៀង ធីរិទ្ធ ក.ស.ច.ស បានសន្និដ្ឋានថា "ដោយផ្ទាស់គ្នាទៅនឹងទម្រង់ [ផ្ទាល់] នៃការ

---

[៤៣១] ដីកាដែលរងការជំទាស់ កថាខណ្ឌទី ១៣១៩ (ជើងទំព័រត្រូវបានលុបចេញ)។

[៤៣២] ដីកាដែលរងការជំទាស់ កថាខណ្ឌទី ១៥៥៧។

[៤៣៣] ដីកាដែលរងការជំទាស់ កថាខណ្ឌទី ១៣១៨។

[៤៣៤] ដីកាដែលរងការជំទាស់ កថាខណ្ឌទី ១៣០៧។

[៤៣៥] ដីកាដែលរងការជំទាស់ កថាខណ្ឌទី ១២៩៩។

អង្គជំនុំជម្រះតុលាការកំពូល * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

ទទួលខុសត្រូវព្រហ្មទណ្ឌដូចបានរៀបរាប់ខាងលើ [...] លោកស្រីគឺជាអ្នកទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ ដោយហេតុផលថា ជនត្រូវចោទមានអំណាចជាក់ស្តែង (ជាពិសេសក្នុងវិស័យសុខាភិបាល) លើអ្នកក្រោមបង្គាប់របស់ខ្លួននៅក្រសួងសង្គមកិច្ច ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៤៣៦]។ ក.ស.ច.ស បានរកឃើញថា "អៀង ធីរិទ្ធ បានដឹង ឬមានហេតុផលដែលដឹងថា ពិតជាអាចមានការប្រព្រឹត្តឧក្រិដ្ឋកម្មដោយអ្នកនៅក្រោមបង្គាប់របស់ខ្លួន ហើយខ្លួនបានខកខាននូវកាតព្វកិច្ចក្នុងការចាត់វិធានការចាំបាច់នានា ដើម្បីបង្ការឧក្រិដ្ឋកម្មទាំងនេះ"[៤៣៧]។ លើសពីនេះទៀត គាត់ "បានដឹង ឬមានហេតុផលដែលដឹងថា ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តយ៉ាងជាក់ស្តែង ដោយអ្នកក្រោមបង្គាប់របស់ខ្លួន ហើយខ្លួនបានខកខានក្នុងការដាក់ទោសចារីទាំងនោះ"[៤៣៨]។

(i) បញ្ហាថាតើមានមូលដ្ឋានដែរឬទេ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩

១៩០. ក្នុងការសម្រេចអំពីមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ជាដំបូង អង្គបុរេជំនុំជម្រះត្រូវតែសម្រេចថាតើ ក.ស.ច.ស មានការភ័ន្តច្រឡំឬយ៉ាងណា នៅក្នុងដីកាដែលរងការជំទាស់ ដែលសម្រេចថាមានមូលដ្ឋាននៅក្នុងច្បាប់អន្តរជាតិ ដើម្បីអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ជាពិសេស ទាក់ទិនទៅនឹងការអនុវត្តទ្រឹស្តីដូចដែលមានចែងនៅក្នុងមាត្រា ២៩(ថ្មី) នៃ ច្បាប់ អ.វ.ត.ក។ មាត្រា២៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា ការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានកំណត់ដូចខាងក្រោម ៖

> ប្រការដែលថាសកម្មភាពណាមួយ ក្នុងចំណោមសកម្មភាពដែលមានចែងក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧ និង មាត្រា៨ នៃច្បាប់នេះ ត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះមិនអាចជួយឱ្យថ្នាក់លើ រួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះបានទេ ប្រសិនបើថ្នាក់លើមានបញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ឬមានអំណាច និងការត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹង និងមានហេតុផលដឹងថា អ្នកនៅក្រោមបង្គាប់

[៤៣៦] ដីកាដែលរងការជំទាស់ កថាខណ្ឌទី ១៥៦១។

[៤៣៧] ដីកាដែលរងការជំទាស់ កថាខណ្ឌទី ១៥៦២។

[៤៣៨] ដីកាដែលរងការជំទាស់ កថាខណ្ឌទី ១៥៦២។

ប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាពបែបនេះ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់ និងសមស្រប ដើម្បីបង្ការអំពើបែបនេះ ឬដាក់ទណ្ឌកម្មចំពោះជនទាំងនេះ។

១៩១. ម្យ៉ាងវិញទៀត ដោយផ្អែកទៅលើមាត្រា ២៩(ថ្មី) អនុលោមតាមទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដើម្បីឱ្យជនជាប់ចោទទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋរបស់អ្នកនៅក្រោមបង្គាប់ខ្លួន ការបង្ហាញអំពីអត្ថិភាពនៃធាតុផ្សំចំនួនបីគឺជាការចាំបាច់។ ទីមួយ "ត្រូវតែមានទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់រវាងជនជាប់ចោទជាមួយនឹងជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋ" ដោយមានការត្រួតពិនិត្យ និងការបញ្ជា ឬការត្រួតពិនិត្យ និងអំណាចដ៏មានប្រសិទ្ធភាព។ ទីពីរ "ជនជាប់ចោទត្រូវតែបានដឹង និងមានហេតុផលដឹងថា ឧក្រិដ្ឋកម្មអាចនឹងត្រូវបានប្រព្រឹត្ត ឬត្រូវបានប្រព្រឹត្ត" ដែលសំដៅទៅលើ*ធាតុផ្សំអត្តនោម័ត* នៃការដឹងពិតប្រាកដ ឬការដឹងតាមការសន្មត និងទីបី "ជនជាប់ចោទខកខានមិនបានចាត់វិធានការចាំបាច់ និងសមស្រប ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្ម ឬដាក់ទណ្ឌកម្មចំពោះអ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនោះ" ដែលសំដៅទៅលើ*ធាតុផ្សំសត្យានុម័ត* តាមរយៈធាតុផ្សំនៃបទល្មើសអកម្ម[៤៣៩]។

១៩២. ជាបញ្ហាបឋម អង្គបុរេជំនុំជម្រះកត់សម្គាល់ថា បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ គ្រាន់តែជំទាស់ទៅនឹងមូលដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ប៉ុណ្ណោះ ចំពោះទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ជាបញ្ហាទូទៅ និងមិនជំទាស់ទៅលើបញ្ហាថាតើទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ក៏ត្រូវបានអនុវត្តផងដែរចំពោះថ្នាក់លើជាជនស៊ីវិល ឬយ៉ាងណានោះឡើយ។ នៅក្នុងទឡ្ហីករណ៍របស់លោកស្រី លោកស្រីបានយោងដដែលៗថា "ការទទួលខុសត្រូវក្នុងការបញ្ជា" គឺដូចគ្នាទៅនឹង "ការទទួលខុសត្រូវរបស់ថ្នាក់លើ" ហើយមិនបានបង្ហាញពីលក្ខណៈខុសគ្នារវាងការទទួលខុសត្រូវរបស់ថ្នាក់លើជាយោធា និងការទទួលខុសត្រូវរបស់ថ្នាក់លើជាជនស៊ីវិលឡើយ[៤៤០]។ លើសពីនេះទៀត លោកស្រីពុំបានជំទាស់ ឬផ្តល់នូវយុត្តិសាស្ត្រណាមួយស្តីពីបញ្ហាថាតើទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើក្រោយសង្គ្រាមលោកលើកទីពីរបានអនុវត្ត ទាក់ទិននឹងការទទួលខុសត្រូវរបស់ថ្នាក់លើជាយោធា ផ្ទុយពីការទទួលខុសត្រូវរបស់ថ្នាក់លើជាជនស៊ីវិល ឬយ៉ាងណានោះទេ។ លើសពីនេះទៀត នៅក្នុងសារណាតបរបស់លោកស្រី ដើមបណ្តឹងឧទ្ធរណ៍បានបញ្ជាក់ថា លោកស្រី

---

[៤៣៩] សាលក្រមរឿងក្តី ០០១ កថាខណ្ឌទី ៥៣៨។

[៤៤០] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌទី ៨៥-៩២។ សារណាតបរបស់ អៀង ធីរិទ្ធ កថាខណ្ឌទី ៧០, ៧៥។

“ពុំបានបដិសេធថា ទស្សនាទាននៃការទទួលខុសត្រូវរបស់ថ្នាក់លើ ក៏អាចត្រូវបានយកមកអនុវត្ត ចំពោះថ្នាក់លើដែលជាជនស៊ីវិលផងដែរ ដូចដែល ក.ស.ព បានលើកឡើងនៅក្នុងចម្លើយតបរបស់ខ្លួនឡើយ”[៤៤១]។ ទោះបីជាលោកស្រីកត់សម្គាល់ថា“វាជាទស្សនាទានមួយដែលចេញមកពីច្បាប់យោធា ដែលអាចយកមកអនុវត្តបាន ជាពិសេស ចំពោះកាលៈទេសៈនានាដែលកើតមានក្នុងក្របខ័ណ្ឌយោធា យ៉ាងណាក៏ដោយ” ក៏លោកស្រីទទួលស្គាល់ថា “គេប្រទះឃើញឧទាហរណ៍ផ្សេងៗក្នុងការយកទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តចំពោះបុគ្គលដែលពុំមែនជាយោធា”[៤៤២]។ ដូច្នេះ អង្គបុរេជំនុំជម្រះបកស្រាយបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ថាជំទាស់ទៅនឹងអត្ថិភាពនៃការទទួលខុសត្រូវរបស់ថ្នាក់លើជាទូទៅនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលវេលាដែលពាក់ព័ន្ធ និងមិនមែនជំទាស់ទៅនឹងបញ្ហាថាតើការទទួលខុសត្រូវរបស់ថ្នាក់លើក៏បានពង្រីកវិសាលភាពផងដែរ ទៅដល់ថ្នាក់លើជាជនស៊ីវិល ឬយ៉ាងណានោះឡើយ។

១៩៣.អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ការវិវឌ្ឍនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលតាមទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ នៅក្រោមបទដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិ មានភាពអវិជ្ជមានដោយសារព្រឹត្តការណ៍នានាក្រោយសង្គ្រាមលោកលើកទីមួយ។ ជាដំបូង នៅក្នុងរបាយ-ការណ៍ឆ្នាំ១៩១៩ របស់គណៈកម្មាការស្តីពីការទទួលខុសត្រូវរបស់ស្ថាបនិកសង្គ្រាម និងស្តីពីការអនុវត្តន៍ការដាក់ទណ្ឌកម្ម ដែលត្រូវបានបង្កើតឡើងដោយសន្និសីទស្តីពីសន្តិភាពបឋម ក្នុងគោលបំណងកំណត់អំពីការទទួលខុសត្រូវទាក់ទិននឹងសង្គ្រាម គណៈកម្មការបានផ្តល់នូវការយល់ឃើញយ៉ាងច្បាស់លាស់ចំពោះទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ក្នុងការផ្តល់យោបល់ថា បទចោទទាំងឡាយគួរតែត្រូវបាននាំយកមកជំនុំជម្រះនៅចំពោះមុខតុលាការអន្តរជាតិ៖

> ប្រឆាំងនឹងអ្នកមានអំណាចទាំងអស់ ផ្នែកស៊ីវិល ឬយោធា ដែលជាសមាជិករបស់ប្រទេសសត្រូវ ទោះបីជាមានតួនាទីខ្ពស់យ៉ាងណាក៏ដោយ ដោយមិនមានការបែងចែកខុសគ្នាអំពីឋានៈឡើយ រួមទាំងប្រមុខរដ្ឋដែលបានបញ្ជា ឬបានដឹង និងមានអំណាចក្នុងការធ្វើអន្តរាគមន៍ នៅស្ងៀមពុំបានទប់ស្កាត់ ឬចាត់វិធានការដើម្បីទប់ស្កាត់ បញ្ចប់ ឬបង្ក្រាបទៅលើការរំលោភច្បាប់ ឬទម្លាប់សង្គ្រាម (មានការ

[៤៤១] សារណាតបរបស់ អៀង ធីរិទ្ធ កថាខណ្ឌទី ៧៨។

[៤៤២] សារណាតបរបស់ អៀង ធីរិទ្ធ កថាខណ្ឌទី ៧៨។

00686587

យល់ថា ពុំមានការនៅស្ងៀមបែបនេះណាមួយឡើយ ដែលគួរតែបង្កើតបានជាការការពារខ្លួនសម្រាប់ចារីពិតប្រាកដ)[៤៤៣]។

១៩៤. ទោះបីជាការជំនុំជម្រះទោសលើបុគ្គលទាំងឡាយមកពីប្រទេសអាល្លឺម៉ង់ និងសម្ព័ន្ធមិត្តរបស់ខ្លួន អនុលោមតាមទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ពុំដែលកើតមានឡើងយ៉ាងណាក៏ដោយ ក៏រដ្ឋាភិបាលប្រទេសអាល្លឺម៉ង់បានយល់ព្រមជំនុំជម្រះទោសបុគ្គលចំនួន ១២នាក់ នៅចំពោះមុខតុលាការកំពូល Reich នៅទីក្រុង Leipzing ពីបទឧក្រិដ្ឋកម្មសង្គ្រាម[៤៤៤]។ នៅក្នុងរឿងក្តីមួយក្នុងចំណោមរឿងក្តីទាំងនេះទាក់ទិននឹង Emil Müller ដែលជាអនុសេនីយ៍ឯក នៅក្នុងកងទ័ពបម្រុងរបស់ទីក្រុង Karlsruhe តុលាការកំពូលបានរកឃើញថា ជនជាប់ចោទមានការទទួលខុសត្រូវលើការធ្វើបាបអ្នកទោសពីសំណាក់អ្នកក្រោមបង្គាប់ ដោយផ្អែកលើមូលដ្ឋានថា គាត់បានឃើញផ្ទាល់ភ្នែកនូវការធ្វើបាបនោះ ហើយពុំបានចាត់វិធានការនៅពេលក្រោយមកទៀត។ តុលាការសន្និដ្ឋានថា Müller យ៉ាងហោចណាស់បានអត់ទ្រាំ និងយល់ព្រមឱ្យមានការធ្វើបាបដ៏ឃោរឃៅនេះ ទោះបីជាអំពើនេះមិនត្រូវបានធ្វើឡើងតាមបញ្ជារបស់គាត់ក៏ដោយ"[៤៤៥]។ ចំណែកឯឧប្បត្តិហេតុមួយទៀត ទាក់ទិននឹងការធ្វើបាបអ្នកទោសពីសំណាក់អ្នកក្រោមបង្គាប់ តុលាការពុំបានរកឃើញថា Müller ជាអ្នកទទួលខុសត្រូវឡើយ ពីព្រោះវា "មិនច្បាស់ថាតើការធ្វើបាបនេះពុំបានកើតឡើង មុនពេលជនជាប់ចោទបានដឹងអំពីការធ្វើបាបនេះ ឬមុនពេលដែលជនជាប់ចោទអាចការពារកុំឱ្យមានអំពើនេះឬយ៉ាងណានោះឡើយ។ ដូច្នេះ ករណីនៃការអនុញ្ញាតដោយចេតនាឱ្យមានអំពើបែបនេះ នៅពេលដែលគាត់អាចការពារបានកុំឱ្យមានអំពើនេះ [...] មិនអាចត្រូវបានបង្កើតឡើងនៅទីនេះទេ"[៤៤៦]។

---

[៤៤៣] គណៈកម្មការស្តីពីការទទួលខុសត្រូវរបស់អ្នកបង្កសង្គ្រាម និងការអនុវត្តទោស "របាយការណ៍ដែលបានដាក់ជូនសន្និសីទសន្តិភាពបឋម (អនុម័តថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩១៩) បោះពុម្ពឡើងវិញនៅក្នុង 14 *Am. J. Int'l L* 1 (1920*)* at 121។ (សេចក្តីបញ្ជាក់បន្ថែម)

[៤៤៤] James F. Willis, បុព្វកថា *Nuremburge*: នយោបាយ និងការទូតនៃការដាក់ទណ្ឌកម្មឧក្រិដ្ឋជនសង្គ្រាម ក្នុងសង្គ្រាមលោកលើកទី១, Greenwood Publishing Group, ឆ្នាំ១៩៨២ ទំព័រទី ១៤២ (អង់គ្លេស)។

[៤៤៥] សាលក្រមនៅក្នុងរឿងក្តី Emil Müller ថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩២១ បោះពុម្ពឡើងវិញ នៅក្នុង 16 *American Journal of International Law* 684, (1922) ទំព័រទី ៦៨១ (អង់គ្លេស)។

[៤៤៦] សាលក្រមនៅក្នុងរឿងក្តី Emil Müller ថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩២១ បោះពុម្ពឡើងវិញ នៅក្នុង 16 *American Journal of International Law* 684, (1922) ទំព័រទី ៦៨១ (អង់គ្លេស)។

១៩៥. ទោះបីជាយ៉ាងណាក៏ដោយ មានតែក្រោយពេលសង្គ្រាមលោកលើកទី២រួចប៉ុណ្ណោះ ទើបការកាត់សេចក្តីជាអន្តរជាតិដែលផ្អែកលើទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានធ្វើឡើងពិតប្រាកដ។ ទោះជាទ្រឹស្តីនេះមិនត្រូវបានចែងច្បាស់លាស់ ក្រោមធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិនៅ Nuremberg ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា នៅទីក្រុងតូក្យូ ("IMTFE") ឬច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងសម្ព័ន្ធមិត្ត ("ច្បាប់គ្រប់គ្រងរបស់ក្រុមប្រឹក្សា") ពាក់ព័ន្ធទៅនឹងការជំនុំជម្រះក្តីនៅក្នុងតំបន់កាន់កាប់របស់អាល្លឺម៉ង់ក៏ដោយ ក៏រឿងក្តីមួយចំនួនរបស់ថ្នាក់លើអាល្លឺម៉ង់ និងជប៉ុនដែលត្រូវបានជំនុំជម្រះនៅចំពោះមុខតុលាការ IMTFE ហើយគណៈកម្មការ ឬតុលាការយោធាសម្ព័ន្ធមិត្ត បានបញ្ជាក់ច្បាស់ និងបានអនុវត្តទ្រឹស្តីនេះ។

១៩៦. ទីមួយ នៅក្នុងការជំនុំជម្រះក្តីឧត្តមសេនីយ៍ជប៉ុន Tomoyuki Yamashita ក្នុងឆ្នាំ១៩៤៥ "ដែលជានាយទាហានមានបទពិសោធន៍ច្រើនឆ្នាំ ដែលមានភារកិច្ចក្នុងការគ្រប់គ្រងទាហាន និងចេញបញ្ជាដ៏ទូលំទូលាយនៅក្នុងកងទ័ពអធិរាជជប៉ុន"[៤៤៧] ក្នុងវិសាលភាពដ៏ទូលាយនៅចំពោះមុខគណៈកម្មការយោធាអាមេរិក ឧត្តមសេនីយ៍ Yamashita ត្រូវបានចោទប្រកាន់ពី៖

> ការមិនយកចិត្តទុកដាក់ និងការខកខានដោយខុសច្បាប់ពុំបានបំពេញតួនាទីរបស់គាត់ជាមេបញ្ជាការ ដើម្បីត្រួតពិនិត្យលើអំពើនានារបស់អ្នកក្រោមបង្គាប់របស់គាត់ ដោយអនុញ្ញាតឱ្យអ្នកក្រោមបង្គាប់គាត់ប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម។ ខ្លឹមសារនៃរឿងក្តីសម្រាប់អយ្យការ គឺថាជនជាប់ចោទបានដឹង ឬប្រាកដជាបានដឹងអំពីអំពើនោះ និងបានអនុញ្ញាតឱ្យមានឧក្រិដ្ឋកម្មទូទៅដែលប្រព្រឹត្តនៅក្នុងប្រទេសហ្វីលីពីន ពីសំណាក់កងទ័ពនៅក្រោមបញ្ជារបស់គាត់ (ដែលរួមមាន អំពើមនុស្សឃាត អំពើលួចប្លន់ ការបំផ្លិចបំផ្លាញ ការរំលោភលើផ្លូវភេទ ការពុំផ្តល់នូវគ្រឿងចាំបាច់សម្រាប់ឈ្លើយសឹក និងការបាញ់សម្លាប់ទ័ពព្រៃដោយពុំមានការជំនុំជម្រះទោស) [. . .][៤៤៨]។

១៩៧. ទោះបីជាភស្តុតាងដែលបានដាក់ជូន មានលក្ខណៈមិនស៊ីសង្វាក់គ្នា ឬមិនច្បាស់លាស់ ទាក់ទិននឹងការដឹងរបស់ឧត្តមសេនីយ៍ Yamashita អំពីបទឧក្រិដ្ឋដែលប្រព្រឹត្តដោយអ្នកក្រោមបង្គាប់របស់គាត់

[៤៤៧] ការជំនុំជម្រះក្តីឧត្តមសេនីយ៍ *Tomoyuki Yamashita* Vol. IV ទំព័រទី ៣៥ (អង់គ្លេស)។

[៤៤៨] សាលក្រមលើរឿងក្តី *Yamashita* ទំព័រទី ១ (អង់គ្លេស)។

ឬការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើអ្នកក្រោមបង្គាប់ទាំងនោះ នៅពេលវេលាដែលពាក់ព័ន្ធយ៉ាងណាក៏ដោយ ក៏មានភស្តុតាងដ៏ច្រើននៅចំពោះមុខគណៈកម្មការដែលថា បទល្មើស "មានច្រើន និងទូទៅនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា"[៤៤៩] ហើយត្រូវបានប្រព្រឹត្តឡើង "ដោយកងទ័ពជប៉ុន ក្រោមបញ្ជារបស់ [ឧត្តមសេនីយ៍ Yamashita]"[៤៥០]។ ដូច្នេះ គណៈកម្មការបានសម្រេចថា "នៅពេលដែលអំពើមនុស្សឃាត និងអំពើរំលោភលើផ្លូវភេទ និងអំពើសងសឹក និងអំពើសាហាវយង់ឃ្នង គឺជាបទល្មើសមានលក្ខណៈទូទៅ និងពុំមានការខិតខំប្រឹងប្រែងប្រកបដោយប្រសិទ្ធភាពពីសំណាក់មេបញ្ជាការដើម្បីរកឱ្យឃើញ និងត្រួតពិនិត្យទៅលើអំពើឧក្រិដ្ឋទាំងនោះ មេបញ្ជាការនោះអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវ ទោះជាការទទួលខុសត្រូវព្រហ្មទណ្ឌក៏ដោយ ចំពោះអំពើខុសច្បាប់របស់កងទ័ពរបស់គាត់ ដោយផ្អែកលើលក្ខណៈរបស់ពួកគេ និងកាលៈទេសៈនៅជុំវិញពួកគេ"[៤៥១]។ ដូច្នេះ គណៈកម្មការបានផ្តន្ទាទោសឧត្តមសេនីយ៍ Yamashita ដោយផ្អែកលើមូលដ្ឋានថា "អំពើសាហាវឃោរឃៅមួយចំនួន និងបទឧក្រិដ្ឋធ្ងន់ធ្ងរដទៃទៀត ត្រូវបានប្រព្រឹត្តឡើងដោយសមាជិកនៃកងកម្លាំងប្រដាប់អាវុធជប៉ុន ក្រោមបញ្ជារបស់រូបលោក" និង "ក្នុងអំឡុងរយៈពេលដែលបានលើកឡើងនោះ លោកពុំបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅលើកងទ័ពរបស់លោក ដូចដែលកាលៈទេសៈបានតម្រូវឡើយ"[៤៥២]។

១៩៨. នៅក្នុងការឆ្លើយតបទៅកាន់បណ្តឹងទាមទារលើដីកាបង្គាប់ឱ្យនាំខ្លួនមកតុលាការ ក្នុងនាមឧត្តមសេនីយ៍ Yamashita តុលាការកំពូលសហរដ្ឋអាមេរិកបានគាំទ្រសំអាងហេតុរបស់គណៈកម្មការយោធាដោយសម្រេចថា បទប្បញ្ញត្តិមួយចំនួននៃច្បាប់អន្តរជាតិ "ពិតជាបានដាក់ទៅលើម្ចាស់បណ្តឹងទាមទារដែលនៅពេលនោះជាអ្នកគ្រប់គ្រងកងកម្លាំងយោធាប្រទេសហ្វីលីពីន និងក៏ជាមេបញ្ជាការកងកម្លាំងជប៉ុនផងដែរនូវភារកិច្ចស្រប (វិជ្ជមាន) មួយដើម្បីចាត់វិធានការដូច្នេះ *ដោយហេតុថា វាស្ថិតក្នុងអំណាចរបស់គាត់* និងសមស្របនៅក្នុងកាលៈទេសៈទាំងនេះ ដើម្បីការពារឈ្លើយសឹក និងប្រជាជន

[៤៤៩] សាលក្រមលើរឿងក្តី *Yamashita* ទំព័រទី ២ (អង់គ្លេស)។

[៤៥០] សាលក្រមលើរឿងក្តី *Yamashita* ទំព័រទី ៣៥ (អង់គ្លេស)។

[៤៥១] សាលក្រមលើរឿងក្តី *Yamashita* ទំព័រទី ៣៥ (អង់គ្លេស)។

[៤៥២] សាលក្រមលើរឿងក្តី *Yamashita* ទំព័រទី ៣៥ (អង់គ្លេស)។

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. C.E.T.C.

ស៊ីវិល។ ដូច្នេះ ភារកិច្ចជាមេបញ្ជាការកាលពីមុននេះ ត្រូវបានទទួលស្គាល់ ហើយការប្រព្រឹត្តល្មើសភារកិច្ចនេះ ត្រូវបានដាក់ទោសទណ្ឌ ដោយតុលាការយោធាផ្ទាល់ខ្លួនរបស់យើង”[៤៥៣]។

១៩៩. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ទោះបីជាសេចក្តីបញ្ជាក់ និងការអនុវត្តជាតុល្យភាពនៃទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ពីសំណាក់ចៅក្រមនៅក្នុងរឿងក្តីនេះមានភាពចម្រូងចម្រាស ជាពិសេសទាក់ទិននឹងលក្ខខណ្ឌជាតុល្យអត្តនោម័តដែលតម្រូវឱ្យមាន រួមទាំងការធ្វេសប្រហែស ឬសូម្បីតែបទដ្ឋានការទទួលខុសត្រូវដ៏តឹងរ៉ឹង និងការខកខានពុំបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់ឧត្តមសេនីយ៍ Yamashita ទៅលើកងទ័ពរបស់គាត់យ៉ាងណាក៏ដោយ ក៏វាពុំមានមន្ទិលឡើយថា រឿងក្តី *Yamashita* គឺជាយុត្តិសាស្ត្រសម្រាប់សញ្ញាណដែលថា ថ្នាក់លើអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌក្រោមច្បាប់អន្តរជាតិ ទាក់ទិននឹងបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងដោយអ្នកក្រោមបង្គាប់។ លើសពីនេះទៀត យោបល់ជំទាស់នៅក្នុងរឿងក្តីរបស់តុលាការកំពូល “បានរួមចំណែកច្រើនជាងសេចក្តីសម្រេចតាមមតិភាគច្រើន ក្នុងការប្រែក្លាយទស្សនាទាននេះឱ្យទៅជាទម្រង់ដែលមានលក្ខណៈជាទ្រឹស្តីនៃការទទួលខុសត្រូវព្រហ្មទណ្ឌ”[៤៥៤]។

២០០. ទីពីរ រឿងក្តីជាច្រើនក្នុងចំណោមរឿងក្តីទាំងដប់ពីរដែលត្រូវបានយកមកជំនុំជម្រះ និងសម្រេចក្រោមច្បាប់របស់ក្រុមប្រឹក្សាគ្រប់គ្រង ចាប់ពីខែ តុលា ឆ្នាំ ១៩៤៦-ខែ មេសា ឆ្នាំ ១៩៤៩ នៅចំពោះមុខតុលាការយោធា Nuremberg “តុលាការ Nurmberg” នៅក្នុងតំបន់កាន់កាប់ដោយសហរដ្ឋអាមេរិកក្នុងប្រទេសអាល្លឺម៉ង់ បានអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ។ ប្រហែលជារឿងក្តីដែលល្បីល្បាញជាងគេបំផុតនោះគឺរឿងក្តី *“High Command Case”* ដែលពាក់ព័ន្ធនឹងការចោទប្រកាន់នាយទាហានជាន់ខ្ពស់ ១៤នាក់ នៅក្នុងកងទ័ពអាល្លឺម៉ង់ ក្នុងចំណោមការចោទប្រកាន់ដទៃទៀត ចំពោះឧក្រិដ្ឋកម្មសង្គ្រាមប្រឆាំងនឹងក្រុមដែលចូលប្រឡូកក្នុងសង្គ្រាម និងឈ្លើយសឹក

[៤៥៣] សាលក្រមលើរឿងក្តី *Yamashita* របស់តុលាការកំពូលសហរដ្ឋអាមេរិក ទំព័រទី ១៦ (អង់គ្លេស) (សេចក្តីបញ្ជាក់បន្ថែម)

[៤៥៤] Guénaël Mettraux ច្បាប់ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ Oxford University Press, 2009 ទំព័រទី៧-៨ (អង់គ្លេស)។

(បទចោទទីពីរ) និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រឆាំងជនស៊ីវិល (បទចោទទីបី) ដូចដែលបានចោទប្រកាន់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[៤៥៥]។

២០១. ចុងចោទ១០នាក់ក្នុងចំណោមចុងចោទទាំងអស់ត្រូវបានរកឃើញថា មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងខណៈដែលចុងចោទនាំមុខ គឺសេនាប្រមុខ von Leeb ត្រូវបានផ្តន្ទាទោស តែចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប៉ុណ្ណោះ[៤៥៦]។ សេនាប្រមុខ von Leeb ត្រូវបានផ្តន្ទាទោសយ៉ាងជាក់លាក់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជាថ្នាក់លើផ្នែកយោធា[៤៥៧]។ នៅពេលដែលបញ្ជាក់អំពីទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ តុលាការបានបញ្ជាក់ដូចខាងក្រោម ដែលឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវនៃ *ធាតុផ្សំអង្គនោម័ត* និង *ធាតុផ្សំសត្យានុម័ត* ៖

> ភាពនៅក្រោមបង្គាប់ផ្នែកយោធាគឺជាកត្តាទូទៅ ប៉ុន្តែពុំមែនជាកត្តាចុងក្រោយគ្មានមន្ទិលក្នុងការកំណត់ការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ អំណាចទាំងផ្នែករដ្ឋបាល និងយោធារបស់មេបញ្ជាការម្នាក់ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់មានការជាប់ពាក់ព័ន្ធគ្នា ប៉ុន្តែពុំមានវិសាលភាពស្មើគ្នាឡើយ។ សង្គ្រាមសម័យទំនើប ដូចជាសង្គ្រាមចុងក្រោយ នាំឱ្យមានវិធានការដ៏ធំនៃវិមជ្ឈការ។ “មេបញ្ជាការជាន់ខ្ពស់មិនអាចត្រូវដឹងឱ្យបានពេញលេញរៀងរាល់ពេល អំពីសេចក្តីពិស្តារនៃប្រតិបត្តិការយោធារបស់អ្នកនៅក្រោមបង្គាប់របស់ខ្លួនឡើយ ហើយពិតណាស់ពុំដឹងអំពីគ្រប់វិធានការរដ្ឋបាលឡើយ។ គាត់មានសិទ្ធិក្នុងការសន្មតថា សេចក្តីពិស្តារដែលត្រូវបានប្រគល់ទៅឱ្យអ្នកក្រោមបង្គាប់ដែលមានការទទួលខុសត្រូវ នឹងត្រូវបានអនុវត្តដោយស្របច្បាប់។ ប្រធានាធិបតីសហរដ្ឋអាមេរិកគឺជាអគ្គមេបញ្ជាការនៃកងកម្លាំងយោធារបស់ខ្លួន។ ការប្រព្រឹត្តបទឧក្រិដ្ឋដែលធ្វើឡើងដោយកងកម្លាំងទាំងអស់នោះ មិនអាចត្រូវបានចោទប្រកាន់ចំពោះគាត់តាមទ្រឹស្តីអំពីភាពនៅក្រោមបង្គាប់នោះបានទេ។ ដូចគ្នាទៅនឹងមេបញ្ជាការជាន់ខ្ពស់ដទៃទៀតដែរនៅក្នុងខ្សែសង្វាក់របស់ថ្នាក់លើ។ ឧក្រិដ្ឋភាពមិនទាក់ទិនទៅនឹងគ្រប់បុគ្គលទាំងអស់ នៅក្នុងខ្សែសង្វាក់របស់ថ្នាក់លើដែលចេញមកពីអង្គហេតុតែមួយប៉ុណ្ណោះឡើយ។ ត្រូវតែមានការធ្វេសប្រហែសផ្ទាល់ខ្លួន។ រឿងនេះអាចកើតឡើងបានតែនៅពេលដែលការប្រព្រឹត្តអាចពាក់ព័ន្ធចំពោះរូបគាត់ ឬនៅពេលដែលការខកខានមិនបានគ្រប់គ្រងអ្នកនៅក្រោមបង្គាប់ឱ្យបានត្រឹមត្រូវ គឺជាការធ្វេសប្រហែសទាក់ទិននឹងបទឧក្រិដ្ឋរបស់គាត់តែ

---

[៤៥៥] *High Command Case* Vol X ទំព័រទី ១០។ Vol XI ទំព័រទី ៤៦៣-៤៦៥ (អង់គ្លេស)។

[៤៥៦] *High Command Case* Vol XI ទំព័រទី ៥៦០-៥៦១ (អង់គ្លេស)។ ចុងចោទផ្សេងទៀតបានធ្វើអត្តឃាតមុនពេលការជំនុំជម្រះក្តី ត្រូវបានផ្អាកដំណើរការ។

[៤៥៧] *High Command Case* Vol XI ទំព័រទី ៥៦០-៥៦១ (អង់គ្លេស)។

PRE-TRIAL CHAMBER E.C.C.C.

00686592

ប៉ុណ្ណោះ។ នៅក្នុងករណីចុងក្រោយគេនេះ វាត្រូវតែជាការធ្វេសប្រហែសផ្ទាល់ខ្លួន ដែលស្មើនឹងការមិនអើពើចំពោះអំពើមិនប្រព្រឹត្តសមរម្យអសីលធម៌របស់អ្នកនៅក្រោមបង្គាប់របស់ខ្លួន ដែលរាប់ទុកថាជាការត្រូវរ៉ូវគ្នា។ ការបកស្រាយច្បាប់អន្តរជាតិផ្សេងទៀត នឹងហួសឆ្ងាយពីគោលការណ៍គ្រឹះនៃច្បាប់ព្រហ្មទណ្ឌដែលត្រូវបានទទួលស្គាល់ ដោយប្រជាជាតិដែលមានអារ្យធម៌ [...]។ មេបញ្ជាការដែលត្រួតត្រា ត្រូវតែមានការដឹងអំពីបទល្មើសទាំងនេះ [ប្រព្រឹត្តឡើងដោយកងទ័ពរបស់គាត់] និងត្រូវរ៉ូវគ្នា ឬចូលរួម ឬមិនអើពើជ្រៀតជ្រែកក្នុងការប្រព្រឹត្តរបស់ពួកគេ និង [...] បទល្មើសដែលត្រូវបានប្រព្រឹត្តត្រូវតែមានលក្ខណៈឧក្រិដ្ឋយ៉ាងច្បាស់ក្រឡែត[៤៥៨]។

២០២. លើសពីនេះទៀត ទាក់ទិនទៅនឹងលក្ខណៈតម្រូវនៃទំនាក់ទំនងថ្នាក់លើ និងអ្នកក្រោមបង្គាប់ តុលាការបានកំណត់នូវទម្រង់នៃលក្ខខណ្ឌនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព នៅពេលបដិសេធទ្រឹស្តីរបស់អយ្យការដែលថាមេបញ្ជាការនៅសមរភូមិ ដែលទទួលខុសត្រូវជាផ្លូវការចំពោះទឹកដីដែលបានកាន់កាប់ អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវយ៉ាងតឹងរ៉ឹង ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិលពីសំណាក់អ្នកក្រោមបង្គាប់របស់គាត់នៅក្នុងទឹកដីនោះ ដោយសារតែសកម្មភាពរបស់អាជ្ញាធរ Reich និងអាជ្ញាធរយោធាជាន់ខ្ពស់[៤៥៩]។ តុលាការយល់ឃើញថា នៅពេលដែល

[៤៥៨] *High Command Case* Vol XI *ទំព័រទី ៥៤៣-៥៤៥* (អង់គ្លេស) ។

[៤៥៩] *High Command Case* Vol XI *ទំព័រទី ៥៤៤-៥៤៥* (អង់គ្លេស) "ទាក់ទិននឹងការទទួលខុសត្រូវរបស់មេបញ្ជាការសមរភូមិចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងតំបន់នៃការបញ្ជារបស់គាត់ ជាពិសេស ប្រឆាំងទៅនឹងប្រជាជនស៊ីវិល មានការទទូចពីអយ្យការថា អនុលោមតាមអនុសញ្ញាទីក្រុងឡាអេ មេបញ្ជាការយោធានៃទឹកដីដែលត្រូវបានកាន់កាប់ គឺទទួលខុសត្រូវដោយខ្លួនឯងនៅក្នុងតំបន់នៃការកាន់កាប់របស់គាត់ ដោយពុំគិតអំពីបញ្ជា បទបញ្ជា និងច្បាប់របស់ថ្នាក់លើគាត់ដែលកម្រិតអំណាចរបស់គាត់ឡើយ និងដោយពុំគិតអំពីអង្គហេតុដែលថាបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើង គឺដោយសារតែសកម្មភាពរបស់រដ្ឋ ឬអាជ្ញាធរ យោធាថ្នាក់លើ ដែលគាត់ពុំបានផ្តួចផ្តើម ឬដែលគាត់ពុំបានចូលរួមនោះឡើយ [...]។ តុលាការនេះយល់ឃើញថា [...] គេមិនអាចនិយាយបានថា គាត់អនុវត្តអំណាច ដែលជនស៊ីវិលត្រូវស្ថិតនៅក្រោមកងទ័ពដែលចូលលុកលុយរបស់គាត់ឡើយ ដែលក្នុងខណៈនោះដែរ រដ្ឋដែលគាត់តំណាងនោះអាចចូលមកគ្រប់គ្រងតំបន់ ដែលគាត់កាន់កាប់ ហើយបង្ខំប្រជាជនឱ្យទទួលរងអំពើមនុស្សឃាត និងការប្រព្រឹត្តអមនុស្សធម៌ដទៃទៀត។ [...] ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលបានបញ្ជាក់នៅក្នុងផ្នែកដទៃទៀត នៃរឿងក្តីនេះ យើងយល់ឃើញថា មេបញ្ជាការដែលកំពុងត្រួតត្រា ប្រាកដជាដឹងអំពីបទល្មើសទាំងនេះ និងត្រូវរ៉ូវគ្នា ឬចូលរួម ឬក៏មិនអើពើជ្រៀតជ្រែកនៅក្នុងការប្រព្រឹត្តបទល្មើសទាំងនោះដែលនាំឱ្យមានទោសព្រហ្មទណ្ឌ ហើយថា បទល្មើសដែលត្រូវបានប្រព្រឹត្តត្រូវតែមានលក្ខណៈព្រហ្មទណ្ឌយ៉ាងច្បាស់ក្រឡែត"។

E.C.C.C. • C.E.T.C. PRE-TRIAL CHAMBER • CHAMBRE PRÉLIMINAIRE

អំណាចបែបនេះត្រូវបានចោទប្រកាន់ថា បានដកចេញពីមេបញ្ជាការ តុលាការនឹងពិនិត្យលើកត្តាអត្តនោម័ត និងកត្តាសត្យានុម័ត នៅក្នុងការពិចារណាអំពីសុពលភាពនៃការការពារខ្លួន[៦៦០]។

២០៣.ទីបី រឿងក្តីមួយទៀតរបស់តុលាការ NMT គឺរឿងក្តីសហរដ្ឋអាមេរិក ទល់នឹង *Wilhelm List* ***និងអ្នកផ្សេងទៀត*** (*“Hostage Case”*)[៦៦១] បានអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើយ៉ាងជាក់លាក់។ រឿងក្តី *Hostage Case* ពាក់ព័ន្ធនឹងសេនាប្រមុខ និងឧត្តមសេនីយ៍ជាន់ខ្ពស់នានា ដែលត្រូវបានចោទប្រកាន់អំពីឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលប្រព្រឹត្តឡើងប្រឆាំងនឹងជនស៊ីវិល កងទ័ពសត្រូវ និងឈ្លើយសឹក[៦៦២] “ពីសំណាក់កងទ័ពនៃកងកម្លាំងប្រដាប់អាវុធអាល្លឺម៉ង់ក្រោមការបញ្ជានិងសមត្ថកិច្ច ការទទួលខុសត្រូវ និងការប្រព្រឹត្តអនុលោមតាមបទបញ្ជាដែលត្រូវបានចេញអនុវត្ត និងផ្សព្វផ្សាយ”[៦៦៣] ដោយចុងចោទ។ តុលាការបានសម្រេចថា “ក្នុងការកំណត់អំពីពិរុទ្ធភាព ឬនិរទោសនៃចុងចោទនីមួយៗក្នុងចំណោមចុងចោទទាំងនេះ យើងត្រូវតម្រូវឱ្យមានភស្តុតាងអំពីអំពើសកម្ម ឬអកម្មយ៉ាងច្បាស់ក្រឡែត ដែលចេតនាពិរុទ្ធអាចត្រូវបានយោងទៅលើអំពើនោះមុនពេលសាលក្រមផ្តន្ទាទោសនឹងត្រូវបានប្រកាស”[៦៦៤]។ ឧត្តមសេនីយ៍ List ត្រូវបានរកឃើញថាមានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមបទចោទទីមួយ និងទីបី នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទិនទៅនឹងអំពើមនុស្សឃាត និងអំពើធ្វើបាប ដែលត្រូវបានធ្វើឡើងប្រឆាំងនឹងជនស៊ីវិល កងទ័ពសត្រូវ និងឈ្លើយសឹករាប់ពាន់នាក់ពីសំណាក់អ្នកក្រោមបង្គាប់របស់គាត់ នៅពេលដែលគាត់ជាមេបញ្ជាការកងកម្លាំងប្រដាប់អាវុធ នៅប៉ែកអាគ្នេយ៍ក្នុងទឹកដីដែលត្រូវបានកាន់កាប់នៃប្រទេសយូហ្គោស្លាវី ប្រទេសក្រិក និងប្រទេសអាល់បានី[៦៦៥]។ តុលាការរកឃើញថា ភស្តុតាងបានបង្ហាញថា ទាក់ទិននឹងលក្ខខណ្ឌ *ធាតុផ្សំអត្តនោម័ត* និង *ធាតុផ្សំសត្យានុម័ត* នៃការទទួលខុសត្រូវរបស់ថ្នាក់លើ៖

---

[៦៦០] *High Command Case* Vol XI ទំព័រទី ៥៤៨-៥៤៩ (អង់គ្លេស)។

[៦៦១] រឿងក្តីសហរដ្ឋអាមេរិក ទល់នឹង *Wilhelm List* និងអ្នកផ្សេងទៀត ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៤៨ បោះពុម្ពឡើងវិញនៅក្នុងការជំនុំជម្រះក្តីរបស់តុលាការយោធា *Nuernberg* Vol XI (*“Hostage Case”*)។

[៦៦២] *Hostage* Case Vol X ទំព័រទី ៧៦៥-៧៧៦, ១២៣៣ (អង់គ្លេស)។

[៦៦៣] *Hostage* Case ទំព័រទី ៧៦៥ (អង់គ្លេស)។

[៦៦៤] *Hostage* Case ទំព័រទី ១២៦១ (អង់គ្លេស)។

[៦៦៥] *Hostage* Case ទំព័រទី ១២៧៤ (អង់គ្លេស)។

PRE-TRIAL CHAMBER • E.C.C.C • C.E.T.C • CHAMBRE PRÉLIMINAIRE

របាយការណ៍ដែលធ្វើឡើងជូនចំពោះចុងចោទ List ដែលជាមេបញ្ជាការកងកម្លាំងប្រដាប់អាវុធប៉ែកអាគ្នេយ៍ ចោទប្រកាន់គាត់អំពីការដឹងនូវការសម្លាប់ប្រជាជនស្លូតត្រង់រាប់ពាន់នាក់ដោយខុសច្បាប់ ជាការសងសឹកចំពោះអំពើរបស់សមាជិកដែលមិនត្រូវបានស្គាល់អត្តសញ្ញាណដែលតាមផ្លូវច្បាប់ មិនត្រូវបានស្ថិតនៅក្រោមការដាក់ទោសទណ្ឌបែបនោះឡើយ។ គាត់មិនដែលថ្កោលទោសអំពើបែបនោះថាខុសច្បាប់ឡើយ។ គាត់មិនដែលហៅអ្នកទាំងឡាយណាដែលទទួលខុសត្រូវចំពោះអំពើយង់ឃ្នង និងអមនុស្សធម៌មកធ្វើការបញ្ជាក់ឡើយ។ ការខកខានពុំបានបញ្ឈប់ការសម្លាប់ដោយខុសច្បាប់ទាំងនេះ និងចាត់វិធានការគ្រប់គ្រាន់ ដើម្បីទប់ស្កាត់កុំឱ្យអំពើទាំងនេះកើតឡើងម្តងទៀត គឺជាការរំលោភយ៉ាងធ្ងន់ធ្ងរលើកាតព្វកិច្ច និងដាក់នូវការទទួលខុសត្រូវព្រហ្មទណ្ឌ។ ជំនួសឱ្យការចាត់វិធានការដ៏ត្រឹមត្រូវ គាត់បានអនុញ្ញាតដោយសេចក្តីពេញចិត្តឱ្យប្រជាជនស្លូតត្រង់រាប់ពាន់នាក់ស្លាប់ នៅចំពោះមុខក្រុមប្រហារជីវិតរបស់កងកម្លាំងប្រដាប់អាវុធ Wehrmacht និងអង្គភាពយោធាដទៃទៀត ដែលប្រតិបត្តិការនៅក្នុងដែនដីនោះ[៤៦៦]។

២០៤. តុលាការបានបដិសេធមេធាវីការពារថា គាត់ពុំបានដឹងអំពីរបាយការណ៍ទាំងនេះ ដោយផ្អែកលើមូលដ្ឋានថា "របាយការណ៍ជូនចំពោះឧត្តមសេនីយ៍បញ្ជាការ ត្រូវបានធ្វើឡើងដើម្បីផលប្រយោជន៍ពិសេសរបស់ពួកគាត់។ ការខកខានណាមួយពុំបានដឹងអំពីខ្លឹមសារនៃរបាយការណ៍បែបនោះ ឬការខកខានពុំបានស្នើសុំឱ្យមានរបាយការណ៍បន្ថែម នៅពេលដែលមានកង្វះខាតបង្ហាញឡើងនៅចំពោះមុខរបស់ពួកគាត់ គឺជាសេចក្តីធ្វេសប្រហែសក្នុងករណីកិច្ចដែលគាត់មិនអាចយកមកប្រើដើម្បីជួយខ្លួនគាត់បានឡើយ"[៤៦៧]។ លើសពីនេះទៀត ទាក់ទិននឹងលក្ខខណ្ឌថ្នាក់លើ/អ្នកក្រោមបង្គាប់ចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើ តុលាការពុំទទួលយកទឡ្ហីករណ៍របស់គាត់ ដែលថា ការសម្លាប់ជាច្រើនត្រូវបានធ្វើឡើងដោយអង្គភាពយោធា ដែលជាយុទ្ធសាស្ត្រពុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់[៤៦៨]។ តុលាការកត់សម្គាល់ថា "ឧត្តមសេនីយ៍បញ្ជាការលើទឹកដីដែលត្រូវបានកាន់កាប់ ត្រូវបានចោទប្រកាន់អំពីការខកខានក្នុងការបំពេញភារកិច្ចរក្សាសន្តិភាព និងសណ្តាប់ធ្នាប់ ការដាក់ទោសទណ្ឌលើបទឧក្រិដ្ឋ និងការពារអាយុជីវិត និងទ្រព្យសម្បត្តិនៅក្នុងតំបន់ក្រោមការបញ្ជារបស់គាត់។ ការទទួលខុសត្រូវរបស់គាត់មានវិសាលភាពគ្របដណ្តប់លើតំបន់នានា ដែលស្ថិតនៅក្រោមការបញ្ជា

[៤៦៦] *Hostage* Case ទំព័រទី ១២៧១-១២៧២ (អង់គ្លេស)។

[៤៦៧] *Hostage* Case ទំព័រទី ១២៧១ (អង់គ្លេស)។

[៤៦៨] *Hostage* Case ទំព័រទី ១២៧២ (អង់គ្លេស)។

របស់គាត់"[៤៦៩]។ ដូច្នេះ តុលាការយល់ឃើញថា អំណាចរបស់ឧត្តមសេនីយ៍ List មានជាប់មកជាមួយនៅក្នុងតួនាទីនោះ ហើយ "ការទទួលខុសត្រូវជាបឋមចំពោះការទប់ស្កាត់ និងការដាក់ទោសទណ្ឌចំពោះបទឧក្រិដ្ឋស្ថិតនៅលើឧត្តមសេនីយ៍បញ្ជាការរូបនេះ។ នេះគឺជាការទទួលខុសត្រូវមួយដែលគាត់មិនអាចគេចផុត ដោយគ្រាន់តែការបដិសេធថាគាត់មិនមានអំណាចលើចារី"[៤៧០] នោះទេ។

២០៥. ស្រដៀងគ្នានេះដែរ ឧត្តមសេនីយ៍ Walter Kuntze ដែលទទួលតួនាទីជាមេបញ្ជាការកងកម្លាំងប្រដាប់អាវុធប៉ែកអាគ្នេយ៍ពីឧត្តមសេនីយ៍ List ត្រូវបានផ្តន្ទាទោសក្រោមបទចោទទីមួយ ទីបី និងទីបួន ចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងជនស៊ីវិល កងទ័ពសត្រូវ និងឈ្លើយសឹករាប់ពាន់នាក់ពីសំណាក់អ្នកក្រោមបង្គាប់របស់គាត់[៤៧១]។ តុលាការសម្រេចថា គាត់ទទួលខុសត្រូវក្រោមទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចំពោះការប្រមូលផ្តុំជនជាតិ Jews និង Gypsies នៅក្នុងជំរំប្រមូលផ្តុំ និងការសម្លាប់ជនជាតិទាំងនោះ នៅពេលដែលតុលាការរកឃើញថា ៖

> ភស្តុតាងបង្ហាញនូវការប្រមូលផ្តុំជនជាតិ Jews នៅក្នុងជំរំប្រមូលផ្តុំ និងការសម្លាប់ជនជាតិ Jews និងជនជាតិ Gypsies មួយក្រុមធំភ្លាមៗ បន្ទាប់ពីចុងចោទបានកាន់តួនាទីជាបញ្ជាការនៅប៉ែកអាគ្នេយ៍ពីសំណាក់អង្គភាពស្ថិតក្រោមបង្គាប់គាត់។ កំណត់ហេតុពុំបានបង្ហាញថា ចុងចោទ Kuntze បានបញ្ជាឱ្យបាញ់សម្លាប់ជនជាតិ Jews ឬផ្ទេរពួកគេទៅជំរំប្រមូលផ្តុំឡើយ។ ភស្តុតាង បង្ហាញថា គាត់បានដឹងតាមរយៈរបាយការណ៍ថា អង្គភាពក្រោមបង្គាប់គាត់បានបាញ់សម្លាប់ជនជាតិ Jews និង Gypsies មួយក្រុមធំ ដូចដែលបានបញ្ជាក់ពីខាងលើ។ គាត់ពិតជាបានដឹងថា កងទ័ពក្រោមបង្គាប់របស់គាត់បានប្រមូល និងដឹកជញ្ជូនជនជាតិ Jews ទៅកាន់ជំរំប្រមូលផ្តុំ។ នៅក្នុងរបាយការណ៍ពុំមានបង្ហាញថា ចុងចោទ Kuntze បានចាត់វិធានការបញ្ឈប់អំពើខុសច្បាប់បែបនេះឡើយ។ វាច្បាស់ណាស់ដែលថា គាត់ពុំជំទាស់នឹងការអនុវត្តរបស់ពួកគេឡើយ នៅពេលដែលគាត់មានភារកិច្ចធ្វើ

[៤៦៩] *Hostage* Case ទំព័រទី ១២៧១ (អង់គ្លេស)។

[៤៧០] *Hostage* Case ទំព័រទី ១២៧២ (អង់គ្លេស)។

[៤៧១] *Hostage* Case ទំព័រទី ១២៨១ (អង់គ្លេស)។

អង្គជំនុំជម្រះសាលាដំបូង
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. C.E.T.C.

អន្តរាគមន៍ ដើម្បីទប់ស្កាត់កុំឱ្យអំពើទាំងនេះកើតឡើងជាថ្មីទៀត។ យើងយល់ថា ការទទួលខុសត្រូវរបស់គាត់ចំពោះអំពើខុសច្បាប់ទាំងនេះបានបង្ហាញយ៉ាងគ្រប់គ្រាន់ តាមរយៈរបាយការណ៍[៤៧២]។

២០៦. លើសពីនេះទៀត មេបញ្ជាការនៃកងទ័ពបម្រុង LXIX (LXIX Reserve Corps) នៅក្នុងប្រទេសក្រូអាស៊ីប៉ែកខាងជើង ឧត្តសេនីយ៍ Ernst Dehner ត្រូវបានផ្តន្ទាទោសក្រោមបទចោទទីមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចំពោះការសម្លាប់ចំណាប់ខ្មាំងស៊ីវិលរាប់ពាន់នាក់ដោយខុសច្បាប់ និងការសងសឹកប្រឆាំងនឹងអ្នកទោសស៊ីវិល ដែលធ្វើឡើងដោយអ្នកក្រោមបង្គាប់ផ្ទាល់របស់គាត់ ដែលអំពើទាំងនេះបង្កើតបានជាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៤៧៣]។ តុលាការរកឃើញថា "កំណត់ហេតុបង្ហាញថា ចុងចោទនេះបានដឹងច្បាស់អំពីអំពើទាំងនេះ។ [...] តាមរយៈការពិនិត្យភស្តុតាងបង្ហាញឱ្យយើងឃើញថា ការអនុវត្តការសម្លាប់ចំណាប់ខ្មាំង និងការសងសឹកអ្នកទោសគឺមិនអាចគ្រប់គ្រងបាន នីត្យានុកូលភាពមិនត្រូវបានគេអើពើ ហើយអំពើតាមតែទំនើងចិត្តបានក្លាយជាគោលនយោបាយដែលត្រូវបានគេទទួលយក។ ចុងចោទគឺជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះការអនុញ្ញាត ឬការអត់ធ្មត់ចំពោះអំពើបែបនេះ នៅលើផ្នែកនៃមេបញ្ជាការក្រោមបង្គាប់របស់គាត់"[៤៧៤]។ ក្នុងការឆ្លើយតបទៅនឹងការការពារខ្លួនរបស់ឧត្តមសេនីយ៍ Dehner ដែលថា មេបញ្ជាការតំបន់ដែលជាអ្នកទទួលខុសត្រូវចំពោះការចេញបញ្ជាឱ្យប្រព្រឹត្តអំពើទាំងឡាយនោះ តុលាការយល់ស្រប ប៉ុន្តែតុលាការយល់ឃើញថា "មេបញ្ជាការថ្នាក់លើក៏ទទួលខុសត្រូវផងដែរ ប្រសិនបើគាត់ចេញបញ្ជា អនុញ្ញាត ឬត្រូវរ៉ូវគ្នានៅក្នុងអំពើឧក្រិដ្ឋបែបនោះ។ ភារកិច្ច និងកាតព្វកិច្ចរបស់គាត់ គឺទប់ស្កាត់នូវអំពើបែបនេះ ឬប្រសិនបើអំពើបែបនេះត្រូវបានប្រព្រឹត្តរួចហើយ គឺត្រូវចាត់វិធានការដើម្បីទប់ស្កាត់កុំឱ្យអំពើនោះកើតឡើងជាថ្មីទៀត"[៤៧៥]។

២០៧. ដូចគ្នានេះដែរ ឧត្តមសេនីយ៍ Hubert Lanz ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមបទចោទទីមួយ ចំពោះការខកខានពុំបានទប់ស្កាត់នូវការសងសឹក

[៤៧២] *Hostage* Case ទំព័រទី ១២៧៩-១២៨០ (អង់គ្លេស)។

[៤៧៣] *Hostage* Case ទំព័រទី ១២៩៧, ១២៩៩ (អង់គ្លេស)។

[៤៧៤] *Hostage* Case ទំព័រទី ១២៩៩ (អង់គ្លេស)។

[៤៧៥] *Hostage* Case ទំព័រទី ១២៩៨ (អង់គ្លេស)។

អង្គជំនុំជម្រះសាលាដំបូង
PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRÉLIMINAIRE

ដោយខុសច្បាប់ប្រឆាំងនឹងជនស៊ីវិលស្លូតត្រង់ ដែលត្រូវបានប្រព្រឹត្តដោយអ្នកក្រោមបង្គាប់[៨៧៦]។ តុលាការសម្រេចថា ៖

> ចុងចោទនិយាយថា ជាមេបញ្ជាការកលយុទ្ធ គាត់មានការមមាញឹកយ៉ាងខ្លាំងមិនបានចាប់អារម្មណ៍ទៅលើបញ្ហានៃការសងសឹកឡើយ។ នេះគឺជាការដោះសារដែលពុំគួរឱ្យជឿឡើយ។ ការសម្លាប់ប្រជាជនស្លូតត្រង់ដោយខុសច្បាប់ គឺជាបញ្ហាមួយដែលទាមទារនូវការចាត់ចែងប្រកបដោយប្រសិទ្ធភាព និងឱ្យបានឆាប់រហ័ស ពីសំណាក់នាយទាហានឋានៈខ្ពស់បំផុតនៃកងទ័ព។ ចុងចោទនេះ ដោយបានដឹងយ៉ាងច្បាស់អំពីអ្វីដែលកំពុងកើតឡើង ពុំបានធ្វើអ្វីទាល់តែសោះអំពីបញ្ហានេះ។ ពុំឃើញមានបទបញ្ជាណាមួយ ដែលបញ្ជាក់ពីគោលបំណងក្នុងការដាក់ចំណាប់ខ្មាំង និងការអនុវត្តការសងសឹកនៅក្នុងវិធានសង្គ្រាមឡើយ។ ចុងចោទពុំបាន សូម្បីតែអះអាងថាគាត់បានធ្វើឡើយ។ ក្នុងនាមជាមេបញ្ជាការកងទ័ព XXII Corps គាត់មានកាតព្វកិច្ចចាត់វិធានការ ហើយនៅពេលដែលគាត់ពុំបានចាត់វិធានការ និងបានអនុញ្ញាតឱ្យមានការសម្លាប់ដោយខុសច្បាប់ និងអមនុស្សធម៌ទាំងនេះ កើតឡើងបន្តទៀតនោះ គាត់ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ។

២០៨. ចុងក្រោយ ឧត្តមសេនីយ៍ Wilhelm Speidal ជាមេបញ្ជាការយោធានៅប្រទេសក្រិកប៉ែកខាងត្បូង ត្រូវបានផ្តន្ទាទោសក្រោមបទចោទទីមួយ ពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះការអនុវត្តការសម្លាប់ចំណាប់ខ្មាំង និងការសម្លាប់សងសឹកដោយខុសច្បាប់ ប្រឆាំងនឹងប្រជាជនស៊ីវិលពីសំណាក់អ្នកក្រោមបង្គាប់របស់គាត់[៨៧៧]។ តុលាការយល់ឃើញថា "មេបញ្ជាការយោធានៅប្រទេសក្រិក អាច*ត្រួតត្រា*ទៅលើការអនុវត្តការសងសឹក និងចំណាប់ខ្មាំង តាមរយៈបញ្ជាការដ្ឋានអនុតំបន់នានាដែលស្ថិតក្រោមបញ្ជារបស់គាត់ មិនអាចត្រូវបានចោទជាបញ្ហាទេ"[៨៧៨]។ លើសពីនេះទៀត តុលាការយល់ឃើញថា ភស្តុតាងបានបង្ហាញថា ឧត្តមសេនីយ៍ Speidal បានដឹងអំពីអំពើទាំងនេះ និងបានអនុញ្ញាតឱ្យអំពើទាំងនេះកើតមានឡើង[៨៧៩]។

---

[៨៧៦] *Hostage* Case ទំព័រទី ១៣១៣ (អង់គ្លេស)។

[៨៧៧] *Hostage* Case ទំព័រទី ១៣១៧ (អង់គ្លេស)។

[៨៧៨] *Hostage* Case ទំព័រទី ១៣១៤ (អង់គ្លេស)។

[៨៧៩] *Hostage* Case ទំព័រទី ១៣១៥-១៣១៦ (អង់គ្លេស)។

២០៩. ទីបួន រឿងក្តីសហរដ្ឋអាមេរិក *ទល់នឹង* Karl Brandt *និងអ្នកផ្សេងទៀត* (“*Medical Case*”)[៤៨០] គឺជារឿងក្តីមួយទៀតរបស់តុលាការ NMT ដែលបានអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ។ ទោះបីជាយ៉ាងណាក៏ដោយ និយាយដោយជាក់ច្បាស់ទៅ មិនដូចជារឿងក្តីទាក់ទងនឹងបញ្ជាការជាន់ខ្ពស់ (*High Command Case*) និងរឿងក្តីចំណាប់ខ្មាំង (*Hostage Case*) ឡើយ ទ្រឹស្តីនេះត្រូវបានយកមកអនុវត្តចំពោះចុងចោទ Karl Brandt ដែលពុំមែនជាថ្នាក់លើផ្នែកយោធា។ ក្នុងឆ្នាំ១៩៣៤ គាត់គឺជាគ្រូពេទ្យផ្ទាល់ខ្លួនរបស់ Hitler និងជាសមាជិកម្នាក់របស់ Allgemeigne SS។ ក្នុងឆ្នាំ១៩៤០ គាត់ត្រូវបានផ្ទេរទៅក្រុមប្រដាប់អាវុធរបស់កងទ័ព SS ដែលជាកងកម្លាំងប្រដាប់អាវុធ Waffen SS ដែលកិច្ចការប្រតិបត្តិនានាស្មើគ្នាទៅនឹងកិច្ចការប្រតិបត្តិរបស់កងទ័ព ទោះបីជាវាពុំមែនជាផ្នែកនៃកងទ័ពអាល្លឺម៉ង់ក៏ដោយ[៤៨១]។ តាមរយៈក្រឹត្យដែលចេញដោយ Hilter នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៤៤ Brandt បានក្លាយជាអគ្គាធិការសម្រាប់សេវាសុខភាព និងវេជ្ជសាស្ត្ររបស់ប្រទេសអាល្លឺម៉ង់ “ដែលផ្តល់អំណាចឱ្យគាត់ចេញសេចក្តីណែនាំ ទៅកាន់គ្រប់សេវាផ្នែកវេជ្ជសាស្ត្រទាំងអស់របស់រដ្ឋ បក្ស និងកងកម្លាំងប្រដាប់អាវុធអាល្លឺម៉ង់ (Wehrmacht) ទាក់ទិននឹងបញ្ហាវេជ្ជសាស្ត្រ” ទាំងស៊ីវិល និងយោធា[៤៨២]។ តុលាការយល់ឃើញថា ក្រៅពីទស្សនកិច្ចរបស់គាត់ទៅកាន់ជំរំប្រមូលផ្តុំ Brandt បានដឹងអំពីការធ្វើពិសោធន៍សារធាតុ sulfanilamide ទៅលើមនុស្សនៅ Ravensbrueck អស់រយៈពេលប្រហែលមួយឆ្នាំ មុនខែ សីហា ឆ្នាំ ១៩៤៣ នៅកិច្ចប្រជុំមួយដែលធ្វើឡើងក្នុងខែ ឧសភា ឆ្នាំ ១៩៤៣ ដែលនៅទីនោះរបាយការណ៍ស្តីពីការធ្វើពិសោធន៍ ត្រូវបានធ្វើឡើង[៤៨៣]។ នៅពេលនោះ៖

> នៅក្នុងវិស័យវេជ្ជសាស្ត្រ Karl Brandt បានកាន់មុខតំណែងមួយដ៏ខ្ពស់ជាងគេបំផុតនៅក្រោម Hitler ដោយផ្ទាល់។ គាត់ស្ថិតនៅក្នុងមុខតំណែងមួយដែលត្រូវធ្វើអន្តរាគមន៍ទៅសមត្ថកិច្ចនានាលើរាល់បញ្ហាដែលទាក់ទិននឹងវេជ្ជសាស្ត្រ។ តាមពិត មុខតំណែងបែបនោះ ហាក់ដូចជាតួនាទី ដែលមានលក្ខណៈវិជ្ជមានរបស់គាត់។ វាបង្ហាញឱ្យឃើញថា គ្មានពេលណាមួយ ដែលគាត់បានចាត់វិធានការណាមួយ ដើម្បីពិនិត្យមើលការពិសោធផ្នែកវេជ្ជសាស្ត្រលើមនុស្សឡើយ។ [...] ក្នុងការកាន់កាប់

---

[៤៨០] *Medical* Case។

[៤៨១] *Medical* Case Vol II ទំព័រ ១៩០ (អង់គ្លេស)។

[៤៨២] *Medical* Case, Vol II ទំព័រ ១៩១-១៩២ (អង់គ្លេស)។

[៤៨៣] *Medical* Case, Vol II ទំព័រ ១៩៣ (អង់គ្លេស)។

អង្គជំនុំជម្រះសាលាដំបូង * E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

មុខតំណែងដូចជាមុខតំណែងរបស់គាត់ និងការមានតួនាទីជាគ្រូពេទ្យមួយរូប ដែលមានសមត្ថភាព និងបទពិសោធន៍ ភារកិច្ចគឺស្ថិតលើរូបគាត់ ដែលត្រូវធ្វើការស៊ើបអង្កេតមួយចំនួនឱ្យបានគ្រប់គ្រាន់ ទាក់ទិននឹងការស្រាវជ្រាវពិសោធន៍ផ្នែកវេជ្ជសាស្ត្រដែលរូបគាត់បានដឹងដោយមិនបាច់សង្ស័យទេថា បាននិងកំពុងតែបន្តធ្វើនៅក្នុងជំរំប្រមូលផ្តុំ[៤៨៤]។

២១០.ដូច្នេះ តុលាការសន្និដ្ឋានថា ៖

យើងយល់ឃើញថា Karl Brandt *បានទទួលខុសត្រូវ* បានជួយនិងជំរុញ បានចូលរួមដោយយល់ព្រម និងពាក់ព័ន្ធជាមួយនឹងផែនការ និងសហកម្ម ដែលទាក់ទិននឹងការធ្វើពិសោធន៍ផ្នែកវេជ្ជសាស្ត្រ ដែលត្រូវបានធ្វើឡើងទៅលើអ្នកដែលមិនមែនជាជនជាតិអាល្លឺម៉ង់ ដោយពុំមានការយល់ព្រមពីពួកគាត់ និងនៅក្នុងអំពើឃោរឃៅដទៃផ្សេងៗទៀត ដែលនៅក្នុងអំឡុងពេលនោះ អំពើមនុស្សឃាត ភាពសាហាវយង់ឃ្នង ភាពព្រៃផ្សៃ ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត ត្រូវបានប្រព្រឹត្តឡើង។ ផ្នែកខ្លះនៃអំពើឧក្រិដ្ឋទាំងនេះ ពុំបង្កើតបានជាឧក្រិដ្ឋកម្មសង្គ្រាម ក៏ផ្នែកទាំងនេះបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៤៨៥]។

២១១.ស្រដៀងគ្នានេះដែរ សហចុងចោទរបស់ Brandt គឺឈ្មោះ Oskar Schroeder ដែលត្រូវបានផ្តន្ទាទោសក្រោមការទទួលខុសត្រូវរបស់ថ្នាក់លើដែលជាថ្នាក់ដឹកនាំយោធា ចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រឆាំងនឹងឈ្លើយសឹក និងជនស៊ីវិលដែលពុំមែនជនជាតិអាល្លឺម៉ង់ ដោយសារតែការធ្វើពិសោធន៍ ត្រាំក្នុងទឹកកកត្រជាក់ ដែលត្រូវបានគេធ្វើឡើងក្នុងឆ្នាំ១៩៤២ នៅជំរំប្រមូលផ្តុំ Dachau ដើម្បីផលប្រយោជន៍របស់កងទ័ពអាកាស (Luftwaffe)។ តុលាការរកឃើញថា នៅពេលដែលគាត់បានក្លាយជាប្រធានផ្នែកសេវាវេជ្ជសាស្ត្រនៃ Luftwaffe គាត់បានដឹងពិតប្រាកដអំពីការពិសោធន៍ ដែលបណ្តាលឱ្យអ្នកដែលជាកម្មវត្ថុសម្រាប់ការពិសោធន៍ ដែលពុំមែនជាជនជាតិអាល្លឺម៉ង់មានការឈឺចាប់ និងស្លាប់ជាច្រើននាក់។ គាត់ក៏បានដឹងថា ការស្រាវជ្រាវវ៉ាក់សាំងសម្រាប់ជំងឺគ្រុនសន្និ ត្រូវបានប្រើទៅលើអ្នកដែលជាកម្មវត្ថុ សម្រាប់ការពិសោធន៍ដែលពុំមែនជាជនជាតិអាល្លឺម៉ង់នៅជំរំប្រមូលផ្តុំ Natzweiler និង Schirmeck ក្នុងឆ្នាំ១៩៤២-១៩៤៣ ហើយគាត់បានដឹងតាមរយៈរបាយការណ៍ដែលផ្ញើជូនគាត់ដែលថាបណ្តាលឱ្យមានការស្លាប់ ប៉ុន្តែគាត់ពុំបានស៊ើបសួរ

---

[៤៨៤] *Medical* Case, Vol II ទំព័រ ១៩៣-១៩៤ (អង់គ្លេស)។

[៤៨៥] *Medical* Case, Vol II ទំព័រ ១៩៨ (អង់គ្លេស) (សេចក្តីបញ្ជាក់បន្ថែម) ។

ទៅលើចំណុចនេះឡើយ[៤៨៦]។ តុលាការបានផ្តន្ទាទោសគាត់ចំពោះការធ្វើពិសោធន៍ទាំងនេះ ដែលធ្វើឡើងដោយអ្នកក្រោមបង្គាប់ ដោយយល់ឃើញថា "ច្បាប់សង្គ្រាមដាក់ទៅលើនាយទាហានដែលកាន់តួនាទីក្នុងការបញ្ជា ដែលមានភារកិច្ចវិជ្ជមានក្នុងការចាត់វិធានការនានាដែលស្ថិតក្នុងអំណាចរបស់គាត់ និងសមស្របចំពោះកាលៈទេសៈ ដើម្បីគ្រប់គ្រងអ្នកទាំងឡាយណាដែលស្ថិតក្រោមបញ្ជារបស់គាត់ ដើម្បីទប់ស្កាត់អំពើទាំងឡាយដែលរំលោភលើច្បាប់សង្គ្រាម"[៤៨៧]។

២១២.សហចុងចោទម្នាក់ទៀត ឈ្មោះ Sigfried Handloser ក៏ត្រូវបានផ្តន្ទាទោសផងដែរ ចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលប្រព្រឹត្តឡើងប្រឆាំងនឹងជនស៊ីវិលអាល្លឺម៉ង់ និងជនស៊ីវិលដែលពុំមែនជាជនជាតិអាល្លឺម៉ង់ និងឈ្លើយសឹក នៅក្នុងតួនាទីរបស់គាត់ជាថ្នាក់លើផ្នែកយោធា[៤៨៨]។ តុលាការយល់ឃើញថា Handloser បានដឹងពិតប្រាកដអំពីការពិសោធគ្រុំក្នុងទឹកកកត្រជាក់ និងការពិសោធសារធាតុ Sulfanimide ដែលត្រូវបានធ្វើឡើង ទៅលើអ្នកទោស ដោយពុំមានការយល់ព្រមពីពួកគាត់ ហើយដែលបានបណ្តាលឱ្យពួកគាត់ស្លាប់។ ទោះបីជាយ៉ាងណាក៏ដោយគាត់ពុំបានព្យាយាមធ្វើការស៊ើបអង្កេត ឬគ្រប់គ្រងលើអ្នកក្រោមបង្គាប់របស់គាត់ដែលកំពុងអនុវត្តការពិសោធនោះឡើយ[៤៨៩]។ ដោយដកស្រង់យុត្តិសាស្ត្ររឿងក្តី *Yamashita* ចៅក្រមបានសម្រេចថា ៖

> ទាក់ទិននឹងការទទួលខុសត្រូវរបស់ Handloser ចំពោះការធ្វើពិសោធន៍ដោយខុសច្បាប់ទៅលើមនុស្ស ភស្តុតាងបង្ហាញថា ដោយដឹងអំពីការយកអ្នកដែលពុំមែនជាជនជាតិអាល្លឺម៉ង់ មកធ្វើជាកម្មវត្ថុសម្រាប់ការពិសោធន៍មនុស្សជារឿយៗ គាត់ពុំបានអនុវត្តកម្រិតក្នុងការគ្រប់គ្រងឱ្យបានត្រឹមត្រូវទៅលើអ្នកដែលនៅក្រោមបង្គាប់របស់គាត់ឡើយ ដែលជាប់ពាក់ព័ន្ធនឹងការពិសោធផ្នែកវេជ្ជសាស្ត្រដែលស្ថិតនៅក្នុងផ្នែកសមត្ថកិច្ចជាផ្លូវការរបស់គាត់។ នេះគឺជាភារកិច្ចមួយ ដែលត្រូវបានប្រគល់ឱ្យគាត់ទទួលខុសត្រូវ ដោយយោងលើតួនាទីផ្លូវការរបស់គាត់។ ប្រសិនបើគាត់បានអនុវត្តការទទួលខុសត្រូវ

---

[៤៨៦] *Medical* Case Vol II ទំព័រ ២១១-២១៣ (អង់គ្លេស)។

[៤៨៧] *Medical* Case Vol II ទំព័រ ២១២ (អង់គ្លេស) ។

[៤៨៨] ជាពិសេស ការផ្តន្ទាទោស ទាក់ទងនឹងអំណាចរបស់គាត់ "ជាប្រធានផ្នែកសេវាវេជ្ជសាស្ត្រនៃ Wehrmacht ដែលកាន់តួនាទីជាថ្នាក់លើគ្រប់គ្រងសេវាវេជ្ជសាស្ត្រកងទ័ព និងជាប្រធានផ្នែកសេវាវេជ្ជសាស្ត្រនៃកងទ័ពជើងទឹក និង Luftwaffe និងស្ថាប័នចំណុះមួយចំនួនទៀត ដែលពាក់ព័ន្ធនឹង Wehrmacht។ តារាងក៏បានបង្ហាញអំពីអំណាចរបស់គាត់ទៅលើប្រធានការិយាល័យផ្នែកសេវាវេជ្ជសាស្ត្រនៃ Waffen SS និងផ្នែកនានានៃ Waffen SS នៅពេលបញ្ចូលជាមួយនឹង Wehrmacht." (*Medical* Case Vol II, ទំព័រទី ២០០) (អង់គ្លេស) ។

[៤៨៩] *Medical* Case Vol II, ទំព័រទី ២០៦ (អង់គ្លេស)។

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER · CHAMBRE PRÉLIMINAIRE · E.C.C.C. · C.E.T.C.

របស់គាត់ អ្នកដែលពុំមែនជាជនជាតិអាល្លឺម៉ង់យ៉ាងច្រើន ប្រាកដជាបានរួចផុតពីអំពើមនុស្សឃាត។ នៅក្នុងកម្រិតណាមួយនោះ ឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តដោយអំណាចរបស់គាត់ ឬដោយអ្នកក្រោមអំណាចរបស់គាត់ពុំមែនជាឧក្រិដ្ឋកម្មសង្គ្រាមនោះទេ។ ឧក្រិដ្ឋកម្មទាំងនោះគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៤៥០]។

២១៣. ទីប្រាំ នៅក្នុងរឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង* *Ernst von Weizsaecker* *និងអ្នកផ្សេងទៀត* *("Ministries Case")*[៤៥១] Gottlob Berger ដែលជាប្រធានទីស្នាក់ការកណ្តាល SS (Main Office SS) ចាប់ពីឆ្នាំ ១៩៤០ ដល់ឆ្នាំ ១៩៤៥ និងជាភ្នាក់ងារទំនាក់ទំនងក្រសួងរបស់ Himmler សម្រាប់ទឹកដីប៉ែកខាងកើត ត្រូវបានរកឃើញថាមានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលប្រព្រឹត្តឡើងដោយអង្គភាព Dirlewanger ដែល*ជាក់ស្តែង* ស្ថិតក្រោមបង្គាប់របស់គាត់[៤៥២]។ ដូចគ្នានឹង Karl Brandt ដែរ និយាយឱ្យចំទៅគាត់ពុំមែនជាថ្នាក់លើផ្នែកយោធាឡើយ។ គាត់ជាឧត្តម

---

[៤៥០] *Medical* Case Vol II, ទំព័រ ២០៦ (អង់គ្លេស)។

[៤៥១] ការជំនុំជម្រះក្តីលើ *Ernst von Weizsaecker* និងអ្នកផ្សេងទៀត សាលក្រមចុះថ្ងៃទី១១ ខែ មេសា ឆ្នាំ ១៩៤៩, នៅក្នុងការជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាម នៅចំពោះមុខតុលាការយោធា *Nuernberg* ក្រោមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង (ឆ្នាំ១៩៥១) Vol XII-XIV ("*Ministries* Case") ។

[៤៥២] នៅសមរភូមិ អង្គភាពមិនស្ថិតនៅក្រោមការបង្គាប់បញ្ជាផ្នែកកលយុទ្ធរបស់គាត់ទេ។ អង្គភាពនោះត្រូវបានរៀបចំឡើង ដោយរូបគាត់ និងបណ្តុះបណ្តាលដោយបុគ្គលដែលគាត់បានជ្រើសរើស។ វាជាគំនិតរបស់គាត់។ អង្គភាព និងមេបញ្ជាការរបស់អង្គភាពនេះ ស្ថិតក្រោមការការពាររបស់គាត់។ គាត់ជារឿយៗបានទទួលព័ត៌មានអំពីទង្វើដែលគ្មានអារ្យធម៌ និងសាហាវឃោរឃៅរបស់អង្គភាពនេះ ដែលគាត់មិនត្រឹមតែបានអនុញ្ញាតឱ្យបន្តសកម្មភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានព្យាយាមធ្វើយុត្តិកម្មផងដែរ។ គាត់បានខិតខំប្រឹងប្រែងដើម្បីឱ្យមានការផ្ទេរ ឬបំបែកអង្គភាពនេះ ដោយបានស្នើឱ្យមានការដំឡើងឋានន្តរសក្តិមេបញ្ជាការអង្គភាពនេះ និងបានជួយការពារគាត់។ គោលបំណងមួយក្នុងចំណោមគោលបំណងនានា ដែលកងពលតូចត្រូវបានបង្កើតឡើង គឺដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយថា អង្គភាពនេះបានប្រព្រឹត្តដូច្នេះ ដល់កម្រិតមួយដែលបានធ្វើឱ្យមានការភ័យខ្លាច និងរន្ធត់ដល់ស្នងការរបស់ Nazi និងក្រសួងសម្រាប់ទឹកដីប៉ែកខាងកើត របស់ Rosenberg ដែលស្ទើរតែមិនអាចត្រូវបានចោទប្រកាន់ដោយយុត្តិធម៌អំពីការអត់ឱនដល់ជនជាតិជ្វីហ្វ និងប្រជាជននៃទឹកដីប៉ែកខាងកើត ត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ។ ការទទួលខុសត្រូវរបស់ Berger មានលក្ខណៈច្បាស់ក្រឡែត។ គាត់មានពិរុទ្ធភាពទាក់ទិនទៅនឹងបញ្ហា នានាដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងរូបគាត់ ពាក់ព័ន្ធនឹងសកម្មភាពរបស់អង្គភាព Dirlewanger ហើយយើងយល់ឃើញបែបនេះ។ *Ministries Case* Vol XIV ទំព័រទី ៥៤៥-៥៤៦ (អង់គ្លេស)។

សេនីយ៍ឯកនៅក្នុងកងទ័ព Waffen SS ហើយលើសពីនេះទៀត គាត់ក៏កាន់តួនាទីមួយចំនួនទៀតនៅក្នុងរដ្ឋាភិបាលផងដែរ[៤៥៣]។

២១៤. ទីប្រាំមួយ នៅក្នុងរឿងក្តី *គណៈកម្មាធិការរដ្ឋាភិបាលនៃតុលាការទូទៅរបស់រដ្ឋាភិបាលយោធាសម្រាប់តំបន់ដែលត្រួតត្រាដោយប្រទេសបារាំងនៅក្នុងប្រទេសអាល្លឺម៉ង់ ទល់នឹង* Roechling ("រឿងក្តី Roechling")[៤៥៤] ឧស្សាហករជនជាតិអាល្លឺម៉ង់ឈ្មោះ Hermann Roechling និង von Gemmingen-Hornberg ត្រូវបានដាក់ឱ្យទទួលខុសត្រូវលើឧក្រិដ្ឋកម្មសង្គ្រាម ចំពោះការប្រព្រឹត្តអមនុស្សធម៌ពីសំណាក់នគរបាលសន្តិសុខផ្ទៃក្នុងអាល្លឺម៉ង់ (Gestapo) ទៅលើនិរទេសជនបរទេស និងកម្មករដែលជាឈ្លើយសឹក នៅក្នុងរោងចក្ររបស់ពួកគាត់ តាមរយៈប្រព័ន្ធវិន័យដែលត្រូវបានបង្កើតឡើងដោយមានការយល់ព្រមជាមុនពីពួកឧស្សាហករ[៤៥៥]។ ទោះបីជាតុលាការបញ្ជាក់ថា ថ្នាក់លើជាជនស៊ីវិលពីរនាក់នេះ "បានអនុញ្ញាត" និង "បានជំរុញ" នូវអត្ថិភាព និងអភិវឌ្ឍន៍បន្ថែមទៀតនៃប្រព័ន្ធនៃការប្រព្រឹត្តអមនុស្សធម៌នេះ នៅក្នុងរោងចក្ររបស់ពួកគាត់យ៉ាងណាក៏ដោយ[៤៥៦] អំពើពិរុទ្ធរបស់ Hermann Roechling ក៏ស្ថិតនៅក្នុងពាក្យនៃការខកខានផងដែរ ក្នុងនាមជាថ្នាក់លើ។ តុលាការយល់ឃើញថា ដោយពិចារណាលើតួនាទី និងអំណាចរបស់គាត់ វាគឺជា៖

> ភារកិច្ចរបស់គាត់ក្នុងការទទួលព័ត៌មានអំពីការប្រព្រឹត្តមកលើនិរទេសជន។ ការពិតដែលគាត់ពុំបានខ្វល់អំពីជោគវាសនារបស់និរទេសជនទាំងនេះ កាន់តែបង្កើនការទទួលខុសត្រូវរបស់គាត់ថែមទៀត។ នៅក្នុងមុខតំណែងទាំងពីររបស់គាត់ ជាប្រធានរោងចក្រ Voelklingen ផង និងជាប្រធាននៃសមាគម Reich Association Iron ផង គាត់មានអំណាចគ្រប់គ្រាន់ដើម្បីធ្វើអន្តរាគមន៍ និងបន្ថយកុំឱ្យមានការរំលោភបំពានធ្ងន់ធ្ងរ ទោះបីជាគាត់ពុំអាចបញ្ឈប់អំពើរំលោភបំពានទាំងនោះបានទាំងស្រុងក៏ដោយ។ សាលក្រមដែលត្រូវបានជំទាស់ បង្ហាញដោយមានសុពលភាពថា សាក្សីជាច្រើនបានអះអាងថា Hermann Roechling មានឱកាសជាច្រើនលើកក្នុងការត្រួតពិនិត្យទៅលើផ្នែកដែល

---

[៤៥៣] *Ministries* Case, Vol XII ទំព័រទី ១៧-១៨ (អង់គ្លេស)។

[៤៥៤] ការជំនុំជម្រះក្តីលើ *Hermann Roechling* និងអ្នកផ្សេងទៀត សាលក្រមចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៤៨, ការជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាម នៅចំពោះមុខតុលាការយោធា *Nuernberg* ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង (ឆ្នាំ១៩៥១) Vol XIV ឧបសម្ព័ន្ធ B ("រឿងក្តី *Roechling*")។

[៤៥៥] *រឿងក្តី Roechling* ទំព័រទី ១១៣៥, ១១៤០-៤១ (អង់គ្លេស)។

[៤៥៦] *រឿងក្តី Roechling* ទំព័រទី ១១៣៦, ១១៤០-៤១ (អង់គ្លេស)។

PRE-TRIAL CHAMBER C.E.C.C.

ពាក់ព័ន្ធចំពោះរូបគាត់ ដើម្បីឱ្យដឹងប្រាកដអំពីជោគវាសនាដែលត្រូវបានកំណត់ទៅលើបុគ្គលិករបស់គាត់។ តាមរយៈឯកសណ្ឋានអ្នកទោសនៅក្នុងអំឡុងពេលដែលគាត់ចុះពិនិត្យទាំងនោះ គាត់មិនអាចបដិសេធថា គាត់មិនបានដឹងអំពីអំពើរំលោភបំពានទាំងនោះបានទេ[៤៩៧]។

២១៥. ស្រដៀងគ្នានេះដែរ ទាក់ទិននឹង von Gemmingen-Hornberg តុលាការបញ្ជាក់ថា៖

> [គាត់] ក្រៅពីធ្វើជាប្រធានគណៈនាយកនៃ Stahlwerke Roechling គាត់ក៏បានកាន់តួនាទីជាអ្នកគ្រប់គ្រងផ្នែកការងារ គឺថាជាអ្នកតំណាងផ្នែកការងារនៅក្នុងការពិភាក្សាចរចាជាមួយនឹងអាជ្ញាធរនានា ដែលមានសមត្ថកិច្ចពិសេសដើម្បីដោះស្រាយបញ្ហានានាទាក់ទិននឹងការងារ។ ផ្នែកសមត្ថកិច្ចរបស់គាត់ក៏រួមបញ្ចូលផងដែរ នូវទំនាក់ទំនងជាមួយនឹង Gestapo ទាក់ទិននឹងប៉ូលីសផ្នែកការងារ។ Von Gemmingen-Hornberg អះអាងថា គាត់ពុំមានសមត្ថភាពក្នុងការផ្លាស់ប្តូរស្ថានភាព ដែលគាត់បានដឹងនោះឡើយ ដោយសារតែកម្មករដែលត្រូវបាននិរទេសទាំងនោះស្ថិតនៅក្រោមអំណាចរបស់ Gestapo និងសហជីពជាតិសង្គមនិយមអាល្លឺម៉ង់ (German Labor Front)។ ទោះបីជាយ៉ាងណាក៏ដោយ តួនាទីខ្ពស់ដែលគាត់កាន់ បានផ្តល់ឱ្យគាត់នូវអំណាចគ្រប់គ្រាន់ដើម្បីធ្វើអន្តរាគមន៍ និងដើម្បីជានាធ្វើឱ្យមានលក្ខណៈប្រសើរក្នុងការប្រព្រឹត្តចំពោះនិរទេសជន ដែលត្រូវបានផ្តន្ទាទោសទាំងនោះ[៤៩៨]។

២១៦. ទីប្រាំពីរ សាលក្រមតុលាការយោធាអន្តរជាតិចុងបូព៌ា ឆ្នាំ១៩៤៩[៤៩៩] បញ្ជាក់អំពីទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ក្រោមជំពូក II ដែលមានចំណងជើងថា "ច្បាប់" ទាក់ទិនទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ចំពោះឧក្រិដ្ឋកម្មសង្គ្រាមប្រឆាំងនឹងអ្នកទោស និងយកវាមកអនុវត្តលើសមាជិករដ្ឋាភិបាល លើនាយទាហាន ឬនាយទាហានជើងទឹក ដែលបញ្ជាទៅលើអង្គភាពយោធានានាដែលមានអ្នកទោសនៅក្នុងដៃរបស់ពួកគាត់ មន្ត្រីទាំងឡាយក្នុងនាយកដ្ឋាននានាដែលទទួលខុសត្រូវចំពោះសុខុមាលភាពរបស់អ្នកទោស និងមន្ត្រីនានា មិនថាផ្នែកស៊ីវិល យោធា ឬជើងទឹក ឡើយ ដែលមានការត្រួតត្រាលើអ្នកទោសដោយផ្ទាល់[៥០០]។ ទោះបីជាសាលក្រមពុំបានសំដៅឱ្យបានច្បាស់

---

[៤៩៧] *រឿងក្តី Roechling* ទំព័រទី ១១៣៦ (អង់គ្លេស)។

[៤៩៨] *រឿងក្តី Roechling* ទំព័រទី ១១៣៦ (អង់គ្លេស)។

[៤៩៩] សាលក្រមតុលាការ IMTFE។

[៥០០] សាលក្រមតុលាការ IMTFE ទំព័រទី ៤៨, ៤៤៣-៤៨, ៤៤៤ (អង់គ្លេស)។

លាស់ទៅលើ "ការទទួលខុសត្រូវរបស់ថ្នាក់លើ" នៅពេលដែលសាលក្រមនេះរៀបរាប់អំពីច្បាប់ជាធរមានទាក់ទិននឹងបញ្ហានេះយ៉ាងណាក៏ដោយ ក៏ពាក្យពេចន៍ដែលប្រើនោះ អនុលោមតាមធាតុផ្សំជាមូលដ្ឋាននៃទ្រឹស្តីដែលមាននៅក្នុងច្បាប់ អ.វ.ត.ក។ សាលក្រមបញ្ជាក់ថា មន្ត្រីទាំងអស់ ដោយផ្អែកលើតួនាទីរបស់ពួកខ្លួន មានភារកិច្ចទប់ស្កាត់មិនឱ្យមានការធ្វើបាបលើអ្នកទោស តាមរយៈ "ការបង្កើត និងការការពារនូវដំណើរការប្រព័ន្ធមួយដ៏មានប្រសិទ្ធភាព និងនិរន្តរភាព ដែលសមស្របសម្រាប់គោលបំណងទាំងនេះ[៥០១]។ នៅពេលដែលប្រព័ន្ធនោះត្រូវបានបង្កើតឡើង មន្ត្រីទាំងនោះមិនទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមប្រឆាំងនឹងអ្នកទោសនោះទេ លើកលែងតែ ៖

> (១) *ពួកគាត់បានដឹង*ថា បទឧក្រិដ្ឋបែបនោះត្រូវបានកំពុងប្រព្រឹត្តឡើង និងដោយបានដឹងបែបនេះ *ហើយពួកគាត់ខកខានពុំបានចាត់វិធានការ ដែលស្ថិតនៅក្នុងអំណាចរបស់ពួកគាត់ ដើម្បីទប់ស្កាត់*ការប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះនៅពេលអនាគត ឬ (២) ពួកគេទទួលខុសត្រូវចំពោះការខកខានពុំបានដឹងបែបនេះ។ *ប្រសិនបើបុគ្គលនោះបានដឹង ឬគួរបានដឹង* ប៉ុន្តែដោយសារការធ្វេសប្រហែស ឬមិនយកចិត្តទុកដាក់ *គាត់មិនត្រូវបានអភ័យទោសចំពោះការមិនចាត់វិធានការនោះឡើយ ប្រសិនបើការិយាល័យរបស់គាត់តម្រូវ ឬអនុញ្ញាតឱ្យគាត់ចាត់វិធានការដើម្បីទប់ស្កាត់នូវបទឧក្រិដ្ឋទាំងនោះ*[៥០២]។

លើសពីនេះទៀត ទាក់ទិនជាពិសេស ទៅនឹងមេបញ្ជាការកងទ័ពជើងគោក ឬជើងទឹក សាលក្រមតុលាការយោធាអន្តរជាតិចុងបូព៌ា បញ្ជាក់ថា៖

> ប្រសិនបើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តប្រឆាំងនឹងអ្នកទោស ក្រោមការត្រួតត្រារបស់ពួកគាត់ *ដែលពួកគាត់បានដឹង ឬគួរបានដឹងជាមុន អំពីភាពអាចកើតមានឡើងនៃបទឧក្រិដ្ឋនោះ* ពួកគាត់ត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនោះ។ ឧទាហរណ៍ ប្រសិនបើមានការបង្ហាញថា *ស្ថិតនៅក្នុងអង្គភាពក្រោមការបញ្ជារបស់គាត់* ឧក្រិដ្ឋកម្មសង្គ្រាមដែលមានចែងក្នុងអនុសញ្ញាត្រូវបានប្រព្រឹត្តឡើង *ដោយគាត់បានដឹង ឬគួរបានដឹងអំពីឧក្រិដ្ឋកម្មទាំងនោះ* មេបញ្ជាការ *ដែលពុំបានចាត់វិធានការគ្រប់គ្រាន់ ដើម្បីទប់ស្កាត់ការកើតឡើងនូវឧក្រិដ្ឋកម្មនោះនៅពេលអនាគត នឹងត្រូវ*ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលមាននៅពេលខាងមុខនោះ[៥០៣]។

---

[៥០១] សាលក្រមតុលាការ IMTFE ទំព័រទី ៤៨, ៤៤៤ (អង់គ្លេស)។

[៥០២] សាលក្រមតុលាការ IMTFE ទំព័រទី ៤៨, ៤៤៥ (អង់គ្លេស) (សេចក្តីបញ្ជាក់បន្ថែម)។

[៥០៣] សាលក្រមតុលាការ IMTFE ទំព័រ ៤៨, ៤៤៦ (អង់គ្លេស) (សេចក្តីបញ្ជាក់បន្ថែម)។

២១៧.លើសពីនេះទៀត អនុលោមតាមជំពូក X នៃសាលក្រមតុលាការយោធាអន្តរជាតិចុងបូព៌ា ដែលមានចំណងជើងថា "ផ្នែកសំអាងហេតុស្តីពីបទចោទនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ចៅក្រមបានអនុវត្តគោលការណ៍ដែលបានចែងក្រោមជំពូក II ទៅលើជនជាប់ចោទដែលជាថ្នាក់លើ នៅពេលធ្វើការសម្រេចអំពីពិរុទ្ធភាពជាលក្ខណៈបុគ្គល ក្រោមបទចោទទី៥៥ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ បទចោទទី៥៥ បានចោទប្រកាន់ជនជាប់ចោទ "អំពីការមិនគោរពភារកិច្ច ស្របច្បាប់របស់ពួកគាត់តាមរយៈការិយាល័យរបស់ពួកគាត់ ក្នុងការចាត់វិធានការឱ្យបានគ្រប់គ្រាន់ ដើម្បីធានាឱ្យមានការគោរពច្បាប់ និងទប់ស្កាត់ការរំលោភបំពានច្បាប់ និងទំនៀមទម្លាប់សង្គ្រាម"[៥០៤]។ ដូច្នេះ ចៅក្រមបានផ្តន្ទាទោសឧត្តមសេនីយ៍ Iwane Matsui ដែលជាអគ្គមេបញ្ជាការនៃកងទ័ពប្រចាំប្រទេសចិនប៉ែកកណ្តាលក្រោមបទចោទទី៥៥ ពាក់ព័ន្ធនឹងអំពើឃោរឃៅ ដែលកងទ័ពរបស់គាត់បានប្រព្រឹត្តប្រឆាំងនឹងជនស៊ីវិល ក្នុងអំឡុងពេលការរំលោភទ្រង់ទ្រាយធំនៅទីក្រុងNanking។ ចៅក្រមបានរកឃើញថា Matsui បានទទួលរបាយការណ៍អំពីអំពើឃោរឃៅ និងបានធ្វើការត្រួតពិនិត្យដោយផ្ទាល់ខ្លួនគាត់។ ដូច្នេះ តុលាការ "យល់ឃើញថា Matsui បានដឹងអំពីអ្វីដែលកំពុងកើតឡើង"[៥០៥]។ ទោះបីជាយ៉ាងណាក៏ដោយ "គាត់ពុំបានចាត់វិធានការអ្វីទាំងអស់ ឬពុំមានអ្វីដែលមានប្រសិទ្ធភាពក្នុងការសម្រាលនូវភាពរន្ធត់ទាំងនេះឡើយ [...]។ គាត់មានអំណាច ដោយគាត់មានភារកិច្ច ដើម្បីត្រួតត្រាកងទ័ពរបស់គាត់ និងដើម្បីការពារពលរដ្ឋទីក្រុងNanking ដែលទទួលភ័ព្វអាក្រក់។ គាត់ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការខកខានពុំបានអនុវត្តភារកិច្ចរបស់គាត់"[៥០៦]។

២១៨.ចៅក្រមតុលាការយោធាអន្តរជាតិចុងបូព៌ា ក៏បានរកឃើញផងដែរថា សេនាប្រមុខ Shunroku Hata មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មសង្គ្រាម ដែលត្រូវបានប្រព្រឹត្តឡើងដោយកងទ័ពដែលត្រូវបានបញ្ជូនឱ្យមកធ្វើសង្គ្រាមក្នុងប្រទេសចិនក្នុងឆ្នាំ ១៩៣៨ និងឆ្នាំ ១៩៤១-១៩៤៤ ដោយបានបញ្ជាក់ថា៖

> អំពើឃោរឃៅត្រូវបានប្រព្រឹត្តឡើងជាទ្រង់ទ្រាយធំ ដោយកងទ័ពក្រោមការបញ្ជារបស់គាត់ និងរីករាលដាលអស់រយៈពេលយ៉ាងយូរ។ Hata បានដឹងអំពីអំពើទាំងនេះ និងពុំបានចាត់វិធានការដើម្បីទប់ស្កាត់កុំឱ្យអំពើទាំងនេះកើតឡើងជាថ្មីទៀតឡើយ ឬក៏គាត់មិនអើពើ និងពុំបានចាត់វិធានការ ដើម្បីឱ្យដឹងថាតើ បទបញ្ជាក្នុងការប្រព្រឹត្តប្រកបដោយមនុស្សធម៌លើឈ្លើយសឹក និងជនស៊ីវិលត្រូវបាន

---

[៥០៤] សាលក្រមតុលាការ IMTFE ទំព័រទី ៤៨, ៤២៤ (អង់គ្លេស)។

[៥០៥] សាលក្រមតុលាការ IMTFE ទំព័រទី ៤៩, ៨១៥ (អង់គ្លេស)។

[៥០៦] សាលក្រមតុលាការ IMTFE ទំព័រទី ៤៩, ៨១៦ (អង់គ្លេស)។ (សេចក្តីបញ្ជាក់បន្ថែម)

គោរព ដែរឬយ៉ាងណាឡើយ។ នៅក្នុងករណីណាក៏ដោយ គាត់រំលោភបំពានលើភារកិច្ចរបស់គាត់ ដូចដែលត្រូវបានចោទប្រកាន់ក្រោមបទចោទទី៥៥[៥០៧]។

២១៩. ស្រដៀងគ្នានេះដែរ ពាក់ព័ន្ធនឹងឧត្តមសេនីយ៍ Heitarō Kimura ដែលជាមេបញ្ជាការកងទ័ពប្រចាំក្នុងប្រទេសភូមា ចាប់ពីឆ្នាំ ១៩៤៤ រហូតដល់ពេលចុះចាញ់កងទ័ពសម្ព័ន្ធមិត្ត ចៅក្រមបានផ្តន្ទាទោសគាត់ក្រោមបទចោទទី៥៥ ពីព្រោះគាត់ត្រូវបានរកឃើញថាបានដឹងអំពីការធ្វើបាបអ្នកទោស ហើយនៅពេលដែលគាត់បានកាន់តួនាទីជាបញ្ជាការកងទ័ពប្រចាំក្នុងប្រទេសភូមា គាត់ពុំបានចាត់វិធានការដាក់វិន័យឱ្យមានប្រសិទ្ធភាព ដើម្បីបញ្ឈប់នូវបទឧក្រិដ្ឋទាំងឡាយឡើយ។ ចៅក្រមយល់ឃើញថា៖

> ភារកិច្ចរបស់មេបញ្ជាការកងទ័ពនៅក្នុងកាលៈទេសៈបែបនេះ មិនត្រូវបានបំពេញ តាមរយៈការគ្រាន់តែចេញបទបញ្ជាធម្មតាៗប៉ុណ្ណោះទេ [...]។ ភារកិច្ចរបស់គាត់គឺត្រូវចាត់វិធានការ និងចេញបទបញ្ជានានា ដែលនឹងទប់ស្កាត់កុំឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមបែបនេះលើកក្រោយទៀត និងដើម្បីធ្វើឱ្យគាត់ប្រាកដថា បទបញ្ជាបែបនេះកំពុងតែត្រូវបានអនុវត្ត។ គាត់មិនបានបំពេញភារកិច្ចនេះឡើយ។ ដូច្នេះ គាត់មានចេតនាមិនគោរពភារកិច្ចស្របច្បាប់របស់គាត់ក្នុងការចាត់វិធានការឱ្យបានគ្រប់គ្រាន់ ដើម្បីទប់ស្កាត់នូវការរំលោភបំពានលើច្បាប់សង្គ្រាម[៥០៨]។

២២០. លើសពីនេះទៀត នៅក្នុងការសម្រេចឱ្យជនជាប់ចោទឧត្តមនាវីឯក Takasumi Oka រួចខ្លួនពីបទចោទក្រោមបទចោទទី៥៥ អំពីការទទួលខុសត្រូវចំពោះការធ្វើបាបឈ្លើយសឹក នៅពេលដែលគាត់ជាប្រធានការិយាល័យផ្នែកកងទ័ពជើងទឹក ចាប់ពីខែតុលា ឆ្នាំ ១៩៤០ ដល់ខែ កក្កដា ឆ្នាំ ១៩៤៤ ដែលទទួលបន្ទុកយ៉ាងសំខាន់ចំពោះកិច្ចការគ្រប់គ្រងប្រព័ន្ធដែលពាក់ព័ន្ធជាមួយឈ្លើយសឹក ចៅក្រមបានយកធាតុផ្សំនៃការទទួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្ត នៅក្នុងការសម្រេចបែបនេះ។ ចៅក្រមរកឃើញថា "មានភស្តុតាងខ្លះបង្ហាញថា Oka បានដឹង ឬគួរបានដឹងថា ឧក្រិដ្ឋកម្មសង្គ្រាមកំពុងត្រូវបានប្រព្រឹត្តឡើងដោយបុគ្គលិកទ័ពជើងទឹក ប្រឆាំងនឹងឈ្លើយសឹកដែលសុខុមាលភាពរបស់ឈ្លើយសឹកទាំងនោះ គឺជាការទទួលខុសត្រូវរបស់អង្គភាពគាត់ ប៉ុន្តែភស្តុតាងនេះ ពុំបានឈានទៅដល់កម្រិតនៃ

[៥០៧] សាលក្រមតុលាការ IMTFE ទំព័រទី ៤៩, ៧៨៤ (អង់គ្លេស)។

[៥០៨] សាលក្រមតុលាការ IMTFE ទំព័រទី ៤៩, ៨០៩ (អង់គ្លេស)។

បទដ្ឋាននៃការបង្ហាញភស្តុតាង ដែលធ្វើយុត្តិកម្មចំពោះការផ្តន្ទាទោសនៅក្នុងរឿងក្តីព្រហ្មទណ្ឌឡើយ[៥០៩]។

២២១.ដូចគ្នានឹងមន្ត្រីយោធាដែរ មន្ត្រីរបស់រដ្ឋាភិបាលជាច្រើននាក់ផ្សេងទៀតត្រូវបានផ្តន្ទាទោសនៅក្រោមបទចោទទី៥៥ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះផងដែរ ដែលពួកគាត់ជាមន្ត្រីស៊ីវិល ឬក៏មានតួនាទីទាំងផ្នែកយោធា និងទាំងផ្នែកស៊ីវិល។ Kōki Hirota ត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មសង្គ្រាម ដែលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុង "ការសម្លាប់រង្គាលក្នុងទីក្រុង Nanjing" នៅចុងទសវត្សរ៍ឆ្នាំ១៩៣០ ដែលក្នុងអំឡុងពេលនោះ គាត់គឺជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស។ តុលាការ IMTFE បានរកឃើញថា គាត់បានដឹងយ៉ាងច្បាស់អំពីព្រឹត្តការណ៍នោះ ពីព្រោះគាត់បានទទួលរបាយការណ៍ជាច្រើនពីប្រភពបរទេស ស្តីអំពីអំពើឃោរឃៅនានា ហើយគាត់បានលើកយកបញ្ហានៃការប្រឆាំងជំទាស់របស់អន្តរជាតិទាក់ទិននឹងទីក្រុង Nanjing មកពិភាក្សា នៅចំពោះមុខគណៈរដ្ឋមន្ត្រី[៥១០]។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការបានសម្រេចថា គាត់មិនគួរផ្អែកតែទៅលើការអះអាងបញ្ជាក់ពីក្រសួងការពារជាតិ ដែលថាពួកគាត់នឹងមិនបន្តសកម្មភាពទៀតនោះឡើយ[៥១១] ហើយតុលាការ "យល់ឃើញថា Hirota ធ្វេសប្រហែស នៅក្នុងភារកិច្ចរបស់គាត់ដោយមិនបានទទូច នៅចំពោះមុខគណៈរដ្ឋមន្ត្រីឱ្យចាត់វិធានការជាបន្ទាន់ដើម្បីបញ្ឈប់អំពើឃោរឃៅឡើយ។ ការខកខានពុំបានចាត់វិធានការណាមួយដែលនៅមានសម្រាប់គាត់ នឹងនាំឱ្យគាត់ទទួលបានលទ្ធផលដូចគ្នា"[៥១២]។

២២២.លើសពីនេះទៀត Mamoru Shigemitsu ត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មសង្គ្រាម ទាក់ទិននឹងការធ្វើបាបអ្នកទោស និងអ្នកជាប់ឃុំឃាំងជាជនស៊ីវិល ក្នុងអំឡុងអាណត្តិរបស់គាត់ជារដ្ឋមន្ត្រីការបរទេស។ ស្រដៀងគ្នាទៅនឹងករណី Hirota ដែរ តុលាការ IMTFE បានរកឃើញថា គាត់បាន

[៥០៩] សាលក្រមតុលាការ IMTFE ទំព័រទី ៤៩, ៨២២ (អង់គ្លេស)។

[៥១០] សាលក្រមតុលាការ IMTFE ទំព័រទី ៤៩, ៧៩១ (អង់គ្លេស)។

[៥១១] សាលក្រមតុលាការ IMTFE ទំព័រទី ៤៩, ៧៩១ (អង់គ្លេស)។

[៥១២] សាលក្រមតុលាការ IMTFE ទំព័រទី ៤៩, ៤៩១ (អង់គ្លេស)។

E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ទទួលព័ត៌មានពីរដ្ឋាភិបាលបរទេសស្ដីអំពីការធ្វើបាបនេះ ចាប់ពីឆ្នាំ ១៩៤៣ ដល់ឆ្នាំ ១៩៤៥[៥១៣]។ តុលាការសម្រេចថា គាត់ ៖

> ពុំបានចាត់វិធានការគ្រប់គ្រាន់ដើម្បីស៊ើបអង្កេតទៅលើបញ្ហានោះឡើយ ក្នុងនាមជាសមាជិកម្នាក់របស់រដ្ឋាភិបាល ទោះបីជាគាត់មានការទទួលខុសត្រូវជាទូទៅចំពោះសុខុមាលភាពរបស់អ្នកទោសយ៉ាងណាក៏ដោយ។ គាត់គួរតែបានចាត់វិធានការដោះស្រាយបញ្ហាឱ្យបានគ្រប់ជ្រុងជ្រោយ តាមដែលគាត់អាចធ្វើបាន ដើម្បីរំដោះខ្លួនគាត់ឱ្យរួចផុតពីការទទួលខុសត្រូវដែលគេសង្ស័យថាជាបន្ទុករបស់គាត់ ហើយប្រសិនបើក្នុងករណីចាំបាច់ គាត់ត្រូវលាលែងចេញពីតំណែងនោះ[៥១៤]។

២២៣. ករណីមួយទៀត នាយករដ្ឋមន្ត្រីឧត្ដមសេនីយ៍ Kuniaki Koiso ត្រូវបានដាក់ឱ្យទទួលខុសត្រូវក្រោមបទចោទទី៥៥ ចំពោះឧក្រិដ្ឋកម្មសង្គ្រាម ដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងឈ្លើយសឹក។ តុលាការកត់សម្គាល់ថា នៅពេលដែលឧត្ដសេនីយ៍ Koiso ធ្វើជានាយករដ្ឋមន្ត្រីចាប់ពីឆ្នាំ ១៩៤៤ ដល់ឆ្នាំ ១៩៤៥ ការធ្វើបាបអ្នកទោសមានលក្ខណៈរីករាលដាលយ៉ាងខ្លាំង រហូតដល់កម្រិតមួយ "មិនគួរឱ្យជឿ"បានឡើយថា គាត់មិនបានដឹងអំពីអំពើនោះ[៥១៥]។ លើសពីនេះទៀត តុលាការរកឃើញថាបន្ទាប់ពីកិច្ចប្រជុំមួយក្នុងឆ្នាំ ១៩៤៤ ដែលរដ្ឋមន្ត្រីការបរទេសបានធ្វើសេចក្ដីរាយការណ៍ ស្ដីពីព័ត៌មានដែលទទួលបានពីប្រភពនានា អំពីការធ្វើបាបអ្នកទោសពីសំណាក់ប្រទេសជប៉ុន "Koiso នៅបន្តធ្វើជានាយករដ្ឋមន្ត្រីរយៈពេលប្រាំមួយខែ ដែលក្នុងអំឡុងពេលនោះការប្រព្រឹត្តមកលើអ្នកទោស និងអ្នកជាប់ឃុំឃាំងពីសំណាក់ជនជាតិជប៉ុន ពុំបានបង្ហាញឱ្យឃើញនូវលក្ខណៈល្អប្រសើរអ្វីឡើយ។ ប្រការនេះ គឺជាការមិនគោរពភារកិច្ចដោយចេតនា"[៥១៦]។

២២៤. មានការកត់សម្គាល់ផងដែរថា តុលាការ IMTFE បានពិចារណាលើបទចោទប្រឆាំងនឹងមន្ត្រីស៊ីវិលជាន់ខ្ពស់ដទៃទៀត ក្រោមបទចោទទី៥៥ និងបានសម្រេចឱ្យពួកគាត់រួចខ្លួនពីបទចោទក្នុងនាមជាថ្នាក់លើ។ ឧទាហរណ៍ Hiranuma Kiichirō ដែលជានាយករដ្ឋមន្ត្រីក្នុងឆ្នាំ ១៩៣៩ និងក្រោយមក

---

[៥១៣] សាលក្រមតុលាការ IMTFE ទំព័រទី ៤៩, ៨២៩-៤៩, ៨៣០ (អង់គ្លេស)។

[៥១៤] សាលក្រមតុលាការ IMTFE ទំព័រទី ៤៩, ៨៣១ (អង់គ្លេស)។

[៥១៥] សាលក្រមតុលាការ IMTFE ទំព័រទី ៤៩, ៨១៣ (អង់គ្លេស)។

[៥១៦] សាលក្រមតុលាការ IMTFE ទំព័រទី ៤៩, ៨១៣ (អង់គ្លេស)។

00686609

ជារដ្ឋមន្ត្រីសន្តិសុខសង្គមនៃព្រះបរមរាជវាំងនៃប្រទេសជប៉ុន ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាមក្រោមបទចោទទី៥៥។ គាត់ត្រូវបានសម្រេចឱ្យរួចខ្លួនពីបទចោទ ដោយសារតែតុលាការយល់ឃើញថា ពុំមានភស្តុតាងដែលភ្ជាប់រូបគាត់ដោយផ្ទាល់ទៅនឹងបទឧក្រិដ្ឋឡើយ[៥១៧]។ ឧទាហរណ៍មួយទៀត គឺ Kōichi Kido ដែលជាមន្ត្រីជាន់ខ្ពស់នៃបរមរាជវាំង ចាប់ពីឆ្នាំ១៩៣៩ ដល់ឆ្នាំ១៩៤០ ដែលត្រូវបានសម្រេចឱ្យរួចខ្លួនពីការចោទប្រកាន់ក្រោមបទចោទទី៥៥ ពីព្រោះ ទោះបីជាគាត់ត្រូវបានរកឃើញថាជាសមាជិកម្នាក់របស់គណៈរដ្ឋមន្ត្រី ក្នុងអំឡុងពេលការសម្លាប់រង្គាលក្នុងទីក្រុង Nanjing យ៉ាងណាក៏ដោយ "ក៏មិនមានភស្តុតាងគ្រប់គ្រាន់ ដើម្បីភ្ជាប់រូបគាត់ទៅនឹងការទទួលខុសត្រូវចំពោះការខកខានពុំបានទប់ស្កាត់ឧក្រិដ្ឋកម្មសង្គ្រាម"[៥១៨] នោះទេ។

២២៥.សរុបមក ស្រដៀងគ្នាទៅនឹងសាលក្រមរឿងក្តី *Yamashita* ដែរ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា រូបភាពនៃធាតុផ្សំរបស់ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលចៅក្រមបានគូសបញ្ជាក់នៅក្នុងជំពូក II នៃសាលក្រមរបស់តុលាការ IMTFE ឬការអនុវត្តរូបភាពនៃធាតុផ្សំទាំងនោះនៅក្នុងជំពូក X ទៅលើជនជាប់ចោទជាក់លាក់ ពុំមានការអភិវឌ្ឍដូចនិយមន័យនៃទ្រឹស្តីនាពេលបច្ចុប្បន្នដែលមាននៅក្នុងយុត្តិសាស្ត្រអន្តរជាតិឡើយ។ នេះគឺជាការពិត ទាក់ទិននឹងលក្ខខណ្ឌនៃទំនាក់ទំនងថ្នាក់លើ និងអ្នកក្រោមបង្គាប់ ដែលមានការត្រួតត្រាប្រកបដោយប្រសិទ្ធភាព ជាពិសេសនៅក្នុងបរិបទថ្នាក់លើដែលពុំមែនជាយោធា នៅពេលដែលសាលក្រមពុំបានបញ្ជាក់នូវសំអាងហេតុឱ្យបានច្បាស់ ដែលបង្ហាញអំពីទំនាក់ទំនងបែបនោះ ប៉ុន្តែទំនងជាធ្វើការសន្មត ដោយផ្អែកលើតួនាទីខ្ពស់របស់ជនជាប់ចោទ ហើយគ្រាន់តែយោងទៅលើ "ការខកខានពុំបានចាត់វិធានការដែល*ស្ថិតក្នុងអំណាចរបស់ពួកគាត់*ដើម្បីទប់ស្កាត់" នៅក្នុងជំពូក II[៥១៩]។ ដូច្នេះ អង្គបុរេជំនុំជម្រះពិចារណាថា តុលាការ

[៥១៧] សាលក្រមតុលាការ IMTFE ទំព័រទី ៤៩, ៧៨៧ (អង់គ្លេស)។

[៥១៨] សាលក្រមតុលាការ IMTFE ទំព័រទី ៤៩, ៨០៥ -៤៩, ៨០៦ (អង់គ្លេស)។

[៥១៩] ការសន្មតដែលថា សមាជិកស៊ីវិលនៃគណៈរដ្ឋមន្ត្រីគួរតែមានអំណាចក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្មលើបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងដោយសមាជិកយោធាហាក់ដូចជាមិនត្រូវគ្នាជាមួយនឹងផ្នែកសាលក្រមតុលាការ IMTFE ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពឡើយ ដែលនៅក្នុងផ្នែកនេះ មានសំអាងហេតុជាច្រើនបង្ហាញថា កងទ័ពអាច "ត្រួតត្រាលើរដ្ឋាភិបាលជប៉ុន" ពុំមែនរដ្ឋាភិបាលត្រួតត្រាលើកងទ័ពឡើយ។ ប្រតិបត្តិការយោធានៅក្រៅប្រទេស ត្រូវបានកំណត់លក្ខណៈថាពុំមានការអនុម័តពីគណៈរដ្ឋមន្ត្រី ឬប្រឆាំងនឹងសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី មានការធ្វើឃាតមេដឹកនាំប្រឆាំង មានផែនការផ្តួលរំលំគណៈរដ្ឋមន្ត្រី ដែលបដិសេធមិនសហការណ៍ជាមួយកងទ័ព និងការបះបោរផ្នែកយោធាដែលបានដណ្តើមកាន់កាប់ទីក្រុង

IMTFE មិនមែនជាតុលាការដែលត្រូវយកមកធ្វើជាសំអាងចុងក្រោយឡើយ ទាក់ទិនទៅនឹងថាតើទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើពង្រីកវិសាលភាព ទៅដល់ថ្នាក់លើដែលពុំមែនជាយោធា ឬយ៉ាងណា ពីព្រោះតុលាការនេះពុំបានបញ្ជាក់សំអាងហេតុ ដែលទាក់ទិននឹងចំណុចសំខាន់នៃទ្រឹស្តី ថាតើមានទំនាក់ទំនងថ្នាក់លើនិងអ្នកក្រោមបង្គាប់ *ជាក់ស្តែង* ឬ *ស្របច្បាប់* ដែរឬទេ រវាងមន្ត្រីរដ្ឋាភិបាល និងបុគ្គលិកយោធាដែលជាប់ពាក់ព័ន្ធនៅក្នុងបទឧក្រិដ្ឋ។

២២៦.ចំពោះថ្នាក់លើជាយោធា សាលក្រមសំដៅយ៉ាងច្បាស់ទៅលើ "អង្គភាពក្រោម [...] ការបញ្ជា" ប៉ុន្តែជាថ្មីម្តងទៀត សាលក្រមហាក់ដូចជាធ្វើការសន្និដ្ឋានអំពីការត្រួតត្រាដែលមានប្រសិទ្ធភាព ដោយផ្អែកទៅលើទំនាក់ទំនង*ស្របច្បាប់* *(de jure)* លើកលែងតែរឿងក្តីឧត្តមសេនីយ៍ Matsui។ លើសពីនេះទៀត "ការខកខានពុំបានដាក់ទោសទណ្ឌ" *ជាតុផ្សំសត្យានុម័ត* មិនត្រូវបានបញ្ចូលឲ្យបានច្បាស់លាស់នៅក្នុងនិយមន័យឡើយ ទោះបីជាការខកខានពុំបានចាត់ "វិធានការគ្រប់គ្រាន់ដើម្បីទប់ស្កាត់កុំឲ្យបទឧក្រិដ្ឋបែបនោះកើតឡើងជាថ្មីទៀតនៅពេលអនាគត" អាចត្រូវបានគេបកស្រាយ ដើម្បីបញ្ចូលជាការដាក់ទោសទណ្ឌយ៉ាងណាក៏ដោយ។ ជាចុងក្រោយ ស្រដៀងគ្នាទៅនឹងរឿងក្តី *Yamashita* ដែរ *ជាតុផ្សំអត្តនោម័ត*ដែលតម្រូវឲ្យមាន រួមបញ្ចូលយ៉ាងទូលំទូលាយនូវបទដ្ឋាននៃការធ្វេសប្រហែសបន្ថែមទៅលើការដឹងពិតប្រាកដ និងតាមការសន្មត។

២២៧.ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា សាលក្រមរបស់តុលាការ IMTFE នៅពេលអានសាលក្រមទាំងមូល បញ្ជាក់យ៉ាងគ្រប់គ្រាន់អំពីទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ជាទម្រង់នៃការទទួលខុសត្រូវជាលក្ខណៈបុគ្គល នៅក្នុងផ្នែកសម្រេចសេចក្តី និងផ្នែកច្បាប់ជាធរមានរបស់សាលក្រមនេះ។

២២៨.ចុងក្រោយ នៅក្នុងការជំនុំជម្រះទោសឧត្តមនាវីឯក Soemu Toyoda ក្នុងឆ្នាំ ១៩៤៨-១៩៤៩ ដែលគាត់ជាអតីតអគ្គមេបញ្ជាការកងនាវារួមជប៉ុន (Japanese Combined Fleet) កងទ័ពជើងទឹករួម (Combined Naval Forces) និងបញ្ជាការដ្ឋានអមកងទ័ពជើងទឹក (Naval Escort Command)

និងបានព្យាយាមផ្តួលរំលំរដ្ឋាភិបាល (ជាពិសេស សូមមើល សាលក្រមតុលាការ IMTFE ទំព័រទី ៤៩, ៧៦៥ (អង់គ្លេស)) (សេចក្តីបញ្ជាក់បន្ថែម)។

ចាប់ពីថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៩៤៤ ដល់ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៤៥ ដែលជាការជំនុំជម្រះក្ដីមួយ ក្នុងចំណោមការជំនុំជម្រះក្ដីឧក្រិដ្ឋកម្មសង្គ្រាមដ៏ធំចុងក្រោយ ដែលត្រូវបានបញ្ចប់ក្រោយសង្គ្រាមលោកលើកទីពីរ តុលាការយោធាអាមេរិក/អូស្ត្រាលីបានលើកនូវបញ្ហានៃការទទួលខុសត្រូវរបស់ថ្នាក់លើ បន្ទាប់ពីពិនិត្យឡើងវិញនូវការជំនុំជម្រះក្ដីអន្តរជាតិដទៃទៀតមុនតុលាការនេះ។ តុលាការបានកំណត់ធាតុផ្សំសំខាន់នៃទ្រឹស្ដី ដូចខាងក្រោម ៖

> ១. ថា អំពើឃោរឃៅត្រូវបានប្រព្រឹត្តឡើងពិតប្រាកដ ២. ការដឹងអំពីការប្រព្រឹត្តអំពើឃោរឃៅ។ ការដឹងនេះអាច ៖ ក. ពិតប្រាកដ [...] ឬ ខ. តាមការសន្និដ្ឋាន [...] ៣. អំណាចបញ្ជា។ គឺថា ត្រូវតែមានការបង្ហាញថា ជនជាប់ចោទមានអំណាចពិតប្រាកដលើអ្នកប្រព្រឹត្តបទល្មើស ក្នុងការចេញបញ្ជាដល់ពួកគេកុំឱ្យប្រព្រឹត្តអំពើខុសច្បាប់ និងដាក់ទោសទណ្ឌលើអ្នកប្រព្រឹត្តបទល្មើស។ ៤. ការខកខានពុំបានចាត់វិធានការសមស្របដែលស្ថិតក្នុងអំណាចរបស់គាត់ ដើម្បីត្រួតត្រាកងទ័ពក្រោមបញ្ជារបស់គាត់ និងដើម្បីទប់ស្កាត់នូវអំពើទាំងឡាយ ដែលជាការរំលោភច្បាប់សង្គ្រាម។ ៥. ការខកខានពុំបានដាក់ទោសទណ្ឌលើអ្នកប្រព្រឹត្តបទល្មើស[៥២០]។

២២៩. នៅក្នុងការសម្រេចឱ្យឧត្តមនាវីឯក Toyoda រួចខ្លួនពីបទចោទអំពីអំពើឃោរឃៅ ដែលប្រព្រឹត្តដោយបុគ្គលិកទ័ពជើងទឹក តុលាការបានកត់សម្គាល់ថា ៖

> ពិរុទ្ធភាពរបស់គាត់ មិនអាច [គ្រាន់តែ] ត្រូវបានកំណត់តាមរយៈថាតើ គាត់មានការបញ្ជាផ្នែកប្រតិបត្តិការ ការបញ្ជាផ្នែករដ្ឋបាល ឬទាំងពីរផ្នែកប៉ុណ្ណោះទេ។ ប្រសិនបើគាត់បានដឹង ឬគួរបានដឹងតាមរយៈការយកចិត្តទុកដាក់ដ៏សមហេតុផល នូវការប្រព្រឹត្តអំពើឃោរឃៅពីសំណាក់កងទ័ពរបស់គាត់ ហើយប្រសិនបើគាត់ពុំបានចាត់វិធានការគ្រប់យ៉ាង ក្រោមអំណាច និងសមត្ថភាពរបស់គាត់នៅក្នុងកាលៈទេសៈជាធរមាន ដើម្បីទប់ស្កាត់កុំឱ្យអំពើឃោរឃៅទាំងនោះកើតឡើងជាថ្មីទៀត និងដាក់ទោសទណ្ឌលើអ្នកប្រព្រឹត្តបទល្មើសទនោះ គឺគាត់ធ្វេសប្រហែស ក្នុងភារកិច្ចរបស់គាត់[៥២១]។

២៣០. ដោយផ្អែកលើមូលដ្ឋានដែលបានបញ្ជាក់ខាងលើ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ទ្រឹស្ដីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដូចដែលមានចែងនៅក្នុងមាត្រា ២៩(ថ្មី) នៃច្បាប់អ.វ.ត.ក មានអត្ថិភាព

---

[៥២០] សាលាជំនុំជម្រះក្ដីឧក្រិដ្ឋកម្មសង្គ្រាម តូក្យូ Honshu ជប៉ុន ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៤៩។ ក្ដីសហរដ្ឋអាមេរិក ទល់នឹង *Soemu Toyoda* ប្រតិចារិកផ្លូវការនៃកំណត់ហេតុសវនាការ ៥០០៤, ៥០០៦ (អង់គ្លេស)។

[៥២១] ដូចជើងទំព័រខាងលើ។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ជាបញ្ហាមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ១៩៧៥។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ការបញ្ជាក់អំពីទម្រង់នៃធាតុផ្សំជាមូលដ្ឋាននៃទ្រឹស្តីនេះ មិនមែនតែងតែមានលក្ខណៈច្បាស់លាស់ ឬពេញលេញ ដូចការយល់ដឹងរបស់យើងអំពីធាតុផ្សំទាំងនោះនាពេលបច្ចុប្បន្ននេះឡើយ ហើយការយកធាតុផ្សំទាំងនោះមកអនុវត្ត ចំពោះអង្គហេតុជាក់លាក់នៅក្នុងរឿងក្តីក្រោយសង្គ្រាមលោកលើកទីពីរ គឺពុំមានលក្ខណៈស៊ីសង្វាក់គ្នា និងពេញលេញឡើយនៅពេលនោះ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះពិចារណាថា គោលការណ៍ដែលថាថ្នាក់លើអាចមានការទទួលខុសត្រូវព្រហ្មទណ្ឌពាក់ព័ន្ធនឹងបទឧក្រិដ្ឋនានាដែលប្រព្រឹត្តដោយអ្នកក្រោមបង្គាប់ នៅពេលដែលមានទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកក្រោមបង្គាប់ ដោយមានការត្រួតពិនិត្យយ៉ាងមានប្រសិទ្ធភាពនោះ *ធាតុផ្សំអត្តនោម័ត* នៃការដឹងពិតប្រាកដ ឬតាមការសន្មត និង*ធាតុផ្សំសត្យានុម័ត* នៃការខកខានមិនបានចាត់វិធានការ ត្រូវបានបង្កើតឡើង។ ចំណុចរៀបរាប់នេះគាំទ្រដល់ទស្សនៈដែលបានលើកឡើងដោយ អៀង ធីរិទ្ធ ដែលថា ទ្រឹស្តីនេះក៏ត្រូវបានអនុវត្តផងដែរ នៅក្នុងរឿងក្តីនានាក្រោយសង្គ្រាមលោកលើកទីពីរ ចំពោះថ្នាក់លើដែលមិនមែនជាយោធា។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះពុំប្រកាន់ជំហរអ្វីនោះទេ នៅក្នុងបណ្តឹងឧទ្ធរណ៍នេះចំពោះបញ្ហាពាក់ព័ន្ធថាតើ ការទទួលខុសត្រូវរបស់ថ្នាក់លើក៏ត្រូវបានអនុវត្តផងដែរចំពោះជនស៊ីវិលដែរឬយ៉ាងណានោះ នៅក្នុងច្បាប់ទំនៀមទម្លាប់ត្រឹមឆ្នាំ ១៩៧៥ ។

(ii) <u>**បញ្ហាថាតើមានមូលដ្ឋានដែរឬទេ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ សម្រាប់ការទទួលខុសត្រូវរបស់ថ្នាក់លើ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩**</u>

២៣១. បញ្ហាថាតើការទទួលខុសត្រូវរបស់ថ្នាក់លើ បានអនុវត្តជាបញ្ហាមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិពាក់ព័ន្ធតែទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ឬយ៉ាងណានោះ រឿងក្តីនៅតុលាការយោធា Nuremberg ផ្តល់នូវចម្លើយលើចំណុចនេះ។ ដូចដែលបានកត់សម្គាល់ខាងលើ បុគ្គលជាច្រើននាក់ដែលត្រូវបានចោទប្រកាន់នៅក្នុងរឿងក្តី *មេបញ្ជាការជាន់ខ្ពស់ (High Command Case)* រឿងក្តី *ចំណាប់ខ្មាំង (Hostage Case)* រឿងក្តី *វេជ្ជសាស្ត្រ (Medical Case)* និងរឿងក្តី *ក្រសួង (Ministries Case)* ត្រូវទទួលខុសត្រូវដោយផ្អែកតាមទ្រឹស្តីដែលពាក់ព័ន្ធតែទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ប៉ុន្តែក៏រងការចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ។

E.C.C.C • C.E.T.C • PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

(iii) សេចក្តីសន្និដ្ឋាន

២៣២. ដូច្នេះ ដោយផ្អែកលើមូលដ្ឋានដែលបានបញ្ជាក់ខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដូចដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ពាក់ព័ន្ធនឹង អៀង ធីរិទ្ធ មានអត្ថិភាពជាបញ្ញាមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ដោយពិចារណាអំពីយុត្តិសាស្ត្រអន្តរជាតិក្រោយសង្គ្រាមលោកលើកទីពីរ ដែលបានដកស្រង់ខាងលើ និងលក្ខណៈធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អៀង ធីរិទ្ធ អាចដឹងថាមានច្បាប់ចែង និងអាចប្រមើលដឹងថាជាបទឧក្រិដ្ឋដែលថាគាត់អាចត្រូវបានចោទប្រកាន់ក្នុងនាមជាថ្នាក់លើម្នាក់ មិនថាជាឃោធា ឬមិនមែនជាឃោធាក្តី អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តដោយអ្នកក្រោមបង្គាប់របស់គាត់ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ អាស្រ័យហេតុនេះ មូលដ្ឋានទី៧ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវបានបដិសេធ។

អនុលោមតាមវិធាន៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវប្តឹងតវ៉ា។ ៧៦

ភ្នំពេញថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១

អង្គបុរេជំនុំជម្រះ ប្រធាន

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

Rowan DOWNING ន៉ីយ ថុល Catherine MARCHI-UHEL ហួត វុទ្ធី ប្រាក់ គឹមសាន